បំណងប្រាថ្នារបស់ខ្ញុំសម្រាប់មនុស្សទាំងអស់គ្នាគឺថា ឲ្យពួកគេបានឃើញ និងបានស្គាល់ព្រះនៃព្រះគម្ពីរ តែស្របពេលជាមួយគ្នាបានធ្វើឲ្យខ្ញុំបាក់ទឹកចិត្ត នៅពេលដែលខ្ញុំឃើញការឈឺចាប់ ការបាត់បង់ និងការខ្វះនូវទំនុកចិត្ត កិច្ចការទាំងនោះនឹងនាំឲ្យពួកគេខ្វះចំណេះដឹងខាងឯព្រះគម្ពីរ។ ហេតុដូច្នេះហើយ ខ្ញុំពិតជារីករាយណាស់ដែលអ្នកកំពុងកាន់សៀវភៅនេះ។ អ្នកគ្រូ **ចេន វាលឃិន** (**Jen Wilkin**) បានបង្ហាញអំពីការស្គាល់ព្រះនៃព្រះគម្ពីរយ៉ាងម៉ត់ចត់។ អ្នកគ្រូជាគ្រូបង្រៀនព្រះគម្ពីរល្អម្នាក់ ដែលខ្ញុំមានឱកាសបានស្តាប់ការបង្រៀនរបស់គាត់។ របៀបបង្រៀនរបស់គាត់អំពីវិធីដែលជួយពួកគេឲ្យលូតលាស់នៅក្នុងចំណេះដឹងនៃព្រះបន្ទូលគឺងាយយល់ ហើយមានប្រយោជន៍ មិនថាភាពធ្វេសប្រហែសរបស់អ្នកដែលជាគ្រីស្ទបរិស័ទជាងមួយទសវត្សរ៍ មានអារម្មណ៍ថាដូចជាយឺតពេល ឬអ្នកដែលទើបនឹងជឿថ្មីដែលស្រេកឃ្លានចង់ស្គាល់ និងយល់ដឹងអំពីព្រះនៃព្រះគម្ពីរនោះទេ។

**Matt Chandler**, Lead Pastor, The Village Church, Dallas, Texas; President, Acts 29 Church Planting Network

ខ្ញុំមើលឃើញថាសៀវភៅស្ត្រីនៃព្រះបន្ទូលនេះ គឺពិតជាមានប្រយោជន៍ខ្លាំងណាស់ បង្ហាញឲ្យឃើញច្បាស់ពីរបៀបជាក់ស្តែងនៅក្នុងការសិក្សាព្រះគម្ពីរ។ មនុស្សជាច្រើនទាំងបុរស និងស្ត្រីពួកគេជ្រើសរើសអានលើខគម្ពីរមួយចំនួន ហើយមានសង្ឃឹមជាមួយនឹងការជំរុញទឹកចិត្តពីខគម្ពីរទាំងនោះ ជាជាងធ្វើការស្វែងយល់ទៅលើអត្ថន័យនៃអត្ថបទ ដែលជាដំណើរការបង្ហាញអំពីផែនការនៃការប្រោសលោះរបស់ព្រះជាម្ចាស់។ សៀវភៅស្ត្រីនៃព្រះបន្ទូលនឹងជួយដល់អ្នកអានទាំងអស់ឲ្យបានរកឃើញផ្លូវដែលមុជចូលជ្រៅទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយមិនបាច់មានការរៀនសូត្រនៅសាលាព្រះគម្ពីរ ជាមនុស្សដែលមានប្រាជ្ញា ឬក៏ជាសិស្សដែលល្អពិសេសអ្វីមួយនោះទេ។ ខ្ញុំមានសេចក្តីប្រាថ្នាតែមួយគត់ គឺត្រង់ចំណងជើង វាមិនគួរធ្វើឲ្យមានការពិបាកដល់មនុស្សប្រុសនៅក្នុងការអានឡើយ....ពួកគេក៏ត្រូវការអានសៀវភៅនេះដែរ។

**Kathy Keller**, Assistant Director of Communications, Redeemer Presbyterian Church, New York City, New York

ខ្ញុំបានឃើញកែវភ្នែករបស់ស្ត្រីដែលពេញទៅដោយទឹកភ្នែករលីងរលោងជាច្រើននាក់ នៅពេលដែលពួកគេបានយល់លើកដំបូងថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជា

Khmer Women of the word_Layout.indd 1 12/3/26 3:56 in the afternoon

ម្ចាស់យ៉ាងពិតប្រាកដមែន។ នេះគឺជាសេចក្តីមេត្តាករុណាដ៏អស្ចារ្យដែលយើងបានឃើញ ដែលព្រះជាព្រះអាទិករបានបង្កើតឲ្យមានរបស់ទាំងអស់ដោយព្រះបន្ទូល ហើយព្រះអង្គមានព្រះជន្មគង់នៅបានប្រទានឲ្យយើងនូវព្រះបន្ទូលរបស់ទ្រង់។ អ្នកគ្រូ **ចេន វ៉ាលឃិន (Jen Wilkin)** បានស្គាល់អំពីជម្រៅនៃសេចក្តីមេត្តាករុណានេះនៅក្នុងជីវិតរបស់គាត់។ អ្នកគ្រូបានភ្លក់ និងបានឃើញភាពល្អអស្ចារ្យរបស់ព្រះនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ ហើយគាត់មិនចង់ឲ្យស្ត្រីណាម្នាក់ខកខានមិនបានឃើញអំពីការនេះនោះឡើយ។ សូមអានសៀវភៅស្ត្រីនៃព្រះបន្ទូល ហើយបើកព្រះគម្ពីររបស់អ្នកជាមួយនឹងមិត្តភក្តិរបស់អ្នកផងដែរ។ សូមគិតអំពីសៀវភៅនេះដូចជាពិធីជប់លៀងអាហារខាងឯការសិក្សាព្រះគម្ពីរ ដែលមានចុងភៅចាំចម្អិនអាហារឲ្យបរិភោគ និងបរិភោគដោយមានអំណរជាមួយគ្នា។

**Gloria Furman**, author, *Glimpses of Grace and Treasuring Christ When Your Hands Are Full*

អ្នកគ្រូ ចេន រស់នៅដូចអ្វីដែលគាត់បានបង្រៀន។ ដួងចិត្តនៃការបម្រើរបស់គាត់បានបង្ហាញឲ្យឃើញអំពីព្រះបន្ទូល ដូចគ្នាទៅនឹងសេចក្តីស្រឡាញ់របស់គាត់ចំពោះស្ត្រី។ នៅពេលដែលអ្នកបានជួបគាត់ ការបង្រៀនរបស់គាត់គឺជាភស្តុតាង ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលគាត់បានស្តាប់បង្គាប់ចំពោះការត្រាស់ហៅរបស់ព្រះក្នុងការសរសេរសៀវភៅនេះ នៅពេលដែលខ្ញុំសិក្សាព្រះគម្ពីរ សៀវភៅនេះបានជួយបកស្រាយនូវអ្វីដែលជារនាំងក្នុងដួងចិត្ត និងគំនិតរបស់ខ្ញុំ។ ហើយប្រាកដណាស់ខ្ញុំពិតជាទន្ទឹងរង់ចាំទិញសៀវភៅនេះឲ្យដល់ស្ត្រីជាច្រើននាក់ទៀត ដែលខ្ញុំបានស្គាល់នៅក្នុងជីវិតរបស់ខ្ញុំដើម្បីឲ្យគេបានស្រឡាញ់សៀវភៅនេះផងដែរ។

Bethany Barnard, singer/songwriter

សៀវភៅនេះឆ្លើយតបទៅនឹងការជំរុញខាងឯអារម្មណ៍ ការដែលយើងផ្តោតមកលើខ្លួនឯង ដែលជាទូទៅបានគ្របដណ្តប់មកលើការសិក្សាព្រះបន្ទូលរបស់យើង។ អ្នកគ្រូចេន បានលើកទឹកចិត្តស្ត្រីឲ្យបានលូតលាស់នៅក្នុងចំណេះដឹងខាងឯព្រះបន្ទូល ដើម្បីឲ្យយើងស្គាល់ព្រះជាម្ចាស់។ គាត់បានបង្ហាញចេញនូវអំណរផ្ទាល់ខ្លួនរបស់គាត់ និងបទពិសោធន៍នៃការលូតលាស់ក្នុងការរៀនសូត្ររបស់គាត់ ដើម្បីធ្វើការរៀនសូត្រ។ ខ្ញុំសង្ឃឹមថា អ្នកដទៃនឹងចូលរួមគាំទ្រដូចគាត់។

Kathleen Nielson, author; speaker; Senior Adviser, The Gospel Coalition

ពេលខ្លះ ការអានព្រះគម្ពីរហាក់បីដូចជាធ្វើឲ្យយើងមានការរុញរា។ មានអត្ថបទពិបាកៗ និងការបកស្រាយជាច្រើន ហើយជាទូទៅយើងមានពេលតិចតួចនៅក្នុងការអានឲ្យបានគ្រប់កន្លែង។ អ្នកគ្រូ ចេន វាល឴ ឃីន (Jen Wilkin) បានទទួលស្គាល់ចំណុចនេះ ហើយបានផ្តល់នូវចំណុចអនុវត្តន៍មួយចំនួន ដើម្បីជួយយើងឲ្យអាចធ្វើដំណើរទៅបានជាមួយនឹងចំណុចទាំងនេះ។ សៀវភៅស្ត្រីនៃព្រះបន្ទូលផ្តល់ឲ្យយើងនូវប្លង់នៃចំណោះខាងឯព្រះគម្ពីរ។ ប្រសិនបើយើងចង់ស្គាល់ព្រះជាម្ចាស់ដែលយើងស្រឡាញ់ យើងត្រូវភ្ជាប់គំនិតរបស់យើងក្នុងការស្គាល់ព្រះបន្ទូលរបស់ព្រះអង្គ ជាកន្លែងដែលទ្រង់បានបង្ហាញអង្គទ្រង់នៅទីនោះ។ វិធីរបស់អ្នកគ្រូ វាល ឃីន ប្រហែលជាថ្មីសម្រាប់បងប្អូនមួយចំនួន ប៉ុន្តែការខិតខំប្រឹងប្រែងគឺជារង្វាន់ដ៏មានតម្លៃ។ នៅចុងបញ្ចប់ វាគឺជាការមើលឃើញ និងការទទួលយកនូវរសជាតិអំពីព្រះសង្គ្រោះរបស់យើង។

Trillia Newbell, author, If God Is for Us; Fear and Faith; and United

សៀវភៅអ្នកគ្រូ ចេន សរសេរឡើងជាមួយនឹងចំណុចដែលគួរឲ្យចូលចិត្ត និងមានភាពកក់ក្តៅ ដែលធ្វើឲ្យសៀវភៅនេះងាយស្រួលនៅក្នុងការអាន។ ប៉ុន្តែ គាត់បានសរសេរជាមួយនឹងគោលបំណងច្បាស់លាស់របស់គាត់ ដែលជំរុញដល់អ្នកអានចង់អាននូវព្រះបន្ទូលរបស់ព្រះឲ្យបានល្អ និងត្រឹមត្រូវ។ ចំណុចសំខាន់គឺ៖ សៀវភៅនេះលើកទឹកចិត្តដល់ស្ត្រីឲ្យបានស្គាល់ព្រះជាម្ចាស់ឲ្យបានល្អប្រសើរដោយអភិវឌ្ឍន៍នូវទម្លាប់ក្នុងការអានព្រះបន្ទូលរបស់ព្រះអង្គ។

Jenny Salt, Dean of Students, Sydney Missionary and Bible College

តើយើងនឹងចូលទៅឲ្យជ្រៅ ឲ្យម៉ត់ចត់ជាងនេះ ទៅក្នុងព្រះគម្ពីរសម្រាប់ការជំរុញទឹកចិត្តដោយរបៀបណា? អ្នកគ្រូ ចេន បង្ហាញយើងអំពីចំណុច ដែលត្រូវតែអានសម្រាប់ស្ត្រីទាំងអស់ដែលមានការចាប់អារម្មណ៍នៅក្នុងការបង្រៀន និងការរៀនសូត្រ ពិភាក្សាព្រះគម្ពីរជាក្រុមនៅក្នុងក្រុមជំនុំរបស់អ្នក។

**Nancy Guthrie,** author, *Even Better Than Eden: Nine Ways the Bible's Story Changes Everything about Your Story*

JEN WILKIN

# ស្ត្រីនៃព្រះបន្ទូល

Women of the Word

របៀបសិក្សាព្រះគម្ពីរដោយចិត្ត
និងគំនិតរបស់យើង

ផ្លូវពិត

Khmer Women of the word_Layout.indd 5 12/3/26 3:56 in the afternoon

Women of the Word: How to Study the Bible with Both Our Hearts and Our Minds

*ស្ត្រីនៃព្រះបន្ទូល៖ របៀបសិក្សាព្រះគម្ពីរដោយចិត្ត និងគំនិត*

©2014 by Jennifer Wilkin

Published by Crossway a publishing ministry of Good News Publishers

Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.

All rights reserved.

Khmer version ©2026 by Crossway

This edition in Khmer copyright ©2026 by ACTION Cambodia Organization

All rights reserved.

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៦

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោកស្រី ហង្ស សោភ័ណ

ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា និងលោក វ៉ើល ណាថាន

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ហុង សម្កស, លោក ឡង់ គឹមឡុង, លោក ឯក សត្យា និងលោកស្រី ហឿន ចាន់ស្រីលុច, លោកស្រី ឡូញ ស្រីរ័ត្ន, លោកស្រី ថារ ប៊ុនរី នឹង កញ្ញា រិន ខារីសា

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ើល ណាថាន និងលោក វណ្ណដ្ឋា សុតរ៉ាប៊ី

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ plovpitshop.com

បោះពុម្ពលើកទី១ ចំនួន ៣.០០០ ក្បាល ២០២6 នៃគ.ស. ISBN 9-789924-566182

ជូនចំពោះ ជេហ្វ (Jeff) ដែលជាប្តីខ្ញុំ។ បងស្គាល់អូនខ្លាំង
ជាងគេ។ បងផ្តល់សេចក្តីក្លាហានដល់អូន។ ទំនុកតម្កើង ៣៤:៣

# មាតិកា


អារម្ភកថាពីអ្នកបកប្រែ ១១

អារម្ភកថា ១៥

ការថ្លែងអំណរគុណ ១៩

សេចក្តីផ្តើម ២១

១. ការបង្វែរត្រឡប់មកវិញ ២៩

២. មូលហេតុដែលយើងត្រូវការសិក្សាព្រះគម្ពីរ ៤៩

៣. ការសិក្សាដោយមានគោលបំណង ៦៧

៤. ការសិក្សាដោយមានទស្សនវិស័យ ៨៣

៥. ការសិក្សាដោយមានការអត់ធ្មត់ ១០៣

៦. ការសិក្សាតាមលំដាប់លំដោយ ១២១

៧. ការសិក្សាដោយមានការអធិស្ឋាន ១៤៥

៨. ការដាក់រួមបញ្ចូលគ្នាទាំងអស់ ១៥៥

៩. ជំនួយសម្រាប់គ្រូបង្រៀន ១៧៥

សេចក្តីសន្និដ្ឋាន ១៩៩

ការណែនាំឲ្យប្រើប្រាស់ធនធាន ២០៩

កំណត់យោង ២១១

លិបិក្រមតាមព្រះគម្ពីរ ២១៣

Khmer Women of the word_Layout.indd 10 12/3/26 3:56 in the afternoon

# អារម្ភកថាពីអ្នកបកប្រែ

កាលពីខ្ញុំអាយុ២០ឆ្នាំ ខ្ញុំធ្វើការនៅក្នុងព័ន្ធកិច្ចមួយដែលផ្តោតទៅលើព្រះគម្ពីរ យើងលើកទឹកចិត្តកុមារ ក្មេងជំទង់ និងយុវជនឲ្យស្រឡាញ់ការអានព្រះគម្ពីរ ដោយបង្រៀនពួកគាត់ឲ្យចេះអំពីរបៀបធ្វើភាពស្ញៀមស្ងាត់។ ហើយរហូតមកដល់ពេលនេះជាង២៥ឆ្នាំកន្លងមកហើយ ខ្ញុំនៅតែបម្រើព័ន្ធកិច្ចក្នុងទម្រង់បែបនេះ គឺផ្តោតទៅលើការបង្កើតសិស្សជាមួយកុមារ ក្មេងជំទង់ និងគ្រូកុមារ។ ហើយអ្វីដែលជាសេចក្តីប៉ងប្រាថ្នាដ៏ធំរបស់ខ្ញុំនោះគឺថា ខ្ញុំចង់ឃើញពួកគាត់ចេះចំណាយពេលផ្ទាល់ខ្លួន ដោយសិក្សាព្រះគម្ពីរ និងរីកចម្រើននៅក្នុងការស្គាល់ព្រះជាម្ចាស់ផ្ទាល់។ ហេតុដូច្នេះហើយបានជាវិធីសាស្រ្ត និងមេរៀនដែលនិយាយអំពីការចូលគាល់ព្រះ ការសិក្សាព្រះបន្ទូលរបស់ព្រះ គឺជាអ្វីដែលខ្ញុំតែងតែចាប់អារម្មណ៍ និងចង់ធ្វើការស្វែងយល់។ ខ្ញុំពិតជាអរគុណព្រះអង្គ សម្រាប់ «សៀវភៅស្រ្តីនៃព្រះបន្ទូល» មួយក្បាលនេះណាស់។ ខ្ញុំបានមានការទាក់ទាញចិត្តចង់អានពេលគ្រាន់តែឃើញចំណងជើងបាត់ទៅហើយ ហើយចង់ដឹង និងចង់សិក្សាថា តើមានអ្វីខ្លះនៅក្នុងសៀវភៅនេះ ឬក៏ដូចជាថាមានចំណុចមួយចំនួនដែលខ្ញុំបានធ្លាប់រៀនពីមុនដែរឬទេ។

តើបងប្អូនដឹងថាការសិក្សាព្រះគម្ពីររបស់យើងពិតជាមានលក្ខណៈត្រឹមត្រូវ ហើយថាពិតជា កំពុងលូតលាស់ដែរឬទេ? តើបងប្អូនស្គាល់ព្រះគម្ពីររបស់ខ្លួន ឬព្រះនៃព្រះគម្ពីរដល់កម្រិតណា? តើការសិក្សាព្រះគម្ពីរ (ព្រះជាម្ចាស់មុនខ្ញុំ គំនិតមុនចិត្ត) ចង់និយាយអំពីអ្វី? តើបងប្អូនអាចស្គាល់ព្រះជាម្ចាស់ និងលក្ខណសម្បត្តិរបស់ទ្រង់ឲ្យបានកាន់តែល្អប្រសើរតាមវិធីណា? តើការសិក្សា



Khmer Women of the word_Layout.indd 11 12/3/26 3:56 in the afternoon

ព្រះគម្ពីរ ដែលទទួលបានការបណ្តុះបណ្តាល ឬការបង្ហាញអំពីចំណេះដឹងនៃសេចក្តីបង្រៀនរបស់ព្រះបន្ទូលមានលក្ខណៈយ៉ាងដូចម្តេច? តើបងប្អូនកំពុងស្វែងរកវិធីសាស្ត្រ ដែលមានសក្តានុពល ដើម្បីជួយបងប្អូនឲ្យលូតលាស់នៅក្នុងចំណេះដឹងខាងឯព្រះបន្ទូលដែរឬទេ? ចម្លើយសម្រាប់សំណួរទាំងអស់នេះ គឺមាននៅក្នុងសៀវភៅនេះ។

សៀវភៅ "ស្ត្រីនៃព្រះបន្ទូល" ឆ្លើយតបនូវសំណួរទាំងនេះ ពីព្រោះអ្នកនិពន្ធបានវែកញែកចំណុចទាំងនេះយ៉ាងស៊ីជម្រៅ។ ហើយចំណុចនីមួយៗឆ្លើយបានយ៉ាងច្បាស់ និងក្បោះក្បាយ ព្រមទាំងលើកយកឧទាហរណ៍មកពន្យល់ឲ្យបងប្អូនកាន់តែយល់ថែមទៀតផង។ ហើយក៏នៅមានចំណុចលម្អិតជាច្រើនទៀតដែលអ្នកនិពន្ធបានលើកយកមក គឺសុទ្ធតែមានប្រយោជន៍ជួយដល់ការរីកលូតលាស់ នៅក្នុងការសិក្សាព្រះគម្ពីរខ្លាំងណាស់។ សៀវភៅនេះពិតជាបានជំរុញយើងឲ្យងាកបែរទៅរកការសិក្សាព្រះគម្ពីរដែលពេញលេញ ស៊ីជម្រៅ និងខ្ជាប់ខ្ជួន។ អ្នកនិពន្ធបានលើកអំពីចំណុចសក្តានុពលនៃការសិក្សាព្រះគម្ពីរ ដែលមានប្រសិទ្ធភាពប្រាំចំណុច គាត់ពន្យល់ដោយមានឧទាហរណ៍ជាគំរូអំពីចំណុចដែលគាត់បានលើកឡើង។ ដោយសារអ្នកនិពន្ធជាគ្រូបង្រៀនព្រះគម្ពីរដល់ស្ត្រី នោះគាត់ក៏បានផ្តល់ជំនួយ និងចំណុចគ្រោះថ្នាក់សម្រាប់យើងក្នុងនាមជាគ្រូបង្រៀនដែរ។

សម្រាប់ខ្ញុំផ្ទាល់ នៅពេលដែលខ្ញុំបានអាន និងធ្វើការសិក្សាអំពីសៀវភៅនេះហើយ ខ្ញុំពិតជាដឹងថា ខ្ញុំមិនបានអាន និងសិក្សាព្រះគម្ពីររបស់ខ្ញុំឲ្យបានត្រឹមត្រូវទេ។ ការបង្រៀនរបស់ខ្ញុំក៏មានការ ខ្វះចន្លោះជាច្រើន ហើយខ្ញុំពិតជាមានបំណងចង់ស្គាល់ព្រះជាម្ចាស់ថែមទៀត សៀវភៅនេះធ្វើឲ្យខ្ញុំកាន់តែចង់សិក្សាព្រះគម្ពីរឲ្យបានត្រឹមត្រូវ និងពេញលេញជាងមុន។ សៀវភៅនេះបានជួយជាគំនិតដល់ខ្ញុំក្នុងនាមជាគ្រូបណ្តុះបណ្តាលម្នាក់ ដែលបង្រៀនព្រះបន្ទូលដល់គ្រូកុមារ យុវជន និងក្មេងៗឲ្យមានការប្រុងប្រយ័ត្ន។ នៅក្នុងការនាំយកសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅដល់សិស្ស ត្រូវធ្វើដោយ



Khmer Women of the word_Layout.indd 12 12/3/26 3:56 in the afternoon

ស្មោះត្រង់ក្នុងការរៀបចំជាមុន ដើម្បីបង្រៀន។

ចំណុចអនុវត្ត សម្រង់សម្ដីលើកទឹកចិត្ត គោលការណ៍លម្អិត ឧទាហរណ៍ចេញពីបទពិសោធន៍ជីវិតគឺពិតជាមានច្រើនណាស់នៅក្នុងសៀវភៅនេះ។ ខ្ញុំអធិស្ឋានដោយប្រាថ្នាចង់ឃើញបងប្អូនអានសៀវភៅនេះ សូមកុំឲ្យចំណងជើងរារាំងមនុស្សប្រុសពីការអានឡើយ។ ប្រសិនបើបងប្អូនកំពុងស្វែងរកវិធីសាស្រ្តសិក្សាព្រះគម្ពីរ ឬចង់យល់ដឹងអំពីរបៀបបង្រៀនព្រះបន្ទូលដែលមានប្រសិទ្ធភាព ជាពិសេសបងប្អូន ដែលមានតួនាទីជាគ្រូបង្រៀនព្រះបន្ទូល មិនថាក្នុងក្រុមតូច ថ្នាក់សាលាថ្ងៃអាទិត្យ ថ្នាក់បង្កើតសិស្ស ឬក៏ចង់បង្កើនចំណេះដឹងព្រះបន្ទូលផ្ទាល់ខ្លួនក៏ដោយ សូមអានសៀវភៅនេះចុះ នោះបងប្អូននឹងមិនខកចិត្តឡើយ។ បន្ទាប់ពីបានអានដោយខ្លួនឯងហើយ នោះបងប្អូននឹងមានបំណងចង់ចែករំលែកឲ្យមិត្តភក្តិ កូនសិស្ស ឬមនុស្សជាទីស្រឡាញ់របស់បងប្អូនដែរជាមិនខាន។

សូមព្រះប្រទានពរ

លោកស្រី ហង្ស សោភ័ណ

— ប្រធានព័ន្ធកិច្ចវាលចម្រូត



Khmer Women of the word_Layout.indd 13 12/3/26 3:56 in the afternoon

Khmer Women of the word_Layout.indd 14 12/3/26 3:56 in the afternoon

# អារម្ភកថា

នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបើកភ្នែកខ្ញុំឲ្យបានជឿ វាហាក់បីដូចជាខ្ញុំត្រូវបានរទេះភ្លើងបរមកបុកអញ្ចឹង។ ខ្ញុំបានលង់ស្រឡាញ់ព្រះយេស៊ូវនៅយប់នោះ ហើយសេចក្ដីស្រឡាញ់នោះនៅតែបន្ត ឥតឈប់ឈរ ប៉ុន្តែបើទោះជានៅក្នុងចិត្តរបស់ខ្ញុំ កំពុងឆេះសន្ធោសន្ធៅក៏ដោយ ក៏ក្នុងគំនិតរបស់ខ្ញុំនៅទទេរស្អាត។ នៅយប់នោះ ខ្ញុំមានសំណួរសួររាប់រយសំណួរ និងក្នុងថ្ងៃបន្ទាប់ៗទៀតផងដែរ។

ដោយសារព្រះគុណរបស់ព្រះជាម្ចាស់ ព្រះអង្គបានប្រទានបុរសម្នាក់មកកាន់ជីវិតខ្ញុំ ដែលមានចិត្តចង់បង្រៀនខ្ញុំទាំងអំពីដំណាក់កាលដំបូងៗអំពីព្រះគម្ពីរ។ នេះគឺជាសម្រង់សម្ដីរបស់**លោក អឺដ ខ្លូវនីយ** ( **Ed Clowney** ) ដែលគាត់បានសង្ខេបអំពីអ្វីដែលខ្ញុំបានរៀនកាលពីដំណាក់កាលដើមដំបូងនោះ។

> “មានសាច់រឿងដ៏អស្ចារ្យជាច្រើននៅក្នុងព្រះគម្ពីរ…ហើយយើងអាចដឹងអំពីសាច់រឿងព្រះគម្ពីរបាន ប៉ុន្តែនៅមានការមិនដឹងអំពីដំណើររឿងក្នុងព្រះគម្ពីរ…. ព្រះគម្ពីរមានខ្សែរឿងជាលំដាប់លំដោយនៃសាច់រឿង។ មានបង្ហាញអំពីឈុតឆាកផ្សេងៗក្នុងសាច់រឿង។ រឿងទាំងនោះគឺបង្ហាញអំពីប្រវត្តិសាស្រ្តរបស់អ៊ីស្រាអែល ប៉ុន្តែប្រវត្តិសាស្រ្តមិនបានចាប់ផ្ដើមនៅទីនោះឡើយ ហើយក៏មិនបានផ្ដល់ឲ្យនូវ អ្វីដែលយើងរំពឹងនៅ ក្នុងប្រវត្តិសាស្រ្តរបស់ជាតិឡើយ…. ប្រសិនបើយើងភ្លេចអំពីខ្សែរឿងទាំងនោះ ដូចជាយើងកាត់ផ្ដាច់ ចំណុចបេះដូងចំកណ្ដាល ចេញពីព្រះគម្ពីរតែម្ដង។ ហេតុដូច្នេះហើយបានជាសាច់រឿងនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យបាននិទានឡើង តាមរបៀបបង្ហាត់ឲ្យចេះនិទានបែបស្រាលៗអំពីតួអង្គក្នុងសាច់រឿងនៅថ្ងៃអាទិត្យ ដូចតួអង្គ សាំសុន ជំនួស



Khmer Women of the word_Layout.indd 15 12/3/26 3:56 in the afternoon

> ឲ្យដូចជាតួវីរបុរសដែលជួយសង្គ្រោះ។ ស្តេច ដាវីឌ បានក្លាយទៅជាតួអង្គអ្នកក្លាហានវ័យក្មេងដែលអាចសម្លាប់យក្សធំបាន។ ទេ! តាមពិតស្តេច ដាវីឌ មិនមែនជាក្មេងប្រុសតូចដែលក្លាហាន មិនចេះភ័យខ្លាចចំពោះយក្សដ៏ធំយង់ឃ្នងនោះទេ។ ព្រះជាម្ចាស់បានចាក់ប្រេងតាំងលើស្តេច ដាវីឌ...ព្រះជាម្ចាស់បានជ្រើសរើសស្តេច ដាវីឌ ឲ្យធ្វើជាស្តេចដែលត្រូវនឹងព្រះហឫទ័យទ្រង់ ដើម្បីរៀបចំបុត្រាដ៏អស្ចារ្យដែលនឹងកើតចេញពីស្តេច ដាវីឌ។ ដែលជាព្រះដែលមានជ័យជម្នះ និងជាព្រះដែលជួយរំដោះយើង»។[១]

អស់រយៈពេលជាង២០ឆ្នាំមកនេះ ព្រះវិញ្ញាណបរិសុទ្ធបានប្រើព្រះបន្ទូលដើម្បីលើកទឹកចិត្តខ្ញុំ កែតម្រង់ រៀបចំអាពាហ៍ពិពាហ៍របស់ខ្ញុំ ការមើលថែបីបាច់ថែរក្សាកូន របៀបប្រើប្រាស់លុយកាក់ និងការសម្លឹងមើលទៅអនាគតដែលស្ថិតក្នុងស្ថានភាពសោកសង្រេងរបស់ខ្ញុំ។ម្តងហើយម្តងទៀត ព្រះអង្គបាននាំភ្នែករបស់ខ្ញុំឲ្យមើលទៅបុគ្គលម្នាក់ ដែលគ្រប់ផ្នែកទាំងអស់នៃព្រះគម្ពីររៀបរាប់អំពីទ្រង់។ ចិត្តរបស់ខ្ញុំមានពេញដោយសេចក្តីប៉ងប្រាថ្នាយ៉ាងខ្លាំងក្នុងការចង់ឲ្យអ្នកដទៃទៀតបានឃើញ និងបានស្គាល់ព្រះនៃព្រះគម្ពីរ ហើយស្របពេលនោះដែរខ្ញុំក៏មានការឆ្លើយតបដែលបាក់ទឹកចិត្តបាននៅពេលដែលខ្ញុំឃើញការឈឺចាប់ ការបាត់បង់ និងការខ្វះនូវទំនុកចិត្ត ដែលកិច្ចការទាំងនោះនឹងនាំឲ្យពួកគេខ្វះចំណេះដឹងខាងឯព្រះគម្ពីរ។ អ្នកគ្រូ ចេន វ៉ាលឃីន (Jen Wilkin) បានលើកអំពីរបៀបស្គាល់ព្រះក្នុងព្រះគម្ពីរយ៉ាងម៉ត់ចត់។ អ្នកគ្រូជាគ្រូបង្រៀនព្រះគម្ពីរល្អម្នាក់ ដែលខ្ញុំមានឱកាសបានស្តាប់ការបង្រៀនរបស់គាត់។ របៀបបង្រៀនរបស់ គាត់ អំពីវិធីដែលជួយពួកគេ ឲ្យលូតលាស់នៅក្នុងចំណេះដឹងនៃព្រះបន្ទូលគឺងាយយល់ ហើយមានប្រយោជន៍ មិនថាភាពធ្វេសប្រហែសរបស់អ្នកដែលជាគ្រីស្ទបរិស័ទជាងមួយទសវត្សមានអារម្មណ៍ថា ដូចជាយឺតពេល ឬអ្នកដែលទើបនឹងជឿថ្មីដែលស្រេកឃ្លានចង់ស្គាល់ និងយល់ដឹងអំពីព្រះនៃព្រះគម្ពីរនោះទេ។ ក្រុមជំនុំទាំងមូលត្រូវតែក្លាយជាបុរស និងស្ត្រី

---

១ លោក Edmund P. Clowney, *The Unfolding Mystery: Discovering Christ in the Old Testament* (Phillipsburg, NJ: P&R, ឆ្នាំ១៩៨៨), ទំព័រ១១១។



Khmer Women of the word_Layout.indd 16 12/3/26 3:56 in the afternoon

នៃព្រះបន្ទូល ហើយ (កុំឲ្យចំណងជើងសៀវភៅ នេះបោកបញ្ឆោតអ្នកឡើយ) ពីព្រោះសៀវភៅនេះបានផ្ដល់នូវការណែនាំដែលយើងទាំងអស់គ្នាត្រូវការ។ ហេតុដូច្នេះ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលអ្នកកំពុងកាន់សៀវភៅនេះ។

មានចំណុច៥យ៉ាង៖ ការមានគោលបំណង ការមានទស្សនវិស័យ ការអត់ធ្មត់ ការសិក្សាតាមលំដាប់លំដោយ និងការអធិស្ឋាន ដែលបានលើកឡើងក្នុងសៀវភៅនេះ ចំណុចទាំងនោះនឹងជួយអ្នកឲ្យមានលក្ខណៈកាន់តែប្រសើរ ពីមួយថ្ងៃទៅមួយថ្ងៃ មួយសប្ដាហ៍ទៅមួយសប្ដាហ៍ និងមួយខែទៅមួយដែលនៅខាងមុខនេះ។ ខ្ញុំពិតជាមានការជឿជាក់នៅពេលដែលអ្នកបានរៀន និងអនុវត្តវិធីសាស្ត្រសិក្សាព្រះគម្ពីររបស់អ្នកគ្រូ ចេន នោះលោកអ្នកនឹងមានការចាប់អារម្មណ៍ទាំងពីរ៖ ទាំងឈុត ឆាក សាច់រឿងរបស់ព្រះគម្ពីរ និងអត្ថន័យនៃរឿងព្រះគម្ពីរផ្ទាល់ផងដែរ។ ហើយអ្នកនឹងទទួលបានការផ្លាស់ប្ដូរជារៀងរហូត នៅពេលដែលអ្នកបាន ស្គាល់ វីរបុរសនៃសាច់រឿងទាំងនោះ។

មានព្រះគ្រីស្ទគ្រប់គ្រាន់ហើយ!<br>
លោក Matt Chandler<br>
គ្រូគង្វាលរៀមច្បងនៅ The Village Church<br>
President, Acts 29 Church Planting Network

Khmer Women of the word_Layout.indd 17 12/3/26 3:56 in the afternoon

# ការថ្លែងអំណរគុណ

ខ្ញុំពិតជាមានការដឹងគុណដល់លោក ខូលីន ហេនសេន (Collin Hansen) និងលោក ដេវ ឌីវីឌ (Dave DeWit) ដែល ជឿជាក់មកលើខ្ញុំ នូវអ្វីដែលខ្ញុំចង់និយាយ និងផ្តល់ឲ្យខ្ញុំនូវវិធីសាស្ត្រក្នុងការនិយាយអំពីវា។ អ្នកទាំង ពីរបានដឹងថាពីមុនខ្ញុំជាអ្នកនិពន្ធ មុនខ្ញុំធ្វើកិច្ចការនេះ។

ជូនចំពោះមិត្តភក្តិដ៏ស្មោះត្រង់របស់ខ្ញុំ (លោកស្រី ហ្វ្រេឌីធរ លីនសេយ, លោកស្រី ប្រីថាន ឃីនដ្រា គ្រីឌើរ, លោកស្រី ឡូរី ឃួយឃីនដល និងលោកស្រី គ្រីស្ទីន វ៉ាបាលេស) ខ្ញុំសូមអរគុណដែលបានអានសៀវភៅនេះពេលដែលនៅមានភាពរញ៉េរញ៉ៃ នៅក្នុងគំនិតរបស់ខ្ញុំ ហើយបានជួយខ្ញុំយ៉ាងទន់ភ្លន់ឲ្យបានក្លាយជាអ្នកទំនាក់ទំនងដ៏ល្អប្រសើរម្នាក់។ ខ្ញុំពិតជាឲ្យតម្លៃលើការកែតម្រូវរបស់អ្នកទាំងអស់គ្នាណាស់ ប៉ុន្តែខ្ញុំឲ្យតម្លៃលើមិត្តភាពរបស់អ្នកទាំងអស់គ្នាច្រើនជាង។

ខ្ញុំសូមអរគុណដល់លោកស្រី អេមីលី ស្ប៉ាលឌីង និងលោកស្រី សាលី ស្ទូម បានផ្តល់ការព្យាបាលដោយមិនយកថ្លៃ នៅពេលដែលជួបខ្ញុំ ដើម្បីប្រឹក្សា។ ខ្ញុំស្រឡាញ់អ្នកទាំងពីរណាស់។

លោកស្រី តារ៉ា ដាវីស ខ្ញុំក៏សូមអរគុណផងដែរ ដែលបានជួយកែសម្រួលសៀវភៅរបស់ខ្ញុំដោយមានការអត់ធ្មត់ និងការអនុគ្រោះ។ ចំពោះ លោកស្រី គ្លូរៀ ហ្វូរមែន ការដែលអ្នកបានអាននូវសេចក្តីពង្រាង នៃការសរសេរសៀវភៅរបស់ខ្ញុំ ក្នុងមួយសប្តាហ៍បន្ទាប់ពីកូនទី៤របស់អ្នកបានសម្រាលមក។ ខ្ញុំដឹងច្បាស់ថាអ្នកមានកិច្ចការផ្សេងទៀតដែលត្រូវធ្វើ តែការលើកទឹកចិត្តរបស់អ្នកគឺ



Khmer Women of the word_Layout.indd 19 12/3/26 3:56 in the afternoon

ជាអំណោយ ដែលមិនអាចកាត់ថ្លៃបានឡើយ។

លោក ម៉ាត ឆានឌ្ល័រ បានពង្រីកនូវចំណងមិត្តភាព និងបានគាំទ្រដល់ព័ន្ធកិច្ច និងអត្ថបទរបស់ខ្ញុំ គឺខ្ញុំមិនអាចសងវិញបានទេ។ ខ្ញុំសូមអរគុណដែលលោកបានធ្វើជាគ្រូគង្វាលរបស់ខ្ញុំ។ លោក ខេន រ៉ាបាលេស និងលោកស្រី សារ៉ា ទ្បេម ការស្ម័គ្រចិត្តជួយរបស់អ្នកបានធ្វើឲ្យតួនាទីរបស់ខ្ញុំនៅក្នុងក្រុមជំនុំ និងការប្តេជ្ញាចិត្តសរសេររបស់ខ្ញុំអាចមានតុល្យភាព ហើយក៏បានជួយមិនឲ្យខ្ញុំវង្វេងដែរ។

ម៉ាត, ម៉ារី ខេត, ឃ្លេរ និង ខាលវីន អ្នកទាំងអស់គ្នាគឺជាកូនសំណព្វរបស់ខ្ញុំក្នុងពិភពលោកនេះ។ ដោយកូនៗអនុញ្ញាតិឲ្យម៉ាក់មានឱកាសការសរសេរ និងជួយម៉ាក់ឲ្យមានជំហរ ក្នុងការថែរក្សាផ្ទះសម្បែង គឺកូនៗជាដៃគូជាមួយម៉ាក់នៅក្នុងព័ន្ធកិច្ចនេះហើយដែរ។ ឥឡូវ សូមផ្អាកញ៉ាំគុយទាវសរសៃធំ មួយរយៈសិន។

ចំពោះក្រុមស្ត្រីសិក្សាព្រះគម្ពីរស្ត្រីនៅ Flower Mound ការស្រេកឃ្លានសម្រាប់សេចក្តីសុចរិតរបស់អ្នកក៏បានបន្តជំរុញ និងលើកទឹកចិត្តឲ្យដៃរបស់ខ្ញុំនៅតែមានចលនាសរសេរ។ ខ្ញុំសូមអរគុណដែលអ្នកទាំងអស់គ្នាបាននៅបន្តជាប់ជាមួយនឹងខ្ញុំ និងបន្តស្រឡាញ់ព្រះជាម្ចាស់អស់ពីគំនិតរបស់អ្នក។ អ្នកទាំងអស់គ្នាមានតម្លៃណាស់ ព្រោះបានរម្លឹកខ្ញុំជាប្រចាំសប្តាហ៍ថា ការសរសេរនេះមានសារៈសំខាន់។



Khmer Women of the word_Layout.indd 20 12/3/26 3:56 in the afternoon

# សេចក្ដីផ្ដើម

តើយើងនឹងកាយរើភ្នំមួយយ៉ាងដូចម្ដេច?
ដោយជាមួយដីមួយស្លាបព្រាម្ដងៗ។
(សុភាសិតរបស់ជនជាតិចិន)

នេះគឺជាសៀវភៅដែលនិយាយអំពីការកាយភ្នំ។ ភ្នំគឺជាខ្លួនខ្ញុំផ្ទាល់ ទោះជាយ៉ាងណាខ្ញុំសូមសារភាពថា ខ្ញុំ ពិតជាបានមើលរំលងវត្តមានរបស់វា រហូតដល់ខ្ញុំមានអាយុ២០ឆ្នាំ។ ខ្ញុំក៏សង្ស័យថានេះប្រហែលអាចជាភ្នំរបស់អ្នកដែរ ប៉ុន្តែអ្នកត្រូវសម្រេចចិត្តសម្រាប់ខ្លួនអ្នកផ្ទាល់។ វាមិនដូចជាភ្នំឪវ៉ាល់ ឬភ្នំគូលែនដែលបង្ហាញឲ្យយើងឃើញភ្លាមៗនោះទេ គឺត្រូវចំណាយពេលយូរ ដើម្បីមើលឃើញ។ ពិតជាល្អណាស់ដែលភ្នំនេះវាមិនមែនជាភ្នំមែនទែន ភ្នំនេះយើងអាចនឹងកាយចេញបាន នោះគឺជាការល្អ ពីព្រោះមានអ្វីមួយនៅជ្រុងម្ខាងទៀតដែលហួសពីការពណ៌នាមានភាពស្រស់ស្អាតដែលយើងនឹងឃើញ។

ប្រសិនបើមានប្រវត្តិសាស្ត្រសាសនាជាផ្លូវការ នោះប្រវត្តិរបស់ខ្ញុំគឺមិនច្បាស់លាស់ទេ—គឺវាមានការលាយឡំគ្នា។ ខ្ញុំបានចំណាយពេលវ័យកុមារភាពរបស់ខ្ញុំ ស្វែងរកក្រុមជំនុំដែលខ្ញុំអាចហៅថាជា ផ្ទះចេញពីកន្លែងមួយទៅកន្លែងមួយទៀតតាមឪពុកម្ដាយរបស់ខ្ញុំ (ដែលពួកគាត់បានលែងលះគ្នាកាលពីខ្ញុំអាយុ៩ឆ្នាំ) ទៅកន្លែងថ្វាយបង្គំរបស់ពួកគាត់ដែលកំពុងថ្វាយបង្គំ។ ខ្ញុំបានចំណាយពេលជាច្រើននៅឯនិកាយធំៗ៧កន្លែង ដែលខ្ញុំបានចូលរួមដូចជាថ្នាក់សាលាថ្ងៃអាទិត្យ កម្មវិធីយុវជន និងការប្រកបសម្រាកលម្ហែ។ ខ្ញុំ



Khmer Women of the word_Layout.indd 21 12/3/26 3:56 in the afternoon

ទទួលការជ្រមុជទឹកកាលពីខ្ញុំនៅជាទារក និងបានធ្វើពិធីជ្រមុជទឹកពេលខ្ញុំមានវ័យជំទង់ម្តងទៀត។ ខ្ញុំបានច្រៀងបទទំនុកតម្កើង ក្នុងសៀវភៅទំនុកតម្កើងដែលរៀបចំសម្រាប់ភ្លេងលេងដោយព្យាណូរ ហើយខ្ញុំក៏បានច្រៀងបទសរសើរ ចេញពីផ្ទាំងបញ្ចាំងស្លាយដែលរៀបចំសម្រាប់អ្នកលេងហ្គីតារ។ ខ្ញុំរៀនលើកដៃពេលខ្ញុំថ្វាយបង្គំ ហើយខ្ញុំក៏បានរៀនដាក់ដៃចុះនៅចំហៀងខ្លួនរបស់ខ្ញុំដែរ ពេលកំពុងថ្វាយបង្គំ។ ខ្ញុំបានឮការចែកចាយព្រះបន្ទូលដែលមានសម្លេង ស្មើរលូន ហើយក៏បានឮការចែកចាយដែលស្រែកខ្លាំងៗ។ ខ្ញុំបានរៀនពីចង្វាក់នៃការសូត្រគោល ជំនឿក្នុងក្រុមជំនុំ ក៏ដូចជាចង្វាក់នៃការគោះក្រាប់និងការរាំផងដែរ។ ខ្ញុំរៀនធ្វើភាព «ស្ងៀមស្ងាត់» និងចងចាំខព្រះគម្ពីរជាច្រើនដើម្បីខ្ញុំអាចទទួលបានសំបុត្រចូលរួមការបោះជំរុំពេលសាលារាំកង ដោយមិនបាច់បង់ប្រាក់។ ខ្ញុំបានរៀនចេះចែកចាយដំណឹងល្អជាមួយមិត្តភក្តិដែលមិនទាន់ជឿ។ ខ្ញុំជាក្មេងដែលធំធាត់ក្នុងក្រុមជំនុំ មិនតែប៉ុណ្ណោះគ្រប់ប្រភេទនៃក្រុមជំនុំផង ខ្ញុំអាចឆ្លើយសំណួរនៅថ្នាក់សាលាថ្ងៃ អាទិត្យដែលធ្វើឲ្យគ្រូខ្ញុំមានមោទនភាពក្រៃលែង។

ហើយនៅមហាវិទ្យាល័យខ្ញុំក៏បានបន្តដំណើរនៅក្នុងនិកាយនៃជំនឿរបស់ខ្ញុំ ទាំងអានសៀវភៅសិក្សា ព្រះបន្ទូល និង ចូលរួមសិក្សាព្រះគម្ពីរ ដើម្បីពង្រឹងសេចក្តីជំនឿរបស់ខ្ញុំឲ្យកាន់តែរឹងមាំឡើង។ នៅឆ្នាំចុងក្រោយ ខ្ញុំត្រូវបានអ្នកដឹកនាំស្នើសុំឲ្យធ្វើអ្នកដឹកនាំការសិក្សា។ ប៉ុន្តែ ខ្ញុំបានលាក់ទុកនៅអាថ៌កំបាំងអំពីជីវប្រវត្តិដែលធម្មតារបស់ខ្ញុំទៅកាន់មនុស្សដែលមានប្រវត្តិដូចខ្ញុំ៖ ខ្ញុំមិនបានស្គាល់ព្រះគម្ពីររបស់ខ្ញុំទេ។ ពិតប្រាកដណាស់ ខ្ញុំគ្រាន់តែស្គាល់ផ្នែកខ្លះៗខ្ញុំចាំសាច់រឿងពីថ្នាក់ព្រះគម្ពីរពេលវិស្សមកាល ហើយខ្ញុំអាចដកស្រង់ខគម្ពីរចេញពីព្រះគម្ពីរសញ្ញាថ្មីទាំងមូល និងគម្ពីរទំនុកតម្កើង ប៉ុន្តែខ្ញុំមិនដឹងថាផ្នែកដែលខ្ញុំដឹងមានចំណុចស៊ីគ្នាយ៉ាងដូចម្តេចទេ ជាពិសេសនៅកន្លែងដែលព្រះគម្ពីរមានចំណុចស៊ីគ្នាក្នុងផ្នែកដែលខ្ញុំមិនទាន់បានដឹងនៅឡើយ។ ការលេចឡើងព្រាលៗនៅក្នុងការមើលឃើញរបស់ខ្ញុំ នោះគឺជាការមិនចេះព្រះគម្ពីរ



Khmer Women of the word_Layout.indd 22 12/3/26 3:56 in the afternoon

របស់ខ្ញុំ គឺបានចាប់ផ្ដើមធ្វើឲ្យខ្ញុំបារម្ភ។ ទោះបីខ្ញុំដាក់តម្លៃខ្ពស់លើអ្វីដែលខ្ញុំបានដឹង ក៏ខ្ញុំកាន់តែបារម្ភចំពោះអ្វីដែលខ្ញុំមិនទាន់ដឹងដែរ។

ការចំណាយពេលនៅក្នុងក្រុមជំនុំខុសៗគ្នាទាំងនោះបានបង្រៀនខ្ញុំឲ្យស្គាល់សេចក្ដីពិតដែលបានធ្វើឲ្យខ្ញុំព្រួយបារម្ភ ព្រោះគ្រូគង្វាលមានចំណុចនិយាយជាច្រើន ប៉ុន្តែមិនមែនគ្រប់គ្រូគង្វាលទាំងអស់និយាយដូចៗគ្នានោះឡើយ។ តើអ្នកណាដែលជាអ្នកត្រូវ? តើមានគ្រាឆក់យក ឬក៏អត់មាន? បើយើងអធិស្ឋានតាមរបៀបដែលត្រឹមត្រូវ តើដាច់ខាតព្រះអង្គត្រូវតែឆ្លើយតបការអធិស្ឋានរបស់យើងដែរឬទេ? តើខ្ញុំត្រូវធ្វើពិធីជ្រមុជទឹកម្ដងទៀតដែរឬទេ? តើផែនដីនេះមានរយៈពេលប៉ុន្មានឆ្នាំហើយ? តើអ្នកដែលជឿនៅក្នុងគ្រាព្រះគម្ពីរសញ្ញាចាស់ទទួលការសង្គ្រោះផ្សេងគ្នាពីអ្នកជឿនៅក្នុងគ្រាព្រះគម្ពីរសញ្ញាថ្មីមែនឬទេ? ភាគច្រើន គ្រូរបស់ខ្ញុំទាំងអស់ដូចជាបង្ហាញចំណុចគួរឲ្យទុកចិត្តដូចគ្នាទាំងអស់។ តើខ្ញុំអាចដឹងបានយ៉ាងដូចម្ដេចថា អ្នកណាកាត់ស្រាយព្រះគម្ពីរបានត្រឹមត្រូវ ហើយអ្នកណាបង្រៀនខុសឆ្គង? ខ្ញុំបានស្គាល់អំពីផលវិបាកឈឺចាប់នៃការបង្រៀនខុស ដូច្នេះបានធ្វើឲ្យបំណងប្រាថ្នាមួយកើតឡើងក្នុងខ្ញុំឲ្យចង់ដឹងដោយខ្លួនឯងថា ព្រះគម្ពីរបង្រៀនអំពីអ្វី។

ជីវិតអាពាហ៍ពិពាហ៍ និងភាពជាម្ដាយបានបង្កើនស្មារតីនៃភាពបន្ទាន់នៅក្នុងការរៀនរបស់ខ្ញុំ ហើយការនោះបានបង្ហាញឲ្យខ្ញុំឃើញអំពីកម្រិតនៃការអសមត្ថភាពរបស់ខ្ញុំ ជាតួនាទីដែលខ្ញុំត្រូវបំពេញជាខ្លាំងនៅក្នុងរបៀបដែលថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ ប៉ុន្តែ ខ្ញុំមិនដឹងចាប់ផ្ដើមចេញពីកន្លែងណាទេ ដើម្បីកែតម្រូវបញ្ហានេះ។ វាហាក់បីដូចលើសពីការជាក់ស្ដែងទៅទៀតគឺថាព្រះជាម្ចាស់បានផ្ដល់ការបើកសម្ដែងនៅក្នុងព្រះគម្ពីរ ដែលខ្ញុំគួរតែចំណាយពេលឲ្យបានច្រើនក្នុងការដឹង និងស្វែងយល់អំពីព្រះគម្ពីរ។ ប៉ុន្តែ ការងារនោះដូចជាធំលើសលប់ តើខ្ញុំត្រូវចាប់ផ្ដើមពីកន្លែងណា? ហើយហេតុអ្វីបានជាការដែលខ្ញុំធ្លាប់បានធ្វើពីមុនមិនបានធ្វើឲ្យបញ្ហានៃការយល់ដឹងរបស់ខ្ញុំបានប្រសើរជាងមុនសោះ? តើខ្ញុំត្រូវកាយភ្នំនៃការមិនចេះព្រះគម្ពីរនេះដោយរបៀប

ណាបាន?

ចម្លើយគឺពិតជាសាមញ្ញអស្ចារ្យណាស់។ ចម្លើយនោះគឺ "ម្តងមួយស្លាបព្រា"។ អរព្រះគុណព្រះអង្គ ដែលមានមនុស្សម្នាក់បានផ្តល់ស្លាបព្រាមួយឲ្យខ្ញុំ។

ខ្ញុំសូមសារភាពថា ពេលខ្ញុំបានចូលរួមការសិក្សាព្រះគម្ពីរស្ត្រីលើកដំបូង គឺខ្ញុំបានទៅដោយចង់មានការសន្ទនាបែបមនុស្សចាស់ៗ ដោយទៅរកនំ និងកាហ្វេ មិនថានៅក្នុងលំដាប់លំដោយដូចនេះនោះទេ។ ការមានអ្នកមើលថែកូនក្មេងដោយមិនគិតថ្លៃ គឺច្រើនហួសពីអ្វីដែលម្តាយវ័យក្មេងម្នាក់នេះដែលមានកូនអាយុបីខែមិនអាចបដិសេធបាន។ នេះជាមូលហេតុដែលខ្ញុំបានទៅចូលរួម គឺដើម្បីទៅកន្លែងដែលមានមនុស្សម្នា ក្រៅតែពីការមើលកូន។ ខ្ញុំបានរកឃើញនូវអ្វីដែលជាភាពផ្អែមល្ហែម ប៉ុន្តែគឺក្រុមស្ត្រីដែលមានចិត្តគំនិតដូចគ្នាផ្សារភ្ជាប់ជាមួយនឹងសហគមន៍ ការអធិស្ឋាន និងការសិក្សា។ អ្វីដែលខ្ញុំបានរកឃើញ ទោះបីជាខ្ញុំមិនបានដឹងនៅពេលនោះ វាគឺជាការចាប់ផ្តើមនៃដំណើរការមួយ ដែលនឹងផ្លាស់ប្តូរខ្ញុំពីសិស្សឲ្យក្លាយទៅជាគ្រូ ដែលធ្វើឲ្យខ្ញុំដេកមិនលក់នៅលើគ្រែពេលយប់ គិតរកវិធីធ្វើដូចម្តេច ដើម្បីឲ្យមានស្លាបព្រាបានចែកទៅដល់ស្ត្រីជាច្រើន ដោយអធិស្ឋានសូមឲ្យភ្នំជាច្រើនត្រូវបានរើបោះទៅក្នុងសមុទ្រវិញបាន។

សៀវភៅនេះមានគោលបំណងក្នុងការផ្តត់ផ្គង់ឲ្យអ្នកនូវស្លាបព្រាដ៏ល្អប្រសើរ ដែលខ្ញុំអាចប្រគល់ឲ្យ។ គឺមានបំណងបង្ហាត់បង្រៀនអ្នក មិនមែនគ្រាន់តែជាគោលលទ្ធិ ទស្សនៈ ឬក៏ខ្សែរឿងនោះទេ ប៉ុន្តែគឺជាវិធីសាស្ត្រនៃការសិក្សាដែលនឹងអនុញ្ញាតឲ្យអ្នកបើកនូវព្រះគម្ពីររបស់អ្នកផ្ទាល់។ ក្នុងគោលបំណងជំរុញអ្នកឲ្យបានគិត និងលូតលាស់ដោយប្រើវិធីសាស្ត្រដែលមានលក្ខណៈងាយស្រួលក្នុងការ ប្រើសម្រាប់យើងទាំងអស់គ្នា។ មិនថាយើងមានសញ្ញាបត្រថ្នាក់វិទ្យាល័យ ឬក៏កម្រិតថ្នាក់សាលាព្រះគម្ពីរ មិនថាក្នុងមួយថ្ងៃយើងមានប៉ុន្មាននាទី ឬក៏មានច្រើនម៉ោង។ សៀវភៅនេះមានគោលបំណង



Khmer Women of the word_Layout.indd 24 12/3/26 3:56 in the afternoon

ក្នុងការផ្លាស់របៀបដែលអ្នកបានគិតអំពីការសិក្សាព្រះគម្ពីរ។

ប្រហែលរឿងរ៉ាវរបស់អ្នកមិនដូចរឿងរ៉ាវរបស់ខ្ញុំសូម្បីតែបន្តិច ប្រហែលអ្នកបានចំណាយពេលពេញមួយជីវិតរបស់អ្នកនៅក្នុងក្រុមជំនុំតែមួយ ឬក៏មិនបានទៅក្រុមជំនុំសោះ។ ការប៉ាន់ស្មានគឺថា អ្នកបានដឹងអំពីការដែលមិនមានភាពងាយស្រួលក្នុងការរស់នៅក្រោមស្រមោលភ្នំនៃការមិនចេះព្រះគម្ពីរ។

មានឃ្លាមួយបានលើកឡើងថា យើងនឹងក្លាយទៅជាអ្វីដែលយើងផ្ដោតការមើលទៅលើ។ ខ្ញុំជឿថា គ្មានអ្វី អាចផ្លាស់ប្ដូរជីវិតយើងបានខ្លាំងជាងការមើលឃើញព្រះជាម្ចាស់ក្នុងព្រះបន្ទូលរបស់ទ្រង់នោះទេ។ ពិតមែនហើយ តើយើងអាចមានលក្ខណៈដូចរូបអង្គនៃព្រះជាម្ចាស់បានយ៉ាងដូចម្ដេច បើយើងមិនដែលមើលឃើញផងនោះ? នៅជ្រុងម្ខាងទៀតរបស់ភ្នំនៃការមិនចេះព្រះគម្ពីររបស់ខ្ញុំ គឺជាទស្សនវិស័យរបស់ព្រះជាម្ចាស់ដែលខ្ពង់ខ្ពស់ និងស័ក្តិសមនឹងលើកតម្កើង។ ទស្សនៈនោះមានតាំងពីកណ្ឌគម្ពីរលោកុប្បត្តិទៅដល់វិវរណៈ ដែលខ្ញុំពិតជាចង់ឃើញយ៉ាងខ្លាំងមែនទែន។ ខ្ញុំពិតជាគ្មានមធ្យោបាយក្នុងការរើភ្នំទាំងមូលចេញពីខ្សែភ្នែករបស់ខ្ញុំបានទេ ប៉ុន្តែខ្ញុំមានបំណងកប់ខ្លួនខ្ញុំក្នុងផ្នូរជាមួយនឹងដីក្នុងក្រចករបស់ខ្ញុំ និងក្ដាប់ស្លាបព្រាជាប់ក្នុងដៃរបស់ខ្ញុំ។ បើសិនជាអាចខ្ញុំធ្វើការសម្រេចចិត្តថា នឹងគ្មានភ្នំនៃការមិនចេះព្រះគម្ពីរ រាំងស្ទះខ្ញុំពីការមើលឃើញព្រះអង្គយ៉ាងច្បាស់នោះទេ ទោះជាក្នុងពេលដែលខ្ញុំមានអាយុ៧០ឆ្នាំ ឬក៏៨០ឆ្នាំ ក្នុងការរស់នៅលើផែនដីនេះក៏ដោយ។

ដូច្នេះ សៀវភៅនេះគឺសម្រាប់អស់អ្នកដែលបានត្រៀមខ្លួនរួចរាល់ ដើម្បីធ្វើការជីកកាយ។ នេះគឺជាសៀវភៅសម្រាប់អស់អ្នកដែលបានត្រៀមបែរចំដោយផ្ទាល់ទៅកាន់ភ្នំនៃការយល់នូវផ្នែកដែលខ្លួនមិនទាន់បានយល់ក្នុងព្រះបន្ទូលឲ្យបានស៊ីជម្រៅ ហើយគ្រវីស្លាបព្រារបស់ពួកគេបញ្ឆោទៅកាន់ភ្នំនោះឲ្យរើចេញ។



Khmer Women of the word_Layout.indd 25 12/3/26 3:56 in the afternoon

## សំណួរសម្រាប់ឆ្លុះបញ្ចាំង

១. តើអ្វីជាប្រវត្តិសាស្ត្រសាសនាជាផ្លូវការ? តើបទពិសោធន៍របស់អ្នកនៅក្នុងក្រុមជំនុំផ្សេងៗមានលក្ខណៈ យ៉ាងដូចម្ដេច (ឬក៏ខ្វះខាតចំណុចណាមួយ) ដែលជួយអ្នកក្នុងការសិក្សាព្រះគម្ពីរឲ្យបានល្អប្រសើរដែរឬទេ?

២. តើអ្នកដឹងខ្លួនខ្លាំងប៉ុណ្ណាអំពីសេចក្ដីត្រូវការផ្ទាល់ខ្លួនក្នុងការធ្វើឲ្យចំណេះដឹងខាងឯព្រះគម្ពីររបស់អ្នកកាន់តែប្រសើរជាងមុន? តើមានព្រឹត្តិការណ៍ ឬបទពិសោធន៍អ្វីខ្លះ ដែលធ្វើឲ្យអ្នកចាប់ផ្ដើមដឹងថា អ្នកត្រូវការស្គាល់ព្រះគម្ពីរល្អជាងមុន?

៣. តើអ្នកមានបទពិសោធន៍អ្វីខ្លះជាមួយនឹងគ្រូបង្រៀនខុសឆ្គង ឬក៏ការបង្រៀនដែលខ្សោយ? តើការខ្វះចំណេះដឹងអំពីអ្វីដែលព្រះគម្ពីរបង្រៀន មានឥទ្ធិពលយ៉ាងដូចម្ដេចលើសមត្ថភាពរបស់គ្រូបង្រៀនក្នុងការផ្សព្វផ្សាយអ្វីដែលខុស?

៤. តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់អ្នក? តើវិធីសាស្ត្រអ្វីដែលអ្នកកំពុងប្រើក្នុងការសិក្សាព្រះគម្ពីររបស់អ្នក?



Khmer Women of the word_Layout.indd 26 12/3/26 3:56 in the afternoon

៥. តើអ្វីដែលជាឧបសគ្គធំបំផុតនៅក្នុងការខិតខំប្រឹងប្រែងសិក្សាព្រះគម្ពីររបស់អ្នក កាលពីអតីតកាល? នៅក្នុងជីវិតពេលបច្ចុប្បន្ននេះ? និងអ្វីដែលអ្នកគិតថាវាអាច ជាឧបសគ្គនៅក្នុងពេលអនាគតផងដែរ?

Khmer Women of the word_Layout.indd 28 12/3/26 3:56 in the afternoon

ជំពូកទី១

# ការបង្វែរត្រឡប់មកវិញ

«គ្រប់ទាំងបទគម្ពីរគឺជាព្រះទ្រង់ បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរម្លឹកឲ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត។ ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសម្រាប់នឹងធ្វើការល្អគ្រប់មុខ»

២ធីម៉ូថេ ៣:១៦-១៧

នេះគឺជាសៀវភៅស្ដីពីការបង្ហាត់បង្រៀនស្ត្រីតាមរយៈការសិក្សាព្រះគម្ពីរ។ ក្រៅពីក្រុមគ្រួសាររបស់ខ្ញុំ នោះជាអ្វីដែលខ្ញុំយកចិត្តទុកដាក់ជាងគេបំផុត។ ប៉ុន្តែនេះមិនមែនជាអ្វីដែលបានកើតឡើងគ្រប់ពេលនោះទេ។ មុនពេលខ្ញុំមានបំណងប្រាថ្នាបង្រៀនព្រះគម្ពីរ ខ្ញុំក៏មានបំណងប្រាថ្នាដ៏ជ្រៅជាក់ និងជាប់ចិត្តយ៉ាងខ្លាំងចំពោះអ្វីផ្សេងមួយទៀត។ ពេលខ្ញុំអាយុបួនឆ្នាំខ្ញុំមានបំណងពាក់អាវដែលមានដេរជួរ ក្បាច់ក្បូរវែងៗ មានខ្សែរំយោលធ្លាក់។

អ្នកប្រហែលជាចាំអំពីខោអាវទាំងនោះគឺសម្រាប់ក្មេងស្រីដែលមើលទៅស្អាត ឡូយជាមួយខ្សែរំយោល ធ្លាក់ទាំងនោះ ខ្ញុំពិតជាស្រឡាញ់វាខ្លាំងណាស់។ ខ្ញុំស្លៀកសំលៀកដែលមានអាវធំពីក្រៅទៅសាលារាល់ថ្ងៃ ហេតុដូច្នេះខ្ញុំអាចពាក់អាវដ៏ស្រស់ស្អាតនោះបាន។ នៅពេលណាខ្ញុំអស់អាវធំ ខ្ញុំ



Khmer Women of the word_Layout.indd 29 12/3/26 3:56 in the afternoon

ក៏ពាក់អាវឃើតពីលើវា។ ពិតណាស់ មែនហើយវាតឹងមែន។ តែតើវានៅស្អាតអត់? អ្នកដឹងស្រាប់ហើយ គឺស្អាតណាស់។

ខ្ញុំស្រឡាញ់គ្រប់យ៉ាងអំពីអាវនោះ លើកលែងចំណុចមួយ៖ ខ្សែរំយោលដែលធ្លាក់នោះគឺនៅពីក្រោយ ដែលអ្នកពាក់មិនអាចមើលឃើញ និងរីករាយជាមួយនឹងខ្សែនោះបាន។ ខ្ញុំមើលមិនឃើញខ្សែជរស្អាតៗទាំងនោះ។ បើនិយាយលេងទៅ ការធ្វើបែបនោះដូចជាមិនសម។ ប៉ុន្តែ ខ្ញុំក៏មានដំណោះស្រាយដ៏សាមញ្ញមួយ ដែលអាចធ្វើបានដោយខ្លួនឯង៖ ខ្ញុំចាប់ផ្តើមពាក់អាវពីក្រោយទៅខាងមុខវិញ។

បញ្ហាត្រូវបានដោះស្រាយរហូតដល់ពេលមួយម្តាយខ្ញុំបានឃើញខ្ញុំ។

ខ្ញុំមិនប្រាកដថា ចំណុចណាដែលធ្វើឲ្យម្តាយខ្ញុំសង្ស័យជាលើកដំបូងនោះទេ៖ រូបភាពដែលនៅលើអាវនោះវាបញ្ច្រាសផ្កាប់ផ្ងារយ៉ាងម៉េចនោះទេ ពេលខ្លះខ្សែនោះវាធ្លាក់មកគ្រវីគ្រវាត់ដែលយើងត្រូវដើរដោយប្រុងប្រយ័ត្ននៅពីក្រោមអាវឃើត ឬក៏ដោយសារខ្សែនោះបានធ្វើឲ្យខ្ញុំហាក់បីដូចជាមានពោះធំ មិនប្រក្រតី។ ម្តាយខ្ញុំចាប់ខ្ញុំបាន ប្រហែលមកពីដំណើររបស់ខ្ញុំ ក្នុងការព្យាយាមលាក់ខ្សែជរ ឬក៏មកពីខ្ញុំមានទម្លាប់គ្រវីចុះគ្រវីឡើង ដូចជាស្លាបទេវតា។ សរុបមក ខ្ញុំមិនដែលបានឲ្យខ្សែធ្លាក់បញ្ច្រាស ដោយពាក់ពីក្រោយមកខាងមុខវិញ ខ្ញុំមិនបានពាក់វាឲ្យបានត្រឹមត្រូវតាមអ្វីដែលគេគួរពាក់អាវនេះឡើយ។ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា ការប្រើប្រាស់មិនត្រូវ មិនមែនជាជម្រើសឡើយ។ អាវខ្សែរំយោលនេះត្រូវបានរចនាឡើងក្នុងរបៀបដែលពិសេសសម្រាប់គោលបំណងដែលពិសេស ហើយខ្ញុំបែរជាត្រឡប់ផ្នែកដែលមានខ្សែនោះទៅក្រោយវិញ ហើយបោះបង់នូវការចង់បានឲ្យមានខ្សែរំយោលធ្លាក់មកនៅខាងមុខអាវ។

នេះការមួយអាចនិយាយថា មិនមែនជាលើកទីមួយប៉ុណ្ណោះទេក្នុងជីវិតដែលខ្ញុំបានធ្វើអ្វីមួយបញ្ច្រាស។ ប៉ុន្តែ មិនដូច្នោះឡើយ ការពិតបំណងប្រាថ្នានៅក្នុងការបង្រៀនព្រះគម្ពីរដល់ស្ត្រីក៏ជាលទ្ធផលនៃការបញ្ច្រាសដូចគ្នាដែរ។



Khmer Women of the word_Layout.indd 30 12/3/26 3:56 in the afternoon

ខ្ញុំចង់ប្រាប់នូវរបៀបពីរយ៉ាងដែលខ្ញុំបានប្រើក្នុងការសិក្សាព្រះគម្ពីរ ដែលមើលទៅដំបូងដូចជាត្រឹមត្រូវ ប៉ុន្តែគឺជាការបញ្ច្រាសទាំងស្រុង។

ប្រហែលជាពេលខ្លះយើងគិតថា ការសិក្សាព្រះគម្ពីរគឺជាអ្វីមួយដែលយើងអាចដឹងបានអំពីរបៀបដែលយើងអាចយល់ច្បាស់បាន ដោយសភាវគតិ។ ចូរពិចារណាមើល—បើព្រះជាម្ចាស់បង្ហាញបំណងព្រះហឫទ័យ និងលក្ខណសម្បត្តិរបស់ព្រះអង្គនៅក្នុងពេលសិក្សា តើព្រះវិញ្ញាណបរិសុទ្ធនឹងមិនបង្ហាញព្រះបន្ទូលរបស់ទ្រង់មកកាន់ចិត្តយើងទេឬ? នោះមិនមែនជាការពិតទេ ពិតណាស់ព្រះវិញ្ញាណបរិសុទ្ធបើកសម្ដែងព្រះបន្ទូលមកកាន់យើង ប៉ុន្តែនោះក៏មិនមែនមានន័យថា វាមិនត្រូវមានការបូករួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់យើងផងដែរ។

តើអ្នកដឹងថាពាក្យ «សិស្ស» នៅក្នុងព្រះគម្ពីរមានន័យថាជា «អ្នករៀន» ដែរឬទេ? ក្នុងនាមជាសិស្សរបស់ព្រះគ្រីស្ទ ព្រះបានហៅទាំងអ្នក ហើយនិងខ្ញុំឲ្យរៀនហើយការរៀនសូត្រតម្រូវឲ្យមានការខិតខំប្រឹងប្រែង។ ហើយក៏ត្រូវការវិធីសាស្ត្រល្អៗក្នុងការសិក្សាផងដែរ។ យើងបានដឹងថានេះជាអ្វីដែលយើងត្រូវធ្វើនៅក្នុងការសិក្សានៅឯសាលារៀន ប៉ុន្តែតើយើងបានដឹងថានេះក៏ជាអ្វីដែលយើងត្រូវធ្វើក្នុងនាមជាអ្នកដែលដើរតាមព្រះគ្រីស្ទដែរឬទេ? ទោះបីជាយ៉ាងណាខ្ញុំធ្លាប់ជាសិស្សល្អម្នាក់នៅសាលារៀនដែរ ប៉ុន្តែមិនមែនជាសិស្សល្អនៃព្រះបន្ទូលឡើយ។ បើខ្ញុំនៅតែឯង នោះខ្ញុំប្រហែលមិនអាចក្លាយទៅជាសិស្សល្អប្រសើរម្នាក់ឡើយ។ ប៉ុន្តែ តាមរយៈការបង្រៀនពីអ្នកដទៃដោយស្មោះត្រង់នោះខ្ញុំក៏ចាប់ផ្ដើមទទួលបានភាពល្អប្រសើរ ហើយឃើញថាអ្វីដែលខ្ញុំធ្វើកាលមុននោះគឺបញ្ច្រាស។ នៅពេលដែលខ្ញុំបង្វែររបៀបពីរយ៉ាងនៃការសិក្សាព្រះគម្ពីរនោះវាបានធ្វើឲ្យខ្ញុំចាប់ផ្ដើមមានសេចក្ដីស្រឡាញ់នៅក្នុងការរៀនសូត្រ ការអនុវត្ត និងការបង្រៀនពេញមួយជីវិតរបស់ខ្ញុំផងដែរ។

## ការបង្វែររបៀបទី១៖ សូមឲ្យព្រះគម្ពីរនិយាយអំពីព្រះជាម្ចាស់

ពេលខ្ញុំប្រាប់ថា ភាពអាម៉ាស់ដំបូងដែលខ្ញុំបានយល់បញ្ច្រាសគឺការបញ្ច្រាសយ៉ាងច្បាស់នេះ៖ ខ្ញុំមិនយល់ថាព្រះគម្ពីរគ្រាន់តែនិយាយរៀបរាប់អំពីព្រះជាម្ចាស់ប៉ុណ្ណោះទេ។ ព្រះគម្ពីរគឺបានបង្ហាញយ៉ាងច្បាស់ និងដោយក្លាហានថាព្រះជាម្ចាស់ ទ្រង់ជាអ្នកណានៅក្នុងគ្រប់ទំព័រទាំងអស់។ កណ្ឌគម្ពីរលោកុប្បត្តិបានបង្ហាញដោយបានដាក់ព្រះជាម្ចាស់ថាជាចំណុចស្នូលនៃអ្នកនិទានអំពីដំណើររឿងនៃការបង្កើតពិភពលោក។ កណ្ឌគម្ពីរនិក្ខមនំបានបង្ហាញព្រះជាម្ចាស់ដោយប្រៀបធៀបទៅនឹងស្តេច ផារ៉ោន និងរូបព្រះនៅក្នុងប្រទេសអេស៊ីព្ទ។ នៅក្នុងកណ្ឌទំនុកតម្កើង ស្តេច ដាវីឌ បានសរសេរអំពីអំណាចចេស្តា និងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ កណ្ឌគម្ពីរពួកហោរាបានប្រកាសអំពីសេចក្តីក្រោធ និងភាពយុត្តិធម៌របស់ព្រះជាម្ចាស់។ កណ្ឌគម្ពីរដំណឹងល្អ និងកណ្ឌគម្ពីរសំបុត្របង្ហាញអំពីលក្ខណសម្បត្តិនៅក្នុងបុគ្គល និងកិច្ចការរបស់ព្រះគ្រីស្ទ។ កណ្ឌគម្ពីរវិវរណៈបង្ហាញអំពីអំណាចនៃការគ្រប់គ្រងរបស់ទ្រង់ លើគ្រប់របស់ទាំងអស់។ ពីការចាប់ផ្តើមរហូតដល់ចុងបញ្ចប់ ព្រះគម្ពីរគឺជានិយាយអំពីព្រះជាម្ចាស់។

ប្រហែលខ្ញុំបានដឹងថាព្រះគម្ពីរជាសៀវភៅដែលនិយាយអំពីព្រះជាម្ចាស់។ ប៉ុន្តែ ខ្ញុំមិនដឹងថា ខ្ញុំមិនបានអានព្រះគម្ពីរដូចជាព្រះគម្ពីរគឺនិយាយអំពីព្រះជាម្ចាស់។ នេះគឺជាអ្វីដែលខ្ញុំបានមើលបញ្ច្រាស៖ ខ្ញុំបានចូលទៅកាន់ការសិក្សារបស់ខ្ញុំដោយសួរនូវសំណួរដែលខុស។ ខ្ញុំអានព្រះគម្ពីរដោយសួរសំណួរថា «ខ្ញុំជាអ្នកណា?» និង «ខ្ញុំគួរធ្វើអ្វីខ្លះ?»។ ព្រះគម្ពីរពិតជាបានឆ្លើយត្រឹមត្រូវលើសំណួរនោះមែន។ កណ្ឌគម្ពីរ អេភេសូរ ២:១០ បានប្រាប់ខ្ញុំថា ខ្ញុំគឺជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលដែលបង្រៀននៅលើភ្នំបានប្រាប់ខ្ញុំក្នុងការទូលសូមអាហារជាប្រចាំថ្ងៃ និងរក្សាទ្រព្យសម្បត្តិនៅឯនគរស្ថានសួគ៌វិញ។ សាច់រឿងអំពីស្តេច ដាវីឌ ប្រាប់ខ្ញុំឲ្យស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ប៉ុន្តែ សំណួរដែលខ្ញុំបានសួរបង្ហាញថា ខ្ញុំពិតជា



Khmer Women of the word_Layout.indd 32 12/3/26 3:56 in the afternoon

មានការភាន់ច្រឡំអំពីលក្ខណសម្បត្តិនៃព្រះគម្ពីរ៖ ខ្ញុំបានជឿថា ព្រះគម្ពីរគឺជាសៀវភៅដែលនិយាយអំពីខ្ញុំ។

ខ្ញុំបានជឿថា ខ្ញុំគួរតែអានព្រះគម្ពីរ ដើម្បីបង្រៀនខ្លួនឯងអំពីរបៀបរស់នៅ និងដើម្បីធ្វើឲ្យខ្ញុំបានប្រាកដថា ព្រះអង្គបានស្រឡាញ់ និងអត់ទោសដល់ខ្ញុំ។ ខ្ញុំបានជឿថា ព្រះគម្ពីរគឺជាផែនទីផ្លូវសម្រាប់ជីវិត និងផ្ដល់ឲ្យនូវគ្រប់កាលៈទេសៈដល់អ្នកណាម្នាក់ដែលដឹងពីរបៀបអាន និងចេះបកស្រាយ អាចស្វែងរកអត្ថបទព្រះគម្ពីរ ដើម្បីដឹកនាំ និងកំសាន្តចិត្ត។ ខ្ញុំបានជឿថា គោលបំណងចម្បងនៃព្រះគម្ពីរគឺ ដើម្បីជួយដល់ខ្ញុំ។

នៅក្នុងសេចក្ដីជំនឿនេះ ខ្ញុំមិនខុសពីលោក ម៉ូសេ ដែលឈរនៅចំពោះគុម្ពបន្លានៅលើភ្នំស៊ីណាយទេ។ រំពេចនោះលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់បានបើកសម្ដែងមកកាន់រូបគាត់៖ អណ្ដាតភ្លើងក្នុងគុម្ពបន្លាដែលឆេះមិនសុសនោះបាននិយាយមកកាន់គាត់យ៉ាងអស្ចារ្យបំផុត។ ពេលដែលព្រះជាម្ចាស់បានបង្គាប់ឲ្យគាត់ទៅស្ដេច ផារ៉ោន ហើយទាមទារឲ្យទ្រង់ដោះលែងប្រជាជនដែលជាទាសករ នោះលោក ម៉ូសេ ក៏បានឆ្លើយដោយដឹងស្មារតីថា «ខ្ញុំជាអ្នកណា ដែលត្រូវទៅជួបផារ៉ោន ហើយនាំកូនចៅអ៊ីស្រាអែលចេញពីប្រទេសអេស៊ីព្ទនោះ?» (និក្ខមនំ ៣:១១)។

ព្រះជាម្ចាស់ឆ្លើយតបដោយអត់ធ្មត់ដោយបង្ហាញអង្គទ្រង់ថាជាចំណុចស្នូលនៃការនិទាន៖ «ប៉ុន្តែអញនឹងនៅជាមួយនឹងឯង» (និក្ខមនំ ៣:១២)។ ប៉ុន្តែ ជំនួសឲ្យទទួលបានការលើកទឹកចិត្តពីចម្លើយនោះលោក ម៉ូសេ បានសួរទៀតថា «ខ្ញុំនឹងធ្វើអ្វី?»៖ «បន្ទាប់មក ម៉ូសេ និយាយទៅកាន់ព្រះជាម្ចាស់ថា "ប្រសិនបើខ្ញុំទៅជួបកូនចៅអ៊ីស្រាអែលហើយប្រាប់ពួកគេថា 'ព្រះនៃឰយុកោអ្នករាល់គ្នា ទ្រង់បានចាត់ខ្ញុំឲ្យមកឯអ្នករាល់គ្នា'"»។ «ហើយគេនឹងសួរទូលបង្គំ "តើព្រះទ្រង់ព្រះនាមអ្វី?" នោះតើត្រូវឲ្យទូលបង្គំប្រាប់គេដូចម្ដេច?» (ខ១៣)។

សូមកត់សម្គាល់ថាជាជាងប្រាប់លោក ម៉ូសេ អំពីអ្វីដែលគាត់ត្រូវធ្វើ ព្រះ



Khmer Women of the word_Layout.indd 33 12/3/26 3:56 in the afternoon

## ជាម្ចាស់ជំនួសដោយប្រាប់អំពីអ្វីដែលព្រះអង្គបានធ្វើ កំពុងធ្វើ ហើយនឹងធ្វើនាពេលអនាគតវិញ៖

"ព្រះទ្រង់មានបន្ទូលទៅម៉ូសេថា "អញជាព្រះដ៏ជាព្រះ" រួចទ្រង់មានបន្ទូលទៀតថា "ឯងត្រូវឆ្លើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា" 'ព្រះដ៏ជាព្រះទ្រង់បានចាត់ឲ្យខ្ញុំមកឯអ្នករាល់គ្នា'។ ព្រះទ្រង់ក៏មានបន្ទូលនឹងម៉ូសេទៀតថា "ចូរនិយាយនឹងពួកកូនចៅអ៊ីស្រាអែលដូច្នេះថា" 'ព្រះយេហូវ៉ាជាព្រះនៃពួកឰយុកោអ្នករាល់គ្នាគឺជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាកហើយជាព្រះនៃយ៉ាកុប ទ្រង់បានចាត់ឲ្យ ខ្ញុំមកឯអ្នករាល់គ្នា' នោះជាឈ្មោះអញនៅអស់កល្បជានិច្ចហើយក៏សម្រាប់ជាសេចក្ដីរម្លឹកពីអញដល់គ្រប់ទាំងដំណរៀងដរាបតទៅ។ ទៅចុះចូរទៅប្រមូលពួកចាស់ទុំជាតិអ៊ីស្រាអែលប្រាប់គេថា 'ព្រះយេហូវ៉ាជាព្រះឰយុកោអ្នករាល់គ្នា គឺជាព្រះនៃអ័ប្រាហាំ អ៊ីសាកនិងយ៉ាកុប ទ្រង់បានលេចមកមានបន្ទូលនឹងខ្ញុំថា "អញបានមកប្រោសអ្នករាល់គ្នាជាប្រាកដហើយក៏បានឃើញការដែលគេធ្វើដល់អ្នករាល់គ្នានៅស្រុកអេស៊ីព្ទ...."' គេនឹងស្តាប់តាមឯង ហើយឯង និងពួកចាស់ទុំជាតិអ៊ីស្រាអែលត្រូវចូលទៅគាល់ស្តេចស្រុកអេស៊ីព្ទទូលថា 'ព្រះយេហូវ៉ាជាព្រះនៃសាសន៍ហេព្រើរ ទ្រង់បានមកជួបនឹងយើងខ្ញុំរាល់គ្នាហើយ ដូច្នេះសូមឲ្យយើងខ្ញុំរាល់គ្នាទៅក្នុងទីរហោស្ថានចំងាយផ្លូវដើរអស់៣ថ្ងៃ ដើម្បីនឹងថ្វាយយញ្ញបូជាដល់ព្រះយេហូវ៉ាជាព្រះនៃយើងខ្ញុំរាល់គ្នា'។ តែអញដឹងថាស្តេចស្រុកអេស៊ីព្ទនឹងមិនព្រមអនុញ្ញាតឲ្យអ្នករាល់គ្នាទៅទេ លើកតែដោយដៃខ្លាំងពូកែប៉ុណ្ណោះ។ អញនឹងលើកដៃវាយស្រុកអេស៊ីព្ទដោយអស់ទាំងការអស្ចារ្យដែលអញនឹងធ្វើនៅកណ្តាលស្រុកនោះក្រោយនោះមកស្តេចនឹងបើកឲ្យអ្នករាល់គ្នាចេញទៅ។ អញនឹងធ្វើឲ្យជនជាតិបានប្រកបដោយគុណនៃពួកសាសន៍អេស៊ីព្ទហើយកាលណាចេញទៅនោះអ្នករាល់គ្នានឹងមិនទៅដោយដៃទទេឡើយ។ គឺគ្រប់ទាំងស្រីៗនឹងសូមគ្រឿងមាស គ្រឿងប្រាក់ និងសំលៀកបំពាក់ពីអ្នកជិតខាងហើយពីអ្នកដែលអាស្រ័យនៅផ្ទះជាមួយគ្នា ហើយឯងរាល់គ្នានឹងបំពាក់ឲ្យកូនប្រុសកូនស្រីឯងវិញ ដូច្នេះអ្នករាល់គ្នានឹងបង្ហិនពួកសាសន៍អេស៊ីព្ទទៅ""។ (និក្ខមនំ ៣:១៤-២២)។



Khmer Women of the word_Layout.indd 34 12/3/26 3:56 in the afternoon

ការសន្ទនានៅតែបន្តក្នុងរបៀបនេះ ក្នុងមួយជំពូកកន្លះនៃកណ្ឌគម្ពីរនិក្ខមនំ នោះលោក ម៉ូសេ សួរសំណួរខុសៈ “តើខ្ញុំជាអ្នកណា? តើខ្ញុំគួរធ្វើអ្វីខ្លះ?” ជាជាងឆ្លើយចម្លើយរបស់គាត់ ព្រះជាម្ចាស់បានមានបន្ទូលថា “ម៉ូសេ អ្នកគឺជាអ្នកបម្រើដែលយើងបានជ្រើសរើស អ្នកគឺជាស្នាព្រះហស្តដ៏មានតម្លៃរបស់យើង ជាអំណោយ និងជាអ្នកដឹកនាំដ៏ឆ្លាតវៃ” ព្រះជាម្ចាស់បានឆ្លើយតបដោយដកលោក ម៉ូសេ ចេញទាំងស្រុងពីប្រធានបទនៃការពិភាក្សា និងដាក់រូបអង្គទ្រង់ចូលជាចំណុចស្នូលវិញ។ ព្រះជាម្ចាស់ឆ្លើយតបសំណួររបស់លោក ម៉ូសេ ដែលបានផ្តោតមកលើខ្លួនគាត់ថា «តើខ្ញុំជាអ្នកណា?» ដោយចម្លើយតែមួយគត់ដែលសំខាន់៖ «អញជា»។

យើងក៏ដូចលោក ម៉ូសេ ដែរ។ ព្រះគម្ពីរគឺជាគុម្ពបន្លាដែលឆេះមិនសុស គឺជាការប្រកាសយ៉ាងស្មោះត្រង់អំពីព្រះវត្តមាន និងភាពបរិសុទ្ធរបស់ព្រះជាម្ចាស់។ យើងបានសួរព្រះគម្ពីរអំពីខ្លួនយើង តែគ្រប់ពេលព្រះគម្ពីរបានប្រាប់យើងអំពី «អញជា»។ យើងគិតថា ប្រសិនបើព្រះគម្ពីរប្រាប់យើងថាយើងជាអ្នកណា យើងគួរធ្វើអ្វី នោះការមិនមានសុវត្ថិភាព ការភ័យខ្លាច និងការសង្ស័យរបស់យើងនឹងរលាយបាត់។ ប៉ុន្តែ យើងមិនអាចដកការមិនមានសុវត្ថិភាព ការភ័យខ្លាច និងការសង្ស័យរបស់យើងចេញបាន តាមរយៈការដឹងថាយើងជាអ្នកណានោះទេ។ ការទាំងនោះគឺដកចេញតាមរយៈការដែលដឹងថា «អញជា» (និយាយម្យ៉ាងទៀតគឺមានន័យថា «តើព្រះជានរណា?»)។ យើងត្រូវអាន និងសិក្សាព្រះគម្ពីរដោយមានការផ្ទៀងត្រចៀករបស់យើងនៅក្នុងការស្តាប់អំពីការប្រកាសអំពីព្រះជាម្ចាស់ផ្ទាល់។

តើនេះមានន័យថា ព្រះគម្ពីរមិនបានលើកឡើងអ្វីអំពីយើងទេមែនទេ ថាយើងជាអ្នកណា? មានដែរ តែយើងបានព្យាយាមឆ្លើយសំណួរនោះ តាមរបៀបបញ្ច្រាស។ ព្រះគម្ពីរពិតជាបានប្រាប់ថាយើងជាអ្នកណា និងអ្វីដែលយើងត្រូវធ្វើ ប៉ុន្តែការនោះគឺបង្ហាញតាមរយៈទស្សនៈដែលថា តើព្រះជាម្ចាស់ជានរណា។ ចំណេះដឹងអំពីព្រះជាម្ចាស់ និងការយល់ដឹងអំពីខ្លួនឯង គឺត្រូវ



Khmer Women of the word_Layout.indd 35 12/3/26 3:56 in the afternoon

ដើរទន្ទឹមគ្នា។ តាមពិត យើងនឹងមិនអាចមានការយល់ដឹងអំពីខ្លួនឯងឡើយ ប្រសិនបើយើងមិនមានចំណេះដឹងអំពីព្រះជាម្ចាស់ទេ។ ព្រះអង្គគឺអង្គដែលបញ្ជាក់តែមួយគត់អំពីចារិកលក្ខណៈរបស់យើង ដែលយើងអាចជឿទុកចិត្តបាន។ ដូច្នេះ នៅពេលដែលខ្ញុំអានអំពីព្រះជាម្ចាស់ថា ទ្រង់អត់ធ្មត់ នោះខ្ញុំយល់ឃើញថា ខ្ញុំមិនចេះអត់ធ្មត់។ នៅពេលដែលខ្ញុំអានអំពីព្រះជាម្ចាស់ថា ទ្រង់យឺតនឹងខ្ញាល់ នោះខ្ញុំយល់ឃើញថា ខ្ញុំងាយនឹងខឹងណាស់។ នៅពេលដែលខ្ញុំអានអំពីព្រះជាម្ចាស់ថា ទ្រង់ជាព្រះដែលយុត្តិធម៌ នោះខ្ញុំយល់ឃើញថា ខ្ញុំមិនសូវមានភាពយុត្តិធម៌ទេ។ ការដែលមើលឃើញអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់នឹងបង្ហាញឲ្យឃើញថា យើងជាអ្នកណាយ៉ាងច្បាស់។ ការមើលឃើញអំពីភាពធំឧត្តម និងការលើកតម្កើងដល់ព្រះជាម្ចាស់បង្ហាញឲ្យខ្ញុំឃើញពីអំពើបាបរបស់ខ្ញុំ និងការដែលខ្ញុំគួរបង្កើននូវសេចក្តីស្រឡាញ់ចំពោះព្រះអង្គថែមទៀត។ ការខកចិត្ត និងសេចក្តីស្រឡាញ់នឹងនាំយើងឲ្យមានការផ្លាស់ប្រែដ៏ពិតត្រង់ ហើយយើងនឹងចាប់ផ្តើមមានចារិកលក្ខណៈដូចជារូបអង្គព្រះ ដែលយើងតែងតែសង្កេតមើល។

ប្រសិនបើខ្ញុំអានព្រះគម្ពីរដោយស្វែងរកមើលតែចំណុចអំពីខ្លួនខ្ញុំ មុនពេលដែលខ្ញុំស្វែងរកព្រះជាម្ចាស់នៅក្នុងអត្ថបទ នោះពិតណាស់ខ្ញុំនឹងរៀនបានថា ខ្ញុំមិនគួរធ្វើជាមនុស្សអាត្មានិយមនោះទេ។ ខ្ញុំប្រហែលជាព្យាយាមឲ្យបានច្រើនថែមទៀតក្នុងការមិនធ្វើជាមនុស្សអាត្មានិយម។ ប៉ុន្តែ ខ្ញុំមិនអាចយល់ត្រឹមត្រូវអំពីអំពើបាបនៃភាពអាត្មានិយមរបស់ខ្ញុំបានទេ ទាល់តែខ្ញុំបានឃើញវា តាមរយៈរូបឆ្លុះនៃភាពមិនស្វះស្វែងរកអត្ថប្រយោជន៍ផ្ទាល់ខ្លួនទាំងស្រុងរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរគឺជាសៀវភៅអំពីព្រះជាម្ចាស់។ ដូចដែលលោក ម៉ូសេ បានដឹងតាមរយៈការយល់ថា គាត់ជាអ្នកណា មិនមានឥទ្ធិពលទៅលើលទ្ធផលចេញពីស្ថានភាពរបស់គាត់ឡើយ។ តែការដឹងថា ព្រះជានរណា នោះនឹងធ្វើឲ្យមានការផ្លាស់ប្រែគ្រប់ទាំងអស់។

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងឃើញថា ព្រះយេស៊ូវបានបង្ហាញនូវបញ្ហា



Khmer Women of the word_Layout.indd 36 12/3/26 3:56 in the afternoon

ដូចគ្នាជាមួយនឹងអ្នកដឹកនាំសាសនាយូដា៖ «អ្នករាល់គ្នាស្ទង់មើលគម្ពីរ ដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក គឺថាគម្ពីរនោះឯងដែលធ្វើបន្ទាល់ពីខ្ញុំ តែអ្នករាល់គ្នាមិនសុខចិត្តមកឯខ្ញុំឲ្យបានជីវិតទេ» (យ៉ូហាន ៥:៣៩-៤០)។ អ្នកដឹកនាំសាសនាយូដាស្វែងយល់ព្រះគម្ពីរ ដោយសួរនូវសំណួរដែលខុសក្នុងការស្វែងរកនូវរូបភាពដែលខុស ឲ្យលេចបង្ហាញចេញមក។

ប្រសិនបើយើងអាចរកឃើញជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងអត្ថបទព្រះគម្ពីរ គឺយើងរកឃើញតាមតែការឆ្លុះអំពីព្រះជាម្ចាស់ថា ទ្រង់ជាអ្នកណា។ ប្រសិនបើការអានព្រះគម្ពីររបស់យើងផ្តោតភ្នែកទៅលើអ្នកណាផ្សេងទៀត ជាជាងព្រះជាម្ចាស់ នោះយើងនឹងមានដំណើរការនៃការផ្លាស់ប្រែបញ្ច្រាសហើយ។ ការសិក្សាព្រះគម្ពីរណា ដែលស្វែងរក ដើម្បីបង្កើតនូវអត្តសញ្ញាណរបស់ខ្លួន ដោយមិនបានប្រកាសអំពីអត្តសញ្ញាណរបស់ព្រះជាម្ចាស់ជាមុន នោះនឹងទទួលបានចំណែកតូច និងជំនួយដែលមានដែនកំណត់ជាមិនខាន។ យើងត្រូវផ្លាស់ប្តូរទម្លាប់របស់យើង ត្រឡប់មកសួរវិញថា «ខ្ញុំជាអ្នកណា?» យើងត្រូវជាដំបូងបែរមកសួរថា «តើអត្ថបទព្រះគម្ពីរនេះបង្រៀនខ្ញុំអ្វីខ្លះអំពីព្រះជាម្ចាស់?» មុនពេលដែលយើងសួរថា តើព្រះគម្ពីរបង្រៀនអ្វីខ្លះអំពីខ្លួនខ្ញុំ។ យើងត្រូវទទួលស្គាល់ថា ព្រះគម្ពីរគឺបង្រៀនខ្ញុំអំពីព្រះជាម្ចាស់។

## ការបង្វែររបៀបទី២៖ សូមឲ្យគំនិតផ្លាស់ប្រែចិត្ត

ចំណុចទីពីរដែលខ្ញុំមើលបញ្ច្រាសនៅក្នុងរបៀបដែលខ្ញុំអានព្រះគម្ពីរ គឺជាសេចក្តីជំនឿដែលចិត្តរបស់ខ្ញុំគួរតែដឹកនាំការសិក្សារបស់ខ្ញុំ។ ដូចដែលបាននិយាយនៅក្នុងព្រះបន្ទូល «ចិត្ត» គឺជាទីតាំងដែលផ្ទុកនៅឆន្ទៈ និងអារម្មណ៍។ គឺជា «គ្រឿងវាស់ស្ទង់» និង «ជាអ្នកធ្វើការសម្រេចចិត្ត» របស់យើង។ ការអនុញ្ញាតឲ្យចិត្តដឹកនាំការសិក្សារបស់ខ្ញុំមានន័យថា ខ្ញុំស្វែងរកខគម្ពីរដែលធ្វើ



Khmer Women of the word_Layout.indd 37 12/3/26 3:56 in the afternoon

ឲ្យខ្ញុំមានអារម្មណ៍មួយចំនួន នៅពេលដែលខ្ញុំអាន។ ខ្ញុំចង់ឲ្យព្រះគម្ពីរផ្តល់នូវសេចក្តីសុខសាន្ត ផាសុខភាព ឬក៏សេចក្តីសង្ឃឹម។ ខ្ញុំចង់ឲ្យព្រះគម្ពីរធ្វើឲ្យខ្ញុំមានអារម្មណ៍ជិតស្និទ្ធជាមួយព្រះជាម្ចាស់។ ខ្ញុំចង់ឲ្យព្រះគម្ពីរផ្តល់ឲ្យខ្ញុំនូវការធានាអះអាងអំពីការសម្រេចចិត្តដែលពិបាកៗ ពីព្រោះខ្ញុំចង់ឲ្យព្រះគម្ពីរមានទំនាក់ទំនងជាមួយនឹងអារម្មណ៍របស់ខ្ញុំ។ ខ្ញុំបានចំណាយពេលតិចតួចនៅក្នុងកណ្ឌគម្ពីរលេវីវិន័យ ឬកណ្ឌគម្ពីរជនគណនា និងពេលវេលាច្រើននៅក្នុងកណ្ឌគម្ពីរដូចជាទំនុកតម្កើង និងកណ្ឌដំណឹងល្អ។

ព្រះគម្ពីរបានបញ្ជាឲ្យយើងស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីចិត្ត (ម៉ាកុស ១២:៣០)។ នៅពេលដែលយើងនិយាយថា យើងស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីចិត្ត នោះមានន័យថាយើងស្រឡាញ់ព្រះអង្គអស់ពីអារម្មណ៍ និងអស់ពីឆន្ទៈរបស់យើងទាំងស្រុង។ ការភ្ជាប់អារម្មណ៍ទៅកាន់សេចក្តីជំនឿរបស់យើងសម្រាប់ស្ត្រី ជាធម្មតាគឺកើតឡើងដោយធម្មជាតិ—និយាយជាទូទៅយើងដឹងពីរបៀបដែលធ្វើឲ្យមានអារម្មណ៍រំភើប ដោយមិនបាច់មានការដឹកនាំច្រើននោះទេ។ ប្រសិនបើយើងគិតអំពីចិត្តថាជាកន្លែងដែលផ្ទុកនូវអារម្មណ៍ និងឆន្ទៈរបស់យើង នោះគឺជាមូលហេតុដែលថា ជារឿយៗយើងចូលទៅចំពោះព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយសួរនូវសំណួរថា «ខ្ញុំជាអ្នកណា» និង «ខ្ញុំគួរតែធ្វើអ្វីខ្លះ?»។ សំណួរទាំងពីរនេះគឺពិសេសណាស់ដែលបង្ហាញអំពីចិត្តរបស់យើង។ ហើយជារឿយៗ យើងបាននិយាយនៅក្នុងក្រុមជំនុំអំពីរបៀបដែលគ្រីស្ទបរិស័ទ គឺជាសាសនាទាក់ទងជាមួយនឹងចិត្តអំពីរបៀបដែលព្រះគ្រីស្ទបានយាងចូលមកកាន់ដួងចិត្តរបស់យើង អំពីរបៀបដែលយើងត្រូវកែប្រែចិត្ត។ វាគឺជាការត្រឹមត្រូវក្នុងការនិយាយអំពីជំនឿគ្រីស្ទបរិស័ទនៅក្នុងរបៀបនេះ ប៉ុន្តែក្នុងរបៀបដែលយើងនិយាយនេះ ដូចជាមិនបានពេញន័យទាំងស្រុងឡើយ។

អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថាក្នុងខគម្ពីរដដែលក៏បានបញ្ជាឲ្យយើងស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត ក៏បានបញ្ជាយើងឲ្យស្រឡាញ់ព្រះអង្គអស់ពីគំនិតរបស់យើងផងដែរ។ គំនិតរបស់យើងគឺជាកន្លែងដែលផ្ទុកនូវ



Khmer Women of the word_Layout.indd 38 12/3/26 3:56 in the afternoon

ប្រាជ្ញានៃការយល់ដឹងរបស់យើង។ ការភ្ជាប់បញ្ញាទៅនឹងសេចក្ដីជំនឿរបស់យើង មិនអាចកើតឡើងបានសម្រាប់មនុស្សគ្រប់គ្នាឡើយ។ យើងរស់នៅក្នុងសម័យកាលដែលជំនឿ និងហេតុផលត្រូវបានលើកឡើង ដូចក្បាលថ្ពិលមានលក្ខណៈផ្ទុយគ្នាទាំងស្រុង។ ក្នុងពេលដែលក្រុមជំនុំបានប្រកាន់យកនូវភាសាបែបនេះ ពេលខ្លះកម្លាំងនៃសេចក្ដីជំនឿរបស់យើងត្រូវបានវាស់ស្ទង់ដោយអារម្មណ៍ ដែលទទួលបានណាមួយដើម្បីមានអារម្មណ៍ថា បានចូលទៅជិតព្រះជាម្ចាស់តាមរបៀប ដែលសេចក្ដីអធិប្បាយធ្វើឲ្យយើងមានអារម្មណ៍ តាមរយៈវគ្គបន្ទរចម្រៀងនៃការថ្វាយបង្គំ ធ្វើឲ្យយើងមានអារម្មណ៍ និងតាមរយៈរបៀបនៃការចំណាយពេលរបស់យើងជាមួយនឹងព្រះអង្គ ដែលធ្វើឲ្យយើងមានអារម្មណ៍។ ការលាក់បាំងនៅក្នុងការគិតបែបនេះគឺជាបំណងប្រាថ្នាដ៏ស្មោះត្រង់ក្នុងការចែកចាយនូវទំនាក់ទំនងដ៏ជ្រាលជ្រៅជាមួយព្រះជាម្ចាស់ដោយផ្ទាល់ ប៉ុន្តែការចង់មានអារម្មណ៍របស់យើងបែបនេះអាចធ្វើឲ្យយើងមានភាពអស់កម្លាំង និងបរាជ័យ។ នៅពេលកាលៈទេសៈមានការផ្លាស់ប្ដូរ នោះនឹងផ្ដួលរំលំនូវស្ថេរភាពនៃអារម្មណ៍របស់យើងបានភ្លាមៗ «ការដើរជាមួយព្រះ» របស់យើងអាចនឹងមានអារម្មណ៍ ដូចការជិះរថយន្តរំអិលដែរ ដែលជិះឡើងដល់ចំណុចកំពូល និងជ្រលងភ្នំ ជាជាងគ្រាន់តែនៅលើផ្លូវដែលរាបស្មើ គឺមានជ្រលងភ្នំ និងកំពូលភ្នំដែលមានកម្រិតផ្សេងៗគ្នា។

តើអាចទេដែលថាដោយព្រោះតែយើងបានអនុវត្តបែបបញ្ច្រាសទិសឬ? តាមរយៈការឲ្យចិត្តដឹកនាំគំនិតរបស់យើង តើយើងស្ម័គ្រចិត្តទិញសំបុត្រជិះរថយន្តរំអិលដែរឬទេ? ដរាបណាយើងមើលបញ្ច្រាស ដោយដាក់គំនិតរបស់យើងឲ្យធ្វើជាអ្នកគ្រប់គ្រងលើចិត្តរបស់យើង នោះយើងនឹងជិះបានយូរ ហើយមានល្បឿនលឿនខ្លាំងផងដែរ។

ការសួរដល់ខ្លួនយើងទាំងអស់គ្នា ឲ្យដាក់គំនិតមុនចិត្តរបស់យើងស្ដាប់ទៅដូចជា មិនមានលក្ខណៈខាងឯព្រះវិញ្ញាណសោះមែនឬអត់? ប៉ុន្តែ សូមកត់សម្គាល់អំពីរបៀបដែលព្រះបន្ទូលនិយាយអំពីតួនាទីនៃគំនិត៖

*នៅក្នុងការប្រែចិត្ត៖* «បើសិនជាគេវិលត្រឡប់មកឯទ្រង់ដោយអស់ពីចិត្ត អស់ពីព្រលឹងនៅក្នុងស្រុករបស់ខ្មាំងសត្រូវ...នោះសូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ជាទីលំនៅទ្រង់ចំពោះពាក្យដែលគេអធិស្ឋានហើយទូលអង្វរនោះ...» (១ពង្សាវតារក្សត្រ ៨:៤៨-៤៩)។

*នៅក្នុងការស្វែងរកព្រះជាម្ចាស់៖* «ដូច្នេះ ចូរអ្នករាល់គ្នាតាំងចិត្ត តាំងព្រលឹងដើម្បីរកតាមព្រះយេហូវ៉ាជាព្រះនៃលោកអ្នករាល់គ្នាចុះ» (១របាក្សត្រ ២២:១៩)។

*នៅក្នុងការស្វែងរកភាពសុខសាន្ត៖* «ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះឲ្យមានសេចក្តីសុខពេញខ្នាតដោយព្រោះគេទុកចិត្តនឹងទ្រង់» (អេសាយ ២៦:៣)។

*នៅក្នុងការថ្វាយបង្គំដែលត្រឹមត្រូវ៖* «បើខ្ញុំអធិស្ឋានជាភាសាដទៃ នោះគឺជាវិញ្ញាណខ្ញុំដែលអធិស្ឋាន តែឥតមានប្រយោជន៍ដល់ប្រាជ្ញាខ្ញុំសោះ។ ដូច្នេះត្រូវធ្វើដូចម្តេច ខ្ញុំត្រូវអធិស្ឋានដោយនូវវិញ្ញាណ ហើយត្រូវអធិស្ឋានដោយនូវប្រាជ្ញាផងខ្ញុំនឹងច្រៀងដោយវិញ្ញាណ ហើយនិងច្រៀងដោយប្រាជ្ញាដែរ» (១កូរិនថូស ១៤:១៤-១៥)។

*នៅក្នុងការស្វែងយល់ព្រះបន្ទូល៖* «ក៏មានបន្ទូលថា នេះហើយជាសេចក្តីដែលខ្ញុំបានប្រាប់អ្នករាល់គ្នា កាលនៅជាមួយគ្នានៅឡើយ គឺថាត្រូវតែសម្រេចគ្រប់ទាំងសេចក្តីដែលបានចែងទុកពីខ្ញុំទោះក្នុងក្រឹត្យវិន័យលោក ម៉ូសេ ក្នុងទំនាយពួកហោរា ឬក្នុងបទទំនុកតម្កើងផង។ នោះទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេឲ្យបានយល់ក្នុងគម្ពីរ» (លូកា ២៤:៤៤-៤៥)។

*នៅក្នុងការបំផ្លាស់បំប្រែយើង៖* «កុំឲ្យត្រាប់តាមសម័យនេះឡើយចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះដែលល្អស្រួលទទួល ហើយគ្រប់លក្ខណ៍ផង» (រ៉ូម ១២:២-៣)។

កុំឲ្យប្រញាប់រំលងនូវសេចក្តីពិតដ៏សំខាន់ៗ ដែលយើងទើបនឹងបានអាន



Khmer Women of the word_Layout.indd 40 12/3/26 3:56 in the afternoon

នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១២:២-៣។ តើគ្រីស្ទបរិស័ទណាពិតជាមិនចង់ឲ្យជីវិតរបស់ពួកគេបានផ្លាស់ប្រែ និងទទួលបានចំណេះដឹងនៃបំណងព្រះហឫទ័យរបស់ព្រះ? ក្នុងខគម្ពីរនេះសាវ័ក ប៉ុល បានគូសបញ្ជាក់យ៉ាងច្បាស់អំពីរបៀបដែលយើងអាចទទួលការទាំងនោះបាន៖ ដោយគំនិតបានកែជាថ្មីឡើង មិនមែនចិត្តរបស់យើងឡើយ។

ខ្ញុំបានព្យាយាមស្រឡាញ់ព្រះជាម្ចាស់ជាច្រើនឆ្នាំជាមួយនឹងចិត្តរបស់ខ្ញុំ ដោយមិនខ្វល់អំពីគំនិតរបស់ខ្ញុំឡើយ ខ្ញុំមិនបានទទួលស្គាល់នូវសេចក្តីត្រូវការនៃការលូតលាស់ក្នុងចំណេះដឹងនៃពាក្យ «អញ្ជា» នោះទេ។ ខ្ញុំមានអារម្មណ៍ថា ការសិក្សាព្រះគម្ពីរដែលមានរបៀបក៏មានលក្ខណៈទ្រង់ទ្រាយដូចជាប្រព័ន្ធគ្រឿងយន្តដែរ ទោះជាការបង្ហាញអំពីភាពមិនមានជំនឿ ឬការដឹងថា ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការនៅខាងក្នុង តាមរយៈការចំណាយពេលជាមួយនឹងព្រះអង្គ មិនគ្រប់គ្រាន់សម្រាប់ខ្ញុំឡើយ។ គឺថាខ្ញុំបានបាត់នូវសេចក្តីពិតសំខាន់ដែលថា ចិត្តមិនអាចស្រឡាញ់នូវអ្វីដែលគំនិតមិនបានដឹងនោះឡើយ។ នេះគឺជាការបកស្រាយកណ្ឌគម្ពីរ រ៉ូម ១២:២-៣៖ មិនមែនគ្រាន់តែគំនិតមួយមុខដែលជះឥទ្ធិពលដល់ការផ្លាស់ប្រែ ប៉ុន្តែផ្លូវដើរចូលទៅក្នុងការផ្លាស់ប្រែ គឺធ្វើដំណើរចេញពីគំនិតទៅកាន់ចិត្ត មិនមែនបញ្ច្រាសពីនេះនោះទេ។

សហគមន៍អ្នកវិទ្យាសាស្ត្របានធ្វើការកត់សម្គាល់ពីទំនាក់ទំនងនៃគំនិតមុនចិត្តនេះ។ លោក ប៉ុល ប្លូម (Paul Bloom) ជាសាស្ត្រាចារ្យជំនាញម្នាក់ដែលទទួលបាន PhD ពីមហាវិទ្យាល័យយែល (Yale) ខាងចិត្តវិជ្ជាផ្នែកការដឹងដោយវិញ្ញាណឯកទេសនៅក្នុងការស្រាវជ្រាវភាពសប្បាយរីករាយ។ គាត់សិក្សាអំពីរបៀបដែលមនុស្សអភិវឌ្ឍន៍នូវលទ្ធភាពទាញយកភាពសប្បាយរីករាយពីមនុស្ស ពីបទពិសោធន៍ និងរបស់របរផ្សេងៗ។ គាត់បានរកឃើញតាមរយៈការស្រាវជ្រាវថា ភាពសប្បាយរីករាយមិនអាចកើតឡើងដោយឯកឯងបានទេ វាត្រូវការការអភិវឌ្ឍ។ ហើយរបៀបដែលវាអភិវឌ្ឍន៍គឺជាចំណុចដែល



Khmer Women of the word_Layout.indd 41 12/3/26 3:56 in the afternoon

មានតម្លៃ៖ "មានគេសួរខ្ញុំ ថា "តើអ្នកទាញយកភាពសប្បាយរីករាយចេញពីជីវិតយ៉ាងដូចម្ដេច?" ។ ចម្លើយរបស់ខ្ញុំគឺថា សិក្សាឲ្យបានច្រើន....។ ចំណុចពិសេសពីភាពរីករាយនៅក្នុងការញ៉ាំស្រា មិនមែនគិតតែពីផឹកស្រាដែលមានតម្លៃថ្លៃនោះទេ គឺកើតឡើងតាមរយៈការសិក្សាអំពីស្រានោះ»។[២]

សាស្ត្រាចារ្យ ប្លូម បានរកឃើញលទ្ធផលនៃភាពរីករាយថាជាការទទួលបានចំណេះដឹងអំពីអ្វីដែលជាគោលបំណងនៃភាពរីករាយរបស់យើង។ មិនមែនតាមការស្រមើស្រមៃរបស់យើងទេ មិនមែនតាមរយៈបទពិសោធន៍ម្ដងហើយម្ដងទៀតដែរ។ ជាក់ស្ដែងភាពសប្បាយរីករាយរបស់យើងមានការអភិវឌ្ឍនៅពេលដែលយើងរៀនអំពីប្រវត្តិរបស់វា ដើមកំណើត និងភាពស៊ីជម្រៅនៃសារជាតិរបស់វា។[៣] នេះគឺជាចំណុចពិសេសទាក់ទងនឹងគ្រីស្ទបរិស័ទ ព្រះអង្គបានត្រាស់ហៅឲ្យយើងមានភាពសប្បាយរីករាយ (អំណរ) នៅក្នុងទ្រង់ ដែលយើងអាចនិយាយបានយ៉ាងជឿជាក់ថា "នៅព្រះហស្តស្ដាំទ្រង់មានសេចក្ដីអរសប្បាយជាដរាបតទៅ" (ទំនុកតម្កើង ១៦:១១)។ យើងភាគច្រើនអាចសម្គាល់បានយ៉ាងងាយនឹងការត្រាស់ហៅឲ្យធ្វើជាគ្រីស្ទបរិស័ទដែលមានអំណរ។ ហើយយើងបានតយុទ្ធក្នុងការរស់នៅរាល់ថ្ងៃ ដើម្បីរស់នៅដូចជាអស់អ្នក ដែលបានស្វែងរកអំណរដ៏អស្ចារ្យដែលមាននៅក្នុងព្រះជាម្ចាស់។ ប្រសិនបើសាស្ត្រាចារ្យ ប្លូម បាននិយាយត្រឹមត្រូវមែន នោះការស្វែងរកមានអំណរដ៏អស្ចារ្យនៅក្នុងព្រះអម្ចាស់ មិនមែនជាលទ្ធផលចេញពីការដេញតាម ឲ្យបានមានបទពិសោធន៍អំពីទ្រង់នោះទេ ប៉ុន្តែគឺចេញពីការកាន់តែស្គាល់ទ្រង់ឲ្យបានល្អប្រសើរវិញ។ ការនោះអាចកើតឡើងបានតាមរយៈការសិក្សាអំពីព្រះជាម្ចាស់។

សូមគិតអំពីទំនាក់ទំនង ទ្រព្យសម្បត្តិ ឬក៏ចំណាប់អារម្មណ៍ណាមួយ

២ "What Do We Value Most?" NPR Radio TED Radio Hour, May 25, 2012, 14:00, http://www.npr.org/player/v2/mediaPlayer.html?action=1&t=3&islist=true&id=57&d=04-27-2012.

៣ "Paul Bloom: The Origins of Pleasure," TED Talks, July 2011, http://www.ted.com/talks/paul_bloom_the_origins_of_pleasure.html.



Khmer Women of the word_Layout.indd 42 12/3/26 3:56 in the afternoon

ដែលអ្នកទទួលបានភាពសប្បាយរីករាយជាមួយច្រើនជាងគេ។ តើអ្នកអភិវឌ្ឍភាពរីករាយនោះយ៉ាងដូចម្ដេច? មិនថាអ្នកចូលចិត្តខ្លាំងទៅលើសិល្បៈទំនើបៗ ដូចជាឡាន ការអភិរក្ស ប្ដី/ប្រពន្ធរបស់អ្នក អាហារបំប៉ន ការសិក្សាអប់រំ ឬក៏កីឡា ការប៉ាន់ស្មានរបស់ខ្ញុំគឺថា អ្នកបានចាប់ផ្ដើមរីករាយជាមួយនឹងការទាំងអស់នោះ ដោយសារអ្នកបានសិក្សារៀនសូត្រអំពីអ្វីដែលអ្នកចូលចិត្ត ហើយផ្នែកទាំងនោះបានចាប់ផ្ដើមលូតលាស់ ស្របពេលដែលចំណេះរបស់អ្នកអំពីការទាំងនោះរីកចម្រើនផងដែរ។

ជីវិតអាពាហ៍ពិពាហ៍ប្រហែលជាឧទាហរណ៍មួយជាក់ស្ដែងសម្រាប់ដំណើរការនេះ។ មានមនុស្សជាច្រើនបានរៀបការជាមួយនឹងព័ត៌មានទទួលបានតិចតួចណាស់អំពីដៃគូរបស់ខ្លួន។ តើអ្នកមានបានកត់សម្គាល់អំពីការនេះទេ? យើងបានដាក់អនាគតរបស់យើងផ្អែកទៅលើចំណេះដឹង ដែលមានតិចតួចទៅលើផ្នែកមួយដ៏ធំ គឺដោយសារអារម្មណ៍របស់យើងដូចជាចង់បានខ្លាំង វាក៏មានឥទ្ធិពលមកលើយើងអំឡុងពេលចែចង់គ្នា។ យើងបានរៀបការជាមួយនឹងអារម្មណ៍ពេញ ទៅដោយសេចក្ដីស្រឡាញ់សម្រាប់ប្រពន្ធ ឬប្ដីរបស់យើង។ នេះគឺជាចំណុចធំមួយដែលយើងបានធ្វើ ខណៈពេលដែលយើងបានស្គាល់តិចតួច អំពីដៃគូរបស់យើង។ អារម្មណ៍នៃសេចក្ដីស្រឡាញ់ដើមដំបូង មិនថាវាកំពុងតែរុះរោយទៅឬក៏កាន់តែរឹងមាំ គឺអាស្រ័យទៅលើរបៀបដែលយើងថែរក្សាវា។ ត្រឡប់មើលទៅជីវិតអាពាហ៍ពិពាហ៍ជាង២០ឆ្នាំរបស់ខ្ញុំ ខ្ញុំអាចនិយាយយ៉ាងស្មោះត្រង់ថា ខ្ញុំពិតជាស្រឡាញ់ប្ដីរបស់ខ្ញុំ ប្រៀបធៀបទៅនឹងពេលបច្ចុប្បន្ននេះ គឺមានការកើនឡើងច្រើនជាងសេចក្ដីស្រឡាញ់ ដែលខ្ញុំមាននៅក្នុងថ្ងៃរៀបការដំបូងទៅទៀត។ ហេតុអ្វី? ពីព្រោះខ្ញុំបានធ្វើការសិក្សាអំពីគាត់ ហើយគាត់បានធ្វើការសិក្សាអំពីខ្ញុំដែរ ការដែលស្គាល់គាត់បានធ្វើឲ្យសេចក្ដីស្រឡាញ់ ដែលខ្ញុំមានចំពោះគាត់រីកចម្រើន។ នៅថ្ងៃរៀបការខ្ញុំមានការសង្ស័យ តើគាត់នឹងក្លាយជាឪពុកដ៏ល្អឬទេ ប្រឹងប្រែងធ្វើការដែរឬទេ និងមានជីវិតរស់នៅស្មោះត្រង់ដែរឬទេ ប៉ុន្តែ២០ឆ្នាំក្រោយមកខ្ញុំដឹងថា គាត់ជាមនុស្ស



Khmer Women of the word_Layout.indd 43 12/3/26 3:56 in the afternoon

មាននូវចំណុចទាំងអស់នេះ។ សេចក្តីស្រឡាញ់របស់ខ្ញុំចំពោះគាត់កើនឡើង នៅពេលដែលចំណេះដឹងដែលខ្ញុំរៀនពីគាត់មានការកើនឡើងដែរ។

ឥឡូវ សូមគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ នៅក្នុងរូបភាពនេះដូចគ្នា។ មានមនុស្សជាច្រើនបានជឿព្រះអម្ចាស់ ដោយមានព័ត៌មានតិចតួច។ យើងយល់ថា យើងត្រូវការការអត់ទោស និងព្រះគុណរបស់ព្រះអង្គ ហើយអារម្មណ៍ដ៏ជ្រាលជ្រៅនោះក៏បានចាប់ផ្តើមដឹកនាំយើងចូលទៅក្នុងនគរព្រះអង្គ។ ប៉ុន្តែ យើងគ្រាន់តែស្គាល់ព្រះអង្គ ដែលបាននាំយើងមករកទ្រង់ តិចតួចប៉ុណ្ណោះ ក្នុងការដែលព្រះអង្គបាននាំយើងមកកាន់អង្គទ្រង់ផ្ទាល់។ យើងសន្មតថា តើព្រះអង្គពិតជាល្អមែនដែរឬទេ ប៉ុន្តែយើងមិនទាន់បានសិក្សាពីព្រះអង្គនៅឡើយ។ ដូចជាកូនក្រមុំថ្មោងថ្មីដែរ នៅពេលយើងបានបញ្ចប់នូវដំណើរកម្សាន្តសម្រាប់គូស្រករថ្មោងថ្មី ហើយចាប់ផ្តើមងឿងឆ្ងល់ពីរបៀបដែលយើងថែរក្សា និងបំប៉ននូវទំនាក់ទំនងនេះយ៉ាងដូចម្តេច។

ដើម្បីស្រឡាញ់ព្រះអង្គឲ្យអស់ពីគំនិតរបស់យើង ចម្លើយគឺផ្អែកទៅលើការស្គាល់ព្រះអង្គ។ តើធ្លាប់ឮឃ្លានេះដែរឬទេ “ដើម្បីស្រឡាញ់អ្នកណាម្នាក់ គឺយើងត្រូវស្គាល់ពីអ្នកនោះ” នេះគឺជាការពិត។ ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ជួយយើងឲ្យស្គាល់អំពីលក្ខណសម្បត្តិរបស់ព្រះអង្គ ហើយក៏មានការលូតលាស់ផងដែរ។ ពេលនោះយើងមិនអាចធ្វើអ្វីបានទេ តែនឹងបង្ហាញឲ្យយើងឃើញសេចក្តីស្រឡាញ់របស់យើងយ៉ាងជ្រាលជ្រៅទៅចំពោះព្រះអង្គ។ នេះគឺជាការបកស្រាយនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១២:២ ដែលបានចែងថា យើងទទួលបានការផ្លាស់ប្រែ ដោយគំនិតយើងបានកែជាថ្មីឡើង។ យើងយល់ថាព្រះជាម្ចាស់ជាអ្នកណា ហើយយើងបានផ្លាស់ប្រែសេចក្តីស្រឡាញ់របស់យើងចេញឆ្ងាយពីសម្ភារៈ ហើយចាប់ផ្តើមភ្ជាប់ទំនាក់ទំនងបែរទៅរកព្រះអង្គវិញ។ ប្រសិនបើយើងចង់មានអារម្មណ៍នៃសេចក្តីស្រឡាញ់ ដ៏ជ្រាលជ្រៅសម្រាប់ព្រះជាម្ចាស់ នោះយើងក៏ត្រូវរៀនសម្លឹងមើលទៅព្រះអង្គឲ្យបានច្បាស់ថា ទ្រង់ជាអ្នកណា ប្រសិនបើយើងចង់មានអារម្មណ៍យ៉ាងជ្រាលជ្រៅអំពីព្រះជាម្ចាស់

យើងត្រូវរៀនគិតឲ្យបានជ្រាលជ្រៅអំពីព្រះជាម្ចាស់ដែរ។

សូមគិតអំពីការបង្ហាញមួយទៀតៈ ប្រសិនបើខ្ញុំបានប្រាប់អ្នកថាខ្ញុំស្រឡាញ់ព្យាណូរ ហើយខ្ញុំសប្បាយរីករាយណាស់ពេលដែលបានលេងព្យាណូរ។ តើលោកអ្នកនឹងឃើញយ៉ាងដូចម្ដេចថា ខ្ញុំមានអារម្មណ៍អំពីព្យាណូរពិតប្រាកដ ឬមិនពិតទេ? គឺសាមញ្ញណាស់ គ្រាន់តែសុំឲ្យខ្ញុំលេងព្យាណូរសម្រាប់លោកអ្នក។ មនុស្សដែលស្រឡាញ់ក្នុងការលេងព្យាណូរពិតប្រាកដនឹងដាក់វិន័យខ្លួនឯងក្នុងការសិក្សាអំពីព្យាណូរ តាមរយៈការអនុវត្តនៃការដាក់វិន័យខាងឯខួរក្បាល អ្នកនោះនឹងទទួលបានជំនាញនៅក្នុងការលេងព្យាណូរ ហើយជាលទ្ធផលគឺពួកគេនឹងស្រឡាញ់នៅក្នុងការលេងហើយបន្តរីកចម្រើនទៅមុខទៀតផងដែរ។

ចិត្តមិនអាចស្រឡាញ់នូវអ្វីដែលគំនិតមិនបានដឹងនោះឡើយ។ ពិតណាស់ វាគឺជាអំពើបាបដែលទទួលចំណេះដឹងសម្រាប់ប្រយោជន៍នៃចំណេះដឹង។ ប៉ុន្តែ ការដែលទទួលចំណេះដឹងសម្រាប់ម្នាក់ដែលយើងស្រឡាញ់សម្រាប់ ប្រយោជន៍ នៃ សេចក្ដី ស្រឡាញ់ ដល់ ព្រះ អង្គ យ៉ាង ជ្រាល ជ្រៅជានិច្ចកាលការនោះនឹងនាំមកនូវការផ្លាស់ប្រែដល់យើង។ យើងត្រូវស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីគំនិត អនុញ្ញាតឲ្យចំណេះដឹងរបស់យើងជាអ្នកប្រាប់នូវអារម្មណ៍របស់យើង ជាជាងធ្វើបញ្ច្រាសពីនោះ។

## ព្រះជាម្ចាស់មុនខ្លួនខ្ញុំ គំនិតមុនចិត្ត

ការមើលឃើញខ្លួនឯងនៅក្នុងព្រះគម្ពីរ និងភ្ជាប់អារម្មណ៍របស់យើងទៅក្នុងការស្រឡាញ់ព្រះជាម្ចាស់គឺជាការមួយដ៏ស្រស់ស្អាត។ ចំណុចទាំងនេះគឺជាការប្រៀបធៀបនៃខ្សែរំយោលធ្លាក់នៃសំលៀកបំពាក់ទៅនឹងការសិក្សាព្រះគម្ពីរ។ ប៉ុន្តែ រំយោលធ្លាក់នោះគឺត្រូវនៅខាងក្រោយ ហើយរង្វាន់បន្ទាប់ទីពីរ គឺសម្រាប់ការស្ដាប់បង្គាប់នៅក្នុងការស្វែងរកអ្វី ដែលជាចំណុចដើមដំបូង។ ការសិក្សាព្រះគម្ពីរដែលបង្ហាត់បង្រៀនយើង មិនបានឲ្យយើងព្រងើយកន្តើយអំពី



Khmer Women of the word_Layout.indd 45 12/3/26 3:56 in the afternoon

ការយល់ដឹងពីខ្លួនឯងនោះឡើយ ប៉ុន្តែត្រូវមានការយល់ដឹងពីខ្លួនឯងឲ្យបានត្រឹមត្រូវ៖ គឺត្រូវបានដាស់តឿនដោយចំណេះដឹង ដែលមកពីព្រះជាម្ចាស់។ ការសិក្សាព្រះគម្ពីរដែលបង្ហាត់បង្រៀនមិនអាចកាត់ផ្តាច់ចិត្តចេញពីការសិក្សាបានឡើយ ប៉ុន្តែត្រូវការដាក់ចិត្តឲ្យបានត្រឹមត្រូវ៖ គឺចិត្តត្រូវបានដាស់តឿនដោយគំនិត។

## សំណួរសម្រាប់ឆ្លុះបញ្ចាំង

១. តើមានវិធីអ្វីខ្លះដែលអ្នកបានធ្លាប់ប្រើប្រាស់ព្រះគម្ពីរហាក់បីដូចជាសៀវភៅ ដែលនិយាយតែពីខ្លួនអ្នកផ្ទាល់? តើការមើលឃើញព្រះគម្ពីរថាជាការនិយាយដើមដំបូងអំពីព្រះជាម្ចាស់ មិនមែនអំពីអ្នក មានការផ្លាស់ប្តូរយ៉ាងដូចម្តេច?

២. តើអ្នកងាយនឹងធ្វើការវាស់ស្ទង់កម្លាំងនៃសេចក្តីជំនឿរបស់អ្នក តាមរយៈកម្លាំងនៃអារម្មណ៍របស់អ្នកដែរឬទេ? តើអ្វីទៅជាគ្រោះថ្នាក់នៅក្នុងការវាស់វែងសេចក្តីជំនឿរបស់អ្នកតាមវិធីនេះ?

៣. សូមរៀបចំឡើងវិញនូវគំនិតនេះដោយពាក្យអ្នកផ្ទាល់ «ចិត្តមិនអាចស្រឡាញ់នូវអ្វីដែលគំនិតមិនបានដឹង» ហេតុអ្វីបានជាមានគ្រោះថ្នាក់ខាងឯព្រលឹងវិញ្ញាណ នៅក្នុងការប្រកាសស្រឡាញ់ព្រះជាម្ចាស់ដោយគ្មានការខិតខំប្រឹងប្រែងក្នុងការស្គាល់ព្រះអង្គ តាមរយៈការបើកសម្តែងនៅក្នុងព្រះបន្ទូលរបស់ទ្រង់?



Khmer Women of the word_Layout.indd 46 12/3/26 3:56 in the afternoon

៤. ជំពូកទី១បានភ្ជាប់រវាងភាពរីករាយទៅនឹងដំណើរការនៃការរៀនសូត្រ។ សូមពណ៌នាពេលណាមួយដែលអ្នកមានភាពសប្បាយរីករាយ នៅក្នុងទំនាក់ទំនងដែលរីកលូតលាស់ដោយសារអ្នកបានស្គាល់បុគ្គលណាម្នាក់នោះបានល្អប្រសើរ។ តើមានលក្ខណៈដូចគ្នាយ៉ាងដូចម្តេច ដែលអ្នកបានឃើញនៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់?

៥. តើអ្នកយល់ឃើញយ៉ាងដូចម្តេចអំពីការភ្ជាប់ទំនាក់ទំនងរវាងចំណុចនៃការបង្វែរទាំងពីរ ទៅលើការសិក្សាព្រះគម្ពីរ (ខ្លួនឯងមុនព្រះជាម្ចាស់ និងចិត្តមុនគំនិត) នេះ?



Khmer Women of the word_Layout.indd 47 12/3/26 3:56 in the afternoon

ជំពូកទី២

# មូលហេតុដែលយើង ត្រូវការសិក្សាព្រះគម្ពីរ

«ដ្បិតអស់ទាំងសេចក្ដីដែលបានចែងទុកមកជាមុននោះបានចែងសម្រាប់នឹងបង្រៀនដល់យើងរាល់គ្នា ដើម្បីឲ្យយើងបានសេចក្ដីសង្ឃឹម ដោយសេចក្ដីអត់ធន់ និងសេចក្ដីកម្សាន្តចិត្តដោយសារគម្ពីរ»។

រ៉ូម ១៥:៤

ចំណុចណែនាំ៖ នេះគឺជាជំពូកដែលអ្នកមិនចង់អាន ហើយអ្នកមានអារម្មណ៍ថាមិនស្រួលនៅក្នុងចិត្ត ប្រហែលជាអ្នកចង់ប្រាប់ខ្ញុំថាកុំខ្វល់ខ្វាយពីរឿងអ្នកដទៃច្រើនពេក។ នេះគឺជា ជំពូកដែលយើងនិយាយអំពីការសិក្សាព្រះគម្ពីរ៖ តើនោះគឺជាអ្វី ថាតើយើងនឹងទទួលបានផលដែរឬទេ និងហេតុអ្វីបានជាវាសំខាន់ដែលយើងត្រូវអនុវត្តបែបនេះ។

សូមឲ្យខ្ញុំសម្រួលឲ្យអ្នកមានភាពងាយស្រួលបន្តិច៖ មនុស្សយើងភាគច្រើនមិនមានចំណុចនេះទេ រួមទាំងខ្លួនខ្ញុំផងដែរ។ ការសិក្សាព្រះគម្ពីរគឺជាអ្វីមួយដែលយើងភាគច្រើននឹងមិនដែលមានអារម្មណ៍ងាយស្រួលក្នុងការប្រកាសថាយើងទទួលបានការនោះ ខណៈពេលដែលយើងកំពុងរស់នៅនោះ



Khmer Women of the word_Layout.indd 49 12/3/26 3:56 in the afternoon

ឡើយ។ ហេតុដូច្នេះហើយបានជានេះគឺជាជំពូកដែលធ្វើឲ្យខ្ញុំមានអារម្មណ៍មិនងាយស្រួលដូចគ្នាផងដែរ។

យើងទាំងអស់គ្នាសុទ្ធតែផ្ទុកនូវអារម្មណ៍មិនងាយស្រួលសម្រាប់ការមិនយល់ដឹងរបស់យើង ហើយមានអារម្មណ៍ខ្មោលឡើងទាក់ទងទៅនឹងចំណុចនេះនៅពេលដែលយើងនិយាយជាមួយនឹងអ្នកមិនជឿ។ ដូចជា មិត្តភក្តិនៅក្នុងក្រុមតូចរបស់យើង ឬក៏អ៊ំស្រីដ៏វៃឆ្លាតម្នាក់។ ពេលខ្លះ ប្រភេទគ្រោះថ្នាក់នៃការបិទបាំងប្រធានបទនៃព្រះគម្ពីរធ្វើឲ្យយើងជួបនូវបញ្ហាដែលមានបទពិសោធន៍ភ័យស្លន់យ៉ាងខ្លាំងតែ លោក អាលិច ទ្រេបិក (Alex Trebek) បានដឹងអំពីរបៀបត្រឡប់ចូលមកអត្ថបទរបស់យើងបានប្រសើរជាងពួកយើងធ្វើទៅទៀត។ យើងមានការទាល់ច្រកក្នុងការរកឈ្មោះសាវ័កទាំង១២ ឬក៏និយាយអំពីការបង្កើតឲ្យបានត្រូវតាមលំដាប់លំដោយ។ យើងធ្លាប់បានឮអំពីរឿងនាង តាម៉ារ ប៉ុន្តែតើនាងបានបង្ហាញគំរូវិជ្ជមាន ឬអវិជ្ជមាន? នៅពេលដែលគ្រូអធិប្បាយដែលយើងចូលចិត្តពីរនាក់បានបង្ហាញនូវជំហរពីរផ្សេងៗគ្នាក្នុងប្រធានបទតែមួយ យើងនឹងជួបនូវការច្របូកច្របល់ជាមិនខាន។

យើងឲ្យតម្លៃទៅលើអ្វីដែលយើងបានដឹង ប៉ុន្តែយើងមានបញ្ហាជាមួយអ្វីដែលយើងមិនបានដឹង យើងបានធ្វើអស់ពីសមត្ថភាពក្នុងការប្រមូលរៀបចំដេរប៉ះចំណុចដែលរហែកនៃចំណេះដឹងក្នុងព្រះបន្ទូល។ ចំណុចចេញពីសេចក្តីអធិប្បាយ ការសិក្សា និងការចំណាយពេលជាមួយព្រះអង្គ ប៉ុន្តែជារឿយៗយើងនូវតែប្រឈមជាមួយនឹងចន្លោះនៃការខ្វះខាត ហើយបាត់បង់ស្នាមប៉ះនៅក្នុងសំលៀកបំពាក់នៃការយល់ដឹងរបស់យើង ជាពិសេសនៅពេលដែលជីវិតយើងជួបនឹងទុក្ខលំបាក។ យើងមិនស្គាល់ព្រះគម្ពីរដូចដែលយើងត្រូវការឡើយ ហើយពួកយើងខ្លះគឺថ្មីនៅក្នុងសេចក្តីជំនឿមិនបានដឹងព្រះគម្ពីរទាំងនោះទេ និងមានពួកយើងជាច្រើនទៀត ដែលនៅក្នុងក្រុមជំនុំលើសមួយទសវត្សហើយក៏នៅតែរកមិនឃើញបានល្អប្រសើរនៅឡើយដែរ។

បើអញ្ចឹង តើយើងធ្វើអ្វីខ្លះ ដើម្បីឲ្យមានចំណេះដឹងក្នុងព្រះគម្ពីរបានល្អ



Khmer Women of the word_Layout.indd 50 12/3/26 3:56 in the afternoon

ប្រសើរ? យើងបានចាប់ផ្ដើមឆ្លើយសំណួរនេះរួចហើយនូវអ្វីដែលធ្វើឲ្យយើងមានការសិក្សាព្រះគម្ពីរបានល្អត្រឹមត្រូវ៖ ការសិក្សាព្រះគម្ពីរដែលត្រឹមត្រូវផ្លាស់ប្ដូរចិត្តតាមរយៈការបណ្ដុះបណ្ដាលគំនិត និងដាក់ព្រះជាម្ចាស់នៅចំណុចកណ្ដាលនៃសាច់រឿង។ ប៉ុន្តែ ការសិក្សាព្រះគម្ពីរដែលល្អត្រឹមត្រូវគឺធ្វើច្រើនជាងនេះ ក៏ទុកឲ្យអ្នកសិក្សាមានការយល់ដឹងអំពីព្រះគម្ពីរប្រសើរជាងមុនទៅវិញ។ អាចនិយាយម្យ៉ាងទៀតថា ការសិក្សាព្រះគម្ពីរត្រឹមត្រូវបង្កើនចំណេះដឹងខាងឯព្រះគម្ពីរ។

## តើអ្វីទៅជាការសិក្សាព្រះគម្ពីរ?

ការសិក្សាព្រះគម្ពីរកើតឡើងនៅពេលដែលអ្នកណាម្នាក់អានព្រះគម្ពីរក្នុងភាសាមួយ ដែលគាត់យល់ហើយនាំពួកគេឆ្ពោះទៅរកចំណេះដឹងបន្តិចម្ដងៗ និងមានការយល់ដឹងអំពីអត្ថបទនៃខ្លឹមសារព្រះបន្ទូលនោះ។ បើនេះគឺជាការពិតដែលថា លក្ខណសម្បត្តិ និងបំណងព្រះទ័យរបស់ព្រះជាម្ចាស់បានបង្ហាញនៅក្នុងព្រះបន្ទូលមែន នោះការប្រឹងប្រែងដ៏ជាក់លាក់ណាមួយ ដូចជានៅក្នុងការបង្វឹកសម្រាប់ការងារបង្កើតសិស្សត្រូវរាប់បញ្ចូលទាំងសេចក្ដីប៉ងប្រាថ្នា ក្នុងការបង្កើតឲ្យមានការសិក្សាព្រះគម្ពីរផងដែរ។ ការសិក្សាព្រះគម្ពីរនឹងដេរប៉ះភ្ជាប់នូវចំណេះដឹងទៅនឹងក្រណាត់នៃការយល់ដឹងរបស់យើង មិនឲ្យមានស្នាមថ្នេរឡើយ។

បើអ្នកកំពុងអានសៀវភៅនេះ នោះអ្នកទំនងជាមានព្រះគម្ពីរជាភាសាដែលអ្នកអាចយល់បាននៅជិតខ្លួន។ នេះមិនមែនជាអំណោយដ៏តូចតាចឡើយ។ អ្វីដែលអ្នកត្រូវធ្វើគឺការធ្វើដំណើរទៅកាន់ចំណេះដឹង និងការយល់ដឹងឲ្យបានខ្ជាប់ខ្ជួន។ សកម្មភាពនៃការខ្ជាប់ខ្ជួននេះមិនមែនកើតឡើងដោយចៃដន្យឡើយ ឬក៏តែងតែកើតឡើងដោយមិនមានការគិតពិចារណានោះដែរ។ យើងប្រហែលមានសេចក្ដីប៉ងប្រាថ្នាយ៉ាងអស់ពីចិត្តនៅក្នុងការទទួលបានការសិក្សាព្រះគម្ពីរ ប៉ុន្តែបើយើងមិនបានទទួលការបណ្ដុះបណ្ដាល នោះយើង



Khmer Women of the word_Layout.indd 51 12/3/26 3:56 in the afternoon

ប្រហែលអភិវឌ្ឍនូវទម្លាប់ក្នុងការភ្ជាប់អត្ថបទទៅនឹងចំណុចដែលល្អ តែយើងមិនបានធ្វើអ្វីសោះជាមួយផ្នែកនោះ ដើម្បីបង្កើនចំណេះដឹងទេ ហើយអ្វីដែលអាក្រក់ជាងនេះទៅទៀតគឺវាអាចនាំទៅកាន់ផលមិនល្អដែរ។ មុនពេលដែលយើងអភិវឌ្ឍនូវទម្លាប់ល្អ យើងត្រូវពិនិត្យមើលបញ្ជីរបស់យើងដោយស្មោះត្រង់ហើយដកនូវចំណុចណាដែលមិនមានប្រយោជន៍ដែលយើងធ្លាប់បានអនុវត្តពីមុនៗមកចោលសិន។

តើអ្នកធ្លាប់មានទម្លាប់ដែលមិនមានប្រយោជន៍ហើយចង់បោះវាចោលដែរឬទេ? កាលខ្ញុំមាន អាយុ២០ឆ្នាំជាង ខ្ញុំយល់ឃើញថាខ្ញុំមានទម្លាប់អត់ល្អមួយនៅក្នុងការនិយាយកាត់សម្ដីរបស់អ្នកដទៃ។ ខ្ញុំចាំបានថា ខ្ញុំពិតជាមានការភ្ញាក់ផ្អើលនៅពេលដែលមានមនុស្សម្នាក់បានប្រាប់ខ្ញុំដោយសេចក្ដីស្រឡាញ់ថា កុំឲ្យខ្ញុំធ្វើដូចនេះទៀត។ មិនមែនខ្ញុំមិនបានដឹងថា ខ្ញុំបាននិយាយកាត់អ្នកណាម្នាក់នោះទេ គឺដោយសារខ្ញុំមិនបានឃើញថាមានអ្វីខុសឆ្គងជាមួយនឹងការនេះទេ។ ខ្ញុំពិតជាបានជឿថា ខ្ញុំបានជួយដល់ការសន្ទនានោះតាមរយៈការចូលមកនិយាយកាត់គេ។ ប៉ុន្តែ នៅពេលដែលខ្ញុំដឹងថា ខ្ញុំបានធ្វើដូច្នេះនោះជារឿយៗនៅពេលការនោះកើតឡើង វាហាក់បីដូចជាខ្ញុំមិនបានឲ្យតម្លៃនិងគោរពដល់អ្នកដទៃឡើយ។ ខ្ញុំពិតជាខ្មាសគេ និងអាម៉ាស់ផងដែរ ហើយខ្ញុំចាប់ផ្ដើមមានសេចក្ដីប៉ងប្រាថ្នាភ្លាមៗនៅក្នុងការឈប់ធ្វើបែបនោះ។ ប៉ុន្តែនៅពេលដែលខ្ញុំទទួលស្គាល់បញ្ហានោះដែលខ្ញុំបានបង្កើតនូវទម្រង់នៃទំនាក់ទំនងមួយនោះហើយ គឺវាពិបាកនៅក្នុងការបំផ្លាញចោលណាស់។ ការរៀនដែលបញ្ឈប់នូវទម្លាប់មិនល្អតម្រូវឲ្យយើងទទួលស្គាល់នូវទំហំនៃបញ្ហារបស់យើង ហើយបន្ទាប់មកធ្វើការប្រឹងប្រែងនៅក្នុងការកែប្រែទម្លាប់នោះ។

នេះគឺជាការពិតសម្រាប់ទម្លាប់មិនល្អណាមួយ ទម្លាប់នោះប្រហែលជាមានការលូតលាស់ជាពិសេសប្រសិនបើទម្លាប់នោះបានអភិវឌ្ឍន៍ច្រើនឆ្នាំមកហើយ។ ដើម្បីបញ្ឈប់វាដំបូងយើងត្រូវទទួលស្គាល់នូវទំហំនៃផលប៉ះពាល់របស់វា ហើយបន្ទាប់មកចាប់ផ្ដើមជំហាននៃការផ្លាស់ប្រែ។



Khmer Women of the word_Layout.indd 52 12/3/26 3:56 in the afternoon

នៅពេលនិយាយអំពីការសិក្សាព្រះគម្ពីរទម្លាប់មិនល្អមានច្រើនណាស់នៅក្នុងការអប់រំរបស់គ្រីស្ទបរិស័ទយើងបានទទួលយកនូវគ្រប់ទាំងឃ្លាល្អៗ ដែលជាទូទៅទម្លាប់របស់យើង គឺដាក់ភ្ជាប់ចូលទៅក្នុងព្រះបន្ទូល៖ «ការចំណាយពេលនៅក្នុងព្រះបន្ទូល» ដែលអ្នកដឹកនាំក្រុមជំនុំបានជំរុញយើងឲ្យធ្វើដូច្នេះ។ ហើយអ្នកនិពន្ធ និងអ្នកសរសេរមាតិកាបានដាស់តឿនយើងក្នុងការឲ្យតម្លៃលើចំណុចនេះដែរ។ ប៉ុន្តែ តើអ្វីដែលកើតឡើងអំឡុងពេលនៃការចំណាយពេលជាមួយនឹងព្រះបន្ទូលរបស់យើងនៅអាចមានភាពមិនច្បាស់ទម្លាប់ជាក់លាក់ដែលយើងមាននឹងមានខុសៗគ្នា ពីមនុស្សម្នាក់ទៅមនុស្សម្នាក់។

គ្រោះថ្នាក់ដ៏ធំនៃភាពមិនច្បាស់នេះគឺថា យើងប្រហែលជាបានសន្និដ្ឋាននូវទស្សនៈរបស់យើងអំពី «ការចំណាយពេលក្នុងព្រះបន្ទូល» នេះនឹងនាំយើងទៅរកចំណេះដឹងពីព្រះគម្ពីរ ដោយសារយើងគ្រាន់តែបានស្តាប់បង្គាប់ក្នុងការអនុវត្តនេះ។ តែមិនមែនគ្រប់ទាំងការពាក់ព័ន្ធជាមួយនឹងព្រះបន្ទូលទាំងអស់សុទ្ធតែបានបង្កើតឲ្យមានការសិក្សាព្រះគម្ពីរនោះឡើយ។ ការសិក្សាអំពីអ្វីដែលព្រះបន្ទូលបានថែង បន្ទាប់មកធ្វើការកាត់ស្រាយស្វែងយល់ ហើយការអនុវត្តន៍តម្រូវឲ្យមានការហ្វឹកហាត់ច្រើនជាងចំណុចទូទៅ ដែលទាក់ទងនឹង «ការចំណាយពេលក្នុងព្រះបន្ទូល» ទាំងនោះ។ យើងមិនអាចសន្និដ្ឋានថាបំណងល្អរបស់យើងគឺគ្រប់គ្រាន់ល្មមហើយនោះទេ។

## តើយើងកំពុងលូតលាស់នៅក្នុងការសិក្សាព្រះគម្ពីរដែរឬទេ?

ប្រសិនបើការសិក្សាព្រះគម្ពីរគឺជាគោលដៅរបស់យើង នោះយើងត្រូវធ្វើការវាយតម្លៃដ៏ស្មោះត្រង់អំពីអ្វីដែលយើងកំពុងធ្វើក្នុងពេលបច្ចុប្បន្ន ដើម្បីទទួលបានគោលដៅនេះ។ ទម្លាប់ដែលយើងកំពុងធ្វើមួយចំនួនមិនមែន «អត់ល្អ» នោះទេគឺនៅក្នុងន័យដែលថា ចំណុចទាំងនោះមិនបានជួយយើងឲ្យរៀននូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ ចំណុចទាំងនោះប្រហែលមានដែនកំណត់គឺថាក្នុងន័យមួយគ្រាន់តែបាននាំយើងឲ្យមានការយល់ដឹងប៉ុណ្ណោះ។ ទម្លាប់



Khmer Women of the word_Layout.indd 53 12/3/26 3:56 in the afternoon

ខ្លះផ្សេងទៀតប្រហែលត្រូវទុកឆ្ងាយមួយឡែកតែម្តង។ ដំបូងយើងមិនអាចដឹងបានទេថា ទម្លាប់របស់យើងកំពុងធ្វើមានដែនកំណត់ ឬក៏មិនមានប្រយោជន៍ ប៉ុន្តែនៅពេលដែលយើងពិនិត្យមើលឲ្យបានល្អិតល្អនោះយើងចាប់ផ្តើមកត់សម្គាល់អំពីចន្លោះនៃការយល់ដឹង វាបង្កើតឲ្យមានចន្លោះខ្វះខាតក្នុងការយល់ដឹង។

ក្នុងអំឡុងពេលដែលខ្ញុំបានបង្រៀនព្រះគម្ពីរទៅកាន់ក្រុមស្ត្រី ខ្ញុំបានជួបប្រទះនូវទម្លាប់ដែលមិនមានប្រយោជន៍ជាច្រើនក្នុង «ការចំណាយពេលក្នុងព្រះបន្ទូល» ។ ខ្ញុំសង្ស័យថា ចំណុចទាំងនោះអ្នកក៏ប្រហែលជាធ្លាប់បានជួបដែរ។

## វិធីរបស់ខ្ញុំ

មានអារម្មណ៍ថារសាប់រសល់? កណ្ឌគម្ពីរ ភីលីព ៤:៦ បានចែងថា ក្នុងគ្រប់ការទាំងអស់មិនត្រូវឲ្យយើងខ្វល់ខ្វាយអ្វីឡើយ។ មានអារម្មណ៍ថា មិនស្អាត? កណ្ឌគម្ពីរ ទំនុកតម្កើង ជំពូក១៣៩ បានចែងថា អ្នកចេះកោតខ្លាច និងបានបង្កើតមកយ៉ាងអស្ចារ្យ។ អានអារម្មណ៍ថា ហត់នឿយ? កណ្ឌគម្ពីរ ម៉ាថាយ ១១:២៨ ចែងថា ព្រះយេស៊ូវនឹងផ្តល់ការសម្រាកដល់អ្នកនឿយព្រួយ។ វិធីបែបអំពីខ្ញុំចាត់ទុកព្រះគម្ពីរ សម្រាប់តែជួយពួកគេឲ្យមានអារម្មណ៍ល្អប៉ុណ្ណោះ។ បើទោះជាបានដាក់ខគម្ពីរទាំងនោះចូលទៅក្នុងសៀវភៅណែនាំសម្រាប់ការសិក្សាព្រះគម្ពីរ នោះគ្រាន់តែជាតារាងបញ្ជីប្រធានបទនៅក្នុងព្រះគម្ពីររបស់ខ្ញុំតែប៉ុណ្ណោះ ខ្ញុំបានប្រកាសពេលវេលារបស់ខ្ញុំនៅក្នុងព្រះបន្ទូលយ៉ាងជោគជ័យ ខ្ញុំអាចនិយាយថា «ពិតជាមានអារម្មណ៍ល្អណាស់»។

*បញ្ហា៖* វិធីរបស់ខ្ញុំធ្វើឲ្យព្រះគម្ពីរគឺជាសៀវភៅដែលនិយាយអំពីខ្ញុំ។ ខ្ញុំបានស្វែងរករបៀបដែលធ្វើឲ្យព្រះគម្ពីរបម្រើខ្ញុំ ជាជាងរបៀបដែលខ្ញុំអាចបម្រើដល់ព្រះជាម្ចាស់ដែលព្រះគម្ពីរបានចែងអំពីទ្រង់។ សេចក្តីពិតគឺថា ព្រះគម្ពីរជារឿយៗមិនបានធ្វើឲ្យយើងមានអារម្មណ៍ល្អគ្រប់ពេលនោះទេ។ តាមពិត



Khmer Women of the word_Layout.indd 54 12/3/26 3:56 in the afternoon

ជាទូទៅព្រះគម្ពីរគឺផ្ទុយពីការនេះ។ (មានអារម្មណ៍ថាអស្ចារ្យឬ? កណ្ឌគម្ពីរយេរេមា ១៧:៩ ចែងថា យើងទាំងអស់គ្នាអាក្រក់ និងបោកបញ្ឆោត។ ពិតណាស់ មានកន្លែងជួយយើងឲ្យមានអារម្មណ៍ល្អនៅក្នុងព្រះបន្ទូល ប៉ុន្តែតើបរិបទគឺជាអ្វីដែលបានធ្វើឲ្យយើងមានអារម្មណ៍ល្អពិតប្រាកដ និងស្ថិតស្ថេរមែន។ សូមកត់សម្គាល់វិធីបែបអំពីខ្ញុំនេះនឹងធានាថា មានផ្នែកជាច្រើននៃព្រះគម្ពីរដែលលោកអ្នកមិនបានអានឡើយ ពីព្រោះពួកគេបរាជ័យក្នុងការទទួលយកដោយសារអារម្មណ៍នៃការមិនពេញចិត្ត។ យើងប្រហែលជានឹងមិនបានអានកណ្ឌគម្ពីរលេវីវិន័យ ឬក៏កណ្ឌគម្ពីរបរិទេវឡើយ ប្រសិនបើយើងជាអ្នកពេញចិត្តជាមួយនឹងវិធីរបស់ខ្ញុំនេះ។ វិធីសាស្ត្រនៃការសិក្សាព្រះគម្ពីរដ៏ពេញលេញលើកទឹកចិត្តយើងឲ្យមើលព្រះគម្ពីរគ្រប់ផ្នែកទាំងអស់ ទោះបើផ្នែកនោះធ្វើឲ្យយើងមានអារម្មណ៍មិនល្អ ឬពេលខ្លះពិបាកក្នុងការយល់ក៏ដោយ។

## វិធីចាក់គម្ពីរ

ការមិនមាននូវអ្វីដែលជាទីពេញចិត្ត ឬការណែនាំអំពីអ្វីនៅក្នុងការអាន ខ្ញុំនឹងអាននូវព្រះបន្ទូលកន្លែងណាដែលខ្ញុំបើកទៅចំ។ សូមមើល ចំណុចទាំងនេះពិតជាល្អមែនអត់? ខ្ញុំនឹងសូមព្រះវិញ្ញាណបរិសុទ្ធឲ្យមានបន្ទូលមកកាន់ខ្ញុំតាមរយៈខគម្ពីរណាមួយដែលខ្ញុំបានបើកទៅចំ។ នេះជាការបញ្ចេញនូវអ្វីដែលជាបំណងល្អរបស់ខ្ញុំ គឺខ្ញុំដាក់នូវអ្វីដែលខ្ញុំអត់ចេះទៅលើអត្ថបទណាមួយដែលខ្ញុំបើកទៅចំ ខ្ញុំនឹងឆ្លុះបញ្ចាំងនូវខគម្ពីរផ្សេងៗ «តាមដែលព្រះវិញ្ញាណដឹកនាំ»។

*បញ្ហា៖* ព្រះគម្ពីរសរសេរឡើងមិនបានឲ្យយើងអានមានលក្ខណៈបែបនេះឡើយ។ វិធីចាក់គម្ពីរនេះនឹងមិនផ្តល់ឲ្យអ្នកអាននូវគំនិតទាក់ទងនឹងវប្បធម៌ប្រវត្តិសាស្ត្រ ឬក៏បរិបទនៃអក្សរសាស្ត្រ ភាពជាអ្នកនិពន្ធ ឬក៏គោលបំណងដើមនៃអត្ថបទព្រះគម្ពីរក្នុងសំណួរឡើយ។ វាមិនបានជួយយើងអ្វីទាំងអស់ក្នុងការយល់ដឹងឲ្យហួសពីបរិបទនៃអត្ថបទដែលយើងកំពុងអាននោះទេ។



Khmer Women of the word_Layout.indd 55 12/3/26 3:56 in the afternoon

នៅពេលយើងអានបែបនេះ យើងមិនមានការគោរពចំពោះព្រះគម្ពីរឡើយ យើងចាត់ទុកព្រះគម្ពីរដូចជាសៀវភៅសិក្សាមួយប៉ុណ្ណោះ។ សូមគិតបន្តិច បើយើងព្យាយាមចង់បានលទ្ធផលល្អផ្នែកគណិតវិទ្យា ដោយគ្រាន់តែអានសៀវភៅអំពីគំនិតវិជ្ជាមួយថ្ងៃតែ១០នាទី ទៅលើឃ្លាណាមួយដែលអ្នកបានបើកសៀវភៅសិក្សាទៅចំ ហើយអ្នកបានអាន។ ការបាត់បង់សន្ទុះគឺដូចគ្នាទៅនឹងបែបបើកចាក់សៀវភៅអានដែរ គឺអ្នកនឹងបាត់នូវកម្លាំងរុញច្រានយ៉ាងឆាប់រហ័ស (ហើយគណិតវិទ្យារបស់លោកអ្នកនឹងមិនមានលទ្ធផលល្អឡើយ)។ វិធីសាស្ត្រនៃការសិក្សាព្រះគម្ពីរដ៏ពេញលេញ គឺរាប់បញ្ចូលទាំងអស់នូវអត្ថបទព្រះបន្ទូលកន្លែងផ្សេងៗទៀតនូវអ្វីដែលព្រះគម្ពីរបានមានព្រះបន្ទូល ដែលឆ្លើយតបទៅនឹងរូបភាពធំ អំពីអ្វីៗដែលព្រះគម្ពីរបានចែង ផ្ដល់តម្លៃដល់បរិបទ ភាពជាអ្នកនិពន្ធ ប្រភេទ ផ្នែក ផ្សេងៗទៀត។

## វិធីរកចម្លើយបែបវេទមន្ត

តើអ្នកចាំអំពីបាល់វេទមន្តបែបផ្ដល់ចម្លើយទេ? កាលពីខ្ញុំនៅក្មេង ខ្ញុំគិតថាវាអាចឆ្លើយនូវសំណួរពិបាកៗរបស់ខ្ញុំ។ ប៉ុន្តែ ឥឡូវនេះខ្ញុំពេញវ័យហើយ ខ្ញុំឆ្ងល់ថាបើពេលនោះខ្ញុំរៀបការជាមួយបង បូប មានការងារថ្មី ឬក៏លាបពណ៌សក់ថ្មីជាដើម។ ខ្ញុំបើកព្រះគម្ពីររបស់ខ្ញុំលឿនញាប់តាមទំព័រនីមួយៗ ហើយដាក់ដៃរបស់ខ្ញុំនៅលើកន្លែងដែលបានបើកនោះ ទៅលើខណាមួយដែលខ្ញុំបានបើកទៅចំ ហើយបន្ទាប់មក ខ្ញុំចាប់ផ្ដើមអានស្វែងរក «ចំណុចបង្ហាញពីការយល់ស្រប»។

*បញ្ហា៖* ព្រះគម្ពីរមិនមែនជាសៀវភៅវេទមន្តទេ ហើយក៏មិនមែនសម្រាប់ឆ្លើយតបជាមួយនឹងការគិត និងបំណងរបស់យើងដែរ ហើយក៏មិនមែនជាតួនាទីរបស់ព្រះគម្ពីរដែលជាអ្នកឆ្លើយសំណួររបស់យើងនោះដែរ។ វិធីរកចម្លើយបែបវេទមន្តបកស្រាយខុសអំពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ តាមរយៈព្រះបន្ទូល ដោយទាមទារឲ្យព្រះគម្ពីរប្រាប់យើងអំពីអ្វីដែលត្រូវធ្វើ ជាជាង



Khmer Women of the word_Layout.indd 56 12/3/26 3:56 in the afternoon

ប្រាប់អំពីខ្លួនយើងនឹងក្លាយទៅជាអ្វី។ ហើយកាន់តែមានគ្រោះថ្នាក់គឺទាក់ទងទៅនឹងការទស្សន៍ទាយ ដែលមានមនុស្សជាច្រើនត្រូវបានគេចោលនឹងដុំថ្ម។ ហេតុដូច្នេះសូមកុំប្រើវិធីបែបរកចម្លើយនេះ វិធីសាស្ត្រនៃការសិក្សាព្រះគម្ពីរដ៏ពេញលេញ ទទួលស្គាល់ថាព្រះគម្ពីរតែងតែយកចិត្តទុកដាក់ទៅលើអ្នកដែលបានធ្វើការសម្រេចចិត្ត ជាជាងផ្ដោតលើតែសេចក្ដីសម្រេចចិត្តនោះ។ ព្រះគម្ពីរមានបំណងផ្លាស់ប្ដូរចិត្តរបស់យើង ដើម្បីឲ្យយើងមានសេចក្ដីប៉ងប្រាថ្នា នូវអ្វីដែលជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ជាជាងគ្រាន់តែផ្ដល់ឲ្យយើងនូវចម្លើយមួយចំណុចម្ដងៗ ទៅនឹងសេចក្ដីសម្រេចចិត្តដែលកើតមានឡើងនៅក្នុងជីវិតយើង។

## **វិធីបែបទិញទំនិញសម្រាប់អ្នក** (ឬក៏ជាការសិក្សាព្រះគម្ពីរបែបប្រធានបទ)

ខ្ញុំចង់ដឹងពីរបៀបក្លាយជាស្ត្រីដែលគោរពកោតខ្លាចព្រះ ឬពីដំណោះស្រាយទាក់ទងនឹងបញ្ហានៃការស្គាល់ពីតម្លៃខ្លួនឯង ប៉ុន្តែខ្ញុំមិនដឹងថាខគម្ពីរកន្លែងណានិយាយអំពីចំណុចអស់ទាំងនេះឡើយ ដូច្នេះខ្ញុំបាន [ដាក់ខព្រះគម្ពីរល្អមួយចំនួន] ដើម្បីជួយដល់ការងាររបស់ខ្ញុំ។ ចំណុចនេះបានជួយខ្ញុំនៅក្នុងការជ្រើសរើសបានយ៉ាងល្អ ហើយខគម្ពីរទាំងនោះមានការជាប់ទាក់ទងគ្នាជាមួយខផ្សេងៗទៀតនៅក្នុងព្រះគម្ពីរទាំងមូល ហើយយើងអាចយកមកប្រើប្រាស់បាននូវខណាមួយដែលត្រូវជាមួយនឹងប្រធានបទរបស់យើង។

*បញ្ហា៖* វិធីបែបឆែកមើលបញ្ជី មិនបានជួយយើងឲ្យមានភាពជា "ម្ចាស់កម្មសិទ្ធិ" លើព្រះបន្ទូល ឡើយ។ វិធីនេះស្រដៀងគ្នាទៅនឹងវិធីចាក់គម្ពីរដែរ យើងឆ្លុះបញ្ចាំងពីប្រធានបទមួយទៅប្រធានបទមួយទទួលបានចំណេះដឹងនូវផ្នែកមួយចំនួន តាមរយៈកណ្ឌគម្ពីរផ្សេងៗជាច្រើនក្នុងព្រះគម្ពីរ ប៉ុន្តែមិនមានចំណេះពិតប្រាកដលើអ្វីមួយឡើយ។ ការសិក្សាតាមប្រធានបទពិតជាមានសក្ដានុពលជួយយើងឲ្យលូតលាស់មែនដែរ ប៉ុន្តែយើងមានការប្រថុយ



Khmer Women of the word_Layout.indd 57 12/3/26 3:56 in the afternoon

ប្រធានលើផ្នែកខ្លះ ក្នុងការហៅការសិក្សាបែបនេះថាជា «ការសិក្សាព្រះគម្ពីរ» ។ ការហៅការសិក្សាសៀវភៅណាមួយថាជាការសិក្សាព្រះគម្ពីរ នោះគួរតែបង្ហាញឲ្យយើងឃើញនូវចំណេះដឹងនៃសេចក្តីបង្រៀនរបស់ព្រះបន្ទូល។ ការសិក្សាតាមប្រធានបទជាច្រើន ទោះបើជាប្រធានបទណាមួយល្អក៏ដោយក៏យើងមិនអាចប្រកាសថាការសិក្សា តាមលក្ខណៈបែបនេះត្រឹមត្រូវដែរ។ ការសិក្សានេះផ្តល់នូវតម្លៃជាលក្ខណៈបំប៉ន ប៉ុន្តែមិនមែនជាលក្ខណៈជំនួសឲ្យការសិក្សាព្រះគម្ពីរ ដែលមានលក្ខណៈជាមូលដ្ឋានឡើយ។ ការសិក្សាបែបប្រធានបទបានបំពេញនូវគោលបំណង៖ ជួយយើងឲ្យមានការចូលរួមនូវប្រធានបទធំៗជាច្រើន ដើម្បីឲ្យយើងមានការយល់ដឹងនៅក្នុងព្រះបន្ទូល។ ប៉ុន្តែ វិធីនេះមិនមែនជាលក្ខណៈគ្រឹះឡើយ។ ប្រសិនបើនេះជាវិធីតែមួយដែលយើងធ្លាប់បានធ្វើកន្លងមក យើងនឹងខកខានអំពីភាពសម្បូរបែបនៃការសិក្សាព្រះគម្ពីរ តាំងពីកណ្ឌគម្ពីរដើមដំបូង រហូតដល់ចុងបញ្ចប់ជាមិនខាន។ វិធីសាស្ត្រនៃការសិក្សាព្រះគម្ពីរដ៏ពេញលេញ កត់សម្គាល់ប្រធានបទដែលបានបង្ហាញនៅក្នុងព្រះបន្ទូល ជាជាងភ្ជាប់ព្រះបន្ទូលទៅកាន់ប្រធានបទ និងជួយឲ្យសិស្សធ្វើការកត់សម្គាល់ដំណើរនៃការសិក្សាស្រាវជ្រាវ។

## វិធីបែបល្បែងទូរសារ

តើអ្នកចាំពីល្បែងទូរសារទេ? នៅពេលដែលយើងឈរជាជួរហើយខ្សឹបនូវឃ្លាណាមួយដាក់ត្រចៀក អ្នកដែលឈរនៅក្បែរយើងនោះ? ចំណុចដែលសប្បាយគឺថា នៅពេលដែលខ្លឹមសារនៃឃ្លានោះ ចាប់ផ្តើមលែងច្បាស់ពីម្នាក់ទៅម្នាក់ ដែលពួកគេបានខ្សឹបជិតដល់អ្នកឈរខាងចុង។ ដំណើរការនេះអាចនឹងកើតឡើងដូចគ្នាផងដែរ នៅពេលដែលយើងអានសៀវភៅអំពីព្រះគម្ពីរជំនួសឲ្យការអានព្រះគម្ពីរផ្ទាល់។ ហេតុអ្វី? ពីព្រោះអ្នកនិពន្ធគឺជាអ្នកដទៃដែលបានសរសេរសៀវភៅនោះ។ នេះមិនមានអ្វីខុសទេ ជាទូទៅវាជាចំណុចសមហេតុសមផលមួយ ប៉ុន្តែវាជាចំណុចដែលសិស្សគួរតែយកចិត្តទុកដាក់។



Khmer Women of the word_Layout.indd 58 12/3/26 3:56 in the afternoon

ប្រសិនបើខ្ញុំចង់អានអ្វីមួយដែលអ្នកណាម្នាក់បានសរសេរអំពីព្រះគម្ពីរ ដើម្បីឲ្យបានអានព្រះគម្ពីរដោយផ្ទាល់។ ខ្ញុំប្រហែលអាននូវអ្វីមួយដែលអ្នកណាម្នាក់និយាយ អំពីអ្នកណាម្នាក់ដែលបាននិយាយអំពីព្រះគម្ពីរបានថែង។ ការសិក្សាអំពីប្រធានបទសៀវភៅអំពីព្រះគម្ពីរគឺមានប្រយោជន៍ ប៉ុន្តែសៀវភៅទាំងនោះមិនមែនជាមូលដ្ឋានគ្រឹះឡើយ។ ប្រសិនបើខ្ញុំបានដកសម្រង់សម្ដីរបស់លោកគ្រូ ចន ផាបភ័រ (John Piper) ច្រើនជាងសម្រង់សម្ដី ដែលខ្ញុំអាចនិយាយអំពី សាវ័ក ប៉ុល ខ្ញុំប្រហែលបានអនុវត្តនូវវិធីបែបរៀនពីអ្នកដទៃ។ ពេលខ្លះយើងមិនបានកត់សម្គាល់ទេថា យើងបានងាកចេញទៅប្រើនូវទម្រង់នេះ។ ដោយព្រោះសៀវភៅអំពីព្រះគម្ពីរ មិនតម្រូវឲ្យធ្វើការសិក្សាស្វែងយល់ច្រើនដូចព្រះគម្ពីរផ្ទាល់នោះឡើយ។ ហើយជាទូទៅសៀវភៅទាំងនោះ ត្រូវបានសរសេរឡើងដោយមនុស្ស ដែលហាក់បីដូចជាចេះដឹងជ្រៅជ្រះអំពីព្រះគម្ពីរ ជាងយើងខ្លួនឯងដែលមិនអាចធ្វើបានឡើយ។

*បញ្ហា៖* ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យស្រឡាញ់ព្រះរបស់យើង ឲ្យអស់ពីគំនិតរបស់យើង មិនមែនពីគំនិតរបស់ លោកគ្រូ ផាបភ័រ ឡើយ។ នៅពេលដែលគាត់ និងអ្នកដទៃផ្សេងទៀតបាននិយាយអំពីព្រះគម្ពីរ គឺពិតជាបានជួយយើងយ៉ាងខ្លាំង ប៉ុន្តែមិនត្រូវយកមកជំនួសឲ្យការសិក្សាព្រះគម្ពីរដោយផ្ទាល់ខ្លួនរបស់យើងឡើយ។ ហេតុអ្វីបានជាយើងត្រូវចំណាយពេលច្រើនអានអត្ថបទ ច្រើនដងដែលបានដកស្រង់ចេញពីព្រះបន្ទូល ជាជាងចំណាយពេលអានព្រះបន្ទូលដោយផ្ទាល់? យើងនឹងបានស្គាល់លោកគ្រូ ផាបភ័រ កាន់តែច្បាស់ ប្រសិនបើយើងចំណាយពេលវេលារបស់យើងទៅលើសៀវភៅដែលគាត់ស្រឡាញ់ជាងគេ។ វិធីសាស្ត្រនៃការសិក្សាព្រះគម្ពីរដ៏ពេញលេញទទួលស្គាល់អំពីសៀវភៅដែលនិយាយអំពីព្រះគម្ពីរ គឺដូចជាការសិក្សាលើប្រធានបទ គឺជាការបំពេញបន្ថែមទៅលើការសិក្សាផ្ទាល់ខ្លួន មិនមែនជាការជំនួសឲ្យការសិក្សាផ្ទាល់ខ្លួនឡើយ។ ប្រសិនបើយើងមិនកំពុងអភិវឌ្ឍន៍ការសិក្សាព្រះគម្ពីរ នោះការជួយរបស់អ្នកដទៃនឹងមានកម្រិតតិចតួចដល់យើង។ នៅពេល



Khmer Women of the word_Layout.indd 59 12/3/26 3:56 in the afternoon

ដែលយើងមានការលូតលាស់ចំណេះដឹងខាងឯព្រះគម្ពីរកាន់តែច្រើន ចំណុច ទាំងនោះនឹងក្លាយទៅជាចំណុចនៃការបំប៉ន និងការពន្យល់បន្ថែមដល់យើង កាន់តែច្រើនផងដែរ។

## វិធីបែបញ៉ាំតាមជម្រើស

ខ្ញុំបានប្រើវិធីនេះនៅពេលដែលខ្ញុំចាប់ផ្ដើមដូចជា «ការរើសចំណី» ជាមួយនឹង ព្រះបន្ទូលរបស់ព្រះ។ ខ្ញុំ អានព្រះគម្ពីរសញ្ញាថ្មី ហើយលើសពីនេះមានកណ្ឌ គម្ពីរទំនុកតម្កើង និងកណ្ឌគម្ពីរសុភាសិតផងដែរ ខ្ញុំចៀសវាងដោយមិនអាន ព្រះគម្ពីរសញ្ញាចាស់ តែបើខ្ញុំអានសៀវភៅដែលនិយាយអំពីចារឹកលក្ខណៈ ដំណើររឿង ឬក៏ប្រធានបទ នោះខ្ញុំអាចស្វែងយល់បានយ៉ាងងាយ។ ជា ពិសេសចំពោះស្ត្រីៗ យើងហាក់ដូចជាទេរទៅរកវិធីនេះ (អ្នកណាខ្លះទៀត មិន សូវមានការនឿយហត់ក្នុងការអានដូចជាកណ្ឌគម្ពីរអេសធើរ កណ្ឌគម្ពីរនាង រស់ និងកណ្ឌគម្ពីរសុភាសិតជំពូក៣១ មែនទេ?) ប៉ុន្តែ ជាការពិត គ្រប់គ្នាក៏ ត្រូវប្រឈមមុខនឹងការល្បួងនេះផងដែរ។

បញ្ហា៖ គ្រប់ទាំងបទគម្ពីរគឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាល ឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់គ្រប់ការទាំងអស់ យើងត្រូវមានតុល្យភាព នៅក្នុងការញ៉ាំអាហារ ដើម្បីឲ្យមានភាពពេញវ័យលូតលាស់—គឺដល់ពេល នៅក្នុងការទទួលអាហារគ្រប់ទាំងអស់ហើយ។ ស្ត្រីត្រូវការគំរូទាំងពីរ ពីខាង មនុស្សប្រុស និងមនុស្សស្រី ដើម្បីចង្អុលបង្ហាញពួកគេអំពីការកោតខ្លាចព្រះ ជាម្ចាស់។ យើងមិនអាចពេញចិត្តទាំងស្រុងតែទៅលើភាពផ្អែមល្ហែមនៃព្រះ គម្ពីរសញ្ញាថ្មី ដោយមិនគិតពីឱជារសនៃព្រះគម្ពីរសញ្ញាចាស់បានទេ។ យើង ត្រូវការដំណើររឿងនិទានប្រវត្តិសាស្ត្រ កំណាព្យ អក្សរសាស្ត្រនៃប្រាជ្ញា ច្បាប់ ការថ្លែងទំនាយ និងរឿងប្រៀបប្រដូចផងដែរ ទាំងអស់នេះបង្ហាញយើងអំពី លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ចេញពីអ្នកនាំសារផ្សេងៗគ្នា។ ហើយយើង ត្រូវមើលសាច់រឿងដំណឹងល្អ ចេញពីកណ្ឌគម្ពីរលោកុប្បត្តិ ទៅដល់កណ្ឌគម្ពីរ

វិវរណៈ។ វិធីសាស្ត្រនៃការសិក្សាព្រះគម្ពីរដ៏ពេញលេញ ជំរុញយើងឲ្យសិក្សាសេចក្តីណែនាំទាំងមូលនៅក្នុងព្រះបន្ទូលរបស់ព្រះ។ នោះនឹងជួយយើងនៅក្នុងការយល់ជារួម អំពីរបៀបដែលព្រះគម្ពីរ គឺជាព្រះបន្ទូលទាំងស្រុងរបស់ព្រះជាម្ចាស់។

នៅក្នុងចំណោមវិធីទាំង៦នេះ តើអ្នកធ្លាប់បានប្រើនូវវិធីណាមួយដែរឬទេ? ការទទួលស្គាល់នូវទម្លាប់មិនមានប្រយោជន៍មួយចំនួន មិនមែនជារឿងគួរឲ្យរីករាយនោះទេ ប៉ុន្តែវាគឺជាការចាប់ផ្តើមនូវ ការផ្លាស់ប្តូរដែលនាំមកនូវភាពល្អប្រសើរ។ ខ្ញុំអាចធានាបានថា ខ្ញុំបានអនុវត្តនូវវិធីទាំងនេះ ក្នុងពេលណាមួយឬពេលណាផ្សេងទៀត ដើម្បីធ្វើការស្វែងរកនូវវិធីដែលល្អប្រសើរ។ ហើយខ្ញុំទទួលស្គាល់ថា ខ្ញុំបានឮស្ត្រីជាច្រើននាក់បានប្រាប់អំពីការដែលពួកគេបានប្រើវិធីដែលដូចៗគ្នា ដែលការនោះជួយពួកគេមានភាពងាយស្រួលបន្តិច ប៉ុន្តែវាក៏មានភាពស្មុគស្មាញផងដែរ ដោយដឹងថាយើងទាំងអស់គ្នាភាគច្រើនសុទ្ធតែបានជួបនូវបញ្ហាដូចគ្នា។ ប្រសិនបើយើងមិនបានទទួលការបណ្តុះបណ្តាលអំពីរបៀបធ្វើជាសិស្សល្អក្នុងការរៀនព្រះគម្ពីរទេ វាមិនមែនជារឿងភ្ញាក់ផ្អើលឡើយ ដែលយើងត្រូវស្វែងរកវិធីងាយៗ។ ប្រសិនបើមានផ្នែកណាមួយក្នុងក្រុមជំនុំ ជាទូទៅបានអនុវត្តនូវវិធីទាំងនេះ ជាជាងមិនមានការពេញចិត្តចង់រៀនអំពីការបង្កើតសិស្ស។ នោះពួកគេមើលមិនឃើញអំពីនិមិត្តរបស់ក្រុមជំនុំក្នុងការបង្កើតសិស្សឡើយ។

ការកាត់ផ្តាច់ទម្លាប់ដែលមានជាប្រចាំគឺជាកិច្ចការដ៏លំបាក មានតែអស់អ្នកដែលជឿលើលទ្ធផល ដែលពួកគេនឹងទទួលបានចេញពីការខំប្រឹងនេះទេ ដែលឲ្យតម្លៃទៅលើការខំប្រឹងប្រែងនេះ ហើយពួកគេ ពិតជាខំប្រឹងដើម្បីបោះបង់ចោលនូវទម្លាប់នោះ។ យើងត្រូវស្គាល់ថា មានវិធីដ៏ល្អប្រសើរកំពុងតែហៅយើងឲ្យទៅរកវា។ យើងត្រូវបញ្ចូលគ្នារវាងការពេញចិត្តនៅក្នុងការសិក្សារបស់យើង ជាមួយនឹងវិធីដែលជួយបង្កើននូវចំណេះខាងឯព្រះគម្ពីរផងដែរ។ យើងត្រូវសិក្សាក្នុងរបៀបមួយដែលយើងទទួលបានការបណ្តុះបណ្តាល មិនមែន

គ្រាន់តែទទួលគំនិតរបស់អ្នកណាម្នាក់នោះទេ ប៉ុន្តែជាទូទៅគឺយើងត្រូវបានបណ្តុះបណ្តាលឲ្យចេះកាត់ស្រាយ និងអនុវត្តនូវព្រះបន្ទូលដោយខ្លួនឯង។ គ្រប់ការសិក្សាដែលយើងរៀន គួរតែទទួលបានចំណុចច្រើន ជាជាងគ្រាន់តែបង្រៀនយើងអំពីកណ្ឌដែលមាននៅក្នុងព្រះគម្ពីរ នោះគួរតែបង្រៀនយើងអំពីរបៀបសិក្សាកណ្ឌផ្សេងៗនៅក្នុងព្រះគម្ពីរដោយមានប្រសិទ្ធភាពខ្ពស់ផងដែរ។

## មូលហេតុដែលការសិក្សាព្រះគម្ពីរសំខាន់

តើអ្នកជឿទៅលើសារៈសំខាន់នៅក្នុងការប្រកាសឡើងវិញ អំពីចំណេះដឹងខាងឯព្រះគម្ពីរដែរឬទេ? សូមឲ្យខ្ញុំណែនាំនូវហេតុផលមួយចំនួន ហេតុអ្វីបានលោកអ្នកត្រូវជឿ៖ ការសិក្សាព្រះគម្ពីរសំខាន់ ពីព្រោះការសិក្សាព្រះគម្ពីរបានការពារយើងពីការធ្លាក់ចូលទៅក្នុងការខុស។ ទាំងគ្រូខុសឆ្គង និងមនុស្សបែបនិយមគឺផ្តោតទៅលើការមិនចេះគម្ពីរ ដោយផ្អែកលើសាររបស់ពួកគេក្នុងការចាក់ឫស គឺជាការមិនយកចិត្តទុកដាក់លើព្រះគម្ពីរឡើយ។ ហើយក្រុមជំនុំសម័យទំនើបបានបញ្ជាក់ឲ្យឃើញច្បាស់នូវខ្លឹមសារទាំងនោះថាត្រឹមត្រូវ។ ពីព្រោះបើយើងមិនបានស្គាល់ព្រះគម្ពីររបស់យើងទេ យើងនឹងបាត់បង់ផ្នែកដែលសំខាន់ជាងគេ នៅក្នុងការប្រឈមទៅនឹងទស្សនៈនៃពិភពលោកនេះ។ ជំនឿខុស និងភាពព្រងើយកន្តើយបានលេបយើងឲ្យចេញឆ្ងាយពីភាពលូតលាស់របស់យើង ជាពិសេសមានស្ត្រីជាច្រើនបានចាកចេញពីក្រុមជំនុំ ច្រើនដែលមិនធ្លាប់មានពីមុនមក។[៤]

នៅពេលដែលស្ត្រីមានការកើនឡើង ហើយមានភាពធូររលុងនៅក្នុងការស្វែងរកចំណេះដឹងខាងឯព្រះគម្ពីរ មនុស្សជាច្រើនដែលទទួលការជះឥទ្ធិពលពីពួកគេនឹងទទួលរងនូវផលប៉ះពាល់ជាមិនខាន។ ជាជាងការធ្វើជាអំបិល និងពន្លឺយើងបានចូលរួមរស់នៅក្នុងបរិយាកាសដែលមិនមាន ការចាប់អារម្មណ៍ និងមានលក្ខណៈហាក់ដូចជាមិនខុសប្លែកពីអ្នកដែលមិនបានផ្លាស់

៤ លោកស្រី Vorjack, “Women Leaving the Church,” Patheos, ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១, http://www.patheos.com/blogs/unreasonablefaith/2011/08/women-leaving-the-church/.



Khmer Women of the word_Layout.indd 62 12/3/26 3:56 in the afternoon

ប្រែតាមរយៈដំណឹងល្អដែរ។ ផ្ទះ ក្រុមជំនុំ សហគមន៍ និងប្រទេសជាតិ ត្រូវការចាំបាច់ណាស់នូវស្ត្រី ដែលមានឥទ្ធិពលដែលដឹងថាហេតុអ្វីបានជាពួកគេជឿ និងជឿទៅលើចំណុចអ្វីខ្លះ ដែលបានចាក់ឫសនៅក្នុងព្រះបន្ទូលរបស់ព្រះ។ ពួកគេត្រូវការខ្លាំងណាស់ចំពោះស្ត្រីដែលមានឥទ្ធិពល ដែលមានសកម្មភាព និងសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅ ចំពោះព្រះជាម្ចាស់ដែលបានប្រកាសនៅក្នុងព្រះគម្ពីរ។

ប្រហែលជាអ្នកខ្លួនឯងផ្ទាល់មិនមានការចាប់អារម្មណ៍ចំពោះព្រះគម្ពីរមានភាពសោះកក្រោះ និងងឿងឆ្ងល់ថាមកពីមូលហេតុអ្វី។ លោកអ្នកប្រហែលជាមានសំណួរអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ទៅលើចំណុចដែលអ្នកមិនមានសេចក្តីប៉ងប្រាថ្នាចង់ស្គាល់ព្រះបន្ទូលរបស់ព្រះអង្គ។ ខ្ញុំជឿថា ស្ត្រីដែលបាត់បង់នូវចំណាប់អារម្មណ៍ចំពោះព្រះគម្ពីររបស់ខ្លួន ដោយព្រោះពួកគេមិនបានទទួលការបង្រៀនឲ្យស្រឡាញ់ព្រះគម្ពីរក្នុងរបៀបដែលពួកគេគួរស្រឡាញ់។ ព្រះជាម្ចាស់ដែលជាព្រះនៃព្រះគម្ពីរគួរឲ្យស្រឡាញ់ខ្លាំងណាស់ ព្រះអង្គមិនស័ក្តិសមក្នុងការឲ្យយើងបោះបង់ និងចំណាយពេលតិចតួចក្នុងការស្វែងរកទ្រង់ឡើយ។ ខ្ញុំចង់ឲ្យស្ត្រីគ្រប់ទីកន្លែងអភិវឌ្ឍនូវសេចក្តីស្រឡាញ់ដែលនៅជាប់ និងជ្រាលជ្រៅចំពោះព្រះអង្គ តាមរយៈការសិក្សាព្រះបន្ទូលដែលជួយយើងឲ្យកាន់តែស្គាល់ទ្រង់។ នៅក្នុងជំពូកបន្ទាប់ៗ ខ្ញុំនឹងបង្ហាញអំពីរបៀបមួយចំនួនដូចតទៅៈ

សិក្សាដោយមាន**គោលបំណង**  
សិក្សាដោយមាន**ទស្សនវិស័យ**  
សិក្សាដោយមាន**ការអត់ធ្មត់**  
សិក្សាដោយមាន**លំដាប់លំដោយ**  
សិក្សាដោយមាន**ការអធិស្ឋាន**

នៅពេលដែលយើងចូលដល់ការសិក្សាឲ្យបានត្រឹមត្រូវ នោះយើងនឹងមិនមានភាពងឿងឆ្ងល់ឡើយ ក្នុងការកត់សម្គាល់ពីទំនាក់ទំនងរវាងចំណុចទាំង៥នេះ ពីចំណុចមួយទៅចំណុចមួយមិនសង្កត់ធ្ងន់ឲ្យបានតាមលំដាប់



Khmer Women of the word_Layout.indd 63 12/3/26 3:56 in the afternoon

លំដោយឡើយ។ យើងផ្តោតទៅលើគំនិត នៅពេលដែលយើងសិក្សា ប៉ុន្តែចំណុចលំដាប់លំដោយដែលយើងពិភាក្សា មិនមានទំនាក់ទំនងបង្ហាញទៅលើចំណុចមួយសំខាន់ជាងចំណុចមួយទៀតឡើយ។ យើងនឹងពិចារណាទៅលើចំណុចសំខាន់នៃការអធិស្ឋានក្រោយគេ ទោះជាយ៉ាងណាមិនមានន័យថាវាជាចំណុចសំខាន់ នៅក្នុងការសិក្សាព្រះគម្ពីរ ដោយព្រោះចំណុចនេះនៅចុងក្រោយគេ ឬថាវាជាចំណុចចុងក្រោយគេ ដែលយើងគួរអនុវត្តនោះទេ។ ចំណុចទាំងប្រាំគាំទ្រឲ្យគ្នាទៅវិញទៅមក៖ យើង អធិស្ឋានសម្រាប់ការអត់ធ្មត់ នៅក្នុងការសិក្សាឲ្យបានប្រសើរ។ ទស្សនវិស័យ និងលំដាប់លំដោយដើរទន្ទឹមគ្នា និងពឹងផ្អែកលើគ្នា ដើម្បីរក្សាការផ្តោតទៅលើគោលបំណង។ សូមចាំថាចំណុចទាំងប្រាំនេះគឺមានសារៈសំខាន់ដូចៗគ្នា និងមានទំនាក់ទំនងចំពោះគ្នាទៅវិញទៅមក។ យើងនឹងរៀបចំការពិភាក្សារបស់យើងទៅលើចំណុចនីមួយៗ ដោយចាប់ផ្តើមចេញពីចំណុចទាំងនេះម្តងមួយជាបន្តបន្ទាប់ពីចំណុចទូទៅរហូតដល់ចំណុចដែលជាក់លាក់។

ចំណុចដែលមានសក្តានុពលនីមួយៗ ទាំងនេះនឹងជួយយើងឲ្យលូតលាស់នៅក្នុងចំណេះដឹងខាងឯព្រះគម្ពីរ បង្ហាត់បង្រៀនយើងនៅក្នុងការអនុវត្តអំពី គំនិតមុនចិត្ត ព្រះជាម្ចាស់មុនខ្លួនឯង។ ដូច្នេះ តោះ! សូមចាប់ផ្តើម។

## សំណួរសម្រាប់ឆ្លុះបញ្ចាំង

១. តើនៅពេលណាដែលជាពេលចុងក្រោយដែលអ្នកមានអារម្មណ៍ដឹងថាមិនស្រួលក្នុងការខ្វះខាតចំណេះដឹងខាងឯព្រះគម្ពីរ? តើអារម្មណ៍ទាំងនេះបានដឹកនាំអ្នកឲ្យធ្វើសកម្មភាពណាមួយដែរឬទេ? ប្រសិនបើមាន ជាសកម្មភាពអ្វីដែរ?



Khmer Women of the word_Layout.indd 64 12/3/26 3:56 in the afternoon

២. តើអ្វីជាទម្លាប់អាក្រក់ដែលពិបាកបំផុតនៅក្នុងការបោះបង់ចោល? តើអ្នកកាត់ចោលទម្លាប់នោះដោយរបៀបណា? តើអ្នកប្រើរយៈពេលយូរប៉ុណ្ណាដែរ?

៣. ក្នុងចំណោមវិធីទាំង៦ នៅក្នុងការសិក្សាព្រះគម្ពីរ (វិធីបែបអំពីខ្ញុំ, វិធីចាក់គម្ពីរ, វិធីរកចម្លើយបែបវេទមន្ត, វិធីបែបទិញទំនិញសម្រាប់អ្នក, វិធីបែបល្បែងទូរសារ និងវិធីបែបញ៉ាំតាមជម្រើស) តើវិធីមួយណាដែលអ្នកបានអនុវត្តដោយផ្ទាល់? តើមានមើលឃើញចំណុចថ្មីណាមួយចេញពីវិធីទាំងនេះ បានបង្ហាញដល់អ្នកដែរឬទេ?

៤. តើអ្វីជាចំណុចភ្ជាប់រវាងវិធីដែលមិនមានប្រយោជន៍ទាំង៦នេះ និងមានអ្វីខ្លះដែលជាការចូលចិត្តរបស់យើងក្នុងការដាក់ខ្លួនឯងមុនព្រះជាម្ចាស់ ហើយដាក់ចិត្តមុនគំនិត?

៥. តើវិធីណាមួយក្នុងចំណោមវិធីទាំង៦នេះ ដែលមានគ្រោះថ្នាក់ខ្លាំងក្លាជាងគេ? តើយើងអាចប្រើក្នុងវិធីបែបណា ដើម្បីទទួលបានប្រយោជន៍?



Khmer Women of the word_Layout.indd 65 12/3/26 3:56 in the afternoon

Khmer Women of the word_Layout.indd 67 12/3/26 3:56 in the afternoon

ជំពូកទី៣

# ការសិក្សាដោយមាន គោលបំណង

តើអ្នករាល់គ្នាមិនបានដឹងទេឬ តើមិនបានឮ តើឥតមានអ្នកណា ប្រាប់ដល់អ្នករាល់គ្នាតាំងពីដើមមក តើអ្នករាល់គ្នាមិនបានយល់ សេចក្ដី តាំងពីកំណើតលោកីយ៍រៀងមកទេឬអី គឺព្រះដែលគង់ពី លើរង្វង់ផែនដី។

អេសាយ ៤០:២១-២២

កាលពីពេលដែលខ្ញុំនៅក្មេង ឪពុកខ្ញុំធ្លាប់បាននាំខ្ញុំ និងបងប្រុសខ្ញុំទៅបោះជំរុំ។ ដំបូង ខ្ញុំជឿថា យើងបានធ្វើដំណើរនេះ ដោយព្រោះតែឪពុករបស់ខ្ញុំចូលចិត្ត ធម្មជាតិ។ នៅពេលដែលខ្ញុំមានវ័យចម្រើនឡើង ខ្ញុំចាប់ផ្តើមយល់ថាអ្វីដែល ឪពុករបស់ខ្ញុំចូលចិត្តជាងគេនោះគឺការមានគ្រែដែលគេងលក់ស្រួល មាន ដំបូលដ៏រឹងមាំដែលនៅពីលើ និងការមើលព័ត៌មានពេលល្ងាចតាមទូរទស្សន៍ ដោយមិនខកខាន។ ខ្ញុំចាប់ផ្តើមយល់ដឹងអំពីហេតុផលនេះ។ ទាក់ទងទៅនឹង ការបោះជំរុំ តើមានហេតុផលអ្វីដែលយើងបានចំណាយពេលចុងសប្តាហ៍ ទៅ ខាងក្រៅញ៉ាំបាយជាមួយនឹងសម្ភារៈកំប៉ុងសំណ នៅពេលដែលឪពុករបស់ខ្ញុំ បង្ហាញឲ្យឃើញច្បាស់ថា គាត់មិនមែនជាអ្នកស្រឡាញ់ការផ្សងព្រេងនៅខាង



Khmer Women of the word_Layout.indd 67 12/3/26 3:56 in the afternoon

ក្រៅនោះទេ? នៅពេលដែលខ្ញុំខ្លួនឯងបានក្លាយជា (ឪពុក) ម្តាយ ហេតុផលនេះបង្ហាញឲ្យខ្ញុំឃើញកាន់តែច្បាស់ថា៖ ឪពុកខ្ញុំបាននាំយើងទៅបោះជំរុំមិនមែនដោយព្រោះគាត់ចូលចិត្តការបោះជំរុំនោះទេ គាត់បាននាំពួកយើងទៅបោះជំរុំដោយព្រោះគាត់ស្រឡាញ់យើងវិញ។ ខ្ញុំកាន់តែមើលឃើញ និងយល់គោលបំណងរបស់គាត់ច្បាស់ គាត់ស៊ូគ្រចិត្តជាមួយនឹងភាពមិនងាយស្រួលផ្សេងៗដោយការប្រើទឹកបាញ់សម្លាប់មូស និងស្នឹងសម្រាប់រឹតតង់ឲ្យតឹង។

គ្រប់ការខិតខំប្រឹងប្រែងគួរតែធ្វើដោយមានគោលបំណង។ បើមិនមានគោលបំណងច្បាស់លាស់ទេ ការខិតខំព្យាយាមធ្វើឲ្យបានល្អអាចនឹងមិនមានសណ្តាប់ធ្នាប់។ ដោយមានគោលបំណងច្បាស់លាស់ នោះវានឹងធ្វើឲ្យយើងកាន់តែមានការតស៊ូ។ នេះគឺពិតប្រាកដណាស់សម្រាប់ការកសាងចំណេះដឹងព្រះគម្ពីរ គឺត្រូវការកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងវា ប៉ុន្តែការរក្សានូវគោលបំណងដ៏ច្បាស់លាស់ទ្រទ្រង់ការខំរបស់យើង។ តើយើងអាចចាប់ផ្តើមនូវគោលបំណងដ៏ច្បាស់លាស់នៅក្នុងរបៀប ដែលយើងនឹងចូលទៅក្នុងការសិក្សាព្រះគម្ពីរយ៉ាងដូចម្តេច?

ជាក់ស្តែងណាស់ ប្រហែលជាយើងអាចនិយាយថា យើងគួរតែសិក្សាព្រះគម្ពីរដោយមានគោលបំណង។ ប្រាកដណាស់ យើងទាំងអស់គ្នាមានគោលបំណងមួយចំនួននៅក្នុងគំនិតរបស់យើង នៅពេលយើងចាប់ផ្តើមសិក្សាព្រះគម្ពីរ យើងបានកត់សម្គាល់ពីរ បីចំណុចផងដែរនៅក្នុងជំពូកមុន៖ គឺជួយឲ្យយើងមានអារម្មណ៍ច្បាស់លាស់ ជួយយើងនៅក្នុងការសម្រេចចិត្ត ជួយយើងក្នុងការស្វែងយល់អំពីខ្លួនយើង។ ប៉ុន្តែ នៅក្នុងគំនិតរបស់យើង យើងចង់បាននូវគោលបំណងដែលព្រះគម្ពីរផ្ទាល់មានបំណងចង់ឲ្យយើងមាន។ គោលបំណងតូចជាងហ្នឹងមិនអាចទៅរួចបានទេ។

យើងបានពិចារណាដឹងហើយថា ព្រះគម្ពីរគឺនិយាយអំពីព្រះជាម្ចាស់ ប៉ុន្តែឥឡូវសូមពិចារណាទៅលើសេចក្តីពិតនៅក្នុងទម្រង់មួយដែលជាក់លាក់ជាងនេះទៅទៀត។ ដោយចាប់ផ្តើមពីកណ្ឌគម្ពីរលោកុប្បត្តិ ទៅដល់កណ្ឌគម្ពីរ



Khmer Women of the word_Layout.indd 68 12/3/26 3:56 in the afternoon

វិវរណៈ គឺព្រះគម្ពីរប្រាប់យើងអំពីព្រះរាជ្យ និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ នេះគឺជារូបភាពធំនៃព្រះគម្ពីរ ជាគោលបំណងនៃការសរសេរព្រះគម្ពីរឡើង នៅក្នុងកណ្ឌគម្ពីរទាំង៦៦កណ្ឌ។ កណ្ឌនីមួយៗមានចំណែកនៅក្នុងការប្រាប់អំពីរូបភាពធំ—សាច់រឿងអំពីការបង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ និងការស្តារឡើងវិញ។ គោលបំណងនៃព្រះគម្ពីរគឺប្រាប់យើងអំពីរូបភាពធំនៅក្នុងសាច់រឿងតូចៗជាច្រើនរាប់ពាន់រឿង ចាប់តាំងពីទំព័រដំបូងរហូតដល់ទំព័រចុងក្រោយបង្អស់។

ជាបន្តបន្ទាប់គ្នា គោលបំណងរបស់យើងនៅក្នុងការសិក្សាព្រះគម្ពីរ ត្រូវតែស្វែងរករូបភាពធំនោះ គ្រប់ពេលដែលយើងចូលទៅកាន់ព្រះបន្ទូលរបស់ព្រះអង្គ។ យើងគួរតែសិក្សាដោយសួរសំណួរមិនគ្រាន់តែទៅលើផ្នែកខ្លះៗនៃព្រះបន្ទូលដែលចង់ប្រាប់យើងប៉ុណ្ណោះទេ ប៉ុន្តែតើផ្នែកនៃព្រះបន្ទូលនោះបានប្រាប់យើងអំពីរូបភាពធំនៃព្រះគម្ពីរជាលក្ខណៈទាំងមូលដែរឬទេ។ ការសិក្សាព្រះគម្ពីរដោយមានគោលបំណងមានន័យថា យើងត្រូវរក្សានូវខ្លឹមសារឲ្យមើលឃើញគ្រប់ពេល មិនថាយើងកំពុងអានកណ្ឌគម្ពីរសញ្ញាចាស់ ឬសញ្ញាថ្មី មិនថាតើយើងកំពុងអានកណ្ឌហោរា ឬក៏កណ្ឌដំណឹងល្អនោះទេ។ ដើម្បីអាចធ្វើការនេះបានយើងត្រូវមើលរូបភាពធំចេញពីសៀវភៅតូចនីមួយៗ ឬក៏ខ្លឹមសារណាមួយ ហើយធ្វើការស្វែងយល់ឲ្យឃើញពីរបៀបដែលព្រះគម្ពីរបានលាតត្រដាងអំពីផ្នែកដើម្បីឲ្យមើលឃើញនូវរូបភាពធំនោះ។

## អ្វីដែលសំបុត្រយន្តហោះបានបង្រៀនខ្ញុំ

ខ្ញុំទទួលបានការយល់ដឹងកាន់តែច្បាស់ អំពីគោលការណ៍នៃរូបភាពធំនេះនៅក្នុងពេលវិស្សមកាល។ ពេលវិស្សមកាលភាគច្រើនសម្រាប់ក្រុមគ្រួសារយើងគឺចំណាយពេល១០ម៉ោងក្នុងការបើកឡានពីទីក្រុង ដាឡាស់ តិចសាស់ (Dallas, Texas) ទៅកាន់ទីក្រុង សាន់តា ហ្វេ ញូ មិចស៊ីកូ (Santa Fe, New Mexico) ដើម្បីចំណាយពេលជាមួយជីដូនជីតាយើង។ យើងចាប់



Khmer Women of the word_Layout.indd 69 12/3/26 3:56 in the afternoon

ផ្តើមស្គាល់ និងដឹងជាមួយនឹងទំនៀមទម្លាប់នៃការធ្វើដំណើរនេះ—ឈប់ញ៉ាំកាហ្វេនៅទីក្រុង វិឈីតា ហ្វលស៍ (Wichita Falls) អាហារថ្ងៃត្រង់នៅទីក្រុង អាម៉ារីឡូ (Amarilo) អាហារសម្រន់នៅទីក្រុង ធូខុមខារី (Tucumcari)។ ទេសភាពនៅតាមផ្លូវបើកបរពីកន្លែងមួយទៅកន្លែងមួយ គឺពិតជាអស្ចារ្យណាស់ ហើយកូនៗរបស់ខ្ញុំស្គាល់យ៉ាងច្បាស់ពីទីកន្លែងដែលខ្ញុំនឹងប្រាប់ពួកគេឲ្យចុះទៅលេង និងបត់ដៃបត់ជើងផងដែរ។ ប្តីរបស់ខ្ញុំស្រឡាញ់ការមើលផែនទី ហើយគាត់មានភាពច្បាស់លាស់ នៅក្នុងការមើលអំពីទីតាំងភូមិសាស្ត្រ ការផ្លាស់ប្តូរការមើលឃើញអំពីទេសភាពនៃចំណុចទាំងនោះតែងតែគួរឲ្យចាប់អារម្មណ៍៖

"យើងកំពុងនៅឯទីវាលខាងត្បូង...."

"យើងចាប់ផ្តើមចូលដល់ច្រកភ្នំនៃទន្លេក្រហម (Red River Valley)..."

"ឥឡូវ យើងនឹងឡើងទៅលើ ឡៀនន្ទ អេសតាខាដូ (Liano Estacado)..."

"យើងចុះមកដល់ មេសាលេនស៍ (Mesalands)..."

ចំណុចដែលប្តីរបស់ខ្ញុំបានដឹងយ៉ាងពិស្តារពីចំណុចទាំងនេះតែងតែអស្ចារ្យណាស់សម្រាប់ខ្ញុំ។ លោកគ្រូផ្នែកភូមិសាស្ត្ររបស់គាត់នៅថ្នាក់វិទ្យាល័យគួរតែសប្បាយចិត្តខ្លាំងជាមួយនឹងការនេះ។ ចំពោះខ្ញុំ វាពិតជាគួរឲ្យអាណិតណាស់សម្រាប់ការមិនយល់ដឹង៖ ខ្ញុំមិនស្គាល់អំពីភូមិសាស្ត្រ ពីព្រោះខ្ញុំមិនបានរៀនអំពីផ្នែកភូមិសាស្ត្រឡើយ។

ដូច្នេះ រហូតដល់ពេលដែលខ្ញុំបានជិះយន្តហោះទៅសាន់តា ហ្វេ ខ្ញុំចាប់ផ្តើមកោតសរសើរចំពោះប្តីរបស់ខ្ញុំយ៉ាងខ្លាំងនូវអ្វីដែលគាត់បានដឹង។ នៅពេលយើងហោះឡើង ហើយបត់ទៅខាងលិច ខ្ញុំបានដឹងថាខ្ញុំកំពុងមើលឃើញទីវាលខាងត្បូងលាតសន្ធឹងនៅខាងក្រោមខ្ញុំ កាត់ទទឹងដោយច្រកភ្នំទន្លេក្រហមមានពេញទៅដោយវល្លិ ឡៀនន្ទ អេសតាខាដូ។ ខ្ញុំបានឃើញម្រាមដៃនៃដីទំនាបឈោងឆ្ពោះទៅកាន់ភ្នំនៅខាងជើង។ ខ្ញុំបានឃើញទិដ្ឋភាព



Khmer Women of the word_Layout.indd 70 12/3/26 3:56 in the afternoon

ចោះៗដែលមើលពីលើមកដូចជាសត្វចាប រឿងដែលខ្ញុំបានដឹងមានតម្លៃសម្រាប់ផ្នែកខ្លះប៉ុណ្ណោះ ហើយរំពេចនោះគ្រប់រូបភាពដ៏អស្ចារ្យពីកន្លែងមួយទៅកន្លែងមួយ ដែលយើងបានឃើញចេញពីការដែលបើកបរនេះបានផ្គុំចូលគ្នាលេចចេញនូវទេសភាព ហើយពិតជាគួរឲ្យអស្ចារ្យណាស់។ការមើលឃើញដែលខ្ញុំទទួលបាននៅពេលខ្ញុំកំពុងហោះហើរនោះ បានផ្លាស់ប្តូរខ្ញុំជារៀងរហូតអំពីរបៀបដែលខ្ញុំដឹងនៅពេលបើកបរ។ សម្រាប់តម្លៃសំបុត្រយន្តហោះនេះកូនៗរបស់ខ្ញុំមិនមែនទទួលបានតែការជិះមួយមុខទេ ពួកគេមានឪពុកម្តាយពីរនាក់ និយាយពីនេះពីនោះអំពីទីតាំងភូមិសាស្ត្រ អស់១០ម៉ោងសម្រាប់វិស្សមកាលរបស់យើងម្តងៗ។

## រូបភាពធំៗនៃព្រះគម្ពីរ

ព្រះគម្ពីរក៏មានទីតាំងភូមិសាស្ត្រ រៀបចំឡើងដោយផ្ទាល់នូវទីតាំង «ភូមិសាស្ត្រសំខាន់ៗ» ដែលត្រូវគ្នាក្នុងការផ្គុំនូវទ្រង់ទ្រាយនៃទេសភាពពីមួយទៅមួយ ហើយអស្ចារ្យ។ ប៉ុន្តែ យើងភាគច្រើនមិនដែលបានទិញសំបុត្រយន្តហោះជិះក្នុងការស្វែងយល់នូវទ្រង់ទ្រាយទាំងនោះទេ។ យើងភាគច្រើន បន្ទាប់ពីបានចូលរួមក្នុងក្រុមជំនុំជាច្រើនឆ្នាំ មិនស្គាល់ពីភូមិសាស្ត្រទេ ពីព្រោះតែយើងមិនបានរៀនអំពីភូមិសាស្ត្រនោះ។ យើងដឹងនៅពេលដែលយើងឃើញអ្វីមួយស្រស់ស្អាតនៅលើទំព័រណាមួយក្នុងព្រះបន្ទូល ប៉ុន្តែជានិច្ចកាលយើងមិនបានដឹងពីរបៀបដែលវាមានភាពស៊ីគ្នាជាមួយនឹងសាច់រឿងទាំងមូលក្នុងព្រះគម្ពីរឡើយ។ យើងមានការយល់ដឹងអំពីព្រះបន្ទូល គឺមានលក្ខណៈជាផ្នែកៗ តគ្នាជាលំដាប់លំដោយ «នៃចំណេះដឹង» បានជំរុញទឹកចិត្តយើងយ៉ាងជ្រៅ ប៉ុន្តែមិនសំខាន់ក្នុងការភ្ជាប់ជាមួយគ្នា ដើម្បីបង្ហាញឲ្យឃើញរូបភាពធំឡើយ។

បើមិនមានរូបភាពធំទេ នោះយើងយល់បានតែផ្នែកខ្លះប៉ុណ្ណោះ ទាក់ទងទៅនឹងអ្វីដែលមានក្នុងរូបភាពនីមួយៗដែលរូបនោះកំពុងព្យាយាមប្រាប់



Khmer Women of the word_Layout.indd 71 12/3/26 3:56 in the afternoon

យើង។ ពីកណ្ឌគម្ពីរលោកុប្បត្តិ ដល់កណ្ឌគម្ពីរវិវរណៈ ព្រះគម្ពីរបានប្រាប់យើងអំពីព្រះរាជ្យ និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ ទីតាំងភូមិសាស្ត្រនៃព្រះគម្ពីរនិយាយអំពី ការបង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ និងការស្តារឡើងវិញ ក្នុងគ្រប់ទីកន្លែងទាំងអស់។ លក្ខណៈភូមិសាស្ត្រនៃរូបភាពធំគឺមនុស្សបានសរសេរខុសៗគ្នាទៅតាមប្រភេទដូចជា—ប្រវត្តិសាស្ត្រ ដំណើររឿងនិទាន កំណាព្យ អក្សរសាស្ត្រនៃប្រាជ្ញា ក្រឹត្យវិន័យ ទំនាយ រឿងប្រៀបប្រដូច និងកណ្ឌសំបុត្រ—ទាំងអស់រួមបញ្ចូលគ្នាដើម្បីពង្រីកការយល់ដឹងរបស់យើងទាក់ទងទៅនឹងព្រះរាជ្យ និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ តាមវិធីផ្សេងៗគ្នា។

ផ្នត់គំនិតនៃរូបភាពធំគឺពន្យល់នូវរឿងតូចៗជាច្រើន ដែលមិនមែនមានតែមួយនៅក្នុងព្រះគម្ពីរ។ អ្នកប្រាជ្ញបានហៅថាជា ដំណើររឿងធំៗ—ការពន្យល់ដ៏ក្បោះក្បាយ ឬប្រធានបទគោលទាំងនោះ នឹងបង្ហាញអំពីប្រធានបទផ្សេងៗទៀតនៅក្នុងព្រះបន្ទូល។ ដំណើររឿងធំៗគឺមានលក្ខណៈសំខាន់សម្រាប់សាច់រឿងដែលនិយាយអំពីរឿងដែលជាចំណុចកណ្តាល និងពន្យល់អំពី «រឿងតូច» នៅជុំវិញនោះ។ ដំណើររឿងធំនៃរឿង ហ្គន់វីដដឺវ៉ាញ (Gone with the Wind) របស់អ្នកស្រី ម៉ាហ្គារេត មីតឆែល (Margaret Mitchell) ជាដំណើររឿងដែលនិយាយអំពីការគាបសង្កត់ ការផ្លាស់ប្តូរ និងការទុកចិត្តខ្លួនឯង។ រូបភាពធំនៃរឿងប្រលោមលោកនេះគឺ ប្រាប់យើងអំពីមនុស្សជនជាតិដើមនៃប្រទេសអង់គ្លេសផ្សេងៗគ្នា បានបង្ហាញតាមរយៈសាច់រឿងនីមួយៗនៃលក្ខណសម្បត្តិតួអង្គក្នុងសៀវភៅ។

ក្នុងនាមជាអ្នកថែសួនម្នាក់ ខ្ញុំមិនអាចជួយអ្វីបាន ក្រៅពីគិតអំពីសាច់រឿងធំតាមរបៀបការថែសួន។ ដូចដំណើររឿងធំនៅក្នុងព្រះគម្ពីរផ្នែកមួយនៃការបង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ ការស្តារឡើងវិញ ដំណើររឿងធំៗរបស់អ្នកថែសួនគឺជា សាច់រឿងអំពីរដូវរងា រដូវស្លឹកឈើលាស់ រដូវក្តៅ និងរដូវស្លឹកឈើជ្រុះ។ គ្រប់រុក្ខជាតិ និងដើមឈើនៅក្នុងទីធ្លារបស់ខ្ញុំប្រាប់

អំពីសាច់រឿងផ្ទាល់របស់វានីមួយៗតាមរយៈ ផ្កា ផ្លែឈើ និងស្លឹកឈើ ប៉ុន្តែរឿងនីមួយៗទាំងនោះគឺចង្អុរបង្ហាញទៅកាន់សាច់រឿងធំនៃការឆ្លងពីរដូវមួយទៅរដូវមួយទៀត។ ប្រសិនបើខ្ញុំមិនមានការយល់ដឹងទាក់ទងនឹងរដូវកាលទេ ខ្ញុំប្រហែលជាឆ្ងល់ថា ហេតុអ្វីដើមឈើរបស់ខ្ញុំភ្លាមៗនោះក្លាយទៅជាពណ៌លឿង ជំនួសឲ្យពណ៌បៃតងទៅវិញ។ ខ្ញុំប្រហែលជាយល់ខុសអំពីការផ្លាស់ប្តូរនេះ ថាជាសញ្ញានៃការមានជំងឺ ជាជាងការបង្ហាញឲ្យដឹងថាវាជាសរទៈរដូវដែលស្លឹកឈើងាប់។ ពីព្រោះខ្ញុំបានយល់អំពីដំណើររឿងធំនៃការមើលថែសួន ខ្ញុំនឹងមិនទៅរកប៉េងប៉ោះនៅក្នុងទីធ្លារបស់ខ្ញុំក្នុងរដូវត្រជាក់ឡើយ ឬក៏ទៅរកមែកផ្កាម្លិះដែលរីកនៅក្នុងរដូវស្លឹកឈើជ្រុះដែរ។ ខ្ញុំអាចបកស្រាយពីចំណុចដើមឈើនីមួយៗបាន គឺវាបង្ហាញឲ្យឃើញតាមរដូវកាលដែលយើងកំពុងរស់នៅ ហើយខ្ញុំក៏អាចមើលដើមឈើទាំងនោះ អំពីសញ្ញានៃដំណើររឿងធំអ្វីផ្សេងបន្ទាប់ទៀត កើតឡើងទាក់ទងនឹងដំណាំសួនច្បារនេះដែរ។

ការដាច់ចេញអំពីដំណើររឿងធំនៃព្រះគម្ពីរអាចផ្តល់ឲ្យយើងនូវចំណុចជាច្រើនដូចអ្នកថៃសួន ដែលខកខានក្នុងការយល់ដឹងអំពីពណ៌នៃស្លឹកឈើថាជាសញ្ញាសរទៈរដូវ ជាជាងគិតថាជាសញ្ញានៃការមានជំងឺ។ នៅពេលយើងមិនយល់ច្បាស់អំពីរូបភាពធំ នោះយើងអាចនឹងពិបាកក្នុងការស្វែងរកនិរន្តរភាពរវាងព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី។ យើងអាចមានបញ្ហា មិនអាចភ្ជាប់ចូលទៅក្នុងព្រះគម្ពីរសញ្ញាចាស់បានឡើយ។ យើងប្រហែលបកស្រាយខុសអំពីគោលបំណង និងការសង្កត់ធ្ងន់ទៅលើសាច់រឿងតូចៗ ពីព្រោះយើងចាត់ទុកថាសាច់រឿងតូចៗគឺជាផ្នែកមួយដែលមិនមានទំនាក់ទំនងទៅនឹងរូបភាពធំ។

ដូច្នេះ សូមគិតពីរបៀបដំណើររឿងធំៗនៃការបង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ និងការស្តារឡើងវិញ ដែលបង្ហាញចេញជារូបភាពធំដែលដឹកនាំ និងប្រាប់អំពីសាច់រឿងតូចៗជាច្រើន។ តាមរយៈកញ្ចក់បង្អួចយន្តហោះ យើងអាចមើលចុះមកនូវទេសភាពនៃព្រះគម្ពីរ និងកត់សម្គាល់ថា នោះ



Khmer Women of the word_Layout.indd 73 12/3/26 3:56 in the afternoon

ជាសាច់រឿងនៃការបង្កើត ដែលបង្ហាញនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក១-២។ ព្រះជាម្ចាស់បង្កើតគ្រប់អ្វីៗទាំងអស់សម្រាប់សិរីល្អរបស់ព្រះអង្គ ដែលមានសណ្ដាប់ធ្នាប់តាមលំដាប់លំដោយ។ ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់។ កណ្ឌគម្ពីរលោកុប្បត្តិ ជំពូក៣ បានណែនាំអំពីការធ្លាក់ក្នុងអំពើបាប៖ មនុស្សព្យាយាមដណ្ដើមយកអំណាចរបស់ព្រះជាម្ចាស់ ហើយជាលទ្ធផលធ្វើឲ្យទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះជាម្ចាស់បានបាក់បែក ដែលនោះក៏បាននាំឲ្យចក្រវាលទាំងមូលបានបាក់បែកខូចខាត។ ប្រធានបទនៃការប្រោសលោះត្រូវបានបង្ហាញភ្លាមៗនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ៣:១៥ ដោយមានសេចក្ដីសន្យានៃសេចក្ដីសង្គ្រោះតាមរយៈនាង អេវ៉ា។ កណ្ឌគម្ពីរលោកុប្បត្តិ និងកណ្ឌគម្ពីរនិក្ខមនំទាំងមូលបានបង្ហាញផែនការនៃការប្រោសលោះជារូបរាង តាមរយៈមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើស គឺពូជពង្សរបស់ លោក អ័ប្រាហាំ ដែលជាប្រជាជាតិអ៊ីស្រាអែល។ ប្រធានបទនៃការប្រោសលោះគឺត្រូវបានបង្ហាញឲ្យឃើញពេញព្រះគម្ពីរសញ្ញាចាស់ទាំងមូល តាមរយៈផ្នែកផ្សេងៗគ្នា ដែលចុងបញ្ចប់ចង្អុរទៅកាន់ការប្រោសលោះដ៏ឥតខ្ចោះ តាមរយៈកិច្ចការដែលព្រះយេស៊ូវបានធ្វើនៅលើឈើឆ្កាង ហើយក៏បានប្រាប់យើងឡើងវិញនៅក្នុងដំណឹងល្អ និងបង្ហាញតាមរយៈកណ្ឌសំបុត្រ។ ព្រះគម្ពីរសញ្ញាថ្មីបានពង្រឹង និងពង្រីកការយល់ដឹងរបស់យើងអំពីការប្រោសលោះ ហើយធានាអះអាងចំពោះយើងអំពីការសង្គ្រោះ ដែលបានធ្វើសម្រេច ហើយទទូចឲ្យយើងដេញតាមការញែកចេញជាបរិសុទ្ធ ហើយលើកទឹកចិត្តយើងឲ្យមានសេចក្ដីសង្ឃឹមអំពីសិរីល្អនាពេលអនាគត។ នៅក្នុងកណ្ឌគម្ពីរវិវរណៈ យើងឃើញការស្ដារឡើងវិញ អំពីសណ្ដាប់ធ្នាប់នៅក្នុងចក្រវាល៖ ព្រះជាម្ចាស់នឹងស្ដារឡើងវិញនូវសណ្ដាប់ធ្នាប់ដ៏ល្អឥតខ្ចោះ ជាមួយនឹងការបង្កើតផ្ទៃមេឃថ្មី និងផែនដីថ្មី។

ការស្គាល់កណ្ឌគម្ពីរជាក់លាក់នៅក្នុងព្រះគម្ពីរដែលផ្សារភ្ជាប់ជាមួយនឹងរូបភាពធំ គឺមានសារៈសំខាន់ណាស់ ហើយប្រធានបទផ្នែកនីមួយៗនៃការ



Khmer Women of the word_Layout.indd 74 12/3/26 3:56 in the afternoon

បង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ ការស្តារឡើងវិញក៏បានបង្ហាញនៅក្នុងសាច់រឿងតូចៗនៃព្រះគម្ពីរផងដែរ នៅក្នុងការបូកផ្សំចំណុចផ្សេងៗបញ្ចូលគ្នា។ ការងាររបស់យើងពេលដែលកំពុងសិក្សា គឺត្រូវស្វែងរកចំណុចប្រធានបទទាំងនេះ។

## តើដំណើររឿងធំៗសម្រួចការយល់ដឹងរបស់យើងយ៉ាងដូចម្តេច?

ឥឡូវ សូមគិតពីរឿងលោក ណូអេ នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ។ យើងទាំងអស់គ្នាបានដឹងអំពីសាច់រឿងលោក ណូអេ និងទូកធំថាជាសាច់រឿងអំពីវីរបុរសនៃសេចក្តីសុចរិត ដែលបានសាងសង់ទូកទៅតាមអ្វីដែលព្រះជាម្ចាស់បានបង្គាប់បញ្ជា ដើម្បីសង្គ្រោះមនុស្សជាតិតាមរយៈការស្តាប់បង្គាប់របស់គាត់។ ប៉ុន្តែ សូមកត់ចំណាំអំពីការដែលដំណើររឿងធំនេះបាននាំឲ្យយើងអានរឿងនេះក្នុងកម្រិតដ៏ជ្រៅមួយទៀត។ តាមរយៈការបង្ហាញចេញពីសាច់រឿងធំ សាច់រឿងលោក ណូអេ គឺជារឿងនៃការបង្កើតឡើងវិញ ដែលព្រះជាម្ចាស់បានបង្កើតផែនដីឡើងវិញឲ្យបានដូចជាលក្ខណៈដើមដំបូង ដែលមិនមានរបៀបរៀបរយ និងបន្ទាប់មកក៏មានសណ្តាប់ធ្នាប់ឡើងវិញដូចគ្នាទៅនឹងអ្វីៗដែលមាននៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក១។ ព្រះជាម្ចាស់បានបំបែកទឹកចេញពីដីស្ងួត ស្តារឡើងវិញនូវរុក្ខជាតិសព្វសារពើ និងមនុស្សដែលជាស្នាព្រះហស្តថ្មីរបស់ព្រះអង្គ។ ហើយព្រះអង្គដាក់ចេញនូវបញ្ជាជាថ្មីម្តងទៀតឲ្យបានលូតលាស់ និងចម្រើនកើនឡើង។ សាច់រឿងរបស់លោក ណូអេ ក៏ជារឿងនៃការប្រោសលោះដែរ នៅពេលដែលលោក ណូអេ បង្ហាញយើងឲ្យឃើញជាមុនអំពីព្រះគ្រីស្ទ។ ជាបាវបម្រើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់ ដែលស្ម័គ្រចិត្តបិទខ្ទប់នៅក្នុងទូកធំ (អាចនិយាយបានថាដូចជាផ្នូរ) ដោយព្រះជាម្ចាស់ ហើយបានអណ្តែតនៅលើទឹកដែលបានបំផ្លិចបំផ្លាញ និងអាចនិយាយបានថាឆ្ពោះទៅរកជីវិតថ្មី។ សាច់រឿងលោក ណូអេ ក៏អាចជារឿងនៃ ការធ្លាក់ក្នុងអំពើបាប



Khmer Women of the word_Layout.indd 75 12/3/26 3:56 in the afternoon

ផងដែរ។ គឺនៅពេលដែលយើងរៀបនឹងប្រកាសថាលោក ណូអេ គឺជាមនុស្សសុចរិតល្អឥតខ្ចោះ គាត់បែរជាទៅស្រវឹងស្រា ហើយគេងអាក្រាតកាយគួរឲ្យអាម៉ាស់នៅក្នុងតង់របស់គាត់។ ការនេះរម្លឹកយើងថា មានមនុស្សតែម្នាក់គត់ដែលល្អឥតខ្ចោះនៅក្នុងសេចក្ដីសុចរិត ដែលអាចជួយសង្គ្រោះយើងបាន។ សម្រាប់យើងទាំងអស់គ្នារឿងលោក ណូអេ ប្រហែលមានអត្ថន័យចេញឆ្ងាយពីចំណុចយោងទៅរករូបភាពធំ ប៉ុន្តែនៅពេលដែលយើងភ្ជាប់សាច់រឿងនេះទៅរូបភាពធំ នោះរឿងតូចមួយនេះបង្ហាញឲ្យឃើញចំណុចស៊ីជម្រៅ និងអត្ថន័យពេញលេញ ដែលសាច់រឿងនេះមានបំណងចង់ប្រាប់យើង។ ទាក់ទងទៅនឹងដំណើររឿងធំៗ រឿងលោក ណូអេ បានក្លាយជាចំណុចផ្ដោតនៃសាច់រឿងអំពីព្រះជាម្ចាស់៖ ព្រះជាម្ចាស់បានបង្កើតព្រះអង្គបានបង្គាប់បញ្ជាព្រះអង្គបានសង្គ្រោះជីវិត ព្រះអង្គបានប្រទានអ្នកជួយសង្គ្រោះ ហើយមានតែព្រះជាម្ចាស់មួយអង្គគត់ដែលអាចជួយសង្គ្រោះបាន។

សូមគិតអំពីរឿងប្រៀបប្រដូចនៃរឿងសាសន៍សាម៉ារីដែលមានចិត្តសប្បុរស ដែលបង្ហាញយើងអំពីដំណើររឿងធំ។ ជារឿយៗ យើងបានរៀនអំពីសាច់រឿងនេះ គឺជារឿងនិទានទាក់ទងទៅនឹងលក្ខណសម្បត្តិសីលធម៌ ដែលជំរុញយើងឲ្យមានចិត្តសប្បុរសទៅកាន់អ្នកដទៃ បើទោះជាពេលខ្លះមិនមានលក្ខណៈងាយស្រួលដល់យើងក៏ដោយ។ ប៉ុន្តែ តើព្រះយេស៊ូវចង់បញ្ជាក់អំពីដំណើររឿងធំនេះយ៉ាងដូចម្ដេច នៅពេលដែលព្រះអង្គបានបង្កើតរឿងប្រៀបប្រដូចនេះ? រឿងសាសន៍សាម៉ារីដែលមានចិត្តសប្បុរសគឺជារឿងដែលបង្ហាញអំពីប្រធានបទម្ដងទៀតអំពីការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ និងការស្ដារឡើងវិញ។ គឺជា សាច់រឿងអំពីបុរសម្នាក់ដែលមិនត្រូវបានរាប់រកពីពួកសាសន៍យូដា (សាសន៍សាម៉ារី) បានជួយសង្គ្រោះជីវិតបុរសម្នាក់ដែលអាចនឹងស្លាប់បាន ប្រសិនបើមិនមានការជួយយកអាសាពីគាត់ (បុរសដែលដេកនៅដងផ្លូវ) ។ បុរសសាសន៍សាម៉ារីនេះគ្មានការចាំបាច់អ្វីដែលត្រូវចូលទៅធ្វើអន្តរាគមន៍ជួយទេ ប៉ុន្តែគាត់បានជួយដោយចំណាយលុយផ្ទាល់ខ្លួនរបស់



Khmer Women of the word_Layout.indd 76 12/3/26 3:56 in the afternoon

គាត់អស់យ៉ាងច្រើន ហើយបន្តជួយថែរក្សាដល់បុរសដែលខ្វះខាតនោះ ដោយសន្យាថានឹងត្រឡប់មកទូទាត់បញ្ជីចំណាយដែលជំពាក់ថែមទៀត។ សូមមើលពីទំនាក់ទំនងទៅកាន់ដំណើររឿងធំ រឿងប្រៀបប្រដូចអំពីសាសន៍សាម៉ារីដែលមានចិត្តសប្បុរស គឺជាសាច់រឿងអំពីព្រះជាម្ចាស់៖ ព្រះជាម្ចាស់បានបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយ ដែលគេបានបដិសេធមិនទទួល ឲ្យមកជួយសង្គ្រោះយើងឲ្យរួចពីបាបដ៏ជាក់ច្បាស់របស់យើង ហើយស្តារអ្វីៗទាំងអស់ឡើងវិញ។

តើព្រះបានត្រាស់ហៅយើងទាំងអស់គ្នាដូចលោក ណូអេ ដែរឬទេ? គឺពិតណាស់។ តើព្រះបានត្រាស់ហៅយើងដូចសាសន៍សាម៉ារីដែលមានចិត្តសប្បុរសដែរឬទេ? ប្រាកដណាស់។ ប៉ុន្តែ មិនមែនដោយព្រោះតែពួកគេជាគំរូវិជ្ជមាន ដើម្បីជំរុញយើងឲ្យប្រព្រឹត្តសេចក្តីសុចរិតនោះទេ។ សាច់រឿងទាំងនេះចង្អុរបង្ហាញយើងទៅកាន់ព្រះគ្រីស្ទ។ ចង្អុរបង្ហាញយើងទៅកាន់រូបភាពធំនៃការគ្រប់គ្រង និងព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ ដោយបើកសម្តែងឲ្យយើងមើលឃើញខ្លួនឯងនៅក្នុងទំនាក់ទំនងទៅកាន់ព្រះជាម្ចាស់។ ចំណេះដឹងក្នុងការស្គាល់ព្រះជាម្ចាស់ និងចំណេះដឹងក្នុងការស្គាល់អំពីខ្លួនយើងត្រូវធ្វើដំណើរទៅស្របគ្នា៖ យើងមើលឃើញសេចក្តីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានបង្ហាញដល់យើងតាមរយៈសាច់រឿងទាំងពីរនេះ ហើយយើងបានឆ្លើយតបដោយស្រែកអំពាវនាវទូលសូមនូវព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានផ្តល់ឲ្យយើងនៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទដែរ៖ គឺរំដោះយើងឲ្យរួចផុតពីរលកនៃសេចក្តីក្រោធដ៏ច្រើនលើសលប់ និងសង្គ្រោះយើងឲ្យរួចពីសេចក្តីស្លាប់ ដែលយើងសមនឹងទទួល។

ប៉ុន្តែ ចុះចំណែកកណ្ឌគម្ពីរផ្សេងៗទៀត ឬក៏ផ្នែកខ្លះនៃព្រះគម្ពីរដែលមិនមែនបែបជាការនិទានរឿង ឬក៏ឈុតសាច់រឿងខ្លី? ក្រឹត្យវិន័យ កំណាព្យ អក្សរសាស្ត្រនៃប្រាជ្ញា និងកណ្ឌទំនាយ ដែលទាំងអស់នេះក៏និយាយអំពីដំណើររឿងធំៗផងដែរ។ នៅក្នុងជំពូក៤ យើងនឹងពិនិត្យមើលពីរបៀបចូលទៅកាន់



Khmer Women of the word_Layout.indd 77 12/3/26 3:56 in the afternoon

ផ្នែកនីមួយៗឲ្យបានកាន់តែស៊ីជម្រៅថែមទៀត ប៉ុន្តែសម្រាប់ពេលនេះសូមមើលចំណុចទាំងនេះដោយសង្ខេប (និងលក្ខណៈទូទៅសិន) ក្នុងការមើលឃើញដំណើររឿងធំៗនៃការបង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ និងការស្តារឡើងវិញ៖

**ក្រឹត្យវិន័យ៖** ព្រះគម្ពីរបានកត់ត្រាក្រឹត្យវិន័យរបស់ព្រះជាម្ចាស់សម្រាប់យើងទាំងអស់គ្នា ដើម្បីឲ្យយើងអាចយល់អំពីសេចក្តីត្រូវការរបស់យើងសម្រាប់ការប្រោសលោះ តាមរយៈព្រះគ្រីស្ទ។ ហើយក៏បានបង្ហាញដល់អ្នកជឿអំពីរបៀបស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយមានការចង្អុរបង្ហាញតាមរយៈលក្ខណសម្បត្តិតួអង្គ និងការត្រាស់ហៅយើងឲ្យមានលក្ខណៈដូចរូបអង្គទ្រង់។ ដោយហេតុនោះការចាប់ផ្តើមដំណើរការនៃការស្តារឡើងវិញ នូវលក្ខណៈរូបអង្គព្រះដែលបានបាត់បង់គឺនៅក្នុងការធ្លាក់ក្នុងអំពើបាប ។

**កំណាព្យ៖** កំណាព្យនៅក្នុងព្រះគម្ពីរផ្តើមចេញពីការទួញសោកទៅកាន់ព្រះពរ ទៅកាន់ចម្រៀងនៃការសរសើរ ទៅកាន់ការថ្លែងទំនាយ។ អ្នកនិពន្ធបានប្រើភាសានៃកំណាព្យ និងរូបភាពផ្សេងៗនៅក្នុងព្រះបន្ទូល ដើម្បីសង្កត់ធ្ងន់ ឬពង្រឹងផ្នែកណាមួយនៃដំណើររឿងធំ។ ដូចជាកណ្ឌគម្ពីរ ទំនុកតម្កើងជំពូក២៣ ដែលយើងបានស្គាល់ ជំពូកនោះចង្អុរបង្ហាញទៅកាន់ការប្រោសលោះ និងការស្តារឡើងវិញ។ ការឆ្លើយតបដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ទៅកាន់សំណួរលោក យ៉ូប ជំពូក (៣០-៤០) ក៏បានចង្អុរបង្ហាញទៅកាន់ការបង្កើត និងការធ្លាក់ចុះ។

**អក្សរសាស្ត្រនៃប្រាជ្ញា៖** ដូចជាក្រឹត្យវិន័យដែរ អក្សរសាស្ត្រនៃប្រាជ្ញាមានរបៀបនៅក្នុងការបង្ហាញយើងអំពីចន្លោះនៅក្នុងការញែកយើងជាបរិសុទ្ធ និងដាស់តឿនយើងឲ្យឆ្លើយតបនៅក្នុងការស្តាប់បង្គាប់។ ហើយក៏បានចង្អុរបង្ហាញអំពីសេចក្តីត្រូវការរបស់យើងសម្រាប់ការប្រោសលោះ និងដំណើរការនៃការស្តារឡើងវិញ នៅក្នុងជីវិតរបស់អ្នកដែលជឿព្រះអង្គ។

**ទំនាយ៖** នៅពេលយើងសិក្សាអំពីការថ្លែងទំនាយ យើងមើលឃើញថាព្រះជាម្ចាស់ពិតជាធ្វើនូវអ្វីដែលព្រះអង្គបានមានបន្ទូលមែន។ សូមសង្កេតមើល



Khmer Women of the word_Layout.indd 78 12/3/26 3:56 in the afternoon

> ដោយយកចិត្តទុកដាក់អំពីការសម្រេចនូវបទទំនាយ នៅក្នុងកណ្ឌគម្ពីរដានីយ៉ែល ឬក៏កណ្ឌគម្ពីរអេសាយ គឺបានចង្អុរបង្ហាញយើងឆ្ពោះទៅរកភាពប្រាកដប្រជា ដែលបទទំនាយទាំងអស់នោះមិនទាន់បានសម្រេចនៅឡើយទេ តែនឹងសម្រេចចេញជារូបរាងយ៉ាងពិតប្រាកដផងដែរ។ ការថ្លែងទំនាយគឺចង្អុរបង្ហាញទៅកាន់ដំណើររឿងធំ ដោយហេតុដូច្នេះ «ការប្រោសលោះបានសម្រេចហើយ និងការស្តារឡើងវិញគឺពិតប្រាកដ»។

ប្រសិនបើយើងរៀន ដើម្បីផ្សារភ្ជាប់ខ្លឹមសារនៃព្រះបន្ទូលទៅកាន់ដំណើររឿងធំមានការងាយស្រួលដូចជាទិញសំបុត្រយន្តហោះទៅកាន់សាន់តា ហ្វេ Santa Fe នោះពិតជាអស្ចារ្យណាស់។ ការកំណត់សម្គាល់ដំណើររឿងធំក្នុងពេលដែលយើងសិក្សា មិនមែនកើតឡើងដោយងាយស្រួលឡើយ—វាគឺជាជំនាញនៃការសិក្សាដែលទាមទារពេលវេលា និងការអនុវត្តន៍ដើម្បីឲ្យការនោះកើតឡើងបាន។ គ្រប់ទាំងជំនាញថ្មីៗតម្រូវឲ្យមានការបត់បែននៅក្នុងការសិក្សា។ នៅពេលដែលអ្នកចាប់ផ្តើមសិក្សាដោយមាន គោលបំណង—ជាមួយនឹងការមើលឃើញនូវរូបភាពធំ—សូមអនុញ្ញាតឲ្យខ្លួនឯងរៀនបត់បែនដែរ នៅពេលដែលភ្នែករបស់អ្នកធ្វើការសម្របទៅនឹងការសិក្សាដែលមានប្រសិទ្ធិភាពនេះ។ មិនយូរមិនឆាប់ នោះអ្នកនឹងចេះដាក់បញ្ចូលគ្នានៅចំណុចដែលជាលក្ខណៈបុគ្គលនៃការសិក្សារបស់អ្នកចូលទៅក្នុងការយល់ដឹង ដែលផ្តុំជាមួយការស្វែងយល់អំពីគោលបំណងរបស់ព្រះជាម្ចាស់ ចាប់តាំងពីកណ្ឌគម្ពីរលោកុប្បត្តិដល់កណ្ឌគម្ពីរវិវរណៈ។

## សំណួរសម្រាប់ឆ្លុះបញ្ចាំង

១. យោងតាមអ្វីដែលអ្នកបានរៀននៅក្នុងជំពូក៣ សូមឲ្យអត្ថន័យអំពីរូបភាពធំនៃព្រះគម្ពីរ ទៅតាមការយល់ឃើញរបស់អ្នកផ្ទាល់។

២. នៅខាងក្រោមនេះគឺផ្នែកសំខាន់ៗនៃដំណើររឿងធំៗ សូមកត់សម្គាល់រឿងណាមួយ ឬក៏អត្ថបទណាមួយ សូមគិតអំពីចម្លើយដែលអ្នកអាចឆ្លើយបានទៅលើផ្នែកនៃរូបភាពធំទាំងនេះ។

ការបង្កើត

ការធ្លាក់ក្នុងអំពើបាប

ការប្រោសលោះ

ការស្តារឡើងវិញ

៣. សូមធ្វើការឆ្លុះបញ្ចាំងទៅលើខ្លឹមសារនេះ «ចំណេះដឹងក្នុងការស្គាល់ព្រះជាម្ចាស់ និងចំណេះដឹងក្នុងការស្គាល់អំពីខ្លួនយើងត្រូវធ្វើដំណើរទៅស្របគ្នា»។ នៅពេលដែលយើងមើលអំពីចំណេះរបស់ខ្លួន យើងដោយមិនមានព្រះជាម្ចាស់ជាចំណុចយោងរបស់យើង តើយើងកំពុងប្រៀបធៀបខ្លួនយើងទៅកាន់អ្វី ឬទៅកាន់អ្នកណា? តើអ្វីជាលទ្ធផល? តើការប្រៀបធៀបខ្លួនយើងទៅកាន់ព្រះជាម្ចាស់នឹងទទួលបានចំណេះដឹងដ៏ពិតអំពីខ្លួនយើងយ៉ាងដូចម្តេច?

៤. តើផ្នែកណាមួយនៃព្រះគម្ពីរ (ការនិទានរឿង ក្រិត្យវិន័យ កំណាព្យ អក្សរសាស្ត្រនៃប្រាជ្ញា ឬទំនាយ) ដែលអ្នកគិតថាមានការពិបាកខ្លាំងនៅក្នុងការសិក្សាកន្លងមក? តើគំនិតអំពីដំណើររឿងធំ ជួយអ្នកនៅក្នុងការសិក្សាផ្នែកនេះក្នុងពេលអនាគតយ៉ាងដូចម្តេច?



Khmer Women of the word_Layout.indd 80 12/3/26 3:56 in the afternoon

៥. តើផ្នែកណាមួយនៃព្រះគម្ពីរ (ការនិទានរឿង ក្រិត្យវិន័យ កំណាព្យ អក្សរសាស្ត្រនៃប្រាជ្ញា ឬទំនាយ) ដែលអ្នកគិតថាមានការងាយស្រួលយល់? តើគំនិតអំពីដំណើររឿងធំ ធ្វើការផ្លាស់ប្តូរ ឬក៏ជួយអ្នកឲ្យសិក្សាកាន់តែស៊ីជម្រៅលើផ្នែកនេះ ក្នុងពេលអនាគតយ៉ាងដូចម្តេច?



Khmer Women of the word_Layout.indd 81 12/3/26 3:56 in the afternoon

Khmer Women of the word_Layout.indd 82 12/3/26 3:56 in the afternoon

ជំពូកទី៤

# ការសិក្សាដោយមាន ទស្សនវិស័យ

«ដូច្នេះគ្រប់អស់ទាំងអាចារ្យណាដែលមានគេបង្ហាត់បង្រៀន ឲ្យធ្វើជាសិស្សនៃនគរស្ថានសួគ៌ នោះធៀបដូចជាចៅកែម្នាក់ដែលបញ្ចេញរបស់ទាំងថ្មី ទាំងចាស់ពីឃ្លាំងរបស់ខ្លួន»

ម៉ាថាយ ១៣:៥២

ការរៀនសូត្រណែនាំខ្លួនយើងអំពីដំណើររឿងធំៗនៅក្នុងព្រះគម្ពីរ ផ្ដល់ឲ្យយើងនូវគោលបំណងច្បាស់លាស់សម្រាប់ការសិក្សារបស់យើង៖ ដើម្បីសម្លឹងមើលទៅកាន់ព្រះរាជ្យ និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលបានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ នោះនឹងធ្វើឲ្យយើងមានការយល់ដឹងអំពីកន្លែងរបស់យើងនៅក្នុងរូបភាពធំ។ នៅពេលដែលយើងបានធ្វើការសម្រេចចិត្តអំពីគោលបំណងរបស់យើង ទៅលើផ្នែកទូទៅទាំងនេះហើយ យើងក៏បានត្រៀមនៅក្នុងការពិចារណាទៅលើចំណុចទី២ នៃការសិក្សាដែលត្រឹមត្រូវនេះផងដែរ៖ នោះគឺជា ទស្សនវិស័យ។ យើងប្ដូរការសួរសំណួរពី “តើអ្វីជាគម្រោងទូទៅសម្រាប់ព្រះគម្ពីរទាំងមូល?” ទៅជា “តើអ្វីជាគម្រោងជាក់លាក់នៃផ្នែកព្រះគម្ពីរដែលខ្ញុំកំពុងសិក្សានេះ?”។

សូមគិតម្តងទៀតអំពីការធ្វើដំណើររបស់ខ្ញុំទៅកាន់ទីក្រុង សាន់តា ហ្វេ អាម៉ារីឡូ តិចសាស់ ជាចំណុចពាក់កណ្តាលផ្លូវរបស់ពួកយើង ដូច្នេះជារឿយៗយើងឈប់នៅទីនោះដើម្បីប្រញាប់ញ៉ាំអាហារថ្ងៃត្រង់។ ប្រសិន បើអ្នកមិនដែលបានទៅទីក្រុង តិសសាស់ ផានហានដល (Texas Panhandle) ទេ សូមឲ្យខ្ញុំប្រាប់ថាវាមិនមែនជាកន្លែងដែលប្រាកដថា មានសួនច្បារទាំងស្រុងឡើយ។ ទីក្រុង អាម៉ារីឡូ ជាកន្លែងមួយដែលមានធំក្លិនឧស្ម័នមេតាន ហើយនៅចម្ងាយផ្លូវប្រហែល៨ម៉ែត្រ គឺជាផ្លូវដែលបើកបរដោយសេរី ពីព្រោះតែការដាក់ទីតាំងនៃទីធ្លានោះមិនត្រូវចំកន្លែង។ ទីតាំងភូមិសាស្ត្រគឺសោះកក្រោះ និងរាបស្មើ។ ប្រសិន បើទីក្រុង អាម៉ារីឡូ ជាកណ្ឌសៀវភៅមួយក្នុងព្រះគម្ពីរវិញគឺ ប្រហែលជាកណ្ឌសៀវភៅលេវីវិន័យហើយ៖ សម្រាប់អ្នកដែលបានធ្វើដំណើរឆ្លងកាត់ទីក្រុង អាម៉ារីឡូ គឺពិបាកនៅក្នុងការគិតថា ហេតុអ្វីម្នាក់ៗមិនចង់ស្នាក់នៅទីនោះឲ្យបានយូរ។ ប៉ុន្តែ នៅពេលដែលខ្ញុំបានចំណាយពេលស្នាក់នៅក្នុងទីក្រុង អាម៉ារីឡូ នោះខ្ញុំយល់ឃើញថាវាគឺជាទីកន្លែងមួយដែលមានវប្បធម៌ និងប្រវត្តិសាស្ត្រផ្ទាល់ខ្លួនផងដែរ។ កសិដ្ឋានចិញ្ចឹមគោ ចម្ការដែលមានខ្យល់បក់ល្វឹងល្វើយនៅទីក្រុង ផាឡូ ឌូរ៉ូ ខេនយ៉ាន (Palo Duro Canyon) និងប៊ីក ថេកសេន ស្ទេក រេនឆ (Big Texan Steak Ranch) (ផ្ទះដែលផ្តល់ឲ្យនូវសាច់គោ ២ គីឡូ ដោយឥតគិតថ្លៃ)។ នៅពេលដែលខ្ញុំចំណាយពេលនៅទីក្រុង អាម៉ារីឡូ កាន់តែយូរ ខ្ញុំចាប់ផ្តើមពេញចិត្តចំពោះរតនសម្បត្តិក្នុងស្រុកនោះកាន់តែច្រើនផងដែរ។ ខ្ញុំពិតជាមិនចង់ចាកចេញពីទីនោះឡើយ។

ចំណុចទាំងនេះគឺមានលក្ខណៈដូចគ្នាទៅនឹងព្រះគម្ពីរផងដែរ។ មិនមែនគ្រាន់តែកណ្ឌគម្ពីរទាំង៦៦កណ្ឌនៃព្រះគម្ពីរប៉ុណ្ណោះទេ ដែលបាននិយាយសាច់រឿងទាំងស្រុង ប៉ុន្តែកណ្ឌនីមួយៗនៃកណ្ឌគម្ពីរទាំង៦៦ នោះគឺបានប្រាប់សាច់រឿងផ្ទាល់តាមរយៈកណ្ឌគម្ពីរនោះផងដែរ លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់នឹងបង្ហាញឲ្យយើងឃើញតាមរយៈការឆ្លុះបញ្ចាំងមើលទៅលើចំណុច



Khmer Women of the word_Layout.indd 84 12/3/26 3:56 in the afternoon

ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលជាក់លាក់។ ការឆ្លុះមើលបែបនេះផ្តល់ឲ្យយើងនូវទស្សនវិស័យដ៏សំខាន់ ដែលយើងត្រូវការក្នុងការជួយយើងឲ្យបានយល់អំពីអត្ថបទព្រះបន្ទូលឲ្យបានត្រឹមត្រូវ។ ប្រសិន បើយើងបានចំណាយពេលក្នុងការសិក្សាវប្បធម៌ និងប្រវត្តិសាស្ត្រ ទស្សនវិស័យនៃកណ្ឌសៀវភៅក្នុងព្រះគម្ពីរ នោះយើងនឹងមានការយល់ដឹងកាន់តែច្បាស់អំពីរបៀបកាត់ស្រាយ និងចេះឲ្យតម្លៃទៅលើការនោះផងដែរ។ ប៉ុន្តែ តើយើងសិក្សាជាមួយនឹងទស្សនវិស័យដែលត្រឹមត្រូវបានយ៉ាងដូចម្តេច? ដើម្បីធ្វើបាន គឺយើងត្រូវក្លាយទៅជាអ្នកបុរាណវត្ថុជាមុនសិន។

## ប្រវត្តិសាស្ត្រដែលជីកគាស់ពីក្នុងដី

ទីក្រុងរ៉ូមបានកកើតឡើងតាំងពីសតវត្សទី៨ មុនគ្រិះសករាជ ជាការពិតប្រជាជនដែលរស់ក្នុងសម័យទំនើបពិតជាបានដឹងយ៉ាងច្បាស់អំពីការនេះ។ ប្រសិន បើអ្នកមានផ្ទះនៅទីក្រុងរ៉ូមក្នុងសម័យពេលបច្ចុប្បន្ន ប្រវត្តិសាស្ត្រនឹងត្រូវបានបញ្ចូលទៅលើគម្រោងកែលម្អនៃផ្ទះនោះដោយឯកឯង ដែលតម្រូវឲ្យមានការជីកគាស់វត្ថុបុរាណនៅទីនោះ។ នេះ ដោយព្រោះក្រុងរ៉ូមសម័យបច្ចុប្បន្នបានសាងសង់ពីលើក្រុងរ៉ូមសម័យពីបុរាណ។ នៅផ្នែកខាងក្រោមនៃទីក្រុងដែលមានការមមាញឹកនេះ គឺមានពេញទៅដោយប្រាសាទបុរាណ កន្លែងងូតទឹក អាគារសាធារណៈ និងទីកន្លែងផ្សេងៗបានរលាយចេញបាត់ពីរូបភាព ហើយផ្នែកផ្សេងៗច្រើនទៀតភាគច្រើនមិនទាន់ខូចខាតនៅឡើយទេ។ ជាច្រើនសតវត្សមកហើយ ទីក្រុងរ៉ូមបានសាងសង់ពីលើគម្រោងដែលមានស្រាប់ ពេលខ្លះគ្រាន់តែបំពេញសំណង់នោះបន្ថែមជាមួយដីខ្លះៗ ដើម្បីធ្វើឲ្យសំណង់នោះមានគ្រឹះដែលសមស្របជាមួយនឹងសំណង់ថ្មី។ ជាលទ្ធផលគឺទីក្រុងនៅពីលើទីក្រុង កន្លែងនេះបន្តិចកន្លែងនោះបន្តិច សសរដែលសល់តាំងពីបុរាណបានលយចេញពីទីក្រុងដែលមានគ្រឹះនាសម័យបច្ចុប្បន្ននេះ ដោយបង្ហាញឲ្យឃើញពីអ្វីដែលមាននៅផ្ទៃខាងក្រោម។ អ្នកបុរាណវត្ថុបានពិនិត្យ



Khmer Women of the word_Layout.indd 85 12/3/26 3:56 in the afternoon

មើលផែនទីក្រុងរ៉ូម (Roma Subterranea) ដែលនៅខាងក្រោមយ៉ាងល្អិតល្អ—«ក្រុងរ៉ូមដែលនៅក្រោមដី»—គឺជាកិច្ចខិតខំប្រឹងប្រែងក្នុងការរក្សាទុកកំណត់ត្រាពីបុរាណកាល ដែលកំពុងរលាយបាត់ទៅនោះ ពិភពលោកនាសម័យបច្ចុប្បន្ន ពិតជាបានទទួលស្គាល់នូវតម្លៃរបស់វាយ៉ាងពិតប្រាកដ។

ដូច្នេះ នៅពេលម្ចាស់ផ្ទះនៅក្នុងសម័យទំនើបនៃទីក្រុងរ៉ូម ចង់ធ្វើការកែប្រែជាថ្មីដែលតម្រូវក្នុងការ ជីកគាស់ គឺមិនមានការលើកលែងឡើយ ក្នុងការហៅអ្នកបុរាណវត្ថុឲ្យមកមើលត្រួតពិនិត្យសិន។ ទីក្រុងរ៉ូមមិនអនុញ្ញាតឲ្យប្រជាពលរដ្ឋរបស់ខ្លួនធ្វើការជីកគាស់ ដោយមិនគិតគូរទៅលើផលប្រយោជន៍ដ៏មានតម្លៃដែលពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រឡើយ។ អាគារទាំងអស់នៅក្នុងសម័យទំនើបបច្ចុប្បន្នត្រូវតែសាងសង់ជាមួយនឹងការយកចិត្តទុកដាក់ដោយទទួលស្គាល់ថា អ្នកស្រុករបស់ខ្លួនដែលរស់នៅក្នុងពេលបច្ចុប្បន្ន គឺនៅក្នុងបរិបទដែលមាន ចំនួនច្រើន ជាងអ្នកដែលមករស់នៅទីនោះក្នុងរយៈពេលខ្លី។ រស់នៅក្នុងទីក្រុងរ៉ូមមានន័យថាយើងគោរព ដល់អ្នកស្រុកដែលរស់នៅដើមដំបូង ដែលចូលទៅរស់នៅក្នុងទីកន្លែងទំនើបៗ ហើយក៏រក្សានូវទស្សនពី បុរាណផងដែរ។ សេចក្តីល្បួងនៅក្នុងការលួចសាងសង់ទីលំនៅជាសម្ងាត់ដែលអាចរស់នៅបានងាយស្រួល ដោយមិនបាច់ផ្តល់ព័ត៌មានឲ្យបានត្រឹមត្រូវទៅកាន់ទីភ្នាក់ងារ នោះគឺពិតជាខ្លាំងក្លាណាស់។ បំណងប្រាថ្នា នៅក្នុងការនិយាយថា «តើខ្ញុំមិនអាចសាងសង់ទីលំនៅទៅតាមអ្វីដែលខ្ញុំចូលចិត្តទេឬ?» ពិតជាអស្ចារ្យណាស់។ មានតាំងពីអតីតកាលមកម្ល៉េះនៅទីនោះសម្រាប់ការជីកគាស់ ប៉ុន្តែមានតែប្រជាពលរដ្ឋដែល មានការយល់ឃើញអំពីទីតាំងប្រវត្តិសាស្ត្រទីក្រុងរ៉ូមប៉ុណ្ណោះ ដែលទំនងជាកាន់ខ្ជាប់ជាមួយនឹងច្បាប់រដ្ឋ តឹងរ៉ឹងនៃការសាងសង់នេះ។

ប្រជាជនទីក្រុងរ៉ូមនាសម័យបច្ចុប្បន្នក៏ដូចគ្នាទៅនឹងគ្រីស្ទបរិស័ទនាសម័យបច្ចុប្បន្នដែរ គឺត្រូវដោះស្រាយជាមួយនឹងការយល់ដឹងនៃព្រះគម្ពីររបស់ពួកគេ ឲ្យមានការយល់ដឹងកាន់តែច្រើនដូចគ្នាផងដែរ។ គ្រីស្ទបរិស័ទសម័យ

ទំនើបគ្រងមរតកនៃសេចក្ដីជំនឿ តាមរយៈការសាងសង់លើគ្រឹះ ដែលបានសាងសង់ពីមុនមក។ យើងក៏ត្រូវរស់នៅក្នុងសម័យទំនើប ខណៈពេលក៏រក្សាទិដ្ឋភាពបុរាណ។ ចំណុចដើមដំបូងនៃអត្ថបទព្រះគម្ពីរនេះ ត្រូវបានសរសេរក្នុងអំឡុងឆ្នាំ ១៥០០ មុនគ.ស. ជាភាសាដែលយើងមិនចេះនិយាយ ហើយទៅកាន់មនុស្សដែលរស់នៅមានលក្ខណៈខុសប្លែកពីយើង។ ប៉ុន្តែ យើងភាគច្រើនជ្រើសរើសសាងសង់ការយល់ដឹងព្រះបន្ទូល នាសម័យទំនើបរបស់យើង ដោយមិនបានគិតដល់បរិបទប្រវត្តិសាស្ត្រ និងវប្បធម៌ដែលជាផ្ទៃខាងក្រោមនោះឡើយ គឺបរិបទដែលសំខាន់សម្រាប់ការយល់ដឹងដ៏ត្រឹមត្រូវ និងជាការអនុវត្តន៍សម្រាប់គ្រប់សារនៃព្រះបន្ទូល។ សេចក្ដីល្បួងនៅក្នុងការអនុវត្តព្រះគម្ពីរឲ្យសមស្របទៅនឹងបទពិសោធន៍នាបច្ចុប្បន្ន ដោយមិនមានការរក្សានូវទំនាក់ទំនងរបស់វាទៅកាន់អ្នកស្ដាប់ដើមដំបូង នោះគឺងាយស្រួលណាស់។ បំណងប្រាថ្នានៅក្នុងការនិយាយថា «តើខ្ញុំមិនអាចអាននូវព្រះបន្ទូលអ្វីដែលចាត់ទុកថាសរសេរមកកាន់ខ្ញុំទេឬ?» នោះក៏ងាយស្រួលធ្វើដែរ។ ប្រវត្តិសាស្ត្រព្រះគម្ពីរ និងបរិបទវប្បធម៌នៅទីនោះគឺសម្រាប់ឲ្យយើងជីកគាស់ ប៉ុន្តែគឺមានតែអស់អ្នកដែលជឿដែលបានគិតអំពីទីកន្លែង ប្រវត្តិសាស្ត្រនៃការប្រោសលោះប៉ុណ្ណោះ ដែលទំនងជាជីកគាស់យ៉ាងយកចិត្តទុកដាក់។

## ការជីកគាស់សម្រាប់ទស្សនវិស័យ

វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលឡើយដែលព្រះគម្ពីរបានប្រៀបធៀប ការរកបានប្រាជ្ញា ដូចជាការស្វែងរកមាស ប្រាក់ និងទ្រព្យសម្បត្តិដែលបានកប់ទុក។ ដើម្បីទទួលបានរបស់ទាំងបីយ៉ាងនេះ យើងត្រូវការការជីកគាស់។ ហើយ ការជីកគាស់គឺជាការងារធ្ងន់ ជាពិសេសគឺនៅពេលដែលយើងធ្វើឡើងជាមួយនឹងការគោរពទៅដល់ប្រវត្តិសាស្ត្រ និងបរិបទវប្បធម៌។ យើងរស់នៅក្នុងពេលវេលាដែលព្រះគម្ពីរភាគច្រើនត្រូវ បានចាត់ទុកថាជាសៀវភៅសម្រាប់ការអប់រំខ្លួន តាមរយៈការដែលគិតថាព្រះវិញ្ញាណបរិសុទ្ធនឹង បង្ហាញសេចក្ដី

ពិតយ៉ាងងាយ ទៅកាន់អស់អ្នកដែលស្ម័គ្រចិត្តឲ្យពេលវេលាក្នុងការចាប់អារម្មណ៍ ពីរបីនាទី ក្នុងមួយថ្ងៃ។ នៅក្នុងផ្នត់គំនិតនាសម័យទំនើបសាច់ដុំនៃប្រាជ្ញាដែលជីដូនជីតានៃជំនឿធ្លាប់បានប្រើក្នុងការជីកគាស់ពីមុន បានវិវឌ្ឍន៍ទៅរកភាពទ្រុឌទ្រោមអស់។ មិនមានមនុស្សច្រើនទេដែលស្ម័គ្រចិត្តចង់ធ្វើការធ្ងន់នៅក្នុងការជីកគាស់ ការចូលចិត្តរស់នៅក្នុងសម័យទំនើប ហើយធ្វើការស្វែងយល់ព្រះគម្ពីរដោយមិនគិតអំពីអ្នកស្តាប់ដើមដំបូង ឬក៏គោលបំណងនោះដូចជាគ្រាន់តែធ្វើឲ្យការអានក្នុងសម័យទំនើបរបស់យើងឆ្លើយតបទៅនឹងគោលបំណងរបស់យើងប៉ុណ្ណោះ។ ពីព្រោះយើងខ្វះនូវការយល់ដឹងថាយើងតូចប៉ុណ្ណា នៅក្នុងទម្រង់នៃប្រវត្តិសាស្ត្រដ៏ធំធេងនេះ យើងមានភាពវៃឆ្លាតនៅក្នុងការគេចវេសអនុវត្តនូវអ្វីដែលត្រឹមត្រូវនៃ «ការហៅអ្នកបុរាណវត្ថុ» ជួយយើងក្នុងការជីកគាស់ឲ្យបានត្រឹមត្រូវនៅពេលដែលយើងអាន និងសិក្សាព្រះគម្ពីរ។ យើងត្រូវការទស្សនវិស័យពីចាស់បុរាណ ហើយដើម្បីឲ្យទទួលបានទស្សនវិស័យនោះ គឺយើងត្រូវការជីកគាស់រក។

អ្នកប្រាជ្ញបានហៅដំណើរការនោះថា ការជីកគាស់រកអត្ថន័យដើមនៅក្នុងការពន្យល់លំអិតអំពីអត្ថបទ។ យើងគ្រប់គ្នាគឺជាលទ្ធផលនៃពេលវេលា និងវប្បធម៌ដែលយើងកំពុងរស់នៅក្នុងហេតុដូច្នេះយើង បាននាំយកមកភាពលំអៀងទៅលើការអានព្រះគម្ពីររបស់យើង។ ហេតុដូច្នេះ ហើយអត្ថបទដែលជាក់លាក់ បានធ្វើឲ្យយើងមានបញ្ហាខ្លាំង នៅពេលដែលយើងអានព្រះបន្ទូលនោះលើកដំបូង ដូចជាអត្ថបទជាទូទៅ គឺកណ្ឌគម្ពីរលេវីវិន័យទាំងមូលតែម្តង។ ការពន្យល់លំអិតបានរុញច្រានចំណុចព្រំដែននៃការយល់ដឹងផ្ទាល់ខ្លួនរបស់យើងទៅលើប្រវត្តិសាស្ត្រ និងវប្បធម៌ នាំយើងឲ្យត្រឡប់ទៅក្រោយទៅកាន់ពេលវេលាដែលអត្ថបទ នោះបានសរសេរ និងឮខ្លឹមសារនោះជាមួយនឹងត្រចៀកនៃអ្នកស្តាប់ដើមដំបូង។ ការពន្យល់លំអិតបានលើកឡើងថា «មុនពេលអ្នកឮអត្ថបទនោះជាមួយនឹងត្រចៀករបស់អ្នក សូមឮជាមួយត្រចៀករបស់ពួកគេជាមុនសិន។ សូមយល់ខ្លឹមសារកាលពីពេលកន្លងនៅសម័យ



Khmer Women of the word_Layout.indd 88 12/3/26 3:56 in the afternoon

នោះសិន មុនពេលអ្នកយល់ខ្លឹមសារក្នុងពេលបច្ចុប្បន្ននេះ។» ចំណុចនេះវាបានឲ្យយើងគិតអំពីទស្សនវិស័យរបស់អ្នកនិពន្ធ និងអ្នកស្តាប់របស់គាត់តាំងពីដំណាក់កាលនៃដើមដំបូងរបស់អ្នកនិពន្ធ។ ការពន្យល់លំអិតបានធ្វើឲ្យយើងក្លាយទៅជាអ្នកបុរាណវត្ថុ បានច្រើនតាម ដែលយើងអាចធ្វើបាន ហើយធ្វើការហៅសុំជំនួយបានច្រើន តាមដែលអ្នកបុរាណវត្ថុអាចធ្វើទៅបាន នៅកន្លែងណាដែលយើងត្រូវការពួកគាត់។ វាជួយយើងឲ្យមានទស្សនវិស័យដែលយើងត្រូវការ នោះគឺការកាត់ស្រាយ ព្រះបន្ទូលឲ្យបានត្រឹមត្រូវ។ ការនេះធ្វើបានតាមរយៈការសួរសំណួរជាមូលដ្ឋាន៥សំណួរ នៃអ្នកបុរាណវត្ថុសម្រាប់គ្រប់អត្ថបទទាំងអស់៖

១. អ្នកណាជាអ្នកសរសេរ?

២. សរសេរឡើងនៅពេលណា?

៣. សរសេរទៅកាន់អ្នកណា?

៤. តើសរសេរក្នុងប្រភេទបែបយ៉ាងដូចម្តេច?

៥. ហេតុអ្វីបានមានការសរសេរឡើង?

ប្រសិន បើពេលនេះអ្នកមានអារម្មណ៍ថា អ្នកដូចជាបានត្រឡប់ទៅកាន់វិទ្យាល័យថ្នាក់ភាសាអង់គ្លេស គឺពិតណាស់ នេះជារបៀបដែលខ្ញុំចង់ឲ្យអ្នកមានអារម្មណ៍។ តើជឿឬមិនជឿយើងមិនចាំបាច់ទៅចូលរួមសាលាព្រះគម្ពីរដើម្បីរៀនពីរបៀបនៃការពន្យល់លំអិតអំពីអត្ថបទឡើយ។ នៅថ្នាក់វិទ្យាល័យយើងប្រហែលជា បានរៀននូវជំនាញមួយចំនួន។ ផ្នែកនៃការបកស្រាយការសិក្សាព្រះគម្ពីរឲ្យយល់ច្បាស់គឺបានទទួលស្គាល់នូវ គោលការណ៍ជាមូលដ្ឋាននៃការកាត់ស្រាយខាងអក្សរសាស្ត្រ ដែលអាចអនុវត្តបានជាមួយគ្រប់សៀវភៅទាំងអស់។ សូម្បី តែព្រះគម្ពីរក៏មានការរួមបញ្ចូលដែរ បើយើងមានការពិបាកច្រើននៅក្នុងសិក្សាព្រះគម្ពីររបស់យើង នោះអាចជាសញ្ញាឲ្យដឹងថា យើងក៏មានការពិបាកជាមួយថ្នាក់ភាសាអង់គ្លេសរបស់យើងនៅវិទ្យាល័យដែរ ហើយយើងពិតជាស្ទាក់ស្ទើរក្នុងការចាត់ទុកថាព្រះគម្ពីរដូចជា



Khmer Women of the word_Layout.indd 89 12/3/26 3:56 in the afternoon

អក្សរសាស្ត្រ។ សូមឲ្យខ្ញុំបញ្ជាក់នូវចំណុចពីរយ៉ាងនេះ៖

១. ការរាប់ព្រះគម្ពីរថាជាអក្សរសាស្ត្រមិនបន្ថយអត្ថន័យឡើយ។

២. សមត្ថភាពរបស់អ្នកនៅក្នុងការយល់ដឹងព្រះគម្ពីរ នឹងកាន់តែប្រសើរឡើងយ៉ាងច្រើន ប្រសិនបើអ្នកចាត់ទុកព្រះគម្ពីរតាមរបៀបនោះ។

ការហៅថា អក្សរសាស្ត្រព្រះគម្ពីរ ជាទូទៅទទួលស្គាល់ថាវាមានទំនាក់ទំនងជាមួយខ្លឹមសារតាមរយៈអ្នកនិពន្ធដែលជាមនុស្សលោក ទៅកាន់អ្នកស្តាប់ដែលជាមនុស្សលោកនៅក្នុងទម្រង់នៃពាក្យពេចន៍។ ដោយផ្អែក ទៅលើវចនានុក្រមសម្តេច ជួនណាត ពាក្យ "អក្សរសាស្ត្រ" មានន័យថា "វិជ្ជាអក្សរ; ក្បួនប្រាប់វិធីអក្សរ ការសរសេរត្រឹមត្រូវក្នុងភាសាណាមួយ មុខការខាងនិពន្ធ,..." ដែលយើងអាចកាត់ស្រាយថាជាការសរសេរណាមួយដែលដំណើរការ "ការមានទម្រង់ដែលល្អប្រសើរ ឬក៏ការបញ្ជាក់អំពីអ្វីមួយ និងការដែលបង្ហាញគំនិតជាអចិន្ត្រៃយ៍ ឬការមានចំណាប់អារម្មណ៍ជាសកល។"[៥] យ៉ាងហោចណាស់ ព្រះគម្ពីរគឺមានលក្ខណៈបែបនេះឯង និងលើសពីនេះទៀត។ ប៉ុន្តែ ការយល់ព្រះគម្ពីរតាមបែបជាអក្សរសាស្ត្រ អនុញ្ញាតឲ្យយើងជួលឧបករណ៍ដែលយើងត្រូវការជាមូលដ្ឋាន ដើម្បីជីកគាស់នូវអ្វីដែលយើងត្រូវរៀន (ឬគួរតែបានរៀន) នៅសាលា។

ប្រហែល ឆ្នាំនោះបានកាត់បន្ថយការចងចាំរបស់អ្នកនៅវិទ្យាល័យថ្នាក់ភាសាអង់គ្លេស ឬប្រហែលជាថ្នាក់របស់អ្នកបង្រៀនដោយគ្រូបង្វឹកកីឡា។ វាមិនទាន់ហួសពេលនៅឡើយទេក្នុងការត្រឡប់ទៅមើលនូវគោលការណ៍សំខាន់ៗនៃការកាត់ស្រាយទាំងនោះឡើងវិញ ដើម្បីជួយអ្នកក្នុងការសិក្សានូវផ្នែកដែលសំខាន់បំផុត នៃអក្សរសាស្ត្រដែលធ្លាប់បានសរសេរឡើង។ ដោយសួរសំណួរទាំង៥ងាយៗនៃអ្នកបុរាណវត្ថុអំពីខ្លឹមសារនោះ មុនពេលអ្នកចាប់ផ្តើមអាន។ ក្នុងពេលជាមួយគ្នា អ្នកអាចបំពេញនូវសេចក្តីសង្ឃឹមដ៏ធំគ្រូថ្នាក់ភាសាអង់គ្លេសរបស់អ្នកនៅវិទ្យាល័យ ហើយអ្នកក៏បានក្លាយទៅជាសិស្សដ៏

៥ Merriam-Webster OnLine, s.v. "literature," http://www.merriam-webster.com/dictionary/literature?show=0&t=1385582790.



Khmer Women of the word_Layout.indd 90 12/3/26 3:56 in the afternoon

ល្អ ក្នុងការសិក្សាព្រះគម្ពីររបស់អ្នកផងដែរ។

សូមពិនិត្យមើលនូវសំណួរទាំង៥នេះដោយសង្ខេបជាមួយគ្នា ដើម្បីស្វែងយល់ពីរបៀបក្នុងការឆ្លើយសំណួរទាំងនេះថា វានឹងជះឥទ្ធិពលដល់ការសិក្សារបស់យើងយ៉ាងដូចម្ដេច។

## ១. អ្នកណាជាអ្នកសរសេរ?

មនុស្សយើងភាគច្រើនអានសៀវភៅ ឬអត្ថបទគឺតែងតែគិតទៅលើប្រភពរបស់សៀវភៅនោះ។ ការដែលដឹងថាអ្នកណាជាអ្នកសរសេរពេលខ្លះជួយយើងឲ្យយល់ ហេតុអ្វីបានជាអត្ថបទសរសេរក្នុងរបៀបតែមួយមិនមានផ្លូវណាផ្សេងទៀត។ ហើយ ក៏បានជួយយើងឲ្យចេះធ្វើការវិនិច្ឆ័យ ទៅលើអ្វីដែលបានសរសេរនោះ អាចជឿទុកចិត្តបានដែរឬទេ។ ជាមួយនឹងអ្នកនិពន្ធខាងឯព្រះគម្ពីរ ភាពគួរឲ្យជឿទុកចិត្តបានមិនមែនជាបញ្ហានោះទេ—យើងចូលមកអត្ថបទជាមួយនឹងសេចក្ដីសន្និដ្ឋានថា ព្រះជាម្ចាស់បានជំរុញទឹកចិត្តអ្នកនិពន្ធដែលជាក់លាក់ឲ្យសរសេរជាមួយនឹងអំណាចដ៏ពេញលេញ។ ប៉ុន្តែដោយព្រោះយើងអានអត្ថបទជាមួយនឹងសេចក្ដីសន្និដ្ឋាននេះ ពេលខ្លះយើងភ្លេចចំណាយពេលពិចារណា ភាពជាអ្នកនិពន្ធព្រះគម្ពីរដែលមានសមភាគជាមនុស្សដែរ៖ ព្រះជាម្ចាស់បានជ្រើសរើសមនុស្សជាក់លាក់ ដើម្បីសរសេរសៀវភៅដែលជាក់លាក់។ តើរបៀបដែលព្រះអង្គបានជ្រើសរើសអ្នកនិពន្ធបានជះឥទ្ធិពលទៅលើរបៀបដែលយើងកាត់ស្រាយកណ្ឌគម្ពីរយ៉ាងដូចម្ដេច? យើងមិនមែនដឹងគ្រប់ទាំងអស់ ថាអ្នកណាបានសរសេរសៀវភៅជាក់លាក់ក្នុងព្រះគម្ពីរ ប៉ុន្តែភាពមិនច្បាស់លាស់របស់អ្នកនិពន្ធ នឹងជះឥទ្ធិពលទៅលើរបៀបដែលយើងអានអត្ថបទជាមិនខាន។

ដូចដែលបានដឹងថា រដ្ឋាភិបាលចេញសេចក្ដីប្រកាស ឬស្ថានទូត និងអង្គការជាក់លាក់មួយចំនួនបានសរសេរអំពីចរាចរណ៍ផ្សេងៗ ឬការប្រកាសព័ត៌មានជាផ្លូវការ ឬស្ថិតិដែលអង្គការនោះបានធ្វើការប្រមូល នឹងជះឥទ្ធិពល



Khmer Women of the word_Layout.indd 91 12/3/26 3:56 in the afternoon

ទៅលើរបៀបដែលយើងអានឯកសារទាំងនោះ។ ការដែលដឹងថា ប្អូនប្រុសរបស់ព្រះយេស៊ូវដែលមានម្តាយជាមួយគ្នា សរសេរកណ្ឌគម្ពីរយ៉ាកុប បានជះឥទ្ធិពលទៅលើរបៀបដែលយើងអាន ពីការសរសេរសំបុត្រនេះ។ យើងទទួលស្គាល់ថា យ៉ាកុបបានសរសេរសំបុត្រនេះដោយមានចំណេះដឹងអំពី ព្រះយេស៊ូវដោយផ្ទាល់ ដែលមិនមានអ្នកណាផ្សេងទៀតមានចំណេះដឹងនោះ និងទស្សនវិស័យដែលមិនមានអ្នកនិពន្ធណាផ្សេងទៀតអាចអះអាងថាខ្លួនមានផងដែរ។ យើងមិនមានការងឿងឆ្ងល់ទេដែលមើលឃើញការសរសេររបស់គាត់មានលក្ខណៈស្រដៀងទៅនឹងសេចក្តីបង្រៀននៅលើភ្នំដើមអូលីវ ហើយការដែលដឹងថាគាត់បានស្លាប់យ៉ាងវេទនា ផ្តល់តម្លៃឲ្យយើងអាននូវព្រះបន្ទូលដែលគាត់បានសរសេរដោយយកចិត្តទុកដាក់អំពី ការរស់នៅដែលបង្ហាញសេចក្តីជំនឿរបស់យើង។

## ២. សរសេរឡើងនៅពេលណា?

យើងប្រើកាលបរិច្ឆេទនៃកណ្ឌ ដើម្បីជួយយើងឲ្យយល់អំពីរបៀបដែលកណ្ឌនោះ បានអានដោយអ្នកអានដើមដំបូងយ៉ាងដូចម្តេច។ តើនិយាយជាក់លាក់ទៅកាន់ពេលវេលានៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេយ៉ាងដូចម្តេច តើកណ្ឌណាផ្សេងទៀតក្នុងព្រះគម្ពីរ បានសរសេរឡើងក្នុងសម័យកាលជាមួយគ្នា ហើយកន្លែងណាដែលវាបានឆ្លើយតបទៅនឹងរូបភាពធំ។ មិនមែនគ្រប់កណ្ឌទាំងអស់សុទ្ធតែអាចកំណត់កាលបរិច្ឆេទដោយច្បាស់លាស់បានទេ ប៉ុន្តែភាគច្រើនអាចកំណត់បាន។ ប្រហែល ក្នុងករណីខ្លះ ជាពិសេសបំផុតសៀវភៅវិវរណៈ អ្នកអត្ថាធិប្បាយជ្រើសរើសកាលបរិច្ឆេទឲ្យបានត្រឹមត្រូវបំផុត ដើម្បីអាចនឹងជះឥទ្ធិពលទៅលើការកាត់ស្រាយអត្ថបទនៃកណ្ឌនោះ។

ការដែលដឹងអំពីការប្រហាក់ប្រហែលនៃកាលបរិច្ឆេទ ដែលសៀវភៅនោះបានសរសេរជួយយើងក្នុងការគិតពិចារណាអំពីចំណុចវប្បធម៌ ដែលបានជះឥទ្ធិពលទៅលើការសរសេរនោះ។ ការភ្ជាប់ទៅនឹងសំណួរបន្ទាប់អំពីអ្នក



Khmer Women of the word_Layout.indd 92 12/3/26 3:56 in the afternoon

បុរាណវត្ថុ («សរសេរទៅកាន់អ្នកណា?») កាលបរិច្ឆេទនៃសៀវភៅអនុញ្ញាតឲ្យយើងពិនិត្យមើលរចនាសម្ព័ន្ធសង្គម តួនាទីភេទ ច្បាប់រដ្ឋ ភូមិសាស្ត្រ និងកងកម្លាំង នយោបាយ ដែលនៅជុំវិញអ្នកស្តាប់ ដែលសៀវភៅដើមដំបូងបានសរសេរទៅកាន់ពួកគេ។ វាជួយយើងឲ្យចាប់ផ្តើមចេះសួរសំណួរត្រូវអំពីសេចក្តីសន្និដ្ឋានជាមូលដ្ឋានរបស់អ្នកនិពន្ធ អំពីការថ្វាយបង្គំ ការរៀបអាពាហ៍ពិពាហ៍ គ្រួសារ ការគោរពរូបព្រះក្លែងក្លាយ ទាសភាព ភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិ តួនាទីពលរដ្ឋ និងផ្សេងៗទៀត។

## ៣. សរសេរទៅកាន់អ្នកណា?

គ្រប់សៀវភៅនៅក្នុងព្រះគម្ពីរត្រូវបានសរសេរឡើងទៅកាន់អ្នកស្តាប់ជាក់លាក់ ដែលរស់នៅក្នុងអតីតកាល។ អ្នកស្តាប់ដើមដំបូងរស់នៅក្នុងពេលវេលា និងវប្បធម៌ដែលខុសពីយើង។ ខ្លឹមសារនៃព្រះបន្ទូលលើសលប់សម្រាប់អ្នកស្តាប់ដើមដំបូងនៃសារនោះ ប៉ុន្តែសារនោះមិនពិបាកសម្រាប់អ្នកស្តាប់ដើមដំបូងឡើយ។ ដូចដែលលោក ហ្គរិន ហ្វី (Gordon Fee) និងលោក ឌឹហ្គ្លស ស្ទូវ៉ាដ (Douglas Steward) បានធ្វើការកត់សម្គាល់ «អត្ថបទមិនអាចមានអត្ថន័យ នូវអ្វីដែលវាមិនដែលអាចនឹងមានន័យទៅកាន់អ្នកនិពន្ធរបស់វា ឬក៏អ្នកស្តាប់ដើម»។[៦]

យើងទាំងអស់គ្នាធ្លាប់បានឮថា «ព្រះគម្ពីរគឺ ជាសំបុត្រនៃសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់សរសេរមកកាន់យើង» សម្រាប់ការយល់ឃើញមួយគឺបែបនេះមែន ប៉ុន្តែដូចដែលយើងធ្លាប់បានគិតពិចារណារួចហើយដំបូងគេ និងសំខាន់ជាងគេបំផុតព្រះគម្ពីរគឺជាសៀវភៅអំពីព្រះជាម្ចាស់។ នៅពេលដែលយើងសួរថា «តើកណ្ឌនេះសរសេរទៅកាន់អ្នកណា?» យើងកំពុងតែពង្រីកនូវគំនិតដើមដំបូងដែលនិយាយថា «ព្រះគម្ពីរគឺ ជាសៀវភៅអំពីព្រះជាម្ចាស់ សរសេរទៅកាន់មនុស្សដែលរស់នៅកាលពីអតីតកាល និងសរសេរ

៦ លោក Gordon Fee និងលោក Douglas Stuart, *How to Read the Bible for All Its Worth* (Grand Rapids, MI: Zondervan, ឆ្នាំ១៩៩៣), ទំព័រ៧៤។



Khmer Women of the word_Layout.indd 93 12/3/26 3:56 in the afternoon

មកកាន់យើងទាំងអស់គ្នាផងដែរ»។ យើងនឹងមិនអាចសិក្សាអំពីលោក ផ្លាតូ (Plato) ឬក៏លោក សូក្រាត (Socrates) បានទេ បើយើងមិនសិក្សាអំពីអ្នកស្តាប់ដើមដំបូងរបស់ពួកគេនោះ។ យើងក៏មិនអាចសិក្សាអត្ថបទព្រះគម្ពីរដោយ មិនពិចារណាទៅលើអ្នកស្តាប់ដើមដំបូងនៃកណ្ឌនោះបានដែរ។

មានការអនុវត្តខុសពីព្រះបន្ទូលជាច្រើនបានកើតឡើង ដោយព្រោះគ្រីស្ទបរិស័ទនាសម័យទំនើបមិនអើពើចំពោះអ្នកស្តាប់ដើមដំបូងនៃអត្ថបទនោះ។ មិនមែនគ្រប់ទាំងសេចក្តីសន្យានៃសាសន៍អ៊ីស្រាអែលយកទៅអនុវត្តមកលើជនជាតិអ៊ីស្រាអែលខាងវិញ្ញាណ (ក្រុមជំនុំ) បាននោះទេ។ មិនមែនគ្រប់ទាំងសេចក្តីណែនាំសម្រាប់ប្រជាជន និងទ្រព្យសម្បត្តិ យកមកអនុវត្តជាមួយនឹងវប្បធម៌នាសម័យទំនើបនេះដែរ។ ប្រសិន បើយើងចង់កាត់ស្រាយឲ្យបានត្រឹមត្រូវ និងអនុវត្តនូវសារនៃអត្ថបទនោះ យើងត្រូវគិតពិចារណាទៅលើសេចក្តីត្រូវការជាក់លាក់ ការប្រឈម រចនាសម្ព័ន្ធសង្គម និងសេចក្តីជំនឿរបស់អស់ អ្នកដែលអ្នកនិពន្ធមានបំណងសរសេរទៅកាន់ពួកគេនោះ។ មុនពេលដែលយើងសួរ «តើអត្ថបទនេះមានបន្ទូលយ៉ាងដូចម្តេចមកកាន់ខ្ញុំ?» យើងត្រូវសួរ «តើអត្ថបទនេះនិយាយអ្វីខ្លះទៅកាន់អ្នកស្តាប់ដើមដំបូង?» ជាមុនសិន។

## ៤. តើសរសេរក្នុងប្រភេទបែបយ៉ាងដូចម្តេច?

នៅក្នុងជំពូកទី៣ យើងបានពិចារណាអំពីប្រភេទខ្លះៗនៃអក្សរសាស្ត្រ ដែលមាននៅក្នុងព្រះគម្ពីរ ដែលបង្ហាញអំពីដំណើររឿងធំៗ។ គ្រប់ទាំងកណ្ឌសៀវភៅនៅក្នុងព្រះគម្ពីរ បានប្រើប្រាស់វិធីនៃប្រភេទទាំងនោះ មួយ ឬច្រើនជាងនេះ ដើម្បីនាំសារនៃកណ្ឌនោះ។ សមត្ថភាពរបស់យើងនៅក្នុងការកាត់ស្រាយព្រះគម្ពីរឲ្យបានត្រឹមត្រូវ និងការអនុវត្តនូវខ្លឹមសារនៃព្រះគម្ពីរ គឺពឹងផ្អែកទៅលើការយល់ដឹង ពីភាពខុសប្លែកគ្នានៃប្រភេទអក្សរសាស្ត្រនីមួយៗទាំងនោះ។ ប្រភេទនីមួយៗប្រើភាសាខុសៗគ្នា។

*ដំណើររឿងនិទានប្រវត្តិសាស្ត្រ* ប្រើភាសាផ្តល់ឲ្យនូវការពិតដោយប្រាប់ពី



Khmer Women of the word_Layout.indd 94 12/3/26 3:56 in the afternoon

ព្រឹត្តិការណ៍ឡើងវិញ។ វាមានគោលបំណងបង្ហាញនូវអ្វីដែលជាគុណតម្លៃ។ ការដែលដឹងអំពីចំណុចនេះជួយការពារយើងក្នុងការអាន ព្រះគម្ពីរប្រភេទនេះបែបជារឿងព្រេង ឬក៏ប្រៀបធៀប។ យើងយល់ថា ចំណុចដំបូងនិងសំខាន់បំផុតនៃរឿងរ៉ាវអំពីទឹកជំនន់គួរតែអានបែបប្រវត្តិសាស្ត្រ។ នេះ មិនមានន័យថាវាមានពេញទៅដោយសុទ្ធតែផ្នែក ប្រៀបធៀបទាំងអស់ទេ ប៉ុន្តែគោលបំណងនៃការប្រៀបធៀបទាំងនោះ គឺជាគោលបំណងបន្ទាប់បន្សំនៅក្នុងការរៀបរាប់ឡើងវិញនូវព្រឹត្តិការណ៍ដែលពិត។

*ការនិទានរឿង/លក្ខណៈប្រៀបធៀប* ប្រើប្រាស់ដោយច្នៃតួអង្គ និងរៀបចំការបង្រៀនមេរៀន ឬក៏ប្រើចំណុចបង្ហាញដោយប្រុងប្រយ័ត្ន។ មិនមែនគ្រប់ចំណុចពិស្តារនៃរឿងប្រៀបធៀប បានបន្ថែមនូវសារៈសំខាន់ទៅលើអត្ថន័យទូទៅឡើយ។ ក៏មិនមែនគ្រប់តួអង្គសុទ្ធតែបង្ហាញអ្នកណាម្នាក់ ឬក៏អ្វីមួយដែរ។ តួអង្គ និងការរៀបចំដែលមើលទៅរាងចម្លែកសម្រាប់យើង នោះគឺមានការងាយស្រួលក្នុងការស្គាល់អំពីអ្នកស្តាប់ដើមដំបូង។ ការរៀនស្តាប់អំពីរឿងរ៉ាវពេញទៅដោយប្រពៃណីក្នុងនាមជាអ្នកស្តាប់ដើមដំបូងនៃរឿងនោះ អនុញ្ញាតឲ្យយើងស្តាប់ឮរឿងនោះបានល្អ និងកាត់ស្រាយបានត្រឹមត្រូវផងដែរ។

ជារឿយៗ *ក្រឹត្យវិន័យ* មាត្រាច្បាប់នៅក្នុងព្រះគម្ពីរប្រើភាសាសំដៅទៅកាន់ស្ថានភាព ឬក៏ទំនាក់ទំនង ដែលបានដកចេញពីវប្បធម៌នាពេលបច្ចុប្បន្ននោះ ហើយការមិនយល់ដឹងអំពីការនេះយើងអាចនឹងខូចខាតធ្ងន់នៅក្នុងរបៀបដែលយល់ដឹងអំពីចំណុចនោះ។ ពេលខ្លះ ក្រឹត្យវិន័យដែលកត់ត្រាគឺជាផ្នែកខ្លះ ឬក៏តំណាងឲ្យនូវបញ្ជីនៃចំនួនច្បាប់ ឬក៏ក្រឹត្យវិន័យទាំងមូលដែលបានសរសេរនៅកន្លែងផ្សេងទៀត សរសេរក្នុងទម្រង់បង្កឲ្យអ្នកអាននាពេលបច្ចុប្បន្នមានការងឿងឆ្ងល់ ហេតុអ្វីមានតែចំណុចជាក់លាក់ដែលត្រូវបានលើកឡើង នៅពេលដែលចំណុច ផ្សេងៗមើលទៅដូចជាបានដកចេញ។ នេះគឺមានសារៈសំខាន់ដែលត្រូវចាំថា ក្រឹត្យវិន័យ ត្រូវបានកត់ត្រានូវគោលការណ៍



Khmer Women of the word_Layout.indd 95 12/3/26 3:56 in the afternoon

ដើម្បីគ្រប់គ្រងអំណាច មិនមែនសម្រាប់ចាត់ចែងយុត្តិធម៌ផ្ទាល់ខ្លួនផ្នែកបុគ្គលឡើយ។ ក្រឹត្យវិន័យដែលគេស្គាល់ក្រឹត្យវិន័យទូទៅមួយគឺ «ភ្នែកឲ្យធួននឹងភ្នែក» មិនអនុញ្ញាតឲ្យមនុស្សទាមទារការផ្តន្ទាទោសពី អ្នកជិតខាងរបស់ពួកគេឡើយ។ គឺសម្រាប់ជាការដឹកនាំដល់ចៅក្រមឲ្យពួកគេធ្វើការកាត់ទោសដាក់ចេញនូវវិធានការនៃការការពារភាគីដែលគេបានធ្វើខុសលើ ពីការទាមទារសងសឹកទៅលើពួកគេក្នុងការ (ដាក់ទោសធ្ងន់) ជំនួសដោយទទួលនូវអ្វីដែលជាការត្រឹមត្រូវ (យុត្តិធម៌) វិញ។

*កំណាព្យ* នៅក្នុងព្រះគម្ពីរ និងនៅកន្លែងផ្សេងប្រើភាសាជាសញ្ញាសម្គាល់ និងធ្វើការប្រៀបធៀបន័យ ដើម្បីគូរគំនូរចេញពីពាក្យកាព្យទាំងនោះ។ នៅពេលដែលអ្នកនិពន្ធកណ្ឌខគម្ពីរទំនុកតម្កើងបានសូមព្រះជាម្ចាស់ឲ្យ បំផ្លាញខ្មាំងសត្រូវរបស់គាត់ទាំងស្រុងនោះយើងអាចមើលឃើញថា គឺជាការបង្ហាញតាមរយៈពាក្យកំណាព្យ អំពីការខឹង និងការឈឺចាប់យ៉ាងខ្លាំង ជាជាងតាមរយៈសំណូមពរអធិស្ឋានដ៏គួរឲ្យភ័យខ្លាច។ នៅពេលអ្នកនិពន្ធថ្លែងការសរសើរថា ធ្មេញរបស់មនុស្សជាទីស្រឡាញ់របស់គាត់ គឺដូចហ្វូងចៀមដែលទើបនឹងឡើងមក ពីការសម្អាត នោះយើងយល់ថាអ្នកនិពន្ធកំពុងសរសើរដល់នាង គឺជាស្នាមញញឹមដ៏គួរឲ្យស្រឡាញ់របស់នាង។

*អក្សរសាស្ត្រនៃប្រាជ្ញា* ជាទូទៅប្រើភាសាក្នុងការទំនាក់ទំនងជាមួយនឹងគោលការណ៍ដែលពិត បើទោះជាមិនមែនការពិតបែបជាសកលក៏ដោយ។ ការអានកណ្ឌគម្ពីរសុភាសិតថាជាសេចក្តីសន្យានឹងនាំយើងទៅរកការឈឺចិត្ត និងសង្ស័យ។ ការយល់ដឹងថា នេះគឺជាច្បាប់ទូទៅសម្រាប់ជីវិតជួយដឹកនាំយើងឲ្យ ចេះធ្វើការសម្រេចចិត្តដែលត្រឹមត្រូវ។ កណ្ឌគម្ពីរសុភាសិតដែលគ្រប់គ្នាបានស្គាល់ «ចូរបង្ហាត់កូនក្មេងឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្ត នោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់» មិនបានសន្យាថាឪពុកម្តាយដែលជាគ្រីស្ទបរិស័ទនឹងបង្កើតកូនមកជាគ្រីស្ទបរិស័ទឡើយ។ នេះ គឺពិតជាបង្ហាញទូទៅអំពីគោលការណ៍ដែលវៃឆ្លាត ថាឪពុក ម្តាយដែលគោរពកោតខ្លាចព្រះ



Khmer Women of the word_Layout.indd 96 12/3/26 3:56 in the afternoon

ជាម្ចាស់ត្រូវបង្ហាត់បង្រៀនកូនរបស់ខ្លួននៅក្នុងរបៀបដែលពួកគេ នឹងគោរពកោតខ្លាចដល់ព្រះជាម្ចាស់ដែរ។

*ការថ្លែងទំនាយ* ដូចជាកំណាព្យ ក៏ប្រើប្រាស់ភាសាជាសញ្ញាសម្គាល់ដែរ ដោយដាក់ការថ្លែងទំនាយទៅក្នុងបរិបទវប្បធម៌ និងប្រវត្តិសាស្ត្រដោយបញ្ជាក់បន្ថែមអំពីការប្រើភាសានោះ។ នៅពេលអ្នកថ្លែងទំនាយនិយាយថា ព្រះអាទិត្យ ព្រះច័ន្ទ ព្រមទាំងផ្កាយនឹងធ្លាក់ចុះពីស្ថានសួគ៌ យើងអាចពិនិត្យមើលភាសានោះដោយផ្អែកទៅលើប្រភេទនៃអក្សរសាស្ត្រ ជាជាងសន្មតចំៗថាវាជាព្រឹត្តិការណ៍អំពីចក្រវាឡដែលត្រូវបានថ្លែងទំនាយ (បើទោះជាបែបនោះមែនក៏ដោយ)។ ការដឹងអំពីវប្បធម៌នៃមនុស្សមិនមានសាសនាសម័យបុរាណ ដែលពួកគេថ្វាយបង្គំព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយជួយយើងឲ្យយល់កាន់តែច្បាស់អំពីការថ្លែងទំនាយអំពីការវិនាស៖ ការថ្វាយបង្គំទេវតាអាទិទេពផ្សេងៗនឹងត្រូវរលាយបាត់នៅពេលដែលការថ្លែងទំនាយបានសម្រេច។

## ៥. ហេតុអ្វីបានមានការសរសេរឡើង?

គ្រប់អ្នកនិពន្ធតែងតែសរសេរដោយមានគោលបំណងជាក់លាក់ ដែលមាននៅក្នុងគំនិតរបស់ខ្លួន។ អ្នកនិពន្ធព្រះគម្ពីរក៏ដូច្នោះដែរ ពួកគេសរសេរកត់ត្រាប្រវត្តិសាស្ត្រ ដើម្បីបង្រៀន ដាស់តឿន ជំរុញចិត្ត ស្តីបន្ទោស ព្រមាន និងលើកទឹកចិត្តផងដែរ។ ពួកគេសរសេរ ដើម្បីបង្ហាញអំពីសេចក្តីត្រូវការ សេចក្តីសង្ឃឹម ឬភាពភ័យខ្លាចរបស់អ្នកស្តាប់ពួកគេ ដែលបង្ហាញឲ្យឃើញតាមរយៈលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ យើងអាចមើលឃើញថា ហេតុអ្វីសៀវភៅសរសេរឡើងដោយយកចិត្តទុកដាក់ទៅលើប្រធានបទធំៗ ហើយបង្ហាញគំនិតម្តងទៀតតាមរយៈអ្នកស្តាប់ដើមដំបូង និងបរិបទវប្បធម៌ ព្រមទាំងប្រវត្តិសាស្ត្រផងដែរ។ ការដឹងអំពីគោលបំណងដែលអត្ថបទសរសេរឡើង នោះនឹងការពារយើងពីការអានព្រះគម្ពីរសម្រាប់តែគោលបំណងរបស់ខ្លួនឯង។



Khmer Women of the word_Layout.indd 97 12/3/26 3:56 in the afternoon

## កុំភ័យស្លន់ស្លោ

នេះ គឺជាដំណឹងល្អមួយចំនួន៖ គ្មាននរណារំពឹងថា អ្នកនឹងដឹងចម្លើយចំពោះសំណួរប្រាំ ក្នុងរយៈពេលភ្លាមៗទេ ហើយអ្នកក៏មិនគួររំពឹងថា ព្រះវិញ្ញាណបរិសុទ្ធក៏នឹងបង្ហាញចម្លើយទាំងនោះឲ្យអ្នកដោយសាមញ្ញដែរ។ ប៉ុន្តែ ព្រះអង្គពិតជាបានឆ្លើយតបដោយប្រទានកិច្ចការមួយចំនួនមកក្នុងជីវិតអ្នកជឿជាមួយនឹងសេចក្តីប៉ងប្រាថ្នា និងសមត្ថភាពស្វែងរកចម្លើយទាំងនោះតាមរយៈការសិក្សាដ៏ខ្ជាប់ខ្ជួន។ ហើយអ្នកអាចសូមជំនួយពី អ្នកបុរាណវត្ថុបានផងដែរ។

ប៉ុន្តែ តើយើងទៅរកជំនួយនោះពីកន្លែងណា? ការសិក្សាព្រះគម្ពីរដែលអាចជឿទុកចិត្តបានមានដូចជា “ការសិក្សាព្រះគម្ពីរពោរពេញដោយជីវិត” “សៀវភៅណែនាំពីព្រះគម្ពីរ” “ដំណើររឿងសង្ខេបព្រះគម្ពីរ” ឬក៏ “ព្រះគម្ពីរបរិសុទ្ធសម្រាប់សិក្សា” នឹងបង្ហាញនូវចំណុចចាប់ផ្តើមដ៏សំខាន់។ ការសិក្សាព្រះគម្ពីរដែលអាចជឿទុកចិត្តបាន គឺជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់អ្នកដែលចង់ចាប់ផ្តើមសង់គ្រឹះនៃចំណេះដឹងខាងឯព្រះគម្ពីរ។ នៅក្នុងការចាប់ផ្តើមនៃកណ្ឌនីមួយៗ អ្នកនឹងឃើញចំណុចពិភាក្សាពីសំណួរនៃអ្នកបុរាណវត្ថុ។ មុនពេលអ្នកចាប់ផ្តើមអានកណ្ឌជាក់លាក់ណាមួយ សូមអាននូវចំណុចណែនាំនៅកន្លែងនោះសិន។ ប៉ុន្តែ សូមកុំគ្រាន់តែអាន សូមធ្វើការសរសេរចុះនូវសំណួរទាំងប្រាំ យើងបានផ្តល់កំណត់សម្គាល់នូវចម្លើយ អ្នកនឹងឃើញនូវចំណុចនីមួយៗទាំងនោះ។ សម្រាប់កណ្ឌសៀវភៅលោកុប្បត្តិកំណត់សម្គាល់របស់អ្នកនឹងមានលក្ខណៈ បែបនេះ៖

| | |
|---|---|
| អ្នកណាជាអ្នកសរសេរ? | គេបានសន្មតថាលោក ម៉ូសេ ជាអ្នកនិពន្ធ គាត់ជាអ្នកដែលជួយរំដោះជនជាតិអ៊ីស្រាអែល អ្នកផ្តល់ច្បាប់ ការកាត់ទោស ប្រហែលប្រើនូវការនិយាយផ្ទាល់មាត់ និងសរសេរជាមួយនឹងធនធាននូវអ្វីដែលពួកគេមាន។. |



Khmer Women of the word_Layout.indd 98 12/3/26 3:56 in the afternoon

| | |
|---|---|
| សរសេរឡើងនៅពេលណា? | ប្រហែលក្នុងឆ្នាំ ១៤០០ មុនគ.ស. អំឡុងពេល ៤០ ឆ្នាំនៃការដើរវិលវល់ក្នុងទីរហោស្ថាន។ |
| សរសេរទៅកាន់អ្នកណា? | ទៅកាន់ជនជាតិអ៊ីស្រាអែលដែលលោក ម៉ូសេ បានដឹកនាំចេញពីប្រទេសអេស៊ីព្ទ ក្នុងអំឡុងពេលដែលពួកគេនៅក្នុងទីរហោស្ថាន។ |
| តើសរសេរក្នុងប្រភេទបែបយ៉ាងដូចម្ដេច? | ជាទូទៅបែបដំណើររឿងនិទានប្រវត្តិសាស្ត្រ។ ខ្លះទៀតបែបកំណាព្យ និងក្នុងលក្ខណៈថ្លែងទំនាយ។ |
| ហេតុអ្វីបានមានការសរសេរឡើង? | ដើម្បីផ្ដល់ឲ្យជនជាតិអ៊ីស្រាអែលនូវប្រវត្តិសាស្ត្រ និងច្បាប់អំពីជីវិតរស់នៅ។ ពេលដែលពួកគេចូលទៅក្នុងទឹកដីកាណាន។ ដើម្បីរម្លឹកនូវអតីតកាលរបស់ ពួកគេ និងសម្រាប់រៀបចំអនាគតរបស់ពួកគេផងដែរ។ |

## ចាស់បុរាណ និង សម័យទំនើប

ដូចគ្នាទៅនឹងទីក្រុងរ៉ូម ព្រះគម្ពីររបស់អ្នកគឺដូចជាសម័យទំនើបដែលមានការរឿងឆ្ងល់ ហើយបានភ្ជាប់ទៅនឹងបរិបទកាលពីសម័យបុរាណ។ ការសិក្សាដោយមានទស្សនៈ គឺជាការធ្វើនូវកិច្ចការធ្វន់ជីកគាស់ទៅកាន់វប្បធម៌តាំងពីដើមដំបូង និងទម្រង់ប្រវត្តិសាស្ត្រនៃអត្ថបទ ធ្វើឲ្យអ្នកអាននូវអត្ថបទនោះអានក្នុងរបៀបដែលអ្នកនិពន្ធមានបំណងចង់ឲ្យពួកគេអាន។ ការចូលទៅកាន់សាច់រឿងនៃគោលបំណងតាំងពីដើមដំបូងនៃសៀវភៅទទួលបាននូវការរីកចម្រើនខាងផ្នែកអក្សរសាស្ត្រ និងចំណុចផ្សេងៗសម្រាប់យកមកប្រើប្រាស់ ហើយនឹងជួយអ្នកឲ្យចាប់ផ្ដើមនូវដំណើរការនៃការសាងសង់គ្រឹះចំណេះដឹងខាងឯព្រះគម្ពីរដ៏ពិតប្រាកដផងដែរ។ នៅពេលដែលអ្នកជីកគាស់រកឃើញនូវចម្លើយនៃសំណួរទាំងប្រាំពីអ្នកបុរាណវត្ថុចហើយ នោះអ្នកនឹងមានការរួចរាល់ក្នុងការត្រៀមចូលទៅក្នុងដំណើរការនៃការសិក្សាអត្ថបទ តាមរយៈការដែលនាំយកនូវទ្រព្យសម្បត្តិ តាំងពីបុរាណចូលមកក្នុងបរិបទសម័យទំនើបបច្ចុប្បន្ន។



Khmer Women of the word_Layout.indd 99 12/3/26 3:56 in the afternoon

## សំណួរឆ្លុះបញ្ចាំង

១. សម្រាប់អ្នក តើមានន័យយ៉ាងដូចម្ដេចក្នុងការដែលមាន «ទីតាំងតូចមួយ» ផ្ទាល់ខ្លួនក្នុងប្រវត្តិសាស្ត្រ? តើយើងនឹងបណ្ដុះការយល់ឃើញនេះយ៉ាងដូចម្ដេច? តើទស្សនៈនេះជួយយើងឲ្យមានការសិក្សាព្រះគម្ពីរយ៉ាងដូចម្ដេច?

២. សូមគិតអំពីសៀវភៅដែលអ្នកចូលចិត្ត ក្រៅពីព្រះគម្ពីរ តើការដែលដឹងអំពីចំណុចមូលដ្ឋានមួយចំនួនរបស់អ្នកនិពន្ធ បានជះឥទ្ធិពលទៅលើការអានសៀវភៅរបស់អ្នកយ៉ាងដូចម្ដេច? តើអ្នករកឃើញការពិតដូចគ្នាយ៉ាងដូចម្ដេច នៅពេលដែលអ្នកអានកណ្ឌក្នុងព្រះគម្ពីរដោយមានការយល់ដឹងអំពីអ្នកនិពន្ធដែលបានសរសេរកណ្ឌទាំងនោះ?

៣. «ខ្លឹមសារនៃព្រះបន្ទូលលើសលប់សម្រាប់អ្នកស្ដាប់ដើមដំបូងនៃសារនោះ ប៉ុន្តែសារនោះមិនពិបាកសម្រាប់អ្នកស្ដាប់ដើមដំបូងឡើយ» (ទំព័រទី ៧១)។ តើអ្នកយល់ស្របជាមួយនឹងទស្សនៈនេះដែរឬទេ? ហេតុអ្វីយល់ស្រប និងហេតុអ្វីមិនយល់ស្រប? ហេតុអ្វីសេចក្ដីល្បួងជាទូទៅមានការកើនឡើងខ្ពស់ នៅពេលដែលយើងមិនបានគិតអំពីរបៀបដែលអ្នកស្ដាប់ដើមដំបូងបានឮកណ្ឌនោះ?



Khmer Women of the word_Layout.indd 100

12/3/26 3:56 in the afternoon

៤. តើនៅក្នុងផ្នែកណាមួយ (ពីទំព័រ ៧២-៧៤) ដែលអ្នកគិតថាមានការពិបាកខ្លាំងជាងគេក្នុងការអាន? តើប្រភេទណាដែលហាក់ដូចជាងាយស្រួលបំផុត? តើផ្នែកដែលពិបាកនេះបានជះឥទ្ធិពលដល់កណ្ដាក្នុងព្រះគម្ពីរ ដែលអ្នកមានបំណងចង់អានយ៉ាងដូចម្ដេច?

៥. តើអ្វីដែលជាចំណុចខុសឆ្គងដ៏ធំជាងគេដែលអ្នកបានធ្វើ នៅក្នុងការកាត់ស្រាយ ឬក៏ការអនុវត្តនូវខគម្ពីរណាមួយ ឬខ្លឹមសារណាមួយដែរឬទេ? តើការយល់ដឹងអំពី "សំណួរបុរាណវត្ថុ" បានជួយអ្នកយ៉ាងដូចម្ដេច? សូមធ្វើការបញ្ជាក់។



Khmer Women of the word_Layout.indd 101 12/3/26 3:56 in the afternoon

ជំពូកទី ៥

# ការសិក្សាដោយមានការអត់ធ្មត់

តែពូជដែលនៅដីល្អ គឺពួកអ្នកដែលមានចិត្តទៀងត្រង់ល្អ ក៏ឮព្រះបន្ទូលហើយយកចិត្តទុកដាក់ រួចបង្កើតផលដោយសេចក្ដីអត់ធន់វិញ។

លូកា ៨:១៥

មកដល់ពេលនេះ យើងបានគិតទៅលើសារៈសំខាន់នៃការសិក្សាដោយមានគោលបំណង ដោយធ្វើការដាក់នូវអត្ថបទជាមួយនឹងរូបភាពធំនៃព្រះគម្ពីរ។ ហើយយើងបានគិតពិចារណាទៅលើសារៈសំខាន់នៃការសិក្សាដោយមានទស្សនៈវិស័យ ដែលគឺជាការដាក់អត្ថបទព្រះគម្ពីរចូលទៅក្នុងបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌ដើមដំបូងនៃអត្ថបទនោះ។ ការទាំងពីរដំបូងនៃការសិក្សាទាំង៥ឲ្យបានត្រឹមត្រូវនេះ ប្រហែលត្រូវការពេលវេលាច្រើន និងការខិតខំប្រឹងប្រែង ដើម្បីធ្វើការអនុវត្ត គឺមានច្រើនជាងការសិក្សារបស់យើងដែលធ្លាប់មានពីមុនៗមក។ ប៉ុន្តែ វាពិតជាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការយល់ដឹងនូវអ្វីដែលយើងបានអានដែរ គឺវាមានតម្រូវការច្រើនសម្រាប់យើងជាសិស្ស លើសពីអ្វីដែលយើងធ្លាប់បានគិតថានឹងមាន ប្រសិនបើយើងធ្វើដោយខ្លួនឯង។ ការ



Khmer Women of the word_Layout.indd 103 12/3/26 3:56 in the afternoon

សិក្សាព្រះគម្ពីរ ក៏ដូចជាការសិក្សាជំនាញដែលមានគុណតម្លៃផ្សេងៗទៀតដែរ គឺតម្រូវឲ្យមានវិន័យ។ ប្រសិនបើអ្នកធ្លាប់បានរៀនជំនាញណាមួយ អ្នកប្រហែលជាចាំនូវភាពស្មុគស្មាញមកជាមួយនឹងការរៀននោះ អារម្មណ៍ដែលមិនចេះគ្រប់គ្រាន់ ភាពដដែលៗនៃដំណើរការម្តងហើយម្តងទៀត រហូតដល់អ្នករៀនយល់អំពីជំនាញនោះ បំណងប្រាថ្នាដ៏ខ្លាំងនៅក្នុងការចង់បោះបង់ចោល ឬការដែលស្វែងរកនូវវិធីដែលងាយស្រួលជាងនេះ។ ការរៀនសិក្សាព្រះគម្ពីរដែលត្រឹមត្រូវ តែងតែបង្ហាញនូវអារម្មណ៍ដូចគ្នាទាំងនេះ ហេតុនេះហើយការទីបីនៃការសិក្សាដ៏ត្រឹមត្រូវរបស់យើង គឺជាការរម្លឹកឲ្យដំណើរការនៃការរៀនសូត្រមានចលនាទៅមុខបាន។ បន្ថែមពីលើការសិក្សាដោយមានគោលបំណង និងទស្សនៈវិស័យ យើងក៏ត្រូវសិក្សាដោយមានការអត់ធ្មត់ផងដែរ។

យើងបានរៀនតាំងពីក្មេងមកជាមួយនឹងឪពុកម្តាយ និងលោកគ្រូអ្នកគ្រូ អំពីការអត់ធ្មត់គឺជាគុណសម្បត្តិមួយ។ យើងអាចមើលឃើញគុណតម្លៃរបស់វានៅក្នុងការដោះស្រាយជាមួយមនុស្ស ឬក៏ការលំបាកផ្សេងៗរបស់វា។ យើងបានដឹងថាការអត់ធ្មត់ជាចំណុចទីបួននៃផលផ្លែខាងឯព្រះវិញ្ញាណដែលបានបង្ហាញនៅក្នុងកណ្ឌខគម្ពីរ កាឡាទី ៥:២២-២៣ ប៉ុន្តែយើងមិនដែលបានរហ័សនឹងដាក់វានៅក្នុងការអនុវត្តឡើយ។ វប្បធម៌របស់យើងជឿថាការអត់ធ្មត់ គឺជាការរំខាន និងស្វែងរកវិធីក្នុងការរារាំងយើងមិនអោយអនុវត្តការនោះទេ។ ទូរទស្សន៍បានបង្ហាញពីការដោះស្រាយជម្លោះក្នុងរយៈពេល ៣០នាទី ឬតិចជាងនេះ។ ភោជនីយដ្ឋានចម្អិនអាហារឲ្យយើងបានយ៉ាងលឿនតាមអ្វីដែលយើងចង់បាន។ ការបញ្ជូនទំនិញតាមប្រព័ន្ធអ៊ីនធឺណិតគ្រប់ប្រភេទ និងគ្រប់ការបញ្ជាទិញ យើងអាចធ្វើបានក្នុង៤៨ម៉ោង ឬតិចជាងនេះ។ បទភ្លេង សៀវភៅអេឡិចត្រូនិក និងភាពយន្តគឺរកបានភ្លាមៗមួយរំពេច។ កម្មវិធីបញ្ចុះទម្ងន់ផ្តល់ឲ្យនូវលទ្ធផលលឿនរហ័ស។ ទស្សនៈការពន្យារពេលបំពេញតាមបំណងប្រាថ្នាអាចនឹងពិបាកនៅក្នុងការរៀន និងអនុវត្តដោយសារយើងរស់នៅក្នុងវប្បធម៌ដែលមានជម្រើសក្នុងការអត់ធ្មត់ ដែលលើកតម្កើង

ភាពលឿនរហ័សទាន់ចិត្ត សម្រាប់គ្រប់តម្រូវការទាំងអស់នេះ។

ដូច្នេះ វាមិនមានការភ្ញាក់ផ្អើលឡើយសម្រាប់សេចក្ដីប៉ងប្រាថ្នាពេញចិត្ត ចង់បានភ្លាមៗអាចលបលួចចូលមកក្នុងការសិក្សាព្រះគម្ពីររបស់យើងផង ដែរ។ ភាពល្អប្រសើរនៃសម្ភារៈសិក្សាព្រះគម្ពីរគ្រប់ប្រភេទយើងអាចរកបាន [ជាភាសាអង់គ្លេស] ជាភស្តុតាងអំពីសេចក្ដីស្រឡាញ់របស់យើងដែលមាន ការវេចខ្ចប់យ៉ាងស្រស់ស្អាត៖ ចំណុចខាងក្នុងដែលឆ្លុះបញ្ចាំងខាងឯវិញ្ញាណ ភ្ជាប់មកជាមួយខព្រះគម្ពីរពីរទៅបីខ និងចំណុចចង្អុរបង្ហាញនៅក្នុងការអនុវត្ត មួយ ឬពីរចំណុច។ យើងចូលមកក្នុង «ការសិក្សាព្រះបន្ទូល» ដូចគ្នាទៅ នឹងការបើកឡាន កាត់ហាងកាហ្វេស្តារបាក់ដែរ (drive-through Starbucks)៖ «ខ្ញុំមានពេលតែពីរបីនាទីប៉ុណ្ណោះ សូមឲ្យអ្វីមួយលឿនៗ ហើយ ងាយស្រួល ដើម្បីបំពេញខ្ញុំបាន»។

ប៉ុន្តែ ការសិក្សាព្រះគម្ពីរដែលត្រឹមត្រូវមានឫសគល់នៅក្នុងការ អបអរសាទរលើការរង់ចាំដោយអត់ធ្មត់ មុននឹងទទួលបានផល។ ការទទួល បានចំណេះដឹងខាងឯព្រះគម្ពីរ តម្រូវឲ្យមានការសិក្សាដែលមានឥទ្ធិពលទៅ លើភាពដដែលៗ ត្រូវការពេលវេលាច្រើនសប្ដាហ៍ ច្រើនខែ និងឆ្នាំ ដើម្បីឲ្យ ចំណុចមួយដែលមានការពាក់ព័ន្ធគ្នាទៅចំណុចផ្សេងទៀតនៅក្នុងព្រះបន្ទូល បានបង្ហាញអត្ថន័យដោយខ្លួនឯងបន្តិចម្ដងៗ និងពេញដោយព្រះគុណ ដូច គ្នាទៅនឹងក្រណាត់ធំមួយដែលគ្របលើគំនូរស្នាដៃឯកមួយ ដែលគេបើកតូចៗ បន្តិចម្ដងៗផងដែរ។ ព្រះគម្ពីរមិនត្រូវបានរៀបចំចេញជាកញ្ចប់ដ៏ស្រស់ស្អាត សម្រាប់ចំនួន៣៦៥ថ្ងៃនោះឡើយ ហើយក៏មិនត្រូវបានកាត់បន្ថយចេញទៅជា សេចក្ដីពិត និងចំណុចដែលត្រូវអនុវត្តដែរ។ ព្រះគម្ពីរចង់ណែនាំអំពីភាពដែល ខុសៗគ្នា ឲ្យយើងគិតបានពិចារណាពង្រីកការយល់ដឹងរបស់យើង។ ព្រះគម្ពីរ ចង់បង្ហាញនូវរូបផ្គុំតូចៗនៃភាពឧត្ដុង្គឧត្ដមរបស់ព្រះជាម្ចាស់តាមរយៈម្ដងមួយ អត្ថបទ ម្ដងក្នុងមួយថ្ងៃពេញមួយជីវិតរបស់យើង។ ក្នុងគ្រប់មធ្យោបាយគឺ នាំ យកភាពចង់បានព្រះគម្ពីរមកក្នុងការសិក្សារបស់អ្នកគឺ ពិតណាស់នាំយកនូវ



Khmer Women of the word_Layout.indd 105 12/3/26 3:56 in the afternoon

ភាពស្រេកឃ្លាន។ ប៉ុន្តែ អ្វីដែលពិតប្រាកដគឺ នាំមកនូវការអត់ធ្មត់ឲ្យរួចរាល់ដើម្បីសិក្សាសម្រាប់រយៈពេលយូរអង្វែង។

## អត់ធ្មត់ជាមួយខ្លួនអ្នក

ថ្នាក់ទី៧គឺជា ឆ្នាំដែលចាប់ផ្ដើមមានការយំនៅក្នុងផ្ទះយើង យើងដូចជាទទួលបាននូវភាពមិនសប្បាយរីករាយបន្តិចជាមួយនឹងកូនច្បងរបស់ពួកយើង សាលារៀនមិនដែលបង្កឲ្យមាននៅការមិនសប្បាយរីករាយកម្រិតនេះពីមុនមកឡើយ។ ប៉ុន្តែ ជាមួយនឹងការណែនាំមូលដ្ឋានគណិត កូនយើងទាំងបួនរៀងរាល់យប់ទទួលបានជាទម្លាប់នូវភាពស្មុគស្មាញ និងទឹកភ្នែក។ ចេហ្វ ហើយនិងខ្ញុំបានអភិវឌ្ឍន៍នូវពាក្យស្លោកមួយ ដកចេញពីរឿង ភាពយន្តកីឡាបាល់បោះដែលយើងចូលចិត្ត “គ្មានការយំឡើយនៅក្នុងគណិតវិទ្យា”[៧] វាបានក្លាយទៅជាការបើកចាប់ផ្ដើមលើកទឹកចិត្តរៀងរាល់យប់នៅពេលពួកគេរៀន ដែលយើងចង់ដោះស្រាយនូវការភ័ន្តច្រឡំ ដែលបានកើតឡើង នៅពេលដែលពួកគេធ្វើកិច្ចការសាលាប្រចាំថ្ងៃ។ ដោយធ្វើឲ្យក្មេងៗប្រាកដថាពួកគេយល់នូវអ្វីដែលពួកគេអាចធ្វើបាន ដើម្បីបញ្ចប់កិច្ចការសាលា ហើយណែនាំពួកគេដោយទន់ភ្លន់ឲ្យបន្តធ្វើតាមសៀវភៅមេរៀនរបស់ពួកគេ។

នៅពេលយើងប្រាប់ពាក្យ “គ្មានការយំឡើយនៅក្នុងគណិតវិទ្យា” លើកដំបូង យើងបាននិយាយដោយមានភាពស្ងប់ស្ងាត់ទៅនឹងប្រធានបទនោះ ដោយមិនខ្វល់ខ្វាយអ្វីឡើយ។ ពួកគេបានយំកាន់តែខ្លាំងជាងមុន៖ *ម៉ាក់មិនយល់ទេគឺ ខ្ញុំកំពុងតែវង្វេង គ្រូរបស់ខ្ញុំពន្យល់មេរៀនអត់ល្អទេ។ មុខវិជ្ជានេះពិបាកណាស់ ហេតុអ្វី ម៉ាក់មិនឲ្យខ្ញុំចុះឈ្មោះចូលរៀន “ការដកពិសោធន៍នៅខាងក្រៅ” (Outdoor Trails) ជំនួសវិញ?*

ប៉ុន្តែ នៅពេលដែលកូនពៅរបស់យើងចូលដល់ថ្នាក់ទី៧ ស្ថានភាពនេះគឺបង្ហាញចេញមកខុសគ្នា។ ដោយសារកូនតូចម្នាក់អង្គុយរួមតុនៅក្នុងក្រុម

៧ A League of Their Own, ឆ្នាំ១៩៩២។ “There’s no crying in baseball!”



Khmer Women of the word_Layout.indd 106 12/3/26 3:56 in the afternoon

គ្រួសារបានជូតទឹកភ្នែកកាលពីដំបូង នៅក្នុងការលើកទឹកចិត្តអំពីប្រធានបទគណិតវិទ្យាដែលពេញទៅដោយភាពស្មុគស្មាញ ខ្ញុំបានលើកពាក្យស្លោកមកនិយាយចំពេល “ខិលវិន (Calvin) គ្មានការយំទ្បើយនៅក្នុងគណិតវិទ្យា” មុនពេលដែលខិលវិនលាក់បាំងពីការនេះ មាត់របស់ខិលវិនបានចាប់ផ្ដើមញញឹម។ ខិលវិនទទួលបានផលប្រយោជន៍នៅក្នុងការដឹងអំពីដំណើរនៃការបញ្ចប់ថ្នាក់ទី៧យ៉ាងដូចម្ដេច។ ដោយមើលដំណើរពួកបងៗរបស់គេចាប់ផ្ដើមពីការយំទៅកាន់ភាពញញឹម ក្នុងអំទ្បុងពេលរៀនមុខវិជ្ជាគណិតនៃថ្នាក់ទី៧ ខិលវិនដឹងថាភាពស្មុគស្មាញគឺជា ផ្នែកធម្មជាតិនៅក្នុងដំណើរការនៃការរៀនសូត្រ។ តើមានការយំនៅក្នុងគណិតវិទ្យាដែរឬទេ? និយាយដោយពិតត្រង់គឺមានច្រើនណាស់ ប៉ុន្តែនៅចុងបញ្ចប់ ខិលវិន បានមើលឃើញនូវភាពប្រឹងប្រែង និងការអត់ធ្មត់ក្នុងការសិក្សាដែលបងៗខិតខំដោយសមត្ថភាពរបស់ពួកគេ នូវជំនាញដែលចាំបាច់ ដើម្បីយល់មុខវិជ្ជាគណិតថ្នាក់ទី៧ ដែលពិបាកជាងនោះ។ ខិលវិន ប្រហែលមានអារម្មណ៍វង្វេង ប៉ុន្តែអារម្មណ៍នោះនឹងនៅមិនយូរទ្បើយ។ ការមានអារម្មណ៍ថា ការរៀនបានធ្វើឲ្យគាត់ភ័ន្តចិត្ត គឺជាការដែលគាត់ចូលរួមជាមួយបងប្អូនរបស់គាត់ ដែលបានឆ្លងកាត់បទពិសោធន៍នោះមុនគាត់ដែរ ពិតណាស់ការយំប្រហែលមានតែមួយយប់ទេ ប៉ុន្តែអំណរនៃការយល់ដឹងលែងឆ្ងល់នឹងទទួលបានជាមួយនឹងពេលវេលា និងការខិតខំប្រឹងប្រែង។

ខ្ញុំសង្ឃឹមថា មានស្ត្រីជាច្រើនយល់អំពីទស្សនៈនេះនៅពេលដែលពួកគេសិក្សាព្រះគម្ពីរ។ ការរៀនអំពីជំនាញអ្វីមួយតម្រូវឲ្យមានការខិតខំប្រឹងប្រែង ដំណើរការនៃការរៀនយល់ដឹងអំពីអ្វីមួយមិនមែនងាយស្រួលទ្បើយ ហើយជារឿយៗក៏មានលក្ខណៈស្មុគស្មាញ។ ការរៀនសូត្រប្រហែលមានភាពរីករាយផងដែរ អាស្រ័យលើមុខវិជ្ជាដែលយើងរៀន ប៉ុន្តែមិនអាចខ្វះការខិតខំប្រឹងប្រែងនោះទ្បើយ។ ការរៀនតម្រូវឲ្យមានការខិតខំ ពិតណាស់ការរៀនព្រះគម្ពីរគឺ មានលក្ខណៈដូចគ្នាទៅនឹងការរៀនគណិតវិទ្យាដែរ។ យើងគិតថា



Khmer Women of the word_Layout.indd 107 12/3/26 3:56 in the afternoon

ការសិក្សាព្រះគម្ពីរគួរតែមានលក្ខណៈធម្មតា ដូចជាការដកដង្ហើមចេញចូលដែរ ប្រសិនបើយើងដឹងថាព្រះបន្ទូលរបស់ព្រះពិតជាល្អសម្រាប់យើងគឺ ពិតណាស់ព្រះអង្គនឹងមិនធ្វើឲ្យយើងមានការពិបាកនៅក្នុងការសិក្សាសម្រាប់យើងទេឡើយ។ ប៉ុន្តែ ការសិក្សាព្រះគម្ពីរតម្រូវឲ្យមានវិន័យ ហើយវិន័យគឺជា អ្វីមួយដែលជាធម្មតាយើងពិបាកនៅក្នុងការទទួលយក។ ពីព្រោះ ការសិក្សាព្រះគម្ពីរគឺជាវិន័យ ហើយការអត់ធ្មត់គឺជា ចំណុចដែលយើងត្រូវការខ្លាំងបំផុតដើម្បីឲ្យយើងទទួលបានការរីកចម្រើន។

មានថ្នាក់ជាច្រើននៅសាលារៀនកូនរបស់ខ្ញុំនឹងមិនធ្វើឲ្យពួកគេយំ និងមិនមានភាពស្មុគស្មាញឡើយ។ ដូចជា ថ្នាក់ការដកពិសោធន៍នៅខាងក្រៅគឺមានភាពសប្បាយរីករាយ សិស្សទទួលបានចំណេះដឹងថ្មីៗ ប៉ុន្តែប្រហែលជាមិនបានពង្រីកការយល់ដឹងរបស់ពួកគេឡើយ។ ការឈានទៅដល់ការយល់ដឹងគឺ ពិតជាមានការពិបាកជាងការដែលទទួលបាននូវខ្លឹមសារថ្មី។ នៅពេលយើងអានកាសែតយើងដូចជាមិនមានភាពស្មុគស្មាញនៅក្នុងការធ្វើឲ្យយល់ឡើយ ពីព្រោះតែកាសែតមិនមានបំណងចង់ពង្រីកការយល់ដឹងរបស់យើងឡើយ វាគឺជាប្រព័ន្ធផ្តល់ឲ្យនូវព័ត៌មាន។ ការសិក្សាព្រះគម្ពីរគឺជាការស្វែងរកនូវចំណេះដឹង ប៉ុន្តែនៅចុងបញ្ចប់វាគឺជា ការស្វែងរកនូវការយល់ដឹងផងដែរ។ មិនដូចជាកាសែតទេ ព្រះគម្ពីរគឺមានលក្ខណៈលើសពីប្រព័ន្ធនៃការផ្តល់ឲ្យនូវព័ត៌មាន ព្រះគម្ពីរមានគោលបំណងសម្រួចនូវអ្វីដែលយើងគិត។ នេះមានន័យថា ត្រូវគិតជារឿយៗ ត្រូវរំពឹងជួបនូវបទពិសោធន៍នៃភាពស្មុគស្មាញនៅពេលដែលយើងអង្គុយចុះហើយអានព្រះគម្ពីរ។

តើអ្នករំពឹងថានឹងជួបនូវភាពស្មុគស្មាញទេ នៅពេលដែលអ្នកសិក្សាព្រះគម្ពីរ? តើអ្នកមានប្រតិកម្មយ៉ាងដូចម្តេច ទៅលើភាពមិនដូចគ្នាដែលអ្នកបានអាន នៅពេលដែលអ្នកមិនមានការយល់ដឹងអំពីអត្ថបទនោះ? ក្នុងនាមជាមនុស្សពេញវ័យយើងលែងប្រកាន់ខ្ជាប់ក្នុងការសិក្សា ដោយព្រោះគ្រូបង្រៀន ឬឪពុកម្តាយមានទំនួលខុសត្រូវមកលើយើងទៀតឡើយ។ ប្រសិនបើយើង



Khmer Women of the word_Layout.indd 108 12/3/26 3:56 in the afternoon

មិនមានការអត់ធ្មត់ជាមួយនឹងដំណើរការនៃការរៀនសូត្រ យើងប្រហែលជាសម្តែងចេញនូវប្រតិកម្មមួយ ឬពីរចំណុច។

*យើងបោះបង់ចោល៖* ពេលយើងឃើញថាការសិក្សាព្រះគម្ពីរមានភាពភ័ន្តច្រឡំច្រើន យើងភាគច្រើនគិតថា «នេះប្រហែលជាមិនមែនអំណោយទានរបស់ខ្ញុំទេ» យើងបន្តទៅលើផ្នែកនៃជំនឿដែលយើងមានដោយងាយស្រួលជាង។ យើងអនុញ្ញាតឲ្យការចែកចាយព្រះបន្ទូល ការផ្សព្វផ្សាយសៀវភៅ ឬមាតិកាជាប្រភពធនធានខាងឯព្រះគម្ពីរតែមួយគត់ដែលយើងទទួលយក។ យើងប្រហែលជាអានព្រះគម្ពីរដោយចិត្តឆេះឆួល ប៉ុន្តែយើងបានសន្មតថា ព្រះអង្គមិនមានព្រះទ័យឲ្យយើងទទួលបានការបណ្តុះបណ្តាលតាមបែបប្រព័ន្ធណាមួយនោះឡើយ។

*យើងស្វែងរកផ្លូវកាត់៖* ការចង់បោះបង់ចោលការវង្វេងឲ្យបានលឿនៗនៅក្នុងពេលដែលយើងកំពុងអាន នោះយើងក៏រត់ទៅមើលការពន្យល់នៅក្នុងព្រះគម្ពីរសិក្សារបស់យើងភ្លាមៗ បន្ទាប់ពីយើងបានអាន។ ឬយើងត្រៀមសេចក្តីពន្យល់អត្ថាធិប្បាយរួចជាស្រេច ដើម្បីផ្តល់គំនិតយោបល់នៅពេលយើងជួបនូវការមិនយល់លើកដំបូង។ ហើយធ្វើការដឹងគុណដល់ជំនួយតាមប្រព័ន្ធអ៊ីនធឺណិតដែលអាចស្វែងរកបានភ្លាមៗផងដែរ។ ប្រសិនបើយើងអានអ្វីមួយដូចជាមិនច្បាស់មិនចាំបាច់យំ ឬស្មុគស្មាញឡើយ យើងអាចអាននូវអ្វីដែលជាកំណត់សម្គាល់នៅក្នុងការសិក្សាព្រះគម្ពីរដែលបានសរសេរ ហើយស្វែងរកចម្លើយសម្រាប់សំណួររបស់យើងតាមប្រព័ន្ធអ៊ីនធឺណិតបាន។ ប៉ុន្តែ តើការបកស្រាយរួចជាស្រេចពិតជាអាចជួយបានដូចអ្វីដែលយើងគិតមែនដែរឬទេ? ឬក៏ដូចក្មេងៗនៅថ្នាក់វិទ្យាល័យនៃភាសាអង់គ្លេស មិនដែលបានអានសៀវភៅសោះ ពីព្រោះតែមានការសង្ខេប (CliffsNotes) និងភាពយន្តដែលងាយស្រួលនៅក្នុងការស្វែងរក? ជាក់ស្តែងហើយ ការប្រើផ្លូវកាត់ គ្រាន់តែប្រសើរជាងការបោះបង់បន្តិចប៉ុណ្ណោះ ពីព្រោះវាមិនបានឲ្យតម្លៃដល់ដំណើរការនៃការរៀនសូត្រ។ ដោយសារការប្រញាប់ប្រញាល់ចេញពីពេលវេលានៃ



Khmer Women of the word_Layout.indd 109 12/3/26 3:56 in the afternoon

ការមិនយល់នៃពាក្យ «ខ្ញុំអត់យល់» ជាទូទៅប្រសិទ្ធភាពបានធ្លាក់ចុះដោយសារតែការរកឃើញនូវចំណុច «ពេលយល់»។

## របៀបដែលការអត់ធ្មត់គាំទ្រការរៀនសូត្រ

យើងចូលចិត្ត «ពេលយល់» នៅពេលដែលយើងយល់ច្បាស់នូវអ្វីដែលធ្លាប់ធ្វើឲ្យយើងភ័ន្តច្រឡំ។ អ្វីដែលយើងមិនបានគិតដល់អំពី «ពេលយល់» ចំណុចសំខាន់គឺថា វាបានកើតឡើងក្រោយពេលដែលយើងមានអារម្មណ៍វង្វេង។ តើអាចទេ អំឡុងពេលវង្វេងទាំងនោះ តាមពិតទៅកំពុងរៀបចំយើងសម្រាប់ការយល់ដឹងដែលនឹងមកដល់? តើអាចទេ អារម្មណ៍វង្វេងទាំងនោះគឺជា វិធីមួយដែលព្រះជាម្ចាស់បន្ទាបខ្លួនយើង នៅពេលដែលយើងចូលទៅចំពោះព្រះបន្ទូលរបស់ព្រះអង្គ។ ដោយដឹងថា ពេលវេលាមកដល់ ព្រះអង្គនឹងបើកសម្តែងឲ្យយើងយល់ដឹង?

ផ្ទុយទៅនឹងប្រតិកម្មដែលមាននៅក្នុងចិត្តរបស់យើង អារម្មណ៍វង្វេង ឬក៏ការមិនយល់មិនមែនជាចំណុចមិនល្អឡើយ សម្រាប់យើងជាសិស្ស។ តាមពិតទៅ នេះជាសញ្ញាដែលថាការយល់ដឹងរបស់យើងត្រូវបានជំរុញឲ្យកាន់តែរីកចម្រើនឡើង ហើយការរៀនសូត្រកំពុងតែចាប់ផ្តើមដំណើរការ។ ការទទួលយកអារម្មណ៍មិនយល់ដែលវង្វេង ជាជាងការគេចវេស (បោះបង់) ឬមិនច្បាស់ (ស្វែងរកផ្លូវកាត់) នឹងជួយយើងទៅក្នុងដំណាក់កាលមួយដែលយើងអាចរៀនសូត្របាន។ យើងត្រូវអនុញ្ញាតឲ្យខ្លួនយើងវង្វេង ហើយអត់ធ្មត់ក្នុងការស្វែងរកវិធី ដើម្បីទទួលការយល់ដឹង។

ច្រើនឆ្នាំមកហើយ ខ្ញុំបានផ្លាស់ទីលំនៅពីទីក្រុងហូសស្តុន (Houston) ទៅរស់នៅទីក្រុងដាឡាស់ (Dallas)។ ការរស់នៅក្នុងទីក្រុងហូសស្តុនអស់១៣ឆ្នាំ ខ្ញុំអាចបើកបរក្នុងក្រុងនោះដោយមានភាពងាយស្រួល។ នៅទីក្រុងដាឡាស់ ខ្ញុំពិតជាមិនដឹងទិសតំបន់ទៅណាមកណាឡើយ ដូច្នេះខ្ញុំបានប្រើផែនទីហ្គូហ្គល (Google Map) ដើម្បីចង់ទៅកន្លែងណាមួយ។ វា



Khmer Women of the word_Layout.indd 110 12/3/26 3:56 in the afternoon

ពិតជា មានអារម្មណ៍សប្បាយណាស់ដែលយើងមិនស្គាល់កន្លែងណាមួយសោះនៅក្នុងទីក្រុង យើងអាចទាញផែនទីផ្លូវទៅតំបន់គោលដៅដែលយើងចង់ទៅបានភ្លាម។ ខ្ញុំមិនដែលគិតថា ខ្ញុំនឹងវង្វេង ឬខាតពេលវេលាក្នុងការជិះជុំវិញខុសផ្លូវឡើយ។

ប៉ុន្តែ បីឆ្នាំក្រោយមក ប្រសិនបើមិនមានផែនទីហ្គូហ្គល ខ្ញុំនៅតែមិនស្គាល់ផ្លូវជុំវិញទីក្រុងដាឡាស់ឡើយ។ ប្រសិនបើទូរស័ព្ទអស់ថ្ម ឬភ្លេចទូរស័ព្ទនៅផ្ទះនោះ ខ្ញុំនឹងមានបញ្ហាជាមិនខាន។ បន្ទាប់មក មានរឿងចម្លែកមួយកើតឡើង៖ ខ្ញុំបានធ្វើដំណើរត្រឡប់ទៅទីក្រុងហូស្តុន ទីក្រុងដែលខ្ញុំបានស្គាល់ច្បាស់ខ្ញុំបានដឹងថា ផែនទីហ្គូហ្គលមិនមែនតែងតែនាំយើងទៅកាន់ផ្លូវដែលត្រូវ ហើយងាយស្រួលជាងគេរហូតនោះឡើយ។ ផែនទីបានប្រើសម្លេងដូចគ្នាទៅនឹងអ្វីដែលខ្ញុំបានប្រើនៅទីក្រុងដាឡាស់ ប៉ុន្តែខ្ញុំអាចដឹងថាគួរតែប្រើផ្លូវមួយផ្សេងទៀតជាជាងផ្លូវដែលផែនទីធ្វើការចង្អុរបង្ហាញ។

នៅពេលដែលខ្ញុំទៅទីក្រុងដាឡាស់វិញ ខ្ញុំដឹងថាខ្ញុំត្រូវធ្វើអ្វី៖ ខ្ញុំត្រូវអនុញ្ញាតឲ្យខ្លួនខ្ញុំវង្វេង ខ្ញុំត្រូវតែបើកទៅបើកមកបន្តិច រៀបចំចំណាយពេលឲ្យបានយូរជាងមុន ខកនូវកន្លែងផ្លូវចេញមួយចំនួន ហើយធ្វើការបត់ត្រឡប់ខុសដើម្បីរៀនស្គាល់ផ្លូវដោយខ្លួនឯង ដែលផែនទីហ្គូហ្គលបានផ្តល់ឲ្យខ្ញុំ។ មានរឿងអ្វីកើតឡើង? ខ្ញុំបានស្គាល់ផ្លូវច្បាស់ ហើយប្រសើរជាងមុន។

នេះគឺជាមេរៀនដូចគ្នាដែលខ្ញុំបានរៀនអំពីការសិក្សាព្រះគម្ពីរ និងសេចក្តីពន្យល់អត្ថាធិប្បាយរួចជាស្រេចដែលជួយបានភ្លាមៗ។ បើខ្ញុំមិនប្រុងប្រយ័ត្ន វាអាចឆ្លុះបញ្ចាំងភាពអន់ខ្សោយក្នុងការយល់ដឹងអំពីព្រះគម្ពីរ ហើយផ្តល់ឲ្យខ្ញុំនូវអារម្មណ៍មិនពិតថា ខ្ញុំស្គាល់ផ្លូវក្នុងទំព័ររបស់វារួចហើយ។ ខ្ញុំមិនបានខិតខំប្រឹងប្រែងដើម្បីឲ្យមានការយល់ដឹង ពីព្រោះនៅពេលដែលខ្ញុំបានជួបនូវខគម្ពីរដែលពិបាកៗ ខ្ញុំបានសម្រេចចិត្តដោះស្រាយជាមួយនឹងភាពមិនងាយស្រួលអារម្មណ៍ដែលវង្វេងរបស់ខ្ញុំភ្លាម ដោយបានសម្លឹងស្វែងរកមើលកំណត់សម្គាល់ ឬសេចក្តីពន្យល់អត្ថាធិប្បាយដើម្បីរកចម្លើយ។ ពេលឮសម្លេងដូចជា



Khmer Women of the word_Layout.indd 111 12/3/26 3:56 in the afternoon

មានអំណាចនៃពួកគេ ខ្ញុំអាចភ្លេចថា តាមពិត គ្រាន់តែជាពាក្យរបស់មនុស្ស—ជាមតិដែលមានការអប់រំ អាចផ្តល់អត្ថប្រយោជន៍ ប៉ុន្តែមិនមែនជាអ្វីដែលមិនអាចខុសបានឡើយ។

និយាយឲ្យខ្លី ប្រសិនបើខ្ញុំមិនដែលអនុញ្ញាតឲ្យខ្លួនខ្ញុំវង្វេង នោះខ្ញុំក៏នឹងមិនដែលអនុញ្ញាតឲ្យដំណើរការនៃការរៀនសូត្រ មានដំណើរការប្រព្រឹត្តទៅបានសមស្របឡើយ។ ប្រសិនបើខ្ញុំមិនដែលធ្វើការប្រយុទ្ធទៅលើការកាត់ស្រាយយល់ដឹងផ្ទាល់ខ្លួននោះទេ ខ្ញុំប្រហែលជានឹងទទួលនូវគ្រប់ការកាត់ស្រាយទាំងឡាយដែលខ្ញុំអានជាមិនខាន ហើយនោះគឺជារបៀបបើកបរប្រកបដោយគ្រោះថ្នាក់។

គោលបំណងរបស់ខ្ញុំគឺមិនមែនចោទសួរអំពីគុណតម្លៃនៃសេចក្តីអធិប្បាយនោះទេ ដ្បិតសេចក្តីអធិប្បាយមួយចំនួនពិតជាមានតម្លៃសម្រាប់សិស្សដែលសិក្សាព្រះគម្ពីរមែន។ គោលបំណងរបស់ខ្ញុំគឺ សួរអំពីការប្រើប្រាស់វានៅក្នុងកន្លែងដ៏ត្រឹមត្រូវនៃដំណើរការនៃការរៀនសូត្រ។ ប្រសិនបើយើងធ្វើការពិគ្រោះយោបល់ក្រោយពេលដែលយើងបានព្យាយាមស្វែងយល់ច្បាស់ និងបានកាត់ស្រាយដោយខ្លួនឯងជាមុន ជាទូទៅយើងនឹងទុកចិត្តទៅលើហេតុផលរបស់វាទាំងស្រុង។ បញ្ហាគឺមិនមែនជាមួយនឹងការសិក្សាព្រះគម្ពីររបស់យើង ឬក៏សេចក្តីពន្យល់អត្ថាធិប្បាយនោះទេ បញ្ហាគឺថាយើងចង់បានការបំពេញចិត្តភ្លាមៗ និងមិនពេញចិត្តចំពោះអារម្មណ៍ដែលវង្វេង។ សេចក្តីពន្យល់អត្ថាធិប្បាយមានកន្លែងដែលមានប្រយោជន៍នៅក្នុងដំណើរការនៃការរៀនសូត្រ យើងនឹងមើលអំពីចំណុចនេះនៅជំពូកបន្ទាប់។ ហើយ ចំណុចនោះផងដែរមិនត្រូវកើតឡើងដំបូងក្នុងដំណើរការនៃការរៀនសូត្រឡើយ។ ពិតណាស់ វាអាចនឹងបន្ថយនូវអារម្មណ៍ដែលវង្វេងរបស់យើង ប៉ុន្តែសូមកុំភ្លេចថា អារម្មណ៍នោះជានិច្ចកាលជាមិត្តភក្តិរបស់យើង។

## ឥទ្ធិពលបន្តបន្ទាប់នៃការសិក្សាដោយការអត់ធ្មត់

ទស្សនៈនៃការសិក្សាដោយមានការអត់ធ្មត់គឺ ត្រូវការពេលវេលាយូរអង្វែង ដោយអនុញ្ញាតឲ្យខ្លួនយើងវង្វេងនៅក្នុងអត្ថបទ មានន័យថានឹងមានពេលវេលាមកដល់នៅពេលដែលអ្នកធ្វើការសិក្សា ការរៀននោះបានធ្វើឲ្យអ្នកមានការភ័ន្តច្រឡំច្រើនជាងពេលដែលអ្នកបានចាប់ផ្តើម។ ជាធម្មតា ចំពោះអ្នកដែលទម្លាប់មានពេលវេលាស្ងៀមស្ងាត់ប្រចាំថ្ងៃ ដើម្បីឲ្យមានភាពស្ងៀមស្ងាត់សិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ដែលលើកទឹកចិត្តយើងមុនពេលចាប់ផ្តើមថ្ងៃថ្មី នោះគាត់នឹងងាយអនុញ្ញាតឲ្យខ្លួនឯងចំណាយពេលយូរដើម្បីសិក្សា និងការដែលជំរុញខ្លួនឲ្យចូលទៅកាន់តែជ្រៅក្នុងការសិក្សា គឺយើងនឹងមានការពិបាកជាមិនខាន។ នៅគ្រប់ចុងបញ្ចប់នៃការសិក្សា យើងប្រហែលជារកមិនបានចំណុចនៃការអនុវត្តដែលបានរៀបចំជាស្រេចនោះទេ ហើយយើងប្រហែលជាគិតថា ការសិក្សារបស់យើងនឹងមិនមានប្រយោជន៍ទេ ប្រសិនបើមិនមានចំណុចនោះ។ ប៉ុន្តែ គិតបែបនោះនឹងធ្វើឲ្យយើងកាន់តែមានកំហុសថែមទៀត។

ជាច្រើនឆ្នាំ ខ្ញុំបានមើលឃើញការចំណាយពេលវេលារបស់ខ្ញុំជាមួយនឹងការសិក្សាព្រះគម្ពីរដូចគ្នាទៅនឹងគណនីដកប្រាក់នៅធនាគារ (debit account)៖ ខ្ញុំទៅស្វែងរកចម្លើយនៅក្នុងព្រះគម្ពីរនៅពេលដែលខ្ញុំមានសេចក្តីត្រូវការ ប៉ុន្តែអ្វីដែលធ្វើឲ្យបានល្អប្រសើរសម្រាប់យើង នៅពេលដែលយើងមើលឃើញការសិក្សាព្រះគម្ពីររបស់យើងគឺជាគណនីសន្សំប្រាក់វិញ (saving account)៖ ខ្ញុំពង្រីកការយល់ដឹងរបស់ខ្ញុំរៀងរាល់ថ្ងៃ ខ្ញុំដាក់នូវអ្វីដែលខ្ញុំប្រមូលបាន ហើយរង់ចាំឲ្យមានការកើនឡើងដោយអត់ធ្មត់ដែលជាគុណតម្លៃដោយដឹងថាថ្ងៃណាមួយខ្ញុំនឹងដកយកមកប្រើប្រាស់វា។ ការសិក្សាព្រះគម្ពីរគឺជាការបណ្តាក់ទុនដែលមានការបង់ផ្តាច់រយៈពេលយូរអង្វែង។ មិនមែនគ្រាន់តែអាននូវអត្ថបទដែលជាក់លាក់ ហើយព្យាយាមស្វែងរកសេចក្តីត្រូវការភ្លាមៗនោះឡើយ ប៉ុន្តែសូមអនុញ្ញាតឲ្យការសិក្សារបស់អ្នកទទួលបាននូវផល



Khmer Women of the word_Layout.indd 113 12/3/26 3:56 in the afternoon

ប្រយោជន៍ត្រៀមបម្រុងទុកសម្រាប់ប្រើនាពេលអនាគត។ ប្រសិនបើថ្ងៃនេះមានអត្ថបទដែលអ្នកបានប្រយុទ្ធព្យុះពារ ដើម្បីយល់ដឹង ហើយស្រាប់តែមួយរំពេចនៅពេលក្រោយអ្នកក៏បានយល់ ក្នុងពេលដែលអ្នកកំពុងតែត្រូវការ មានរយៈពេល១០ឆ្នាំចាប់គិតពីឥឡូវនេះ តើវាល្អប៉ុណ្ណាទៅណ៎? ដូចអ្វីដែលគេនិយាយថា យើងបានគិតខុសនូវអ្វីដែលយើងទទួលបានក្នុងរយៈពេលមួយឆ្នាំ ហើយមើលងាយនូវអ្វីដែលយើងទទួលបានក្នុងរយៈពេល១០ឆ្នាំ។ តើអ្នកស្ម័គ្រចិត្តវិនិយោគ១០ឆ្នាំក្នុងការរង់ចាំ ដើម្បីទទួលបានការយល់ដឹងដែរឬទេ? តើអ្នកស្ម័គ្រចិត្តរង់ចាំជាងមួយទសវត្សសម្រាប់ចំណុចដែលត្រូវអនុវត្តនោះឲ្យបានលេចឡើងដែរឬទេ? សូមទុកក្នុងចិត្តថា អ្នកកំពុងតែសន្សំនូវទ្រព្យសម្បត្តិ ទោះបើជាអ្នកមិនបានឃើញ ឬមានអារម្មណ៍ពីការនោះក្នុងរយៈពេលខ្លីក៏ដោយ។

នោះមិនមានន័យថា ការសិក្សារយៈពេលខ្លីមិនទទួលបានផលប្រយោជន៍នោះទេ គឺទទួលបាន។ កូនប្រុសរបស់ខ្ញុំនឹងមិនបានបញ្ចប់មុខវិជ្ជាគណិតកម្រិតខ្ពស់ទេ បើពួកគេមិនចាប់ផ្ដើមរីករាយជាមួយនឹងផលប្រយោជន៍ដែលបានបញ្ចប់មុខវិជ្ជាគណិតថ្នាក់ទី៧នោះ។ ហើយគណិតវិទ្យាជាថ្នាក់ទី៧គឺជាការបណ្ដាក់ទុនរយៈពេលយូរនៅក្នុងសមត្ថភាពរបស់ពួកគេ ដើម្បីឲ្យពួកគេទទួលបានការយល់ដឹងទៅកាន់កម្រិតថ្នាក់ខ្ពស់បាន។ ការសិក្សាកណ្ឌគម្ពីរយ៉ាកុប ប្រហែលជាបង្ហាញអត្ថន័យភ្លាមៗដល់ខ្ញុំអំពីការឲ្យឆាប់នឹងស្ដាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹង។ ប៉ុន្តែ ច្រើនឆ្នាំបន្តទៅមុខ គឺពិតណាស់ខ្ញុំទទួលបានការយល់ដឹងមេរៀនទាំងនោះកាន់តែជ្រៅទៅៗនៅក្នុងចិត្តរបស់ខ្ញុំ។

## ការអត់ធ្មត់ជាមួយនឹងកាលៈទេសៈ

ប្រសិនបើ ខ្ញុំជាអ្នកមកដល់ពេលនេះខ្ញុំប្រហែលជាមានអារម្មណ៍មិនសប្បាយចិត្តបន្តិចបន្តួចជាមួយនឹងអ្នកនិពន្ធហើយ។ អ្នកប្រហែលជាគិតថា «ខ្ញុំពិតជាចង់មានការអត់ធ្មត់ជាមួយនឹងដំណើរការនៃការរៀនសូត្រណាស់ ប៉ុន្តែតាម



Khmer Women of the word_Layout.indd 114 12/3/26 3:56 in the afternoon

ពិតទៅតើឲ្យខ្ញុំមានពេលណាក្នុងការស្វែងរកពេលវេលា ចាប់ផ្ដើម ដំណើរការនៃការរៀនសូត្រឲ្យបានច្រើនជាមួយនឹងការអត់ធ្មត់តិចតួចដើម្បីទទួលបានចំណុចនោះ?»។ ស្ត្រីជានិច្ចកាលមិនត្រូវផ្ដេកផ្ដួលលើជីវិតដែលបានផ្ដល់ឲ្យដល់គេនូវឱកាសច្រើនដើម្បីធ្វើការសិក្សាព្រះគម្ពីរទេ។ ការងារថ្មី ការចាប់ផ្ដើមក្រុមគ្រួសារដំបូង ការមានឪពុកម្ដាយមានវ័យចាស់ដែលត្រូវធ្វើការថែទាំ កាលៈទេសៈមួយចំនួនទាំងនេះអាចនាំយើងទៅកាន់ស្ថានភាពមួយដែលពេលវេលារបស់យើងជាមួយព្រះគម្ពីរ ត្រូវបានលួចធ្លាក់ចូលទៅក្នុងចន្លោះពេលប្រែប្រួលទាំងនោះ។

សម្រាប់ខ្ញុំ ស្ថានភាពទាំងនេះពេលខ្លះមានរយៈពេលរាប់ឆ្នាំ ការស្ដាប់ព្រះបន្ទូល និងការចាក់ផ្សាយគឺជាផ្លូវនៃជីវិតខ្ញុំ។ ការដែលមានរចនាសម្ព័ន្ធនៃក្រុមសិក្សាព្រះគម្ពីរ ដែលខ្ញុំបន្តចូលរួមក៏បានជួយឲ្យខ្ញុំនៅតែមានទំនាក់ទំនងជាមួយនឹងព្រះគម្ពីរមែន ប៉ុន្តែក៏មានខែខ្លះទៀតដែលការចូលរួមបែបនោះច្រើនពេកសម្រាប់ខ្ញុំនៅក្នុងការបន្តអនុវត្តដែរ។ ខែខ្លះទៀត ការគ្រាន់តែរក្សារាងកាយខ្លួន និងព្រលឹងរបស់ខ្ញុំឲ្យនៅមូលជាមួយគ្នា និងក្រុមគ្រួសាររបស់ខ្ញុំ គឺវាហាក់បីដូចជាមានការរវល់រវីកខ្លាំងមែនទែនរួចបាត់ទៅហើយ។ ខ្ញុំមិនបានរាប់ទុកថា ពេលវេលាទាំងនោះគឺជា ពេលវេលាដែលខាត ឬក៏ជាពេលវេលានៃឧបសគ្គនៅក្នុងការរីកលូតលាស់របស់ខ្ញុំឡើយ។ នោះ គឺជាពេលដែលខ្ញុំបានប្រើការអត់ធ្មត់ ហើយមិនមានពេលវេលាដែលសកម្មជាមួយនឹងការសិក្សាព្រះបន្ទូល ប៉ុន្តែជាមួយនឹងពេលវេលានៃការរង់ចាំព្រះអង្គវិញ។ ពេលវេលាទាំងនោះបានធ្វើឲ្យខ្ញុំកាន់តែមានបំណងប្រាថ្នាចង់ជីកចូលព្រះគម្ពីរឲ្យកាន់តែជ្រៅជាងមុន នៅក្នុងការសិក្សា។ ពេលវេលាដែលមានផលផ្លែមួយចំនួនរបស់ខ្ញុំនៅក្នុងការបង្រៀន និងការសរសេរគឺកើតឡើងភ្លាមៗនៅក្រោយពេលដែលខ្ញុំបានរង់ចាំព្រះអង្គដូចនេះ។

ប្រសិនបើ ដំណាក់កាលនៅក្នុងជីវិតបានធ្វើឲ្យអ្នកមានការពិបាកនៅក្នុងការរៀបចំពេលវេលាដែលទៀងទាត់សម្រាប់ការសិក្សាព្រះគម្ពីរ ឬក៏ជាមួយនឹង



Khmer Women of the word_Layout.indd 115 12/3/26 3:56 in the afternoon

ក្រុមសិក្សា ឬជាមួយនឹងការខិតខំប្រឹងប្រែងដោយផ្ទាល់ខ្លួន នោះសូមស្តាប់នូវអ្វីដែលខ្ញុំនិយាយនេះ៖ មិនអីទេ សូមថ្វាយទៅកាន់ព្រះជាម្ចាស់នូវអ្វីដែលអ្នកអាចធ្វើបាន ហើយទុកចិត្តលើព្រះអង្គថា ទ្រង់នឹងប្រើប្រាស់នូវអ្វីដែលអ្នកបានស្មោះត្រង់ជាមួយនឹងការនោះ មិនថាតូច ឬធំ។ សូមទុកចិត្តលើព្រះអង្គថាទ្រង់ស្គាល់កាលៈទេសៈរបស់អ្នកជាងខ្លួនអ្នកបានស្គាល់ ហើយដឹងថាព្រះអង្គបានឃើញបំណងប្រាថ្នារបស់អ្នកនៅក្នុងការរៀន និងរីកលូតលាស់។ ហើយទុកចិត្តថា ពេលវេលាទាំងនោះត្រូវបានប្រើប្រាស់ ដើម្បីឲ្យអ្នកបានពេញវ័យឡើង ដើម្បីបង្រៀនអ្នកឲ្យដឹងថា វាគឺជាអភ័យឯកសិទ្ធិជួយឲ្យអ្នកចេះថ្វាយខ្លួនអ្នកផ្ទាល់ ដើម្បីធ្វើការសិក្សាទទួលការយល់ដឹង និងចាក់ឫសឲ្យបានជ្រៅចូលទៅក្នុងចិត្តរបស់អ្នកនូវសេចក្តីពិតដែលអ្នកបានរៀនរួចមកហើយ។

## ការអត់ធ្មត់ និងការមានផលផ្លែ

ការអត់ធ្មត់ និងការមានផលផ្លែ ជារឿងប្រៀបប្រដូចដំបូងដែលព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សរបស់ព្រះអង្គ។ ប្រសិនបើអ្នកបានចូលរួមនៅក្នុងក្រុមជំនុំក្នុងពេលណាមួយ អ្នកនឹងធ្លាប់បានឮអំពីដំណើររឿងនេះ។ ព្រះយេស៊ូវបានពណ៌នាអំពីអ្នកព្រោះគ្រាប់ពូជដែលបានចេញទៅព្រោះ គ្រាប់ពូជបានធ្លាក់ចុះទៅលើកន្លែងផ្សេងៗគ្នា ដែលរារាំងមិនឲ្យគ្រាប់ពូជនោះលូតលាស់បានល្អ ប៉ុន្តែចុងក្រោយគឺមានគ្រាប់ពូជខ្លះធ្លាក់ទៅលើដីដែលមានជីវជាតិល្អ ដែលបានបង្កើតផលយ៉ាងច្រើន។ សូមកត់សម្គាល់មើលការបកស្រាយក្នុងរឿងប្រៀបប្រដូចនេះ ដែលព្រះយេស៊ូវបានលើកឡើងអំពីស្ថានភាពនៃអាកាសធាតុ៖ «តែ [ពូជ] ដែលនៅដីល្អ គឺពួកអ្នកដែលមានចិត្តទៀងត្រង់ល្អ ក៏ឮព្រះបន្ទូល ហើយយកចិត្តទុកដាក់រួចបង្កើតផលផ្លែដោយសេចក្តីអត់ធន់វិញ» (លូកា ៨:១៥)។

នៅពេលកូនៗរបស់ខ្ញុំនៅតូច ពួកគេចូលចិត្តស្តាប់រឿងនិទាន កង្កែប និងគីង្គក់ និពន្ធដោយលោក អាណូល ឡូបែល (Arnold Lobel) ក្នុងរឿងមួយ



Khmer Women of the word_Layout.indd 116 12/3/26 3:56 in the afternoon

គីង្គក់បានព្រោះគ្រាប់ពូជឲ្យដុះក្លាយជាសួនច្បារ។ ពីព្រោះគីង្គក់មិនដែលបានធ្វើចំការពីមុនមក វាមើលគ្រាប់ពូជដោយគិតស្រមៃចង់ឃើញគ្រាប់ពូជនោះដុះមានពន្លកឡើងភ្លាមៗបន្ទាប់ពីបានព្រោះហើយ។ វាលេងវីយ៉ូឡុង និងច្រៀងឲ្យគ្រាប់ពូជស្ដាប់ វាបានអានរឿងនិទាន និងសូត្រកំណាព្យឲ្យគ្រាប់ពូជនោះផងដែរ។ បន្ទាប់ពីមានការខិតខំប្រឹងប្រែងយ៉ាងច្រើនទៅលើដំណើរការនោះ វាបានស្រែក «ឥឡូវ គ្រាប់ពូជសូមចាប់ផ្ដើមដុះឡើងភ្លាម» នៅក្នុងពេលវេលាកំណត់ដែលមកដល់ តាមកាលបរិច្ឆេទនៃការលូតលាស់របស់គ្រាប់ពូជ នោះវានឹងដុះពន្លកចេញមកបែបនេះ។

រឿងប្រៀបប្រដូចអំពីអ្នកព្រោះគ្រាប់ពូជដែលព្រះយេស៊ូវបានលើកឡើង អ្នកព្រោះមិនមានការអន្ទះសាចំពោះគ្រាប់ពូជរបស់គាត់ ដូចគីង្គក់ក្នុងរឿងរបស់លោក ឡូបែល ឡើយ កូនរបស់ព្រះមានចិត្តដែលជាដីមានជីវជាតិ។ យើងអាចឮ និងទទួលនូវព្រះបន្ទូលរបស់ព្រះអង្គបាន នៅពេលដែលការអត់ធ្មត់បានបញ្ចប់ដល់ពេលកំណត់យើងនឹងច្រូតបានផលជាច្រើន។ សូមមានការអត់ធ្មត់ នៅពេលដែលអ្នកអនុវត្តនូវវិន័យនៃការសិក្សានេះ។ សូមអនុញ្ញាតឲ្យគ្រាប់ពូជនៃព្រះបន្ទូលបានដុះពន្លកឡើង និងរីកលូតលាស់ស្របតាមពេលវេលាដ៏ត្រឹមត្រូវរបស់ព្រះជាម្ចាស់ ដោយទុកចិត្តថានៅពេលដែលកំណត់មកដល់យើងនឹងទទួលផលបានយ៉ាងច្រើនមហិមា។

## សំណួរឆ្លុះបញ្ចាំង

១. សូមគិតអំពីសារៈប្រយោជន៍មួយចំនួនដែលអ្នកពេញចិត្តក្នុងការពន្យារពេលបំពេញតាមបំណងចិត្ត នៅក្នុងផ្នែកផ្សេងៗនៃជីវិតរបស់អ្នក។ តើអ្នកអាចរកឃើញសារៈប្រយោជន៍ដែលស្រដៀងគ្នាទៅនឹងការសិក្សាព្រះគម្ពីរយ៉ាងដូចម្ដេច?



Khmer Women of the word_Layout.indd 117 12/3/26 3:56 in the afternoon

២. តើអ្វីជាភាពខុសគ្នារវាងការដែលគ្រាន់តែទទួលបានចំណេះដឹង និងការពង្រីកការយល់ដឹងរបស់យើង ហើយហេតុអ្វីបានជាការខុសគ្នានោះសំខាន់ម្ល៉េះ?

៣. តើអ្នករំពឹងថានឹងមានភាពស្មុគស្មាញទេនៅពេលដែលអ្នកសិក្សាព្រះគម្ពីរ? ប្រសិនបើ មិនមានតើការរំពឹងអំពីភាពស្មុគស្មាញជួយដល់ការសិក្សារបស់អ្នកយ៉ាងដូចម្តេច? ប្រសិនបើអ្នកបានរំពឹងថានឹងមានភាពស្មុគស្មាញ (ហើយប្រហែលជាមានការគេចវេះក្នុងការសិក្សា) តើមានការលើកទឹកចិត្តបែបណាខ្លះដែលអ្នកទទួលបានចេញពីជំពូកនេះ?

៤. តើអ្នកធ្លាប់បានគិតអំពីការប្រើប្រាស់ «ជំនួយក្នុងការសិក្សា» (ដូចជាការសង្ខេបមេរៀន) ដែលអាចបង្រួញខ្លីដំណើរការនៃការរៀនសូត្រពីមុនដែរឬទេ? តើអ្នកយល់ស្រប ឬមិនយល់ស្របជាមួយនឹងឃ្លាដែលថាការប្រើផ្លូវកាត់ជាចំណុចបន្ទាប់បន្សំដែលប្រសើរជាងការបោះបង់ (ទំព័រទី៨៤)? សូមពន្យល់អំពីចម្លើយរបស់អ្នក។

៥. សូមពណ៌នាអំពីភាពខុសគ្នារវាងការមើលឃើញ ការចំណាយពេលវេលាជាមួយនឹងព្រះបន្ទូលដូចគ្នាទៅនឹងគណនីដកប្រាក់នៅធនាគារ ឬគណនីសន្សំប្រាក់។ តើប្រភេទណាមួយដែលអ្នកបានធ្វើជាទម្លាប់នៅក្នុងពេលវេលារបស់អ្នកជាមួយ

នឹងព្រះបន្ទូល? តើដំណាក់កាលនៃជីវិតរបស់យើងមានការប៉ះពាល់យ៉ាងដូចម្ដេចជាមួយនឹងជ្រុងជ្រោយនៃទស្សនៈដែលអ្នកបានជ្រើសរើសយក?



Khmer Women of the word_Layout.indd 119 12/3/26 3:56 in the afternoon

ជំពូកទី៦

# ការសិក្សាតាម លំដាប់លំដោយ

«ចូរត្រៀមការងារនៅខាងក្រៅចុះ ហើយរៀបចំសម្រាប់ខ្លួននៅឯវាលជាមុនសិន ទើបសង់ផ្ទះឯងឡើងជាក្រោយ»

សុភាសិត ២៤:២៧

យើងបានសិក្សាអំពីការសាងសង់ចំណេះដឹងខាងឯព្រះគម្ពីរតាមរយៈការសិក្សា ដោយមាន គោលបំណង ដោយមាន ទស្សនៈ និងការអត់ធ្មត់។ ប៉ុន្តែជាមួយនឹងការសាងសង់ គម្រោងណាមួយក៏តម្រូវឲ្យមានការសិក្សាតាមលំដាប់លំដោយល្អផងដែរ។

ការសិក្សាតាមលំដាប់លំដោយដែលខ្ញុំនឹងលើកឡើងនៅទីនេះ គឺខុសពីការសិក្សាតាមលំដាប់លំដោយដែលអ្នកធ្លាប់បានសិក្សាមានជា "កញ្ចប់" កន្លងមក។ ការសិក្សាជាច្រើនបានណែនាំឲ្យអ្នកអានព្រះបន្ទូលនៅផ្នែកណាមួយ ហើយធ្វើការឆ្លុះបញ្ចាំង បន្ទាប់មកពួកគេក៏ផ្ដល់នូវគំនិតនៃការកាត់ស្រាយដ៏សមរម្យទៅលើផ្នែកនៃព្រះបន្ទូលនោះ ហើយអនុវត្ត។ ការសិក្សាតាមលំដាប់លំដោយដែលខ្ញុំចង់ណែនាំ គឺចង់ឲ្យអ្នកដែលជាសិស្សទទួលយកនូវចំណុចសំខាន់មិនមែនគ្រាន់តែក្នុងពេលអាន ប៉ុន្តែឲ្យ ទទួលយក អត្ថបទនោះ



Khmer Women of the word_Layout.indd 121 12/3/26 3:56 in the afternoon

ដោយផ្ទាល់ ហើយបន្ទាប់មកឲ្យពួកគេព្យាយាមធ្វើការកាត់ស្រាយ និងស្វែងរកចំណុចអនុវត្តដោយខ្លួនគេផ្ទាល់។ គឺនៅពេលដែលពួកគេបានធ្វើដូច្នេះហើយទើប ការសិក្សាតាមលំដាប់លំដោយនេះនឹងនាំពួកគេឲ្យចូលមើលនូវគំនិត និងជំនួយរបស់អ្នកប្រាជ្ញផ្សេងៗដែលបានបកស្រាយ។

ខ្ញុំជាមនុស្សមានគំនិតច្នៃប្រឌិតខ្លះៗ ខ្ញុំនឹងគូរលើក្រដាសទទេដោយមិនមានស្នាមដានវិធីសាស្ត្រអ្វីទេ ខ្ញុំចូលចិត្តលេងព្យាណូដោយស្តាប់ ល្អប្រសើរជាងការអានណោតភ្លេង ខ្ញុំចូលចិត្តដេរ ដោយមិនចាំបាច់មានគំរូតាងណាមួយឡើយ ជំនួសឲ្យការដាំតាមលំដាប់លំដោយឲ្យមានគម្លាតស្មើៗគ្នា ខ្ញុំចូលចិត្តដាំផ្កាពាសវាលពាសកាល ហើយខ្ញុំចូលចិត្តចម្អិនម្ហូបដោយមិនបាច់មានការវាល់គ្រឿងគ្រៅអ្វីទាំងអស់។ លទ្ធផលដែលខ្ញុំទទួលបានដូចជាមិនមានការភ្ញាក់ផ្អើលអ្វីទេ ពេលខ្លះខកខានបន្តិចបន្តួច ពេលខ្លះក៏ជោគ ជ័យផងដែរ។

ប្តីរបស់ខ្ញុំ ចេហ្វ ផ្នែកមួយនៃជីវិតរបស់គាត់ គឺជាអ្នកជំនាញខាងដំណើរការ គាត់ធំធាត់នៅក្នុងក្រុមគ្រួសារដែលលើកទឹកចិត្តឲ្យមានការសិក្សាតាមលំដាប់លំដោយ ដែលចូលចិត្តធ្វើអ្វីៗក្នុងរបៀបដែលត្រឹមត្រូវ ហើយមានការពេញចិត្តទាំងស្រុងនៅក្នុងការធ្វើបែបនោះ។ មានរបៀបរបបក្នុងការធ្វើនូវអ្វីមួយឲ្យបានត្រឹមត្រូវ ហើយក្រុមគ្រួសារ វាលឃីន (Wilkin) ដឹងពីវិធី ហើយពួកគេធ្វើតាមរបៀបនោះបានយ៉ាងត្រឹមត្រូវមិនថា ពិបាកប៉ុណ្ណា ឬក៏មានរយៈពេលយូរប៉ុណ្ណានោះទេ។ ត្រូវមានរបៀបនៅក្នុងការបត់កន្សែង ត្រូវមានរបៀបនៅក្នុងការរៀបចំបន្ទប់ដាក់ចានឆ្នាំង ទីកន្លែងត្រូវមានសណ្តាប់ធ្នាប់ ការលាងជក់គំនូរជាដើម។ ខ្ញុំពេញចិត្តនេះជារបៀបរបស់ក្រុមគ្រួសារ វាលឃីន។ ខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំទាំងមូលគឺ បត់កន្សែងមិនស្មើ និងរៀបរយទេ ហើយជាជាងលាងជក់ដែលប្រើហើយ ប្រហែលទិញជក់គូរគំនូរថ្មីវិញការយល់ដឹងពីរបៀបរបស់ក្រុមគ្រួសារ វាលឃីន គឺពិតជាមានលក្ខណៈល្អប្រសើរ និងមិនអាចយល់បានឡើយ។

អាចនិយាយបានថា ឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍របស់ខ្ញុំ ផ្តល់ឱកាសឲ្យខ្ញុំ



Khmer Women of the word_Layout.indd 122 12/3/26 3:56 in the afternoon

នៅក្នុងការរៀន និងរីកចម្រើនបានច្រើនណាស់។

ខ្ញុំគិតថា ចេហ្វ គាត់បានរីកចម្រើននៅក្នុងការពេញចិត្តសម្រាប់ឱកាសសប្បាយផ្សេងៗ និងការមិនបានគិតទុកជាមុនទៅលើទេពកោសល្យដែលខ្ញុំបានចម្អិនអាហារ សំលៀកបំពាក់បុណ្យហាឡូវីន (Halloween) និងការធ្វើដំណាំទៅតាមរដូវកាលបានយ៉ាងល្អប្រសើរ។ ខ្ញុំបានមើលពីរបៀបគ្រួសារ វាលឃីន ដែលបង្ហាញតាមការដុសខាត់លាបពណ៌គ្រឿងសង្ហារិមយ៉ាងស្រស់ស្អាត ការលាបពណ៌បន្ទប់យ៉ាងល្អិតល្អ ការរៀបចំជាន់ថ្នាក់នៃទូរបានយ៉ាងល្អឥតខ្ចោះ ការបោសសំអាតទីធ្លាស្មៅ និងការអាំងសាច់ដែលធ្វើឲ្យអ្នកពិតជាចង់សាកល្បងនូវរសជាតិនោះខ្លាំងណាស់។

ពិភពលោកត្រូវការទាំងពីរ អ្នកដែលមានការច្នៃប្រឌិតដោយមិនបានព្រៀងទុក និងអ្នកដែលម៉ត់ចត់ជាមួយនឹងការសិក្សាតាមលំដាប់លំដោយ។ ចំណុចទាំងពីរបូកផ្សំគ្នាផ្តល់នូវកម្លាំងដល់រូបកាយនៃគ្រីស្ទបរិស័ទ ប៉ុន្តែចំណេះដឹងខាងឯ ព្រះគម្ពីរគឺ ទេរទៅរកគម្រោងនៃការសាងសង់ ជាជាងគម្រោងខាងសិល្បៈជំនាញ។ ប្រសិនបើអ្នកសាងសង់ផ្ទះ អ្នកត្រូវការជួលអ្នកសាងសង់ដែលវិភាគលើដំណើរការ មិនមែនអ្នកដែលគិតពីលេខកូដនៃការសាងសង់ថាជា «សំណើដ៏អស្ចារ្យ» នោះទេ អ្នកប្រហែលត្រូវការអ្នកសាងសង់ដែលមានគំនិតយល់ស្រប តាមរបៀបដូចគ្រួសារ វាលឃីន។ អ្នកហើយនឹងខ្ញុំ ត្រូវមានលក្ខណៈដូចជាងសាងសង់នេះដើម្បីកសាងចំណេះដឹងខាងឯព្រះគម្ពីរ។ យើងត្រូវតែជាអ្នកដែលសាងសង់នៅលើគ្រឹះថ្មដារឹងមាំនៃគំនិតដែលភ្ជាប់ទៅនឹងដំណើរការ ជាជាងលើដីខ្សាច់ហើយហូរទៅបាត់ ត្រូវមានការវិនិច្ឆ័យទុកជាមុន «តើខព្រះគម្ពីរនេះនិយាយអ្វីមកកាន់ខ្ញុំ»។

តើយើងគួរសាងសង់ការយល់ដឹងអំពីព្រះបន្ទូលយ៉ាងដូចម្តេច? តើអ្វីដែលជារបៀបនៃការសិក្សាតាមលំដាប់លំដោយ?

ការសាងសង់ចំណេះដឹងដែលល្អឲ្យតម្លៃទៅលើការសិក្សាតាមលំដាប់លំដោយនៃការរៀនសូត្រ ដោយឆ្លងកាត់ដំណាក់កាលនៃការយល់ដឹងបីផ្សេង



Khmer Women of the word_Layout.indd 123 12/3/26 3:56 in the afternoon

គ្នា៖ ការយល់ដឹង ការកាត់ស្រាយ និងការអនុវត្ត។ ចំណុចនីមួយៗក្នុងបីដំណាក់កាលនេះ នឹងព្យាយាមឆ្លើយនូវសំណួរដ៏ជាក់លាក់អំពីអត្ថបទព្រះបន្ទូលដែលយើងបានអាន។

*១. ការយល់ដឹង សួរថា «តើវានិយាយអំពីអ្វី?»*

*២. ការកាត់ស្រាយ សួរថា «តើវាមានន័យយ៉ាងដូចម្ដេច?»*

*៣. ការអនុវត្ត សួរថា «តើវាបានផ្លាស់ប្រែខ្ញុំយ៉ាងដូចម្ដេច?»*

ជាទូទៅ យើងជួបប្រទះនូវដំណាក់កាលទាំងនេះគឺ យើងមានការយល់ច្បាស់នៅក្នុងការរស់នៅប្រចាំថ្ងៃ គ្រប់ពេលដែលយើងប្រើកិច្ចការទាំងនេះនោះវាជាដំណើរការដើម្បីទទួលព័ត៌មាន។ អ្នកណាខ្លះក្រោកឡើងពេលព្រឹកដោយសារនាឡិការោទ៍ ដែលបានឆ្លងកាត់ពីការយល់ដឹង ទៅកាន់ការកាត់ស្រាយ រួចអនុវត្ត៖

- នៅក្នុងការដេកលក់ស៊ុបរបស់យើង យើងចាប់ផ្ដើមស្គាល់នូវសម្លេង ដំបូងខួរក្បាលរបស់យើងប្រហែលមិនចាប់អារម្មណ៍ទេ ហើយបានដាក់សម្លេងរោទ៍នោះចូលទៅក្នុងការយល់សប្តិណាមួយដែលយើងកំពុងតែមាន។ នៅពេលដែលសម្លេងនោះចេះតែបន្តរោទ៍ ខួរក្បាលរបស់យើងទទួលស្គាល់ថា «សម្លេងរោទ៍របស់ខ្ញុំបានបិត» យើងចាប់ផ្ដើម យល់ដឹង នូវសម្លេង។ មិនមែនសម្លេងរោទ៍ពេលមានផ្សែង ក៏មិនមែនជាផ្នែកមួយនៃការយល់សប្តិដែរ គឺជាសម្លេងនាឡិការោទ៍របស់យើងដែលកំពុងរោទ៍។
- នៅពេលដែលយើងដឹងថានោះគឺជាសម្លេងនាឡិការោទ៍របស់យើង ខួរក្បាលរបស់យើងធ្វើ ការកាត់ស្រាយ នូវអត្ថន័យរបស់វា៖ «ម៉ោង៧ ព្រឹកហើយ» ។
- បន្ទាប់មកយើងចាប់ផ្ដើម អនុវត្ត នូវអ្វីដែលខួរក្បាលងងុយដេករបស់យើងបានយល់ដឹង និងកាត់ ស្រាយ៖ «ដល់ពេលដែលខ្ញុំត្រូវក្រោកឡើង និងចាប់ផ្ដើមថ្ងៃថ្មីហើយ»។

នេះគឺជារឿងងាយធម្មតាចេញពីគំរូនៃការរស់នៅប្រចាំថ្ងៃ ពេលខ្លះយើងបានឆ្លងកាត់ពីការយល់ដឹង ទៅកាន់ការបកស្រាយ និងទៅការអនុវត្តយ៉ាង



Khmer Women of the word_Layout.indd 124 12/3/26 3:56 in the afternoon

លឿន ដោយយើងមិនបានចាប់អារម្មណ៍នូវដំណាក់កាលទីមួយ ទីពីដំបូងកើតឡើងនៅពេលណានោះទេ។ ជាមួយនឹងការសិក្សាព្រះគម្ពីរដំណាក់កាលនីមួយៗ តម្រូវឲ្យមានការប្រឹងប្រែងទុកជាមុន និងចំណាយពេលច្រើនក្នុងការគិតពិចារណាផងដែរ។ យើងគួរកត់សម្គាល់នូវដំណាក់កាលនីមួយៗនឹងធ្វើឡើងនៅក្នុងទម្រង់នៃគោលបំណង ទស្សនៈ និងការអត់ធ្មត់ ដែលយើងបានកំណត់ទីកន្លែងរួចមកហើយ។

- យើងនឹងឆ្លុះបញ្ចាំងទៅលើគោលបំណងនៃការសិក្សារបស់យើង ដោយអនុញ្ញាតឲ្យដំណាក់កាលទាំងបីនេះជួយយើងដាក់នូវអត្ថបទព្រះគម្ពីររបស់យើងចូលទៅក្នុងរូបភាពធំបាន។
- យើងត្រូវប្រើទស្សនៈនៃសំណួរអំពីបុរាណវត្ថុទាំងប្រាំជួយយើង ដើម្បីឲ្យមានការយល់ដឹង និងការកាត់ស្រាយ។
- យើងនឹងប្រើនូវចំណុចនៃការអត់ធ្មត់ដែលយើងបានពិភាក្សានៅក្នុងជំពូកមុន ដើម្បីជួយឲ្យយើងទប់ទល់នឹងការចង់ប្រញាប់បញ្ចូលទៅរកការអនុវត្តភ្លាមៗ។

ឥឡូវយើងនឹងពិចារណាថា តើដំណាក់កាលទាំងបីនេះដើរតួនាទីយ៉ាងដូចម្ដេច នៅក្នុងបរិបទនៃការសិក្សាព្រះគម្ពីរ ដែលជាការសិក្សាតាមលំដាប់លំដោយសម្រាប់ការកសាងចំណេះដឹងខាងឯព្រះគម្ពីរ។

## ដំណាក់កាលទី១៖ ការយល់ដឹង—«តើវានិយាយអំពីអ្វី?»

ដំណាក់កាលនៃការយល់ដឹងប្រហែលជាចំណុច ដែលសិស្សរៀនព្រះគម្ពីរភាគច្រើនជាទូទៅមិនយកចិត្តទុកដាក់ និងមានការយល់ច្រឡំពីព្រោះតែយើងចាត់ទុកថា ការអានអត្ថបទព្រះគម្ពីរ និងការទទួលបានអត្ថន័យខ្លឹមសារនៃព្រះគម្ពីរ គឺដូចគ្នាទៅនឹងការយល់ដឹងព្រះគម្ពីរដែរ។ យើងនឹងចំណាយពេលវេលារបស់យើងពិភាក្សាអ្វីទៅជាការយល់ដឹង និងតើយើងអាចទៅដល់ចំណុចនេះបានយ៉ាងដូចម្ដេច។ ប្រសិនបើអ្នកបានអានសៀវភៅផ្សេងៗអំពីការសិក្សាព្រះគម្ពីរ នោះអ្នកប្រហែលជាធ្លាប់បានឮអំពីជំហានដំបូងនៅក្នុងការសិក្សាតាម



Khmer Women of the word_Layout.indd 125 12/3/26 3:56 in the afternoon

លំដាប់លំដោយនៃការរៀនសូត្រ គេហៅចំណុចនោះថា «ការសង្កេត» ជាជាង «ការយល់ដឹង»។ ខ្ញុំជឿថា ពាក្យ ការយល់ដឹង ប្រើការសង្កេតល្អជាង វាផ្តល់ឲ្យនូវអ្វីដែលពណ៌នាបានល្អជាងអំពីអ្វីដែលយើងចង់បាន។ ការសង្កេតអាចជាអ្វីដែលផ្អែកលើមតិផ្ទាល់ខ្លួន វាអាចមានន័យថាជាការអានត្រួសៗ ដើម្បីយើងអាចរកឃើញនូវចំណុចលម្អិត ឬក៏គំនិតដែលមានសារៈសំខាន់។ ផ្ទុយទៅវិញ «ការយល់ដឹង» ផ្អែកលើភស្តុតាង វាធ្វើឲ្យយើងស្វែងរកនូវគោលបំណង អំពីអ្វីដែលអ្នកនិពន្ធដើមដំបូង មានគោលបំណង ឲ្យខ្ញុំធ្វើការកត់សម្គាល់ ឬសួរនាំ។

តើអ្នកចាំទេ ពេលដែលអ្នកអាននូវផ្នែកនៃការយល់ដឹងសម្រាប់ការប្រឡងថ្នាក់ទី១២នោះ។ ចាំអំពីអត្ថបទវែងៗដែលអ្នកបានអានទេ ដោយភ្ជាប់មកជាមួយនឹងសំណួរដើម្បីធ្វើការសាកល្បងនូវចំណេះដឹង របស់អ្នកនូវអ្វីដែលអ្នកទើបតែបានអាន? គោលបំណងនៃសំណួរទាំងនោះគឺ បង្ខំអ្នកឲ្យអានដើម្បីស្វែងរកនូវចំណុចលម្អិត។ នេះគឺជា របៀបដែលយើងចាប់ផ្តើមសិក្សាអំពីអត្ថបទរបស់យើងយ៉ាងពិតប្រាកដ។ ដោយសួរខ្លួនយើងថា «តើអត្ថបទនេះនិយាយអំពីអ្វី?» នេះមិនមែនជារឿងងាយស្រួលឡើយ គឺវាត្រូវការឲ្យយើងបន្ថយល្បឿននៅពេលដែលយើងអាន។ នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិជំពូក១ អ្នកដែលយល់ដឹងអំពីសាច់រឿងនៃការបង្កើតទាំង៦ថ្ងៃ អាចប្រាប់អ្នកយ៉ាងពិសេសនូវអ្វីដែលបានកើតឡើងក្នុងថ្ងៃនីមួយៗ។ ជំហានដំបូងនៃការយល់ដឹង គឺអ្វីដែលអត្ថបទបាននិយាយនឹងនាំយើងឲ្យអាចធ្វើការកាត់ស្រាយ និងអនុវត្តសាច់រឿងនៃការបង្កើតចូលទៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងបាន។

អ្នកសាងសង់ល្អប្រើនូវឧបករណ៍ដែលល្អៗ តើឧបករណ៍អ្វីដែលយើងអាចប្រើដើម្បីចាប់ផ្តើមសាងសង់ការយល់ដឹងអំពីអត្ថបទ? ខ្ញុំសូមផ្តល់ជូននូវចំណុចទាំង៦នេះ៖



Khmer Women of the word_Layout.indd 126 12/3/26 3:56 in the afternoon

## ១. ចតចម្លងអត្ថបទ

ប្រសិនបើ អ្នករកមើលនៅក្នុងទូរដាក់សៀវភៅរបស់ខ្ញុំ អ្នកនឹងមិនសូវចំណាយពេលយូរប៉ុន្មានទេក្នុងការដឹងថា សៀវភៅមួយណាដែលខ្ញុំស្រឡាញ់ជាងគេ។ សៀវភៅណាដែលចាស់សឹក ឬរហែកជាចំណុចដំបូងដែលនឹងនាំអ្នក ប៉ុន្តែ សៀវភៅណាដែលមានបត់ទំព័រជាច្រើន នោះនឹងបង្ហាញឲ្យឃើញច្បាស់ថា វាជាសៀវភៅដែលខ្ញុំចូលចិត្តៈ គែមទំព័រមានសរសេរកំណត់សម្គាល់កថាខ័ណ្ឌដែលចូលចិត្តគឺ ត្រូវបានដាក់វាជាចំណុចសំខាន់ ឃ្លា ប្រយោគដែលពីរោះត្រូវបានគូសបន្ទាត់ពីក្រោម គំនិតណាដែលមិនយល់ស្របគឺ មានកំណត់សម្គាល់ដោយសញ្ញាខ្វែងធំមួយ និងមានការផ្តល់នូវគំនិតយោបល់ផងដែរ។ ប៉ុន្តែ ប្រសិនបើអ្នកបើកព្រះគម្ពីររបស់ខ្ញុំ អ្នកនឹងឃើញតែអត្ថបទព្រះគម្ពីរប៉ុណ្ណោះ មិនមានការសរសេរកំណត់សម្គាល់អ្វីទាំងអស់។ ហេតុអ្វីបានជាមិនមាន កំណត់សម្គាល់នៅលើសៀវភៅដែលពិសេសបំផុត និងជាកម្មសិទ្ធិរបស់ខ្ញុំដូចនេះ? ពីព្រោះមិនមានកន្លែងគ្រប់គ្រាន់ឡើយ។

អ្នកនឹងមិនដែលសរសេរកំណត់សម្គាល់នៅលើគែមពណ៌មាស និង នៅលើក្រដាសស្តើងដែលមានអក្សរតូចៗ នៅលើទំព័រក្នុងព្រះគម្ពីររបស់អ្នកឡើយ តាមរបៀបដែលត្រឹមត្រូវក្នុងការធ្វើកំណត់សម្គាល់។ នៅពេលដែលអ្នកសិក្សាអំពីអត្ថបទព្រះគម្ពីរ សូមចតចម្លងចេញនៅលើក្រដាសដែលមានចន្លោះគុណនឹងពីររឹងស្អាតជាមួយនឹងទំហំពុម្ពអក្សរធំ។ សូមចតចម្លងនូវអត្ថបទដែលអាចឲ្យអ្នកមានកន្លែង និងសេរីភាពក្នុងការធ្វើកំណត់សម្គាល់ជាពាក្យ ឬឃ្លា ឬគំនិតដូចៗគ្នា និងអាចសរសេរអក្សរពណ៌ក្រហមធំនៅគែមទំព័រជាមួយនឹងពាក្យ "តើកន្លែងនេះមានន័យយ៉ាងដូចម្តេច?"។ សូមចតចម្លងនូវអត្ថបទដែលអាចឲ្យអ្នកធ្វើការ ពន្យល់បន្ថែមទៅលើអត្ថបទដូចជាសិស្សគ្រប់គ្នាបានធ្វើដែរ។ សូមចាប់ផ្តើម និងរៀបចំខ្លួនអ្នកជាមួយនឹងប្រអប់ខ្មៅដៃពណ៌ប្រដាប់គូរពណ៌ពីលើចំណុចដែលសំខាន់ នៅពេលដែលអ្នកកំពុងតែធ្វើការសិក្សាចំណាយពេលឲ្យបានច្រើនបន្តិចថែមទៀតជាមួយនឹងការនេះ។



Khmer Women of the word_Layout.indd 127 12/3/26 3:56 in the afternoon

យ៉ាកុប ១:១-១៨

## ការជម្រាបសួរ

១សំបុត្រយ៉ាកុប ជាបាវបម្រើរបស់ព្រះ ហើយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទខ្ញុំផ្ញើមកជម្រាប
សួរដល់ពូជអំបូរទាំង១២ ដែលត្រូវខ្ចាត់ខ្ចាយ ។

## ការល្បងលសេចក្ដីជំនឿ

២បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្ដីល្បួងផ្សេងៗនោះត្រូវរាប់ជាសេចក្ដី
អំណរសព្វគ្រប់ វិញ ។ ៣ដោយដឹងថាការល្បងលមើលសេចក្ដីជំនឿនៃអ្នករាល់គ្នានោះ
នាំបង្កើតឲ្យមានសេចក្ដីខ្ជាប់ខ្ជួន ។ ៤ចូរទុកឲ្យសេចក្ដីខ្ជាប់ខ្ជួននោះបានធ្វើការឲ្យសម្រេច
ពេញលេញចុះ ដើម្បីឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ ។
៥តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះដែលទ្រង់ប្រទានដល់មនុស្ស
ទាំងអស់ដោយសទ្ធាឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ ។ ៦តែត្រូវឲ្យអ្នកនោះសូម
ដោយចិត្តជឿឥតសង្ស័យ អ្វីសោះ ដ្បិតអ្នកណាដែលសង្ស័យនោះប្រៀបដូចជារលកសមុទ្រ
ដែលត្រូវផាត់ដោយខ្យល់ទាំងរំពើកចុះឡើង ។ ៧កុំឲ្យមនុស្សយ៉ាងនោះនឹកស្មានថាខ្លួននឹង
បានអ្វីអំពីព្រះអម្ចាស់ឡើយ ។៨ដ្បិតអ្នកនោះជាមនុស្សមានចិត្ត២ចេះតែសារ៉ាក្នុងគ្រប់ផ្លូវ
ទាំងអស់ ។
៩ត្រូវឲ្យបងប្អូនណា ដែលមានសណ្ឋានទាបថោកបានត្រេកអរ ដោយបានដំកើង
ឡើង ។ ១០ហើយអ្នកមានត្រូវអរសប្បាយ ដោយត្រូវបន្ទាបចុះវិញដ្បិតគេនឹងបាត់ទៅដូច
ជាផ្កាស្មៅ ។ ១១ពីព្រោះថ្ងៃរះឡើងមានចំហាយក្តៅរលោណា នោះធ្វើឲ្យស្មៅក្រៀមស្វិត
ហើយផ្កាក៏រោយចុះ ឯលំអក៏វិនាសសូន្យទៅ ដូច្នេះអ្នកមានក៏នឹងត្រូវស្រពោនទៅក្នុងផ្លូវខ្លួន
យ៉ាងនោះដែរ ។



Khmer Women of the word_Layout.indd 128 12/3/26 3:56 in the afternoon

១២មានពរហើយមនុស្សណាដែលស៊ូទ្រាំនឹងសេចក្ដីល្បួង ដ្បិតកាលណាត្រូវល្បងល
“មិនងាយ” ប៉ុន្តែ ទទួលបានជំនួយ និងសេចក្ដីសម្រេច ពីព្រះអម្ចាស់ផ្ទាល់!
ឃើញថាខ្ជាប់ខ្ជួនហើយ នោះនឹងទទួលបានមកុដនៃជីវិត ដែលព្រះអម្ចាស់ទ្រង់សន្យានឹង
ប្រទានឲ្យដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់ ។១៣កាលណាមានសេចក្ដីល្បួង នោះកុំឲ្យ
អ្នកណានិយាយថាព្រះទ្រង់ល្បួងខ្លួនឡើយ ដ្បិតសេចក្ដីអាក្រក់ពុំអាចនឹងល្បួងនាំព្រះហឫទ័យ
លោកុប្បត្តិ 3:11-17 ការដាំ និងលាយការនេះ
ព្រះបានឡើយ ហើយព្រះក៏មិនដែលល្បួងអ្នកណាដែរ ។១៤តែដែលគ្រប់គ្នាកើតមាន ខ13: ព្រះអង្គមិនដែលល្បួងព្រោះសេចក្ដីល្បួងឡើយ ។
សេចក្ដីល្បួង នោះគឺដោយសារតែសេចក្ដីប៉ងប្រាថ្នារបស់ខ្លួននាំប្រទាញ ហើយលួង
លោមទេ ។១៥រួចកាលណាសេចក្ដីប៉ងប្រាថ្នាជាប់មានជាផ្ទៃ នោះសំរាលចេញមកជា
អំពើបាប ហើយកាលណាបាបបានពោរពេញឡើង នោះក៏បង្កើតជាសេចក្ដីស្លាប់ ។ ព្រះអម្ចាស់ទ្រង់បង្កើតការល្អ ដែលមានសេចក្ដីសន្យារបស់ទ្រង់ ។

ព្រះមិនល្បួងយើងឡើយ យើងមានកញ្ចក់ ខ្លួនយើងធ្លាក់ទៅក្នុងសេចក្ដីល្បួង និងការល្បួងលោម

១៦បងប្អូនស្ងួនភ្ងាររបស់ខ្ញុំអើយ កុំឲ្យត្រូវបំភាន់ឡើយ ។១៧គ្រប់ទាំងរបស់ដ៏ល្អ ខ16: ព្រះទ្រង់ប្រាប់យើងសេចក្ដីពិត
ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍នោះសុទ្ធតែមកពីស្ថានលើ
គឺមកពីព្រះវរបិតានៃពន្លឺ ដែលទ្រង់មិនចេះប្រែប្រួល សូម្បីតែស្រមោលនៃសេចក្ដីផ្លាស់ប្រែ ខ17: ព្រះអង្គប្រទានអ្វីដែលល្អ ហើយគ្រប់លក្ខណ៍
ក៏គ្មានដែរ ។១៨ទ្រង់បានបង្កើតយើងរាល់គ្នាមកតាមព្រះហឫទ័យទ្រង់ ដោយសារ ខ17: ព្រះអង្គទ្រង់ជាពន្លឺ
ព្រះបន្ទូលដ៏ពិត ប្រយោជន៍ឲ្យយើងបានបែបដូចជាផលដំបូង ក្នុងរបស់ទាំងប៉ុន្មាន ខ17: ព្រះអង្គមិនប្រែប្រួល
ដែលទ្រង់បង្កើតមក ។ ខ18: ព្រះអង្គបាននាំយើងចេញមកដោយព្រះហឫទ័យរបស់ទ្រង់ផ្ទាល់ ។

លោកយ៉ាកុបប្រាប់យើងពីអ្វីដែលល្អ និងអាក្រក់ ។ ព្រះអង្គដែលបង្កើតយើង ទ្រង់មានអ្វីផ្ដល់នូវអ្វីដែលល្អដល់យើង ។

សំណួរ: តើអ្វីដែលខ្ញុំជឿខុស ហើយមានគិតថាជារបស់ល្អ?

សំណួរ: តើការល្បួងអ្វី ដែលខ្ញុំបានឃើញ ដូចជាមិនល្អ តែការចុងក្រោយ ផ្ដល់ឲ្យខ្ញុំនូវអំណោយទាន នៃភាពចាស់ទុំ?



Khmer Women of the word_Layout.indd 129 12/3/26 3:56 in the afternoon

ការប្រើអត្ថបទថតចម្លងសម្រាប់ការយល់ដឹង នៅពេលដែលអ្នកសិក្សាព្រះគម្ពីរ នឹងជួយអ្នកនៅក្នុងការបដិសេធនូវចំណង់ក្នុងការក្រឡេកមើលទៅលើការពន្យល់ក្នុងព្រះគម្ពីរសិក្សា។ អ្នកអាចថតចម្លងអត្ថបទដែលភ្ជាប់មកជាមួយនឹងឯកសារយោងផ្សេងៗបាន យើងនឹងប្រើប្រាស់នូវឯកសារទាំងនោះ។

## ២. *ការអានម្តងហើយម្តងទៀត*

នៅពេលដែលអ្នកមានអត្ថបទថតចម្លងដែលមានគំនូសចំណាំរួចហើយ អ្នកអាចចាប់ផ្តើមនៅក្នុងការអានគឺ អានម្តងហើយម្តងទៀត។ ចំណុចទាក់ទងប្រវត្តិសាស្ត្រ វប្បធម៌ និងគម្លាតនៃភាសាដែលកើតមានឡើងរវាងអ្នកអានក្នុងពេលបច្ចុប្បន្នទៅនឹងព្រះគម្ពីរ បានធ្វើឲ្យការអានម្តងហើយម្តងទៀត គឺជាឧបករណ៍ដ៏មានសារៈសំខាន់ នៅក្នុងការខិតខំប្រឹងប្រែងកសាងការយល់ដឹងរបស់យើង។ និយាយឲ្យងាយស្រួលយល់យើង ប្រហែលជាមិនអាចស្វែងរកឃើញនូវអ្វី ដែលអ្នកនិពន្ធចង់មានទំនាក់ទំនងមកកាន់យើងនៅក្នុងអត្ថបទតែមួយកន្លែងនោះឡើយ។ ជំហានដំបូងនៅក្នុងការយល់ដឹងអំពីអត្ថបទ គឺ ត្រូវអានឲ្យបានច្រើនដងពីដើមរហូតដល់ចប់។ យើងមិនរំពឹងថា អ្នកអានឈុតមួយនៃរឿង «ការកូរសមុទ្រទឹកដោះ» អានម្តង អាចយល់ច្បាស់ដឹងនូវរឿងនោះនិយាយអំពីអ្វីនោះឡើយ យើងក៏មិនត្រូវរំពឹងគិតថាអាចធ្វើដូចនេះជាមួយ នឹងព្រះគម្ពីរបានដែរ។ ការផ្តល់ឲ្យខ្លួនយើងនូវចំណុចដែលទាក់ទងទៅនឹងប្រវត្តិសាស្ត្រ និងបរិបទវប្បធម៌ (គឺ អាននូវឯកសារណែនាំនៅក្នុងព្រះគម្ពីរសិក្សា និងឆ្លើយនូវសំណួរអំពីបុរាណវត្ថុទាំងប្រាំ) យើងកំពុងអានដោយមានការខិតខំស្តាប់នូវអត្ថបទក្នុងនាមជាអ្នកស្តាប់ដើមដំបូង។

តើយើងគួរតែអានអត្ថបទប៉ុន្មានដង? អានឲ្យបានច្រើនដងផ្អែកទៅលើអ្វីដែលយើងត្រូវការ។ សម្រាប់កណ្ឌគម្ពីរដែលខ្លីខ្ញុំបានឲ្យស្ត្រីនៅក្នុងថ្នាក់សិក្សាព្រះគម្ពីររបស់ខ្ញុំ អានមួយចប់នៃកណ្ឌនៃគម្ពីរនោះរៀងរាល់សប្តាហ៍មុនពេលពួកគេចាប់ផ្តើមខគម្ពីរជាក់លាក់ ដែលយើងកំពុងសិក្សា។ នេះមាន



Khmer Women of the word_Layout.indd 130 12/3/26 3:56 in the afternoon

ន័យថា ពួកគេនឹងអានកណ្ឌគម្ពីរយ៉ាកុបយ៉ាងហោចណាស់១១ដង នៅពេលវគ្គសិក្សាបានបញ្ចប់។ សម្រាប់កណ្ឌគម្ពីរដែលវែងគឺ ត្រូវអានសៀវភៅនោះទាំងមូល ជាទូទៅពីរទៅបីដងគឺគ្រប់គ្រាន់មុនពេលដាក់បញ្ចូលគ្នាជាមួយនឹងសៀវភៅជួយឲ្យមានការយល់ដឹងផ្សេងៗទៀត។ ត្រូវមានភាពស្មោះត្រង់ជាមួយនឹងកម្រិតនៃជំនាញផ្ទាល់ខ្លួនរបស់អ្នក ប្រសិនបើអ្នកថ្មីនៅក្នុងការអានព្រះគម្ពីរ ដើម្បីយល់ដឹងអ្នកប្រហែលត្រូវការជំនួយក្នុងការអានព្រះគម្ពីរដំបូង ច្រើនជាងអ្នកដែលធ្លាប់បានប្រើសម្ភារៈនោះយូរមកហើយ។

ការអានម្តងហើយម្តងទៀតផ្តល់ឲ្យសិស្សនូវគុណប្រយោជន៍ពីរយ៉ាង៖ ការចងចាំព្រះគម្ពីរ និងការស្គាល់នូវអត្ថបទព្រះគម្ពីរ។ សម្រាប់យើងទាំងអស់គ្នាដែលមិនសូវចងចាំព្រះគម្ពីរ ការអានម្តងហើយម្តងទៀត គឺជាវិធីមួយដ៏ល្អបំផុតក្នុងការកាន់តែយល់ព្រះបន្ទូល។ ខ្ញុំហៅការនេះថា «វិធីសាស្រ្តខ្ជិល» ក្នុងការចងចាំព្រះគម្ពីរ។ ប៉ុន្តែ ត្រូវណាស់ វាមិនមែនជាការខ្ជិលទាំងស្រុងនោះទេ វាជាការយល់ដឹងច្បាស់។ ភាពដដែលៗគឺជា វិធីដែលយើងរៀនមុនដំបូងគេកាលពីពេលដែលយើងនៅជាកុមារគឺជា របៀបដែលយើងរៀនច្រៀងចម្រៀងគោរពទង់ជាតិ និងដកស្រង់នូវឃ្លាគេនិយាយក្នុងខ្សែភាពយន្តដែលយើងចូលចិត្តជាដើម។ ការអានម្តងហើយម្តងទៀតជួយយើងឲ្យចងចាំព្រះគម្ពីរនៅក្នុងវិធីមួយដែលល្អ និងអាចធ្វើទៅបាននៅក្នុងបរិបទដើម។ យើងប្រហែលជាមិនចាំអត្ថបទទាំងមូលទេ ប៉ុន្តែយើងចាប់ផ្តើមចងចាំអំពីព្រះគម្ពីរទាំងនោះបាន ដែលវាជាផ្នែកមួយជួយឲ្យយើងមានការយល់ដឹងច្រើនទៅលើព្រះគម្ពីរទាំងមូលដែលយើងអាន។ នៅពេលណាដែលយើងចងចាំខព្រះគម្ពីរដោយមិនបានដឹងអ្វីដែលបានកើតឡើងពីមុន និងក្រោយខគម្ពីរនោះ យើងនឹងជួបនូវគ្រោះថ្នាក់យ៉ាងពិតប្រាកដក្នុងការអនុវត្តខុស។

ទីបំផុត យើងទទួលបានការយល់ដឹងទូទៅជាមួយនឹងអត្ថបទដែលយើងអានម្តងហើយម្តងទៀតនៅពេលយើងអានសៀវភៅ ឬអត្ថបទដែលកាន់តែវែងយើងនឹងមើលឃើញបាវចនា និងរចនាសម្ព័ន្ធទូទៅកាន់តែច្រើនផង



Khmer Women of the word_Layout.indd 131 12/3/26 3:56 in the afternoon

ដែរ។ វានឹងជួយយើងឲ្យមានការយល់ដឹងនូវចំណុចបន្ទាប់ ដែលមាននៅក្នុងបញ្ជីឧបករណ៍នៃការយល់ដឹងរបស់យើង៖ ការបង្កើតគ្រោងទម្រង់។ សូមចាំនៅដើមដំបូងនៃការសិក្សាទម្រង់របស់យើងគឺ អានម្តងហើយម្តងទៀតដើម្បីទទួលបានការយល់ដឹងជា លក្ខណៈទូទៅ អំពីអត្ថបទ—នេះគឺជាចំណុចចាប់ផ្តើមនៃការយល់ដឹង។ ការអានម្តងហើយម្តងទៀត មិនតម្រូវឲ្យយើងព្រួយបារម្ភទៅលើអត្ថន័យ ឬក៏ស្វែងរកវិធីដើម្បីអនុវត្តនូវអ្វីដែលជាសេចក្តីពិតនោះឡើយ។ ជាទូទៅយើងប្រើវាជាលក្ខណៈនៃការណែនាំ ដូចជាការសន្ទនាពីរបីសាច់រឿងដែលយើងមានជាមួយនឹងមនុស្សថ្មី។

## ៣. ចំណុចពន្យល់

នៅពេលដែលយើងអានចប់ជាលើកទីមួយហើយ សូមចាប់ផ្តើមសរសេរលើអត្ថបទរបស់អ្នកក្នុងការអានជាបន្ទាប់ ដើម្បីទទួលបានចំណុចដែលល្អប្រសើរអំពីអ្វីដែលមាននៅក្នុងអត្ថបទនោះ។

- តើមានពាក្យ ឃ្លា ឬក៏គំនិតខ្លះៗ ដែលនិយាយម្តងហើយម្តងទៀតឬទេ? សូមប្រើខ្មៅដៃពណ៌របស់អ្នកកត់សម្គាល់ចំណុចនោះ នៅលើក្រដាសចតចម្លងអត្ថបទដោយខ្សែរបស់អ្នក។ អ្នកអាចកំណត់របៀបដែលអ្នកចូលចិត្ត ដូចជាគូរវង្វង់, គូរប្រអប់, គូរបន្ទាត់ពីក្រោមខុសៗគ្នា ឲ្យបានខ្ជាប់ខ្ជួន និងធ្វើទៅតាមអ្វីដែលអ្នកអាចយល់បានច្បាស់ដោយខ្លួនឯង។
- តើមានលក្ខណរបស់ព្រះជាម្ចាស់បានបើកសម្តែង ឬលើកតម្កើងដែរឬទេ? សូមសរសេរនៅគែមដើមទំព័រ។
- តើអត្ថបទបានលើកឡើងចំណុចមួយចំនួនជាបន្តបន្ទាប់ដែរឬទេ? សូមរាប់ចំណុចនីមួយៗ ដែលបានណែនាំនៅក្នុងអត្ថបទ។
- តើមានពាក្យណាមួយដែលអ្នកអត់យល់ដែរឬទេ? សូមកត់សម្គាល់ពាក្យទាំងនោះជាមួយនឹងសញ្ញាសំណួរ ដើម្បីឲ្យអ្នកអាចស្វែងរកនិយមន័យសម្រាប់ពាក្យទាំងនោះ។



Khmer Women of the word_Layout.indd 132 12/3/26 3:56 in the afternoon

- តើមានពាក្យភ្ជាប់ពិសេសដែរឬទេដូចជា ប្រសិនបើ/បន្ទាប់មក ហេតុដូច្នេះ ដូចគ្នាផងដែរ ប៉ុន្តែ, ពីព្រោះ, ឬក៏ពាក្យ ដូចគ្នាទៅនឹង? គូសសញ្ញាព្រួញភ្ជាប់ពីចំណុចសន្និដ្ឋានទៅកាន់ហេតុផលដើម។
- តើមានគំនិតរឿងឆ្ងល់ណាមួយដែរឬទេ? សូមសរសេរសំណួររបស់អ្នកនៅគែមទំព័រ ដើម្បីគូសបញ្ជាក់ពេលក្រោយ។

## *៤. វចនានុក្រម*

ដើម្បីធ្វើការពិនិត្យមើល យើងប្រើវចនានុក្រម ដើម្បីស្វែងរកពាក្យដែលយើងមិនធ្លាប់ស្គាល់ ឬក៏ពាក្យដែលស្រដៀងៗគ្នា។ ការប្រើប្រាស់វចនានុក្រមពិតជាជួយបានច្រើនណាស់។ អ្នកបកប្រែជ្រើសរើសពាក្យយកមកប្រើ គឺមានការយកចិត្តទុកដាក់ខ្លាំងណាស់។ ការយល់ដឹងរបស់យើងអំពីអ្វីដែលមាននៅក្នុងអត្ថបទ គឺកើនឡើងតាមរយៈការរកមើលពាក្យដែលពិបាកនៅក្នុងវចនានុក្រម។ វិធីមួយដែលតែងតែកើតមានឡើង គឺយើងប្រញាប់ចេញពីដំណាក់កាលនៃការយល់ដឹងលឿនពេក ដោយគិតថា យើងបានយល់នូវនិយមន័យនៃពាក្យដែលយើងបានអានហើយ។ យើងប្រហែលត្រូវចំណាយពេលមើលពាក្យ ការផ្សះផ្សា ប៉ុន្តែតើយើងមានបានចំណាយពេលមើលពាក្យដែលស្រដៀងគ្នា ដូចជា បរិសុទ្ធ ការញែកជាបរិសុទ្ធ កិត្តិយស ឬក៏ ការតស៊ូដែរឬទេ? តាមរយៈការបង្អង់សិន និងគិតពិចារណាទៅលើអត្ថន័យនៃពាក្យដែលសំខាន់ ឬក៏ពាក្យដែលយើងមិនធ្លាប់បានស្គាល់ នោះយើងអាចឈានចូលទៅរកការយល់ដឹងបាន។ សូមមើលពាក្យដែលយើងបានដាក់ជាសំណួរបន្ទាប់មកដោយផ្អែកទៅលើបរិបទ សរសេរចុះនូវនិយមន័យដែលត្រូវជាងគេសម្រាប់ប្រើនៅក្នុងអត្ថបទនោះ។ បន្ទាប់មកធ្វើកំណត់សម្គាល់និយមន័យនៅលើគែមនៃទំព័រដែលយើងបានថតចម្លងនោះ។



Khmer Women of the word_Layout.indd 133 12/3/26 3:56 in the afternoon

## ៥. ព្រះគម្ពីរបកប្រែផ្សេងៗ

ការអានអត្ថបទព្រះគម្ពីរត្រូវការការបកប្រែពីរទៅបីផ្សេងគ្នា ដើម្បីជួយពង្រីកការយល់ដឹងរបស់អ្នកអំពីអត្ថន័យនៃព្រះគម្ពីរ។ ប្រសិនបើជាធម្មតាអ្នកប្រើព្រះគម្ពីរបរិសុទ្ធបកប្រែនៅឆ្នាំ១៩៥៤ (ពគម) សម្រាប់ប្រៀបធៀបខព្រះគម្ពីរដែលពិបាកទៅនឹងការបកប្រែផ្សេងៗ ដូចជាព្រះគម្ពីរដ៏វិសុទ្ធ (គខប) បកប្រែនៅឆ្នាំ២០០៥ ព្រះគម្ពីរបរិសុទ្ធកែសម្រួល (ពកស) បកប្រែនៅឆ្នាំ២០១៤ ហើយបញ្ចប់នៅឆ្នាំ២០១៦ ព្រះគម្ពីរគ្រីស្ទបរិស័ទខ្មែរ (ពគខ) បកប្រែដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត ឬក៏ព្រះគម្ពីរខ្មែរសាកល (ពខស) ពេលខ្លះអាចជួយដល់ការភ័ន្តច្រឡំបានផងដែរ។ វាពិតជាសំខាន់ណាស់ដែលអ្នកត្រូវកត់សម្គាល់អំពីភាពខុសគ្នារវាងការបកប្រែ និងការបកស្រាយនៅក្នុងអត្ថបទ។ ការបកប្រែគឺ ផ្តោតទៅលើភាសាដើមរក្សានូវចំណុចដែលថា «តើអត្ថបទនេះនិយាយអំពីអ្វី?» សម្រាប់ភាសាហេព្រើរ និងក្រិក ដូចដែលពួកគេបកប្រែភាសាពាក្យទៅតាមពាក្យ ឬក៏គំនិតទៅតាមគំនិតជាភាសាខ្មែរ។ ការបកស្រាយ ដូចជានៅក្នុង ព្រះគម្ពីរដ៏វិសុទ្ធ ផ្តោតទៅលើភាសាដើមដែលបានសួរថា «តើអត្ថបទនេះមានន័យយ៉ាងដូចម្តេច?» ពួកគេបកស្រាយ។ ព្រះគម្ពីរដែលបកប្រែបែបជាការបកស្រាយអាចមានប្រយោជន៍ ប៉ុន្តែគួរតែចាត់ទុកប្រើដូចជាការបកស្រាយអត្ថាធិប្បាយដែរ (ការបកស្រាយរបស់មនុស្សទៅលើព្រះបន្ទូលរបស់ព្រះ)។ ការបកស្រាយនឹងក្លាយទៅជាការប្រឹក្សាបានល្អ បន្ទាប់ពីមានការសិក្សាដោយយកចិត្តទុកដាក់ទៅលើការបកប្រែដែលត្រឹមត្រូវ។ សូមចាំនូវចំណុចទាំងនេះ យើងនឹងនិយាយនៅជំហានបន្ទាប់ទៀត។

## ៦. គម្រោងទម្រង់

បន្ទាប់ពីពេលដែលអ្នកអានអត្ថបទពីរទៅបីដងហើយ និងបានសរសេរការពន្យល់លើអត្ថបទ ហើយស្វែងរកនិយមន័យនៃពាក្យ ហើយប្រៀបធៀបជាមួយនឹងការបកប្រែផ្សេងៗ អ្នកអាចផ្តើមរៀបចំនូវអ្វីដែលអ្នកបានអានទៅ



Khmer Women of the word_Layout.indd 134 12/3/26 3:56 in the afternoon

ជាទម្រង់មួយ។ នៅពេលដែលយើងរៀបចំគម្រោងទម្រង់ យើងត្រូវទទួលស្គាល់នូវអ្វីដែលជាគោលបំណងដើមរបស់អ្នកនិពន្ធដំបូង ហើយព្យាយាមស្វែងយល់អំពីគោលបំណងនោះ។

អ្នកមិនចាំបាច់ក្លាយទៅជាអ្នកប្រាជ្ញខាងឯព្រះគម្ពីរដើម្បីសរសេរនូវគម្រោងទម្រង់នោះឡើយ។ អ្នកគ្រាន់តែត្រូវព្យាយាមឲ្យអស់ពីសមត្ថភាព បន្ទាប់មកប្រៀបធៀបជាមួយនឹងអ្វីដែលអ្នកប្រាជ្ញផ្សេងៗបាននិយាយ។ សូមស្វែងរកនូវចំណុចសំខាន់ និងចំណុចបន្ទាប់បន្សំដែលគាំទ្រឲ្យចំណុចសំខាន់នោះ។ មិនមែនគ្រប់ទម្រង់នៃកណ្ឌគម្ពីរទាំងអស់សុទ្ធតែមានរបៀបរៀបរយនោះទេ ពេលខ្លះកាលប្រវត្តិនៃសាច់រឿងមានភាពស្មុគស្មាញ ឬពេលខ្លះ អ្នកនិពន្ធបានបង្ហាញប្រធានបទនៅក្នុងអត្ថបទលើសពីមួយក៏ថាបាន។ គម្រោងទម្រង់របស់អ្នកមិនចាំបាច់មានភាពល្អិតល្អនោះទេ អ្វីដែលសំខាន់គឺ ជួយអ្នកឲ្យមើលឃើញនូវរចនាសម្ព័ន្ធទូទៅ និងអ្វីដែលជាគោលបំណងរបស់អត្ថបទ មិនចាំបាច់ប្រមូលមកនូវគ្រប់គំនិតទាំងអស់ឡើយ។ អ្នកអាចពិនិត្យគម្រោងរបស់អ្នកឡើងវិញ នៅពេលដែលការសិក្សា និងការស្គាល់អត្ថបទរបស់អ្នកមានការរីកចម្រើន។ ជាទូទៅ នៅចុងការសិក្សារបស់ខ្ញុំ ជារឿយៗខ្ញុំមើលនូវគម្រោងទម្រង់ដើមដំបូងរបស់ខ្ញុំ ហើយស្វែងរកវិធីដែលល្អដើម្បីរៀបចំអត្ថបទរបស់ខ្ញុំ។

ការអានម្តងហើយម្តងទៀត ការសរសេរពន្យល់បន្ថែមលើអត្ថបទថតចម្លង ស្វែងរកពាក្យគន្លឹះប្រៀបធៀបការបកប្រែ និងការធ្វើគម្រោងទម្រង់ ទាំងអស់នេះពិតជាបានជួយយើងឲ្យមានការយល់ដឹងនូវជំហានដំបូង «តើអត្ថបទនេះនិយាយអំពីអ្វី?» ការស្វែងយល់អំពីអត្ថបទនិយាយអំពីអ្វី វាគឺជាគោលដៅដ៏មានប្រយោជន៍ខ្លាំងណាស់សម្រាប់ការចំណាយពេលវេលា នៅក្នុងការសិក្សារបស់អ្នក។ ការយល់ដឹងដែលសមស្រប នឹងជួយឲ្យអ្នកមានការកាត់ស្រាយដែលសមស្រប ហើយក៏នឹងធ្វើឲ្យមានការអនុវត្តកើតឡើងផងដែរ។



Khmer Women of the word_Layout.indd 135 12/3/26 3:56 in the afternoon

## ដំណាក់កាលទី២៖ ការកាត់ស្រាយ—«តើវាមានន័យយ៉ាងដូចម្តេច?»

នៅពេលដែលការយល់ដឹងសួរ "តើវានិយាយអំពីអ្វី?" ការកាត់ស្រាយសួរថា "តើវាមានន័យយ៉ាងដូចម្តេច?" នៅពេលដែលយើងបានខិតខំប្រឹងប្រែងដើម្បីយល់ពីរចនាសម្ព័ន្ធ ភាសា និងចំណុចជាក់លាក់នៃអត្ថបទ ឥឡូវយើងត្រៀមរួចរាល់នៅក្នុងការមើលទៅលើអត្ថន័យម្តង។ អ្នកដែល យល់ដឹង អំពីសាច់រឿងនៃការបង្កើតទាំង៦ថ្ងៃ នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិជំពូក១ អាចប្រាប់អ្នកយ៉ាងពិសេសនូវអ្វីដែលបានកើតឡើងក្នុងថ្ងៃនីមួយៗ។ អ្នកដែល កាត់ស្រាយ សាច់រឿងអំពីការបង្កើតអាចប្រាប់អ្នកអំពីហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតពិភពលោក នៅក្នុងវិធីមួយដែលមានរបៀបរៀបរយ និងតាមលំដាប់លំដោយ។ អ្នកអាចសន្និដ្ឋានហេតុការណ៍នេះចេញពីអត្ថបទ លើសពីអ្វីដែលអត្ថបទបាននិយាយ។

យើងទាំងអស់គ្នាភាគច្រើនពឹងផ្អែកទៅលើការអធិប្បាយ ការសិក្សាទៅលើកំណត់សម្គាល់នៃព្រះគម្ពីរ និងសៀវភៅសេចក្តីអធិប្បាយដើម្បីជួយយើងនៅក្នុងការកាត់ស្រាយ។ ការនេះពិតជាសមហេតុផលដូច ដែលយើងបានពិភាក្សារួចហើយអំពីភាពចាំបាច់នៃសម្ភារៈទាំងនេះ ក្នុងការជួយយើងដើម្បីឆ្លើយនូវសំណួរអំពីបុរាណវត្ថុទាំងប្រាំ។ ក្នុងចំណោមយើងទាំងអស់គ្នា ព្រះជាម្ចាស់ពិតជាបានប្រទានអំណោយទានដល់មនុស្សនូវចំណេះ និងការយល់ដឹងដែលជាក់លាក់។ ហើយជាការល្ងង់ល្ងើណាស់ប្រសិនបើយើងរំលងការរួមចំណែករបស់ពួកគេទៅក្នុងការសិក្សារបស់យើង។ ពួកគេបានផ្តល់នូវការបម្រើដ៏សំខាន់សម្រាប់ការស្អាងរូបកាយគ្រីស្ទបរិស័ទ។ ប៉ុន្តែ យើងត្រូវចងចាំថា ព្រះជាម្ចាស់បានត្រាស់ហៅយើងជាបុគ្គលម្នាក់ៗឲ្យស្រឡាញ់ទ្រង់ជាមួយនឹងគំនិតរបស់យើងដែរ។ នេះមានន័យថា វាគឺជាការល្អសម្រាប់យើងនៅក្នុងការធ្វើការកាត់ស្រាយយ៉ាងស្មោះត្រង់ដោយខ្លួនឯងជាមុនសិន គឺមុនពេលយើងអានការកាត់ស្រាយរបស់អ្នកដទៃទៀត។ ហើយចំណុចនេះក៏មានន័យ



Khmer Women of the word_Layout.indd 136 12/3/26 3:56 in the afternoon

ថា ឲ្យយើងចាំសិនមុននឹងប្រឹក្សាយោបល់ជាមួយនឹងសៀវភៅសេចក្តីអត្ថាធិប្បាយ ព្រះគម្ពីរសិក្សា ការចាក់ផ្សាយពន្យល់ កំណត់ហេតុបណ្តាញ និងការបកស្រាយពន្យល់នានា ដើម្បីឲ្យទទួលបានការយល់ដឹង គឺយើងត្រូវចាំរហូតទាល់តែយើងបានចាប់ផ្តើមព្យាយាមកាត់ស្រាយឲ្យអស់ពីសមត្ថភាពរបស់យើង តាមដែលយើងអាចធ្វើទៅបាន។

ដូច្នេះ មុនពេលយើងប្រើប្រាស់ធនធានទាំងនោះជាជំនួយ គឺមានធនធានពីរដែលនឹងជួយយើងឲ្យអាចធ្វើការកាត់ស្រាយដោយខ្លួនឯងជាមុនបាន។

## *១. ខគម្ពីរយោង*

ខគម្ពីរយោងគឺជា ខគម្ពីរដែលបានដាក់នៅគែមទំព័រ ឬនៅផ្នែកខាងក្រោមនៃទំព័រ នៅក្នុងព្រះគម្ពីរសិក្សា។ វាបញ្ជាក់អំពីភាពដូចគ្នាទៅលើផ្នែកផ្សេងទៀតនៃព្រះគម្ពីររវាងប្រធានបទស្រដៀងគ្នា ពាក្យ ព្រឹត្តិការណ៍ ឬក៏មនុស្សជាដើម។ អ្នកប្រហែលធ្លាប់ឮអំពីឃ្លានេះ «សូមឲ្យព្រះបន្ទូលកាត់ស្រាយព្រះបន្ទូល» នេះគឺជា គោលការណ៍មូលដ្ឋានដំបូងគេនៃការកាត់ស្រាយ។ វាគឺជាគំនិតដ៏ល្អបំផុតនៅក្នុងការដឹងថាតើព្រះគម្ពីរ និយាយអំពីអ្វី ដោយមើលទៅកាន់កន្លែងផ្សេងៗទៀតនៃព្រះគម្ពីរដែលនិយាយដូចគ្នា ឬទៅលើចំណុចដែលស្រដៀងគ្នា។ ខគម្ពីរយោងជួយយើងក្នុងការឲ្យតម្លៃទៅលើគោលការណ៍ដើម និងគួរតែប្រើជាចំណុចដើម ដំបូងនៅក្នុងការរកចម្លើយលើសំណួរ «តើវាមានន័យយ៉ាងដូចម្តេច?»។ នៅពេលដែលអ្នកអានអត្ថបទដែលមានការពិបាកយល់ សូមប្រើប្រាស់ខគម្ពីរយោងជាមុនសិន ដើម្បីជួយបន្ថែមដល់ការយល់ដឹងរបស់អ្នក។

## *២. ការបកស្រាយ*

ការបកស្រាយគឺជា ជំនាញនៅក្នុងការសរសេរគំនិតរបស់អ្នកណាម្នាក់ ចេញពីពាក្យផ្ទាល់ខ្លួនរបស់អ្នក។ ចំណុចនេះយើងបាននិយាយពីខាងដើមមក



Khmer Women of the word_Layout.indd 137 12/3/26 3:56 in the afternoon

ហើយ ខ្ញុំជឿថាការបកស្រាយគឺជា ចំណុចដែលពិបាកជាងគេ។ វាតម្រូវឲ្យយើងបង្អង់សិន និងមានការអត់ធ្មត់ ប្រសិនយើងគិតថាការបកស្រាយងាយស្រួលប្រហែលមកពី យើងមិនចំណាយពេលផ្តោតឲ្យបានគ្រប់គ្រាន់ទៅនឹងអ្វីដែលចំណុចនេះត្រូវការ។ ប្រសិនបើ យើងបណ្តាក់ទុននៅក្នុងចំណុចនេះ នោះយើងនឹងរីកលូតលាស់នៅក្នុងភាពពេញវ័យរបស់យើងក្នុងនាមជាសិស្ស។

នៅពេលដែលយើងអានខព្រះគម្ពីរ ឬអត្ថបទដែលពិបាកនៅក្នុងការយល់ សូមមើលទៅលើបរិបទមើលទៅលើពាក្យដែលធ្វើឲ្យយើងភ័ន្តច្រឡំនៅក្នុងវចនានុក្រមសិន មើលខព្រះគម្ពីរយោង ហើយបន្ទាប់មកសរសេរអត្ថបទចេញពីពាក្យរបស់អ្នកផ្ទាល់។ ការបកស្រាយជួយអ្នកឲ្យផ្តោតទៅលើអ្វីដែលបាននិយាយ បើទោះជាការបកស្រាយរបស់អ្នកមិនសូវល្អ តែវាបានជំរុញអ្នកឲ្យអានដើម្បីទទួលបានអត្ថន័យ និងចំណុចដែលពិស្តារផងដែរ។ អ្នកមិនចាំបាច់ចែកចាយជាមួយអ្នកណាម្នាក់ឡើយ វាគឺគ្រាន់តែជាឧបករណ៍សម្រាប់អ្នកប្រើផ្ទាល់ខ្លួនទេ។ នៅពេលដែលអ្នកចាប់ផ្តើមផ្ទៀងផ្ទាត់មើលជាមួយនឹងសៀវភៅសេចក្តីអត្ថាធិប្បាយ នោះប្រហែលអ្នកនឹងគិតថា ការបកស្រាយរបស់អ្នកដូចយកជាការអត់បានសោះ។ នោះមិនជាអ្វីទេ។ វានឹងជំរុញអ្នកឲ្យបន្តមើលអត្ថបទ ការអនុវត្តនឹងជួយអ្នកឲ្យសម្រេចបាន និងទទួលនូវអ្វីដែលអ្នកត្រូវការ។

នៅពេលដែលយើងប្រឹងប្រែងធ្វើការយល់ដឹងដោយយកចិត្តទុកដាក់ និងកាត់ស្រាយដោយខ្លួនឯងហើយ យើងត្រៀមរួចរាល់នៅក្នុងការមើលការកាត់ស្រាយរបស់អ្នកដទៃ។ ការប្រឹងប្រែងកាត់ស្រាយដោយខ្លួនឯង មុនពេលមើលការបកស្រាយនៅក្នុងសៀវភៅអត្ថាធិប្បាយ គឺសំខាន់ខ្លាំងណាស់ ពីព្រោះមិនមានសេចក្តីអធិប្បាយពីរដែលនឹងនិយាយដូចគ្នាឡើយ។ ការដែលយើងយល់ដឹង និងកាត់ស្រាយដោយខ្លួនយើងផ្ទាល់ធ្វើឲ្យយើងមើលឃើញថា សេចក្តីអធិប្បាយមួយណាដែលអាចទុកចិត្តបាន ការកាត់ស្រាយមួយណាដែលត្រឹម



Khmer Women of the word_Layout.indd 138 12/3/26 3:56 in the afternoon

ត្រូវ ជាមួយនឹងអ្វីដែលអត្ថបទបាននិយាយ។ គឺត្រូវការពេលវេលានៅក្នុងការស្គាល់អ្នកនិពន្ធ ឬគ្រូបង្រៀន ដែលអ្នកអាចទុកចិត្តសម្រាប់ផ្តល់គំនិត និងការកាត់ស្រាយដែលអាចយកជាការបាន។ សូមសួរគ្រូគង្វាល ឬគ្រូជំនួយរបស់អ្នក សម្រាប់ការណែនាំនៅក្នុងការចាប់ផ្តើមរៀបចំបណ្ណាល័យផ្ទាល់ខ្លួនអំពីអ្នកអត្ថាធិប្បាយដែលអ្នកអាចទុកចិត្តបាន។ នៅពេលដែលអ្នករកបានសៀវភៅនៃសេចក្តីអធិប្បាយដែលអ្នកពេញចិត្តហើយ សូមស្វែងរកកំណត់ហេតុយោងរបស់ពួកគាត់ ដែលនោះជាចំណុចសក្តានុពលនៃធនធានល្អៗផងដែរ។

## ដំណាក់កាលទី៣៖ ការអនុវត្ត—«តើវាបានផ្លាស់ប្រែខ្ញុំយ៉ាងដូចម្តេច?»

យើងបានមកដល់ចំណុចចុងក្រោយអំពីការសិក្សាតាមលំដាប់លំដោយនៃការរៀនសូត្រ ដែលការខិតខំប្រឹងប្រែងរបស់យើងនឹងប្រែក្លាយទៅជាការអនុវត្តម្តង។ បន្ទាប់ពីយើងបានកំណត់ថា តើអត្ថបទព្រះគម្ពីរនិយាយអ្វី និងមានន័យដូចម្តេច នោះយើងបានដល់ដំណាក់កាលដែលអាចសួរថា តើវាគួរមានឥទ្ធិពលលើយើងដូចម្តេច។ ការអនុវត្តសួរថា៖ “តើអត្ថបទព្រះគម្ពីរនេះគួរផ្លាស់ប្តូរខ្ញុំដូចម្តេច?”។

នៅក្នុងជំពូក១ យើងបានទទួលស្គាល់ថាព្រះគម្ពីរគឺជាសៀវភៅនិយាយអំពីព្រះជាម្ចាស់ នៅពេលយើងអនុវត្តទៅលើអត្ថបទ យើងត្រូវរម្លឹកខ្លួនយើងម្តងទៀតថា ចំណេះដឹងអំពីព្រះជាម្ចាស់ និងចំណេះអំពីខ្លួនយើងត្រូវដើរទន្ទឹមគ្នា គឺថាមិនមានចំណេះដឹងដ៏ពិតប្រាកដអំពីខ្លួនយើង ដាច់ចេញពីចំណេះដឹងអំពីព្រះជាម្ចាស់ឡើយ។ ការយល់ដឹងអំពីទស្សនៈដែលយកព្រះជាម្ចាស់ជាចំណុចកណ្តាល សំណួរសួរថា “តើអត្ថបទនេះនឹងផ្លាស់ប្រែខ្ញុំយ៉ាងដូចម្តេច?” មានសំណួរតូចៗ៣សម្រាប់ឆ្លើយទៅនឹងឃ្លានេះ៖

- តើអត្ថបទព្រះគម្ពីរនេះបង្រៀនខ្ញុំអ្វីខ្លះអំពីព្រះជាម្ចាស់?



Khmer Women of the word_Layout.indd 139 12/3/26 3:56 in the afternoon

- តើទិដ្ឋភាពអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ផ្លាស់ប្តូរការយល់ឃើញរបស់ខ្ញុំអំពីខ្លួនឯងយ៉ាងដូចម្តេចខ្លះ?
- តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីឆ្លើយតប?

អ្នកដែល យល់ដឹង អំពីសាច់រឿង នៃការបង្កើតទាំង៦ថ្ងៃ នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិជំពូក១អាចប្រាប់អ្នកយ៉ាងពិសេសនូវអ្វីដែលបានកើតឡើងក្នុងថ្ងៃនីមួយៗបាន។ អ្នកដែល កាត់ស្រាយ សាច់រឿងអំពីការបង្កើតអាចប្រាប់អ្នកហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតពិភពលោក នៅក្នុងវិធីមួយដែលមានរបៀបរៀបរយ និងតាមលំដាប់លំដោយ។ អ្នកដែល អនុវត្ត សាច់រឿងអំពីការបង្កើតអាចប្រាប់អ្នកថា ពីព្រោះតែព្រះជាម្ចាស់បានបង្កើតនៅក្នុងរបៀបមួយដែលមានរបៀបរៀបរយ នោះយើងក៏ដូចគ្នាផងដែរត្រូវរស់នៅឲ្យមានសណ្តាប់ធ្នាប់ល្អ (យើងនឹងនិយាយច្រើនអំពីចំណុចនេះនៅពេលក្រោយទៀត)។ ចំណេះដឹងអំពីព្រះជាម្ចាស់គឺ បានមកតាមរយៈការយល់ដឹងអំពីអត្ថបទ និងការកាត់ស្រាយអត្ថន័យអំពីអត្ថបទនោះ ឥឡូវនេះអាចអនុវត្តចូលមកក្នុងជីវិតហើយក្នុងរបៀបមួយដែលជំរុញដល់សិស្សឲ្យធ្វើនូវអ្វីដែលមានភាពខុសប្លែកផងដែរ។

## មូលហេតុដែលការសិក្សាតាមលំដាប់លំដោយជាកិច្ចខិតខំប្រឹងប្រែងដ៏មានតម្លៃ

ការសិក្សាដែលប្រើប្រាស់លំដាប់លំដោយអនុញ្ញាតឲ្យយើងមើលឃើញនូវលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ នៅក្នុងព្រះបន្ទូលដោយប្រុងប្រយ័ត្ន តាមរយៈការយល់ដឹង និងការកាត់ស្រាយ។ បន្ទាប់មក ការនោះអនុញ្ញាតឲ្យយើងអនុវត្តព្រះបន្ទូលឲ្យបានត្រឹមត្រូវ នៅក្នុងរបៀបដែលព្រះជាម្ចាស់បានបើកសម្តែងអង្គទ្រង់។ តើដំណើរការនៃការយល់ដឹង ការកាត់ស្រាយ ការអនុវត្តមើលទៅពិបាកដែរឬទេ? ដំបូងអាចពិបាក ប៉ុន្តែយើងនឹងមានការយល់ដឹងកាន់តែច្បាស់នៅពេលដែលយើងកាន់តែប្រើប្រាស់ចំណុចទាំងនេះ។ នេះគឺជា



Khmer Women of the word_Layout.indd 140 12/3/26 3:56 in the afternoon

ការសិក្សាតាមលំដាប់លំដោយ ការសាងសង់គម្រោងរយៈពេលវែងដែលមានអត្ថប្រយោជន៍ផ្ទួនៗ។ ទោះបើអ្នកស្ថិតនៅក្នុងកាលៈទេសៈនៃជីវិត ដែលមិនអនុញ្ញាតឲ្យអ្នកប្រើនូវរបៀបទាំងនេះឲ្យបានជិតដល់យ៉ាងណាក៏ដោយក៏អ្នកនៅតែអាចប្រើវិធីសាស្ត្រទាំងនេះបានច្រើន ទៅតាមពេលវេលាដែលអ្នកមានផងដែរ។ បើអ្នកត្រូវសង់ដោយយឺតៗ ក៏អ្នកត្រូវសង់ដែរ ប៉ុន្តែសូមប្រាកដថាអ្នកសង់ចុះ។ ក្នុងការដើរតាមលំដាប់លំដោយ អ្នកកំពុងតាមគំរូដែលព្រះបានកំណត់ឲ្យផ្ទាល់។

ព្រះជាម្ចាស់ដែលជាព្រះនៃព្រះគម្ពីរ គឺជាព្រះដែលមានរបៀបរៀបរយ។ ពិតណាស់! តាំងពីដើមដំបូងដល់ចុងបញ្ចប់ព្រះបន្ទូលបានកត់ត្រានូវរូបភាពសម្រាប់យើង អំពីព្រះជាម្ចាស់ដែលទ្រង់បង្កើតលោកធាតុតាមលំដាប់លំដោយ។ កណ្ឌគម្ពីរលោកុប្បត្តិជំពូក១ដល់៣បានបង្ហាញអំពីសួនច្បារ ដែលព្រះជាម្ចាស់បង្គាប់បញ្ជាទៅតាមដំណាក់កាល ដោយបង្កើតចេញពីអ្វីដែលទទេ និងគ្មានទម្រង់សោះ។ ទ្រង់បានធ្វើឲ្យមានទម្រង់ និងតួនាទីសម្រាប់៦ដំណាក់កាលបន្តបន្ទាប់គ្នា ពោលគឺព្រះអង្គបានបង្កើតឡើងយ៉ាងឥតខ្ចោះសម្រាប់ព្រះវត្តមានរបស់ព្រះអង្គដែលកំពុងគង់នៅទីនោះដែរ។ កណ្ឌគម្ពីរ វិវរណៈ ជំពូក២១ បានបង្ហាញអំពីទម្រង់ផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលព្រះជាម្ចាស់នឹងរៀបចំឡើងវិញ ចេញពីការធ្លាក់ក្នុងអំពើបាបនៃផែនដីដែលគ្មានសណ្តាប់ធ្នាប់។ ដែលនៅចុងបញ្ចប់ការនេះ គឺជាការបង្ហាញអំពីក្រុងយេរូសាឡឹមថ្មី ដែលរៀបចំយ៉ាងល្អឥតខ្ចោះសម្រាប់ព្រះវត្តមានរបស់ព្រះជាម្ចាស់នឹងគង់នៅទីនោះ។

ប្រសិនបើអ្នកធ្លាប់បានអានកណ្ឌគម្ពីរនិក្ខមនំ នោះអ្នកក៏នឹងដឹងអំពីការនេះផងដែរ គឺជាសាច់រឿងបង្ហាញអំពីការបង្កើតដែលមានរបៀបរៀបរយ។ ព្រះជាម្ចាស់បង្គាប់បញ្ជាដល់ជនជាតិអ៊ីស្រាអែលឲ្យសាងសង់រោងឧបោសថយ៉ាងឥតខ្ចោះ តាមរយៈការសិក្សាតាមលំដាប់លំដោយដែលមានជាបន្តបន្ទាប់ ព្រះអង្គទ្រង់នឹងយាងគង់ក្នុងរបាំងរាំងននោះ។ ពីទំព័រមួយទៅទំព័រ



Khmer Women of the word_Layout.indd 141 12/3/26 3:56 in the afternoon

មួយគឺ ផ្តោតទៅលើចំណុចពិស្តារនៃដំណើរការសាងសង់នូវរចនាសម្ព័ន្ធ ហើយលទ្ធផលចុងក្រោយមកដល់ចំណុចដែលស្រស់ស្អាតនោះគឺ ព្រះជាម្ចាស់ និងមនុស្សមានទំនាក់ទំនងជាមួយគ្នាឡើងវិញ។ គឺខុសប្លែកគ្នាទៅនឹងសាច់រឿងនៃការបង្កើតក្នុងសួនច្បារអេដែន និងក្រុងយេរូសាឡឹមថ្មីមាន ព្រះជាម្ចាស់តែអង្គឯងទេ ដែលទ្រង់ជាអ្នកសាងសង់ តែនៅក្នុងការសាងសង់រោងឧបោសថព្រះជាម្ចាស់បានឲ្យមនុស្សមានការរួមចំណែក។ ព្រះអង្គបានអញ្ជើញពួកគេឲ្យមានចំណែកចូលរួមក្នុងលំដាប់លំដោយនៃការសិក្សាក្នុងការសាងសង់នេះ។ នៅក្នុងកណ្ឌគម្ពីរ ពង្សាវតារក្សត្រ ខ្សែទីមួយ សាច់រឿងនៃការសាងសង់ប្រាសាទរបស់ស្តេច សាឡូម៉ូន និងការសាងសង់ក្រុងយេរូសាឡឹមឡើងវិញនៅក្នុងកណ្ឌគម្ពីរ អែសរ៉ា និងកណ្ឌគម្ពីរ នេហេមា គឺនិយាយអំពីពេលវេលាដែលមនុស្សបានចូលរួមនៅក្នុងដំណើរនៃការសាងសង់តាមលំដាប់លំដោយ ឬការស្តាបនាឡើងវិញនូវទីកន្លែងសម្រាប់ការប្រកបជាមួយនឹងព្រះជាម្ចាស់។ ហើយក្នុងនាមជាព្រះដំណាក់ (ឬក៏ព្រះវិហារ) របស់ព្រះវិញ្ញាណបរិសុទ្ធ ដែលមានចែងនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៦:១៩-២០ អ្នកហើយនិងខ្ញុំត្រូវបានហៅឲ្យចូលរួមនៅក្នុងដំណើរការ នៃការបង្កើត និងថែរក្សាទីកន្លែងដ៏ស្រស់ស្អាតនៅក្នុងចិត្តរបស់យើងឲ្យមានរបៀបរៀបរយ ដែលជាកន្លែងព្រះជាម្ចាស់គង់នៅដែរ។ វិធីមួយដែលសំខាន់បំផុត នោះគឺតាមរយៈការសិក្សាព្រះគម្ពីរ។

ព្រះជាម្ចាស់គឺជាព្រះដែលមានពេញទៅដោយអធិបតេយ្យភាពនៃពិភពលោកទាំងមូល ទ្រង់បានគង់នៅជាមួយយើងក្នុងសួនច្បារដ៏ឥតខ្ចោះដែលព្រះអង្គទ្រង់ផ្ទាល់ជាអ្នកបង្កើតមក។ នឹងមានថ្ងៃណាមួយ ព្រះអង្គនឹងគង់នៅជាមួយយើងម្តងទៀតនៅក្នុងទីក្រុងដ៏ឥតខ្ចោះដែលព្រះអង្គជាអ្នកបង្កើតផ្ទាល់។ ប៉ុន្តែ នៅក្នុងប្រឡោះរវាងលំហទាំងពីរនេះ ព្រះអង្គបានផ្តល់ឱកាសដ៏អស្ចារ្យបំផុតដល់យើង គឺឲ្យយើងចូលរួមបង្កើតកន្លែងមួយដែលជាកន្លែងព្រះជាម្ចាស់ និងមនុស្សអាចប្រកបជាមួយគ្នាវិញបាន។ ការសិក្សាព្រះគម្ពីរដោយ



Khmer Women of the word_Layout.indd 142 12/3/26 3:56 in the afternoon

មានលំដាប់លំដោយគឺជា វិធីនៅក្នុងការបង្កើតប្រទេ្បាះនេះ។

យើងប្រហែលចាប់ផ្ដើមការងារនៃការសាងសង់ ហើយក៏ជាអ្នកសាងសង់ដែលមានការធ្វេសប្រហែសច្រើនដែរ ប៉ុន្តែយើងមានព្រះជាម្ចាស់ដែលស្មោះត្រង់ ទ្រង់អត់ធ្មត់ជាមួយនឹងកម្មកររបស់ទ្រង់ ព្រះអង្គនឹងបង្ហាត់បង្រៀនពួកគេជាមួយអ្វីដែលគេត្រូវការ ដើម្បីឲ្យពួកគេធ្វើកិច្ចការនោះដោយផ្ទាល់បានល្អ។ អ្វីដែលយើងត្រូវការ យើងគ្រាន់តែសូមព្រះអង្គជាមួយនឹងការនោះនៅក្នុងគំនិតរបស់យើងប៉ុណ្ណោះ។ យើងបានត្រៀមរួចរាល់ហើយនៅក្នុងការគិតពិចារណាទៅលើចំណុចចុងក្រោយ នៃការសិក្សាព្រះគម្ពីរដែលត្រឹមត្រូវគឺៈសិក្សាជាមួយនឹងការអធិដ្ឋាន។.

## សំណួរឆ្លុះបញ្ចាំង

១. តើវិធីណាមួយដែលអ្នកតែងតែប្រើ វិធីបែបច្នៃប្រឌិតដោយមិនបានព្រៀងទុក ឬក៏វិធីដែលជំរុញឲ្យមានការសាងសង់នូវដំណើរការ? តើវិធីសាស្ត្រដែលអ្នកបានជ្រើសរើសយកមកប្រើនឹងជះឥទ្ធិពលទៅលើរបៀបដែលអ្នកបានគិតអំពីការសិក្សាព្រះគម្ពីរយ៉ាងដូចម្ដេច?

២. តើឧបករណ៍នៃការយល់ដឹងណាមួយដែលអ្នកនឹងលើកឡើង (ការថតចម្លងអត្ថបទ ការអានម្ដងហើយម្ដងទៀត ចំណុចពន្យល់ វចនានុក្រម ព្រះគម្ពីរបកប្រែផ្សេងៗ និង គម្រោងទម្រង់) តើអ្នកគិតថាចំណុចទាំងនេះនឹងជួយអ្នកបានច្រើនដែរឬទេ? តើអ្នកបានប្រើប្រាស់ឧបករណ៍ណាមួយពីមុនមក ហើយតើឧបករណ៍មួយណាដែលថ្មីសម្រាប់អ្នក?



Khmer Women of the word_Layout.indd 143 12/3/26 3:56 in the afternoon

៣. តើអ្វីទៅជាគ្រោះថ្នាក់នៅក្នុងការព្យាយាមអនុវត្តនូវអត្ថបទព្រះគម្ពីរ ដោយមិនបានធ្វើការកាត់ស្រាយជាមុន? តើអ្វីទៅជាគ្រោះថ្នាក់នៅក្នុងការព្យាយាមកាត់ស្រាយអត្ថបទព្រះគម្ពីរ ដោយធ្វើការយល់ដឹងជាលឿនពេក?

៤. ហេតុអ្វីបានជាវាសំខាន់ក្នុងការដែលយើងផ្ទៀងផ្ទាត់ការកាត់ស្រាយរបស់យើងជាមួយនឹងសៀវភៅសេចក្តីអធិប្បាយនៅក្រោយពេលដែលយើងបានស្វែងរកការកាត់ស្រាយដោយខ្លួនឯងជាមុនសិន? តើអ្វីដែលជាកត្តាជំរុញដល់អ្នកឲ្យចេះតែឆាប់ចូលទៅស្វែងរកជំនួយពីសៀវភៅសេចក្តីអធិប្បាយមុន?

៥. គំនិតដែលមាននៅក្នុងជំពូកនេះនឹងពេញមួយសៀវភៅនេះ ការសិក្សាតាមលំដាប់លំដោយគឺមានតម្លៃខ្លាំងណាស់ បើទោះជាការបកស្រាយរបស់អ្នកមិនសូវល្អ ការអនុវត្តនៃការសរសេរនេះនឹងបង្កើនការយល់ដឹងរបស់អ្នក។ តើអ្នកមានទម្លាប់នៅក្នុងការគិតអំពីដំណើរការបែបនេះដែរឬទេ? ហេតុអ្វីគិត និងហេតុអ្វីមិនគិត?



Khmer Women of the word_Layout.indd 144 12/3/26 3:56 in the afternoon

ជំពូកទី ៧

# ការសិក្សាដោយ មានការអធិស្ឋាន

តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធាឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ។

យ៉ាកុប ១:៥

ជារឿយៗយើងឮអ្វីមួយដែលល្អបានមកតាមរយៈកញ្ចប់តូចមួយ។ ខ្ញុំអធិស្ឋានសូមឲ្យការនេះក្លាយទៅជាការពិតទាក់ទងទៅនឹងប៉ុន្មានទំព័រសន្លឹកនេះដែលអ្នកកំពុងតែអាន។ កុំអនុញ្ញាតឲ្យចំនួនពាក្យបោកបញ្ឆោតអ្នកឡើយ៖ បើទោះជាមានទំព័រច្រើនបាននិយាយយ៉ាងយកចិត្តទុកដាក់ ទៅលើការសិក្សានៃចំណុចទាំងបួនដែលបាននិយាយរួចមកហើយយ៉ាងណាក៏ដោយ ចំណុចទីប្រាំដែលជាចំណុចចុងក្រោយនៃការសិក្សាព្រះគម្ពីរដែលត្រឹមត្រូវក៏ មានសារៈសំខាន់ផងដែរ។ ជាការពិតយើងអាចធ្វើការវែកញែកបានថា ការអធិស្ឋាន គឺជាការដែលមានសារៈសំខាន់ជាងគេ ក្នុងចំណោមការសិក្សាទាំងនោះ។ ការអធិស្ឋាន គឺជាមធ្យោបាយដែលយើងសូមឲ្យព្រះវិញ្ញាណបរិសុទ្ធយាងមកគង់ជាមួយ ក្នុងពេលវេលានៃការសិក្សារបស់យើង។ បើមិនមានការអធិស្ឋាន ការ



Khmer Women of the word_Layout.indd 145 12/3/26 3:56 in the afternoon

សិក្សារបស់យើងនឹងមិនមានប្រយោជន៍អ្វីឡើយ វាហាក់បីដូចជាគ្រាន់តែការដេញតាមស្វះស្វែងរកតែចំណេះដឹងប៉ុណ្ណោះ។ ការអធិស្ឋាន គឺជារបៀបដែលយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ការអធិស្ឋាន គឺបានផ្លាស់ប្តូរការសិក្សារបស់យើងពីការដេញតាមរកចំណេះដឹងឲ្យមកស្វះស្វែងរកព្រះជាម្ចាស់ដោយផ្ទាល់វិញ។

អ្នកប្រហែលមានភាពងាយស្រួលជាមួយនឹងការប្រើពាក្យកាត់នៃដើមអក្សរ ដើម្បីជួយនៅក្នុងការចងចាំទាក់ទងទៅនឹងចំណុចសំខាន់ៗនៃការអធិស្ឋាន ដោយផ្តើមនឹងពាក្យថា «ការ»៖

| | |
|---|---|
| **ការ**សរសើរ | ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ចំពោះលក្ខណសម្បត្តិរបស់ព្រះអង្គ និងអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង។. |
| **ការ**សារភាព | សារភាពទៅចំពោះព្រះជាម្ចាស់នូវអ្វីដែលជាចំណុចខ្វះចន្លោះរបស់យើង។ |
| **ការ**ស្នើសូម | ទូលសូមព្រះអង្គឲ្យទ្រង់បានអត់ទោសបាបរបស់យើង និងឆ្លើយតបនូវតម្រូវការដែលយើងមានផងដែរ។ |
| **ការ**អរគុណ? | អរគុណដល់ព្រះជាម្ចាស់ចំពោះលក្ខណសម្បត្តិរបស់ព្រះអង្គ និងអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង។ |

ឥឡូវយើងនឹងពិចារណាពីរបៀបនៅក្នុងការដាក់បញ្ចូលចំណុចអធិស្ឋានទាំងនេះ ទៅក្នុងការសិក្សារបស់យើងទាំងមុនពេលសិក្សា អំឡុងពេលកំពុងសិក្សា និងក្រោយពេលសិក្សា ដោយប្រើប្រាស់លំនាំនៃការអធិស្ឋាននេះដើម្បីដឹកនាំយើង។ អ្នកប្រហែលជាបានអនុវត្តនូវការអធិស្ឋានទាំងនេះរួចហើយជារៀងរាល់ថ្ងៃ ដោយបញ្ចូលចំណុចសំខាន់ៗនៃការអធិស្ឋាននេះ។ ពេលវេលានៃការសិក្សារបស់អ្នក គឺបានផ្តល់ឱកាសដ៏ពិសេសដើម្បីឲ្យ អ្នកអាចអនុវត្តនូវការអធិស្ឋានជាក់លាក់ដែលឆ្លើយតបទៅនឹងព័ន្ធកិច្ចនៃព្រះបន្ទូល។

ពេលវេលាអធិស្ឋានរបស់អ្នកអាចយូរ ឬលឿន អាចជាពេលនៅក្នុងចន្លោះ



Khmer Women of the word_Layout.indd 146 12/3/26 3:56 in the afternoon

ពេលណាមួយនៃការសិក្សារបស់អ្នក។ គ្រប់ដំណាក់ទាំងអស់ដែលអ្នកកំពុងសិក្សា ស្វែងរកអត្ថប្រយោជន៍នៃការអធិស្ឋាន ហើយផ្តល់ឱកាសឲ្យខ្លួនអ្នកបញ្ចូលប្រើប្រាស់នូវចំណុចទាំងនោះនៅពេលដែលអ្នកត្រូវបានដឹកនាំឲ្យធ្វើនូវកិច្ចការទាំងនោះផងដែរ។ សូមអធិស្ឋានចេញពីបំណងប្រាថ្នាដែលស្មោះត្រង់ មិនមែនចេញពីស្មារតីដែលមានកាតព្វកិច្ចនៅក្នុងការ “ធ្វើកិច្ចការដែលត្រឹមត្រូវ” នោះឡើយ។ ពេលដែលអ្នកកំពុងសិក្សា ប្រសិនបើអ្នកមិនមានបំណងប្រាថ្នានៅក្នុងការអធិស្ឋានទេ សូមសារភាពការនោះទៅព្រះជាម្ចាស់ ដោយសូមឲ្យព្រះអង្គបន្ថែមសេចក្តីប៉ងប្រាថ្នានៃការមានចិត្តអធិស្ឋាន នៅក្នុងជីវិតអ្នកផងដែរ។

## អធិស្ឋានមុនពេលសិក្សា

*ការសរសើរ៖* សូមចាប់ផ្តើមដោយការសរសើរដល់ព្រះជាម្ចាស់ ដោយសារព្រះអង្គបានបើកសម្តែងបំណងព្រះហឫទ័យនិងលក្ខណសម្បត្តិរបស់ព្រះអង្គនៅក្នុងព្រះបន្ទូលទ្រង់។ ប្រសិនបើអ្នកកំពុងសិក្សានៅក្នុងកណ្ឌគម្ពីរ សូមសរសើរព្រះអង្គសម្រាប់លក្ខណសម្បត្តិជាក់លាក់របស់ទ្រង់ ដែលបានបើកសម្តែងនៅក្នុងការសិក្សារបស់អ្នក។ ប្រសិនអ្នកចាប់ផ្តើមនូវដើមកណ្ឌគម្ពីរណាមួយ សូមសរសើរព្រះអង្គដែលមានព្រះទ័យមេត្តាករុណា និងព្រះគុណដែលបានផ្តល់ឲ្យអ្នកនូវព្រះគម្ពីរនេះ។

*ការសារភាព៖* ការស្គាល់អំពីចំណុចខ្សោយ និងចំណុចមិនច្បាស់លាស់នៅពេលដែលអ្នកចាប់ផ្តើមការសិក្សារបស់អ្នក ហើយថ្វាយការនោះទៅចំពោះព្រះអង្គ។ ហើយវាហាក់ដូចជាពិបាកពេក។ សូមសារភាពពីអំពើបាប ឬកំហុសណាមួយដែលអាចរាំងដល់ការសិក្សារបស់អ្នក (អំនួត? មិនមានការអត់ធ្មត់? ការរំខាន?)។ សូមសារភាពអំពីការខ្វះនូវសេចក្តីប៉ងប្រាថ្នារបស់អ្នកផងដែរ។

*ការស្នើសូម៖* នៅពេលដែលអ្នកសិក្សា សូមព្រះអង្គឲ្យប្រទាននូវត្រចៀក



Khmer Women of the word_Layout.indd 147 12/3/26 3:56 in the afternoon

សម្រាប់យល់ និងភ្នែកសម្រាប់ឃើញ។ សូមព្រះអង្គជួយអ្នកឲ្យចេះគ្រប់គ្រងពេលវេលាដែលអ្នកបានរៀបចំទុក ចេញពីការរំខានផ្សេងៗ សូមព្រះអង្គសម្អាតនូវគំនិតរបស់អ្នកចេញពីការព្រួយបារម្ភផ្សេងៗ។ សូមឲ្យព្រះអង្គបង្ហាញលក្ខណសម្បត្តិរបស់ទ្រង់ និងអំពើបាបរបស់អ្នក។ សូមព្រះអង្គជួយឲ្យព្រះបន្ទូលរបស់ទ្រង់ជាព្រះបន្ទូលរស់មកក្នុងជីវិតរបស់អ្នកនៅក្នុងរបៀបមួយដែលអាចស្គាល់ព្រះអង្គបានប្រសើរជាងមុន និងមើលឃើញនូវសេចក្ដីត្រូវការរបស់អ្នកក្នុងការចង់បានព្រះអង្គយ៉ាងច្បាស់ផងដែរ។

*ការអរគុណ៖* សូមអរគុណព្រះអង្គដែលព្រះអង្គបានបើកសម្ដែងអង្គទ្រង់នៅក្នុងព្រះគម្ពីរ ហើយបានប្រទាននូវលទ្ធភាពដល់អ្នកក្នុងការស្គាល់ព្រះអង្គ។ សូមអរគុណព្រះអង្គសម្រាប់ពេលវេលានៃការសិក្សា សូមអរគុណព្រះអង្គសម្រាប់អំណោយ គឺអង្គព្រះយេស៊ូវគ្រីស្ទ។

## សូមអធិស្ឋានអំឡុងពេលកំពុងសិក្សា

*ការសរសើរ៖* នៅពេលដែលអ្នកសិក្សា សរសើរព្រះជាម្ចាស់នៅពេលដែលអ្នកឃើញចំណុចភ្ជាប់ទាក់ទងអំពីលក្ខណសម្បត្តិរបស់ទ្រង់ ដែលអ្នកមិនបានស្គាល់ពីមុនមក។ សរសើរព្រះអង្គនៅពេលដែលអ្នកកត់សម្គាល់ឃើញថា អ្នកបានចាប់ផ្ដើមសួរសំណួរដែលត្រឹមត្រូវអំពីអត្ថបទដោយខ្លួនឯង។ សរសើរព្រះអង្គនៅពេលដែលអ្នកមានភាពសប្បាយរីករាយជាមួយនឹងការសិក្សារបស់អ្នក ដោយដឹងថាព្រះអង្គជាប្រភពនៃអំណរនោះ។

*ការសារភាព៖* សូមសារភាពទៅព្រះអង្គនៅពេលដែលអ្នកមានភាពស្មុគស្មាញជាមួយនឹងការសិក្សារបស់អ្នកសារភាពទៅព្រះអង្គប្រសិនបើអ្នកមានអារម្មណ៍ថាធុញថប់។ សូមប្រាប់ព្រះអង្គនូវអ្វីដែលអ្នកចង់ធ្វើជាជាង ឬប្រាប់ព្រះអង្គនូវអ្វីដែលអ្នកគិតថាសំខាន់ជាង។ សូមសារភាពផងដែរប្រសិនបើអ្នកទ្រាំមិនបាន ហើយប្រឆាំងទៅនឹងព្រះបន្ទូលដែលបានបង្ហាញអំពីអ្នក ឬសូមអ្វីមួយឲ្យអ្នកចុះចូល។



Khmer Women of the word_Layout.indd 148 12/3/26 3:56 in the afternoon

*ការស្នើសូម៖* ប្រសិនបើអ្នកបានអាននូវព្រះបន្ទូលដែលពិបាក ចូរសូមព្រះអង្គប្រទានឲ្យអ្នកនូវការយល់ដឹង ប្រសិនបើអ្នកមានការងឿងឆ្ងល់នៅក្នុងគំនិតរបស់អ្នក សូមព្រះអង្គជួយដល់អ្នកឲ្យនៅតែរក្សាការផ្ដោតអារម្មណ៍ផងដែរ។ ប្រសិនបើអ្នកមានភាពស្មុគស្មាញ សូមព្រះអង្គបង្រៀនអ្នកឲ្យចេះអត់ធ្មត់ និងបន្ទាបខ្លួន ប្រសិនបើអ្នកមានអារម្មណ៍ថាដូចជាប្រញាប់ប្រញាល់ សូមព្រះអង្គជួយអ្នកឲ្យចេះបន្ថយល្បឿន។ ប្រសិនបើអ្នកហ៊ុមព័ទ្ធដោយការរំខានជាច្រើន សូមព្រះអង្គផ្ដល់ឲ្យអ្នកនូវភាពសុខសាន្ត និងជួយអ្នកឲ្យបានដឹង តើនេះជាពេលដែលគួរបញ្ចប់ការសិក្សាសម្រាប់ថ្ងៃនេះហើយមែនឬ។

*ការអរគុណ៖* សូមអរគុណដល់ព្រះអង្គនៅពេលដែលទ្រង់បានផ្ដល់ឲ្យអ្នកនូវខ្លឹមសារព្រះបន្ទូលផ្សេងទៀតដែលបញ្ជាក់អះអាង ឬពង្រឹងនូវអ្វីដែលយើងកំពុងរៀនក្នុងពេលវេលាសិក្សារបស់អ្នក។ អរគុណព្រះអង្គនៅពេលដែលអ្នកទទួលបានការកែតម្រូវចេញពីអត្ថបទ ឬក៏ទទួលបានគំរូណាមួយ ដើម្បីដើរតាម។ សូមអរព្រះគុណព្រះសម្រាប់រាល់ពេលដែលអ្នកសិក្សា ហើយព្រះអង្គបង្ហាញដំណឹងល្អឲ្យអ្នកឃើញ។

## សូមអធិស្ឋានក្រោយពេលសិក្សា

*ការសរសើរ៖* សញ្ជឹងគិតទៅលើទិដ្ឋភាពអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលបានបង្ហាញតាមរយៈការសិក្សារបស់អ្នក។ តើព្រះបន្ទូលបានបង្ហាញព្រះជាម្ចាស់ពេញដោយព្រះគុណដែរ ឬទេ? អត់ធ្មត់? សេចក្ដីក្រោធ? បរិសុទ្ធ? សូមសរសើរដល់ព្រះអង្គសម្រាប់ទិដ្ឋភាពនេះតាមបែបលក្ខណសម្បត្តិរបស់ព្រះអង្គ។ ប្រសិនបើអាចធ្វើទៅបាន សូមអធិស្ឋាននូវឃ្លានៃព្រះបន្ទូលនោះឲ្យបានឮៗ ដោយលើកសរសើរអំពីទិដ្ឋភាពនៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។

*ការសារភាព៖* សូមសារភាពពីការល្បួងរបស់អ្នកដែលចង់យកបទព្រះគម្ពីរនេះទៅអនុវត្តចំពោះអំពើបាបរបស់អ្នកផ្សេង ជំនួសឲ្យអនុវត្តចំពោះខ្លួន



Khmer Women of the word_Layout.indd 149 12/3/26 3:56 in the afternoon

ឯង។ សារភាពផងដែរ ប្រសិនបើអ្នកអនុញ្ញាតឲ្យមានការរំខាននៅក្នុងពេលសិក្សារបស់អ្នក តើការសិក្សារបស់អ្នកមានផល និងបានធ្វើឲ្យអ្នកយល់ដឹងច្រើនជាងមុនអំពីភាពខ្វះខាតការយល់ដឹងរបស់អ្នកឬទេ? តើអ្នកប្រញាប់បញ្ចប់ការសិក្សាដែរឬទេ? សូមសារភាពអំពីការទាំងនេះផងដែរ។

*ការស្នើសូម៖* សូមព្រះអង្គជួយអ្នកឲ្យអនុវត្តនូវអ្វីដែលអ្នកបានរៀន តើការសិក្សាអំពីព្រះជាម្ចាស់ដែលពេញដោយព្រះគុណ បានបង្ហាញអំពីខ្លួនយើងដែលមិនបានផ្តល់ព្រះគុណទៅកាន់អ្នកណាម្នាក់ដែរឬទេ? ចូរសូមព្រះអង្គជួយអ្នកឲ្យអនុវត្តនូវអ្វីដែលអ្នកបានរៀន។ សូមព្រះអង្គបានដឹកនាំអ្វីដែលយើងបានសិក្សាចូលមកក្នុងគំនិតរបស់អ្នក សម្រាប់សកម្មភាពរស់នៅប្រចាំថ្ងៃ និងរៀងរាល់សប្តាហ៍របស់អ្នកផងដែរ។ ប្រសិនបើពេលវេលាសិក្សារបស់អ្នកដូចជាមិនមានផលផ្លែទេ សូមព្រះអង្គជួយអ្នកឲ្យទុកចិត្តថា គឺមានផលផ្លែដែលអ្នកមើលមិនឃើញ។ អធិស្ឋានសូមព្រះអង្គប្រទានឲ្យអ្នកនូវបំណងប្រាថ្នាខិតខំព្យាយាម នៅក្នុងដំណើរការនៃការរៀនសូត្រនេះ។

*ការអរគុណ៖* សូមអរគុណដល់ព្រះជាម្ចាស់នូវអ្វីដែលព្រះអង្គបានបង្រៀនអ្នក។ សូមអរព្រះគុណទ្រង់ចំពោះអំណោយនៃការយល់ដឹងផ្ទាល់ខ្លួន ហើយសម្រាប់បុរស និងស្ត្រីដែលបានសរសេរសេចក្តីពន្យល់អត្ថាធិប្បាយដែលអ្នកបានប្រើ។ សូមអរគុណដល់ព្រះអង្គសម្រាប់សេចក្តីពិតជាក់ស្តែងណាមួយ ដែលព្រះអង្គបានបង្ហាញអ្នកក្នុងអំឡុងពេលដែលអ្នកសិក្សាផងដែរ។

## ហាក់ដូចជាត្រូវអធិស្ឋានច្រើនពេកឬ?

សំណូមសម្រាប់សេចក្តីអធិស្ឋានដែលខ្ញុំបានផ្តល់ឲ្យ គឺគ្រាន់តែជាសំណើចំណុចទាំងនេះមិនបានបង្ហាញអំពីប្រភេទរូបមន្តនៃមន្តគាថាអ្វីឡើយ ហើយក៏មិនមែនជាបញ្ជីដែលល្អិតល្អ ឬក៏ពួកគេត្រូវបំពេញនូវចំនួនពេលវេលាជាក់លាក់ណាមួយដែរ។ គំនិតរបស់ខ្ញុំ គឺជំរុញអ្នកឲ្យបានពេញទៅដោយការ



Khmer Women of the word_Layout.indd 150 12/3/26 3:56 in the afternoon

អធិស្ឋានធ្វើឲ្យការសិក្សារបស់អ្នកមានការជ្រួតជ្រាបតាំងពីការចាប់ផ្ដើម រហូតដល់ទីបញ្ចប់។ ការសិក្សាព្រះគម្ពីរមិនមែនជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់មនុស្សតែប៉ុណ្ណោះទេ ក៏ដូចជាចំណុចផ្សេងៗទៀតនៃការញែកចេញជាបរិសុទ្ធរបស់យើង គឺជាលទ្ធផលនៃព្រះវិញ្ញាណបរិសុទ្ធដែលធ្វើការក្នុងយើង និងតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់យើង។

ពេលវេលាដែលអ្នកបានចំណាយ និងជម្រៅប៉ុណ្ណាដែលអ្នកបានចូលទៅដល់នៅក្នុងការសិក្សាដែលភ្ជាប់ជាមួយនឹងការអធិស្ឋាន វាអាស្រ័យទៅលើទំហំនៃពេលវេលារបស់អ្នកដែលបានកំណត់។ នឹងមានថ្ងៃមួយពិតប្រាកដដែលអ្នកបាននិយាយខ្សឹបៗ «ព្រះអង្គសូមជួយកូនផង» នៅមុនពេលសិក្សា។ ហើយក៏សូមឲ្យមានថ្ងៃដែលមានពេញទៅដោយការអធិស្ឋានពីដើមដល់ចប់នៅក្នុងការសិក្សារបស់អ្នកផងដែរ។ ព្រះវិញ្ញាណបរិសុទ្ធមានវិធីនៅក្នុងការមានបន្ទូលតាមរយៈព្រះបន្ទូល មិនថានៅពេលដែលយើងបានសូមព្រះអង្គ ឬក៏អត់នោះទេ។ ការអញ្ជើញព្រះអង្គបែបណាដែលល្អប្រសើរ? ដើម្បីស្វាគមន៍ព្រះអង្គមែនទេ? ឬក៏ដើម្បីលើកតម្កើងព្រះវត្តមានរបស់ព្រះអង្គនៅក្នុងការសិក្សាប្រចាំថ្ងៃរបស់យើង? ប្រសិនបើព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតជាមានព្រះជន្មរស់ និងមានចលនាមែន នេះគឺដោយព្រោះតែជំនួយដែលមកពីព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ តាមរយៈការបញ្ចប់ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ គឺដោយសារកម្រិតនៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតា៖ ក្នុងពេលវេលានៃការសិក្សារបស់អ្នក ការអធិស្ឋានជាការអំពាវនាវឲ្យមានការប្រកបគ្នារវាងអង្គទាំងបីនៃព្រះត្រៃឯក ជាពេលវេលាប្រកបដែលមានភាពស្និទ្ធស្នាល និងចាំបាច់សម្រាប់គ្រប់សិស្សទាំងអស់ដែលសិក្សាព្រះបន្ទូល។

ទោះបីជំពូកនេះខ្លីក៏ដោយក៏ការអធិស្ឋានគឺជាអ្វីដែលសំខាន់ខ្លាំងណាស់។



Khmer Women of the word_Layout.indd 151 12/3/26 3:56 in the afternoon

## សំណួរឆ្លុះបញ្ចាំង

១. «បើមិនមានការអធិស្ឋាន ការសិក្សារបស់យើងនឹងមិនមានប្រយោជន៍អ្វីឡើយ វាហាក់បីដូចជាគ្រាន់តែការដេញតាមស្វះស្វែងរកតែចំណេះដឹងប៉ុណ្ណោះ។ ការអធិស្ឋាន គឺជារបៀបដែលយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ការអធិស្ឋានគឺបានផ្លាស់ប្ដូរការសិក្សារបស់យើងពីការដេញតាមរកចំណេះដឹងឲ្យមកស្វះស្វែងរកព្រះជាម្ចាស់ដោយផ្ទាល់វិញ»។ (ទំព័រ១១១)។ តើការខកខានមិនបានអធិស្ឋាននៅក្នុងពេលវេលានៃការសិក្សារបស់អ្នក បង្ហាញអំពីគោលបំណង និងវិធីសាស្ត្ររបស់អ្នកក្នុងការរៀនព្រះគម្ពីរអ្វីខ្លះ?

២. «សូមអធិស្ឋានចេញពីបំណងប្រាថ្នាដែលស្មោះត្រង់ មិនមែនចេញពីស្មារតីដែលមានកាតព្វកិច្ចនៅក្នុងការ «ធ្វើកិច្ចការដែលត្រឹមត្រូវ» នោះឡើយ»។ (ទំព័រ១១២)។ តើអ្នកនឹងធ្វើអ្វី ប្រសិនបើអ្វីដែលអ្នកមាន គឺជាស្មារតីដែលមានកាតព្វកិច្ចនោះ? តើអ្នកនឹងមានការលូតលាស់ឲ្យមានបំណងប្រាថ្នាដែលស្មោះត្រង់បានយ៉ាងដូចម្ដេច?

៣. តើមានចំណុចណាមួយនៃការអធិស្ឋាននេះ (ការសរសើរ ការសារភាព ការស្នើសូម និងការអរគុណ) ដែលអ្នកមិនសូវបានអធិស្ឋាន? តើសំណើនៃការអធិស្ឋានណាមួយដែលអ្នកគិតថាមានប្រយោជន៍ខ្លាំងបំផុត?



Khmer Women of the word_Layout.indd 152 12/3/26 3:56 in the afternoon

៤. តើមានសំណើនៃការអធិស្ឋានណាមួយដែលអ្នកគិតថា បានជំរុញអ្នក និងចាក់ចុចចិត្តអ្នក? ចំណុចណាមួយដែលអ្នកគិតថាបានលើកទឹកចិត្ត និងធ្វើឲ្យអ្នកមានសេរីភាព? តើមានសំណើអធិស្ឋានជាក់លាក់ណាមួយដែលធ្វើឲ្យអ្នកភ្ញាក់ផ្អើលដែរឬទេ?

៥. ការដែលដឹងថា ព្រះវិញ្ញាណបរិសុទ្ធបានមានបន្ទូលមកកាន់យើង ហើយធ្វើឲ្យយើងមានការជឿជាក់តាមរយៈព្រះបន្ទូល មិនថាយើងបានសូមព្រះអង្គ ឬក៏មិនបានសូម។ តើការនេះអាចនឹងលួចនូវគោលបំណងដែលយើងចង់ទូលសូមពីព្រះអង្គដែរឬទេ។ នៅក្នុងការសិក្សារបស់យើង តើយើងបានទទួលអ្វីខ្លះតាមរយៈការអញ្ជើញព្រះវត្តមានរបស់ព្រះអង្គ និងការស្វែងរកព្រះពររបស់ទ្រង់?



Khmer Women of the word_Layout.indd 153 12/3/26 3:56 in the afternoon

ជំពូកទី៨

# ការដាក់រួមបញ្ចូលគ្នាទាំងអស់

«ទូលបង្គំបានស្វែងរកទ្រង់អស់ពីចិត្ត ឱសូមកុំឲ្យទូលបង្គំវង្វេងចេញពីសេចក្ដីបង្គាប់របស់ទ្រង់ឡើយ ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្តប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ»

ទំនុកតម្កើង ១១៩:១០-១១

ឥឡូវនេះ អ្នកមានអស់ហើយ៖ ការទាំងប្រាំនៃការសិក្សាដែលត្រឹមត្រូវ ឧបករណ៍ទាំងប្រាំជួយអ្នកនៅក្នុងការកសាងអក្សរសាស្ត្រព្រះគម្ពីរ ជាហេតុដែលជួយឲ្យអ្នកមានការរីកលូតលាស់នៅក្នុងសេចក្ដីស្រឡាញ់ចំពោះព្រះជាម្ចាស់ ដែលព្រះគម្ពីរបានបង្ហាញ។ នេះគឺជាការរម្លឹកដោយសង្ខេបអំពីចំណុចនីមួយៗ ដែលសរុបបញ្ចូលគ្នានូវអ្វីដែលយើងបានរៀនកន្លងមក។

| | |
|---|---|
| ការសិក្សាដោយមាន*គោលបំណង* | យល់ដឹងអំពីអត្ថបទព្រះគម្ពីរនៅកន្លែងណាក្នុងរូបភាពធំនៃការបង្កើត ការធ្លាក់ក្នុងអំពើបាប ការប្រោសលោះ និងការស្ដារឡើងវិញ។ |
| ការសិក្សាដោយមាន*ទស្សនៈ* | យល់ដឹងអំពី «បុរាណវត្ថុ» នៃអត្ថបទរបស់អ្នក (គឺជាបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌)។ |



Khmer Women of the word_Layout.indd 155 12/3/26 3:56 in the afternoon

| | |
|---|---|
| ការសិក្សាដោយមាន*ការអត់ធ្មត់* | មិនប្រញាប់ប្រញាល់នៅក្នុងការពន្យល់ ដាក់ការរំពឹងទៅលើដំណើរការនៃការសិក្សារបស់អ្នកតាមល្បឿនរបស់អ្នក ដោយផ្តោតទៅលើភាពយូរអង្វែង។ |
| ការសិក្សាដោយមាន*លំដាប់លំដោយ* | ចាប់ផ្តើមការអានដោយមានវិធីសាស្ត្រអំពី ការយល់ដឹងការកាត់ស្រាយ និងការអនុវត្ត។ |
| ការសិក្សាដោយមាន*ការអធិស្ឋាន* | ទូលសូមព្រះវរបិតាឲ្យជួយយើងនៅមុនពេលរៀន អំឡុងពេលរៀន និងក្រោយពេលរៀនផងដែរ។ |

មកដល់ពេលនេះ យើងបានឃើញនូវវិធីសាស្ត្រទាំងអស់ហើយ សូមមើលពីរបៀបដែលអ្នកអាចនឹងប្រើចំណុចទាំងនេះ តាមចំណុចឧទាហរណ៍។ ដូចដែលខ្ញុំបានបញ្ជាក់រួចហើយនៅពេលដែលខ្ញុំបានណែនាំនូវចំណុចទាំងនេះ ការសិក្សាទាំងប្រាំគឺមានទំនាក់ទំនងគ្នាទៅវិញទៅមក មិនមែនឈរនៅតែឯងឡើយ។ ចំណុចទាំងនេះក៏មិនមែនជាបញ្ជីទូទាត់ដែរ ប៉ុន្តែជាគំរូនៃការអនុវត្តដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក និងប្រើច្រើនដង។ គ្មានគំរូឧទាហរណ៍ណាមួយដែលធ្វើឲ្យអ្នកចាប់បានយ៉ាងពិតប្រាកដ ពីរបៀបនៃការសិក្សារបស់អ្នកឲ្យមានការរីកចម្រើន ប៉ុន្តែជំពូកនេះគួរតែជាចំណុចចាប់ផ្តើមរបស់អ្នកដែលមានទិសដៅត្រឹមត្រូវ។ សម្រាប់គោលបំណងនៃគំរូឧទាហរណ៍របស់យើង យើងនឹងចាត់ទុក ការអត់ធ្មត់ និង ការអធិស្ឋាន គឺជាចំណុចដែលត្រូវការនៅក្នុងគ្រប់កន្លែងនៃការសិក្សារបស់យើង។ យើងនឹងផ្តោតការយកចិត្តទុកដាក់ពីរបៀបនៃការសិក្សាដែលមាន គោលបំណង ទស្សនៈ និងលំដាប់លំដោយ ដោយប្រើកណ្ឌគម្ពីរយ៉ាកុប។

អ្នកនឹងមានការកត់សម្គាល់នៅពេលដែលអ្នកអនុវត្តជាមួយនឹងឧទាហរណ៍នេះ ជំហាននីមួយៗមិនបានបំបែកចេញសម្រាប់ពេលវេលាបន្ថែមជាក់លាក់ឡើយ។ ប្រសិនបើអ្នកមានទម្លាប់ប្រើសេចក្តីណែនាំសម្រាប់ការសិក្សា ឬក៏ចំណុចបំបែកដំណើរការនៃការសិក្សារបស់គ្រូ នៅក្នុងពេលវេលាបន្ថែមប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍របស់អ្នក ដោយមិនប្រើរចនាសម្ព័ន្ធ នោះអ្នក



Khmer Women of the word_Layout.indd 156 12/3/26 3:56 in the afternoon

ប្រហែលត្រូវការពេលវេលាបន្តិច ក្នុងការមានទម្លាប់ប្រើចំណុចទាំងនេះ។ ចំណុចនេះក៏បានផ្តល់ឲ្យអ្នកនូវសេរីភាពក្នុងការសិក្សាជាមួយនឹងល្បឿនរបស់អ្នកផ្ទាល់ខ្លួន ដោយអ្នកអាចអនុវត្តច្រើន ឬក៏តិចទៅតាមពេលវេលារបស់អ្នកដែលបានដាក់។ អ្នកប្រហែលត្រូវការបីថ្ងៃ ឬក៏បីសប្តាហ៍ដើម្បីអានអត្ថបទឲ្យបានចប់ច្រើនដង វាអាស្រ័យទៅលើពេលវេលាដែលអ្នកមាន។ អ្វីដែលសំខាន់ជាងការសម្រេចការសិក្សាឲ្យបាន នោះគឺការសិក្សាដែលធ្វើឲ្យមានភាពរីកចម្រើន ដែលស្ថិតស្ថេរនៅក្នុងទិសដៅដែលត្រឹមត្រូវ ដោយប្រើវិធីកសាងនូវអក្សរសាស្រ្ត។

ដោយគិតអំពីចំណុចនោះ សូមអនុវត្តអំពីរបៀបនៃការសិក្សារបស់អ្នកដែលនឹងមានការរីកចម្រើន ប្រសិនបើអ្នកសម្រេចចិត្តនៅក្នុងការសិក្សាកណ្ឌគម្ពីរយ៉ាកុប ដោយផ្អែកទៅលើវិធីសាស្រ្តនៃការសិក្សារបស់យើង។ មុនពេលដែលអ្នកចាប់ផ្តើមសូមប្រមូលនូវអ្វីៗដែលបានរៀបរាប់ដូចខាងក្រោមនេះ៖

- ថតចម្លងអត្ថបទដែលមានចន្លោះគុណនឹងពីរ និងមានកន្លែងរឹមទំព័រធំ រួមជាមួយនឹង កំណត់ត្រានៅខាងក្រោមសៀវភៅ និងឯកសារយោងផ្សេងៗ។
- ប៊ិច និងប៊ិចសម្រាប់គូរពណ៌ពីលើ
- ប្រអប់ខ្មៅដៃពណ៌ ឬខ្មៅដៃសម្រាប់សរសេរពន្យល់បន្ថែម
- សៀវភៅកំណត់ហេតុ ឬក៏សម្ភារៈទុកដាក់ឯកសារ សម្រាប់រក្សាទុកកំណត់ហេតុរបស់អ្នក ទាំងអស់ឲ្យបាននៅក្នុងកន្លែងតែមួយ។

## ជំហានទី១៖ សូមចាប់ផ្តើមជាមួយនឹងគោលបំណង

សូមចាប់ផ្តើមការសិក្សារបស់អ្នកជាមួយនឹងការគិតពិចារណា ថាតើកណ្ឌគម្ពីរយ៉ាកុបនៅកន្លែងណាបើយើងដាក់ចូលទៅក្នុងសាច់រឿងធំនៃព្រះគម្ពីរ។ តើផ្នែកណាខ្លះដែលបានបង្ហាញនៅក្នុងការប្រាប់អំពីសាច់រឿងនៃការបង្កើត ការធ្លាក់ចុះ ការប្រោសលោះ និងការស្តារឡើងវិញ? តើបានចង្អុរបង្ហាញទៅកាន់ព្រះរាជ្យ និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់យ៉ាងដូចម្តេច? ប្រសិនបើអ្នក



Khmer Women of the word_Layout.indd 157 12/3/26 3:56 in the afternoon

មិនបានសិក្សាអំពីកណ្ឌគម្ពីរលោកុប្បត្តិ ឬវិវរណៈទេ អាចនឹងមានការពិបាក នៅក្នុងការចាប់ផ្តើមការសិក្សារបស់អ្នក ក្នុងការដឹងកន្លែងណាឲ្យពិតប្រាកដ សម្រាប់កណ្ឌគម្ពីរដែលអ្នកបានជ្រើសរើសឲ្យត្រូវទៅនឹងរូបភាពធំ។ តែនោះ មិនជាអ្វីទេ។ អ្នកអាចស្វែងរកគំនិតទូទៅនៅពេលដែលអ្នកចាប់ផ្តើម (ដោយ ពិគ្រោះសេចក្តីផ្តើមជាមួយនឹងសៀវភៅសិក្សាព្រះគម្ពីររបស់អ្នក ឬក៏សេចក្តី អធិប្បាយព្រះគម្ពីរ) ហើយរក្សាទុកនូវសំណួរនោះក្នុងគំនិតរបស់អ្នកនៅពេល ដែលអ្នកចាប់ផ្តើម។

នៅពេលដែលអ្នកចំណាយពេលទៅមើលអត្ថបទ ចំណុចដែលរួមចំណែក ជាក់លាក់នៅក្នុងសាច់រឿងធំ នឹងចាប់ផ្តើមលេចរូបរាងឡើងកាន់តែច្បាស់ ឡើងៗ។ នៅចុងបញ្ចប់នៃការសិក្សារបស់អ្នក អ្នកអាចចង្អុរបង្ហាញទៅកាន់ បាវចនានៃដំណើររឿងធំៗដែលបានបង្ហាញនៅក្នុងអត្ថបទ។ ពីព្រោះកណ្ឌ គម្ពីរយ៉ាកុប គឺជាអក្សរសាស្ត្រនៃប្រាជ្ញាក្នុងព្រះគម្ពីរសញ្ញាថ្មី (យើងនឹងមើល ឃើញនៅក្នុងចំណុចខាងក្រោម) ចំណុចនោះបានបង្ហាញយ៉ាងច្បាស់អំពី បាវចនានៃការប្រោសលោះ ជាពិសេសភាពរីកចម្រើននៃការញែកជាបរិសុទ្ធ ហើយក៏មានចំណុចផ្សេងៗទៀតនៃដំណើររឿងធំៗបានបង្ហាញផងដែរ។

## ជំហានទី២៖ ស្វែងរកទស្សនៈនៅក្នុង កណ្ឌគម្ពីរដែលអ្នកនឹងសិក្សា

ការប្រើព្រះគម្ពីរសម្រាប់សិក្សា សេចក្តីអធិប្បាយព្រះគម្ពីរដែលទុកចិត្ត ឬក៏ប្រើ ទាំងពីរអាចជួយយើងឲ្យឆ្លើយនូវសំណួរអំពីបុរាណវត្ថុក្នុងកណ្ឌគម្ពីរយ៉ាកុប បាន។ សូមចំណាយពេលជាមួយការនេះឲ្យបានគ្រប់គ្រាន់ នៅពេលដែល អ្នកចាប់ផ្តើមអាន អ្នកអាចនឹងស្តាប់អំពីរបៀបដែលសំបុត្រនេះត្រូវបានស្តាប់ ដោយអ្នកស្តាប់ដើមដំបូង។ នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក សូម សរសេរសំណួរអំពីបុរាណវត្ថុនីមួយៗ ហើយសរសេរចម្លើយដោយសង្ខេប សម្រាប់សំណួរទាំងនោះ។ អ្នកអាចនឹងប្រើចម្លើយទាំងនោះធ្វើជាចំណុច



Khmer Women of the word_Layout.indd 158 12/3/26 3:56 in the afternoon

យោងនៅក្នុងជំហានទី៣ ចម្លើយដែលអ្នកបានឆ្លើយទៅនឹងសំណួរអំពីបុរាណវត្ថុនៅក្នុងកណ្ឌគម្ពីរយ៉ាកុប គឺមានលក្ខណៈបែបនេះ៖

| | |
|---|---|
| ១. អ្នកណាជាអ្នកសរសេរ? | លោក យ៉ាកុប ដែលជាប្អូនរបស់ព្រះយេស៊ូវ មានតួនាទីនៅក្នុងក្រុមជំនុំ ក្នុងក្រុងយេរូសាឡឹម<br>(កិច្ចការ ១៥)។<br>ត្រូវបានស្គាល់ថាជា «យ៉ាកុបដ៏យុត្តិធម៌» និងត្រូវ បានគេដឹងថាគាត់បានចំណាយពេលវេលារបស់គាត់ភាគច្រើនសម្រាប់ការអធិស្ឋាន។<br>ស្លាប់នៅក្នុងឆ្នាំ៦២ នៃគ.ស. ដោយសារជំនឿលើព្រះជាម្ចាស់។ ដោយបោះពីលើអាគារគប់នឹងថ្ម និងវាយដំរហូតដល់ស្លាប់។ |
| ២. សរសេរឡើងនៅពេលណា? | ក្នុងអំឡុងឆ្នាំ៤៩ នៃគ.ស. គឺជាការសរសេរឡើងដើមដំបូងបំផុតនៃព្រះគម្ពីរសញ្ញាថ្មី។ |
| ៣. សរសេរទៅកាន់អ្នកណា? | ទៅកាន់គ្រីស្ទបរិស័ទសាសន៍យូដាដែលទទួលរងការបៀតបៀននៅក្នុងក្រុមជំនុំដើមដំបូង។ ស្គាល់យ៉ាងល្អអំពីព្រះគម្ពីរសញ្ញាចាស់បានសរសេរ និងប្រៀបធៀប។ |
| ៤. តើសរសេរក្នុងប្រភេទបែបយ៉ាងដូចម្ដេច? | សរសេរដូចជាអក្សរសាស្ត្រខាងប្រាជ្ញាក្នុងព្រះគម្ពីរសញ្ញាចាស់ ដូចជាសុភាសិត យ៉ូប និងបទចម្រៀងសាឡូម៉ូន។<br>មានការរំលឹកដាស់តឿនជាពាក្យសម្ដី ការហៅដោយផ្ទាល់ឲ្យស្ដាប់បង្គាប់ព្រះ ៥៤ ដង។<br>សម្លេងពេញដោយអំណាច ការបង្គាប់បញ្ជាឲ្យមានការគោរព។ |
| ៥. ហេតុអ្វីបានមានការសរសេរឡើង? | ដើម្បីបង្ហាញពីរបៀបរស់នៅក្នុងជីវិតដែលស្ដាប់បង្គាប់ព្រះដោយអនុវត្តជាក់ស្ដែងនៅក្នុងសកម្មភាពរាល់ថ្ងៃ។<br>ឆ្លើយទៅនឹងសំណួរ «តើសេចក្ដីជំនឿដែលពិតត្រង់មានលក្ខណៈយ៉ាងដូចម្ដេច? |

ប្រសិនបើអ្នកមិនបានស្គាល់ប្រភេទបែបអក្សរសាស្ត្រខាងប្រាជ្ញាទេ អ្នកត្រូវបន្ថែមការអានខ្លះៗ ដើម្បីស្វែងយល់ឲ្យបានច្រើនអំពីចំណុចនេះ។ ប្រសិន



Khmer Women of the word_Layout.indd 159 12/3/26 3:56 in the afternoon

បើមានទិដ្ឋភាពប្រវត្តិសាស្ត្រណាមួយធ្វើឲ្យអ្នកចាប់អារម្មណ៍ អ្នកប្រហែលត្រូវស្វែងយល់បន្ថែមទៀតផងដែរ។ នៅពេលដែលអ្នកចំណាយពេលកាន់តែច្រើន "ដាក់ខ្លួន ធ្វើជា" អ្នកស្តាប់ដើមដំបូង នោះអ្នកអាចនឹងទទួលបាននូវការយល់ដឹង ការកាត់ស្រាយ ការអនុវត្តកាន់តែច្រើនផងដែរ។

## ជំហានទី៣៖ សូមចាប់ផ្តើមនូវដំណើរនៃការយល់ដឹង ការកាត់ស្រាយ ការអនុវត្ត

*ការយល់ដឹង៖ តើវានិយាយអំពីអ្វី?*

សូមប្រើអត្ថបទថតចម្លងដែលមានចន្លោះគុណនឹងពីរ អានកណ្ឌគម្ពីរយ៉ាកុបទាំងមូលពីដើមដល់ចប់ យកចិត្តទុកដាក់ទៅលើកំណត់ត្រាដែលនៅខាងក្រោមសៀវភៅ ហើយធ្វើកំណត់ត្រានៅរឹមទំព័រដោយសង្ខេបនូវគោលគំនិតធំៗ។ ពេលអ្នកធ្វើការសង្ខេប សូមចងចាំនៅក្នុងគំនិតអំពីអ្នកស្តាប់ដើមដំបូងរបស់សាវ័ក យ៉ាកុប។ តើអ្វីទៅជាគោលគំនិតដ៏ធំដែលពួកគេនឹងទទួលបានពីក្នុងសំបុត្ររបស់គាត់ ដោយផ្អែកលើកាលៈទេសៈ នាពេលបច្ចុប្បន្នរបស់ពួកគេ ទៅលើការបៀតបៀនសេចក្តីជំនឿរបស់ពួកគេ?

សូមអានសំបុត្រនោះពីរទៅបីដង ស្វែងរកពាក្យ ឬឃ្លាដដែលៗ ឬក៏គំនិតដែលចាប់ផ្តើមលេចឡើងនៅក្នុងការយល់ដឹងរបស់អ្នក។ សូមអានសំបុត្រនោះជាមួយនឹងការបកប្រែពីរផ្សេងគ្នា នេះជាផ្នែកនៃការអានម្តងហើយម្តងទៀត។ នៅពេលដែលអ្នកចាប់ផ្តើមស្គាល់ដឹងនូវអ្វីដែលអត្ថបទបាននិយាយហើយ សូមចាប់ផ្តើមបញ្ចូនខ្លឹមសារនៃសេចក្តីសង្ខេបរបស់អ្នក ចូលទៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ដើម្បីធ្វើគម្រោងទម្រង់ព្រាងអំពីសំបុត្រនោះ។ គម្រោងទម្រង់ទូទៅនៃកណ្ឌគម្ពីរយ៉ាកុបរបស់អ្នក ប្រហែលមានលក្ខណៈបែបនេះ៖

- ការជម្រាបសួរ (១:១)។
- ការសាកល្បង និងសេចក្តីល្បួង (១:២-១៨)។



Khmer Women of the word_Layout.indd 160 12/3/26 3:56 in the afternoon

    - គឺជាការល្អដែលសេចក្ដីជំនឿរបស់យើងត្រូវបានល្បងល (១:២-១២)។
    - យើងមិនបានធ្លាក់ទៅក្នុងសេចក្ដីល្បួងដោយសារព្រះជាម្ចាស់ទេ ប៉ុន្តែដោយសារសេចក្ដីប៉ងប្រាថ្នារបស់យើង (១:១៣-១៨)។
- កុំឲ្យគ្រាន់តែស្ដាប់ព្រះបន្ទូលសូមអនុវត្តនូវអ្វីដែលអ្នកបានឮផងដែរ (១:១៩-២៧)។
- កុំលំអៀងរើសមុខ (២:១-១៣)។
- សេចក្ដីជំនឿដ៏ពិតតែងតែបង្ហាញនៅក្នុងការប្រព្រឹត្ត (២:១៤-២៦)។
- សូមប្រយ័ត្នពាក្យសម្ដីរបស់អ្នក (៣:១-១២)។
- ប្រាជ្ញាពីរប្រភេទ (៣:១៣-១៨)។
- កុំឲ្យចុះចូលចំពោះអ្វីៗដែលមាននៅក្នុងលោកីយ៍ (ជំពូកទី៤)។
    - កុំឲ្យឈ្លោះប្រកែកគ្នា (៤:១-៣)។
    - កុំធ្វើជាមិត្តសម្លាញ់នឹងលោកីយ៍ (៤:៤)។
    - កុំឲ្យមានចិត្តអំនួត (៤:៥-១០)។
    - កុំឲ្យនិយាយនិន្ទាគ្នាឡើយ (៤:១១-១២)។
    - កុំឲ្យអួត (៤:១៣-១៧)។
- ការព្រមានដល់ពួកអ្នកមាន ដែលមិនមានយុត្តិធម៌ (៥:១-៦)។
- ការបញ្ចប់ដោយរម្លឹកដាស់តឿន (៥:៧-២០)។
    - ចូរអត់ធ្មត់នៅក្នុងទុក្ខលំបាក (៥:៧-១១)។
    - និយាយអ្វីដែលចង់និយាយ បាទ គឺបាទ ទេ គឺទេ (៥:១២)។
    - អធិស្ឋានដោយសេចក្ដីជំនឿ (៥:១៣-១៨)។
    - ស្ដារអ្នកដែលវង្វេងចេញពីសេចក្ដីពិតឲ្យត្រឡប់មកវិញ (៥:១៩-២០)។

កុំបារម្ភអំពីគម្រោងទម្រង់ យើងអាចនឹងពិនិត្យមើលឡើងវិញ នៅពេលដែលការសិក្សារបស់អ្នកមានការរីកចម្រើន។ នៅពេលដែលមានអារម្មណ៍ដឹងអំពីអ្វីដែលសាវ័ក យ៉ាកុប និយាយក្នុងន័យទូទៅ សូមចាប់ផ្ដើមស្វែងរកមើលអ្វីដែលគាត់និយាយក្នុងលក្ខណៈពិសេស។ សូមចាប់ផ្ដើមធ្វើការតាមរយៈផ្នែកនៃសំបុត្រដែលសមហេតុសមផលពីមួយចំណុចទៅមួយចំណុច។



Khmer Women of the word_Layout.indd 161 12/3/26 3:56 in the afternoon

គម្រោងទម្រង់ព្រាងរបស់អ្នកបង្ហាញអំពីកណ្ឌគម្ពីរ យ៉ាកុប ១:១-១៨ ដោយបញ្ចូលនូវផ្នែកដែលសមហេតុផល ពីរយ៉ាងនៅក្នុងព្រះគម្ពីរ៖ ការជម្រាបសួរ និងការពិភាក្សាអំពីការសាកល្បង និងសេចក្តីល្បួង។ សូមមើលអត្ថបទផ្នែកនោះ និងកត់សម្គាល់នូវចំណុចដែលមាននៅខាងក្រោម៖

- តើអត្ថបទមានបង្ហាញពាក្យ ឃ្លា ឬក៏គំនិតណាមួយម្តងហើយម្តងទៀតដែរឬទេ?
- តើអត្ថបទនេះមានបានបើកសម្តែងអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ (អ្វីៗដែលពិតប្រាកដអំពីព្រះអង្គ) ដែរឬទេ?
- តើអត្ថបទបានបង្ហាញចំណុចណាមួយច្រើនដងនៅលើជួរឃ្លាតែមួយដែរឬទេ? សូមរាប់ចំណុចនីមួយៗ ដែលបានណែនាំនៅក្នុងអត្ថបទ។
- តើមានពាក្យណាមួយដែលអ្នកអត់យល់ដែរឬទេ សូមកត់សម្គាល់ពាក្យទាំងនោះជាមួយនឹងសញ្ញាសំណួរ ដើម្បីឲ្យអ្នកអាចស្វែងរកនិយមន័យសម្រាប់ពាក្យទាំងនោះ ហើយសរសេរនិយមន័យ ឬក៏ពាក្យស្រដៀងគ្នានៅក្នុងក្រដាសថតចម្លងរបស់អ្នក។
- តើមានពាក្យភ្ជាប់ពិសេសដែរឬទេដូចជា ប្រសិនបើ/បន្ទាប់មក ហេតុដូច្នេះ ដូចគ្នាផងដែរ ប៉ុន្តែ ពីព្រោះ ឬក៏ពាក្យ ដូចគ្នាទៅនឹង? គូសសញ្ញាព្រួញភ្ជាប់ពីចំណុចសន្និដ្ឋានទៅកាន់ចំណុចដែលវែក ញែកដើមដំបូង។
- តើមានគំនិតងឿងឆ្ងល់ណាមួយដែរឬទេ? សូមសរសេរសំណួររបស់អ្នកនៅគែមទំព័រ ដើម្បីគូសបញ្ជាក់ពេលក្រោយ។

សូមចាំថា សេចក្តីពន្យល់របស់សិស្សម្នាក់ៗនឹងមិនដូចគ្នាឡើយ នេះជាអ្វីដែលអត្ថបទថតចម្លងពីកណ្ឌគម្ពីរ យ៉ាកុប ១:១-១៨ របស់អ្នកអាចមានជារូបរាង នៅពេលដែលអ្នកបានធ្វើកំណត់សម្គាល់រួចហើយ (សូមមើលគំរូឧទាហរណ៍ពីការពន្យល់ក្នុងទំព័រ១២៨-១២៩)។



Khmer Women of the word_Layout.indd 162 12/3/26 3:56 in the afternoon

## *ការកាត់ស្រាយ៖ តើវាមានន័យយ៉ាងដូចម្ដេច?*

នៅពេលដែលអ្នកបានអានយ៉ាងយកចិត្តទុកដាក់ដើម្បីឲ្យមានការយល់ដឹងរួចហើយ សូមប្រើខគម្ពីរយោង ការបកស្រាយ និងសេចក្ដីអធិប្បាយព្រះគម្ពីរ (តាមលំដាប់លំដោយនេះ) ដើម្បីជួយអ្នកចូលទៅក្នុងចំណុចនៃការកាត់ស្រាយ។

*ខគម្ពីរយោង*

សូមមើលខគម្ពីរយោងដែលមាននៅខាងក្នុងព្រះគម្ពីររបស់អ្នក សម្រាប់ខគម្ពីរនីមួយៗគឺមាននៅក្នុងផ្នែកដែលអ្នកសិក្សា (ខគម្ពីរនោះអាចមានដាក់នៅគែមទំព័រ ឬនៅផ្នែកខាងក្រោមនៃទំព័រនៅក្នុងព្រះគម្ពីរសិក្សា)។ បន្ទាប់មក សូមធ្វើការកត់សម្គាល់តើខគម្ពីរយោង បានជួយអ្នកឲ្យមានការយល់ដឹងបន្ថែមទៅលើអត្ថបទដែលអ្នកកំពុងសិក្សានោះដែរឬទេ។ ឧទាហរណ៍៖ ខគម្ពីរយោងដែលមានសម្រាប់កណ្ឌគម្ពីរ យ៉ាកុប ១:២-៣ នៅក្នុងព្រះគម្ពីរសម្រាប់សិក្សា គឺ ម៉ាថាយ ៥:១២ និង ១ពេត្រុស ១:៦។ សូមមើលខគម្ពីរយោងនីមួយៗ ហើយអានខគម្ពីរនៅជុំវិញនឹងខនោះ ដើម្បីឲ្យអ្នកអាចដាក់ចូលទៅក្នុងបរិបទនៃខគម្ពីរនោះបាន។ សូមកត់សម្គាល់តើអ្នកណាដែលបាននិយាយ ហើយនិយាយទៅកាន់អ្នកណានៅក្នុងចំណុចនេះយើងត្រូវអានកណ្ឌគម្ពីរ ម៉ាថាយ ៥:១១-១២ ព្រះយេស៊ូវ ដែលជាបងប្រុសរបស់លោក យ៉ាកុប ដែលបានបង្ហាញថាពួកគេជាសិស្ស) និងកណ្ឌគម្ពីរ ១ពេត្រុស ១:៦-៧ (សាវ័ក ពេត្រុសបានបង្ហាញអំពីការបៀតបៀនដល់គ្រីស្ទបរិស័ទ) ដើម្បីឲ្យយល់កាន់តែច្បាស់អំពីទំនាក់ទំនងនៃខគម្ពីរយោងនីមួយៗ។

> **យ៉ាកុប ១:២-៣៖** «បងប្អូនអើយ កាលណាអ្នករាល់គ្នាមានសេចក្ដីល្បួងផ្សេងៗ នោះត្រូវរាប់ជាសេចក្ដីអំណរសព្វគ្រប់វិញ ដោយដឹងថាការល្បួងលមើលសេចក្ដីជំនឿនៃអ្នករាល់គ្នា នោះនាំបង្កើតឲ្យមានសេចក្ដីខ្ជាប់»។



Khmer Women of the word_Layout.indd 163 12/3/26 3:56 in the afternoon

**ម៉ាថាយ ៥:១១-១២៖** «អ្នករាល់គ្នាមានពរក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្ដីអាក្រក់ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ។ ចូរមានអំណរហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នាបែបដូច្នោះដែរ»។

**១ពេត្រុស ១:៦-៧៖** «អ្នករាល់គ្នាក៏មានសេចក្ដីអំណរជាខ្លាំងក្នុងសេចក្ដីសង្គ្រោះនោះ ទោះបើសព្វថ្ងៃនេះត្រូវរងទុក្ខព្រួយជាយូរបន្តិច ដោយកើតមានសេចក្ដីល្បួងផ្សេងៗក៏ដោយ។ ដើម្បីឲ្យការសាកលសេចក្ដីជំនឿនៃអ្នករាល់គ្នា ដ៏វិសេសជាងមាសដែលតែងតែខូច ទោះបើបានសាកនឹងភ្លើងក៏ដោយនោះ បានឃើញសម្រាប់ជាសេចក្ដីសរសើរកេរ្តិ៍ឈ្មោះ និងសិរីល្អក្នុងកាលដែលព្រះយេស៊ូវគ្រីស្ទទ្រង់លេចមក»។

សូមធ្វើការកត់សម្គាល់អំពីព្រះបន្ទូលរបស់ព្រះយេស៊ូវ និងការសរសេររបស់សាវ័ក ពេត្រុស ដែលពង្រីកការយល់ដឹងរបស់យើងនៅក្នុងកណ្ឌគម្ពីរយ៉ាកុប។ ចុងបញ្ចប់នៃការសាកល្បង គឺជាព្រះពរ៖ ការនោះបានផ្ដល់ឲ្យយើងនូវរង្វាន់នៃស្ថានសួគ៌ ទាំងនេះជាការប្រៀបធៀបដោយសង្ខេប ដោយបង្ហាញថាសេចក្ដីជំនឿរបស់យើងគឺពិតត្រង់ និងថ្វាយសិរីល្អដល់ព្រះជាម្ចាស់។

*ការបកស្រាយ*

សូមចាំថា ការបកស្រាយគឺគ្រាន់តែជាការសរសេរខគម្ពីរ ឬក៏ឃ្លាចេញពីពាក្យរបស់យើងផ្ទាល់ ដើម្បីជួយយើងក្នុងការស្វែងរកអត្ថន័យរបស់ខគម្ពីរនោះ។ ការបកស្រាយភាគច្រើនគឺមានប្រយោជន៍ នៅពេលដែលខគម្ពីរហាក់បីដូចជាអត់ច្បាស់ ឬមានភាពស្មុគស្មាញ។

ការរម្លឹកដាស់តឿននៅក្នុង យ៉ាកុប ១:២-៣ ត្រូវ «រាប់ជាសេចក្ដីអំណរ» ប្រហែលដំបូងចង់ប្រាប់យើងថាការសាកល្បង គួរតែជាប្រភពនៃអំណរសម្រាប់យើង នៅពេលដែលយើងស៊ូទ្រាំជាមួយនឹងការសាកលទាំងនោះ។ តើសាវ័ក យ៉ាកុបបានប្រាប់អស់អ្នកដែលទទួលការបៀតបៀនដ៏ខ្លាំង ថាពួក



Khmer Women of the word_Layout.indd 164 12/3/26 3:56 in the afternoon

គេគួរតែញញឹម និងសប្បាយចិត្តអំពីការនោះមែនឬ? នៅពេលដែលយើងពិគ្រោះជាមួយនឹងការបកប្រែផ្សេង យើងបានរកឃើញតាមរយៈការអានព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន "សូមចាត់ទុកថា ជាការដែលធ្វើអោយបងប្អូនមានអំណរដ៏បរិបូណ៌វិញ" (គខប) និងមើលការបកប្រែព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ២០១៦ "នោះត្រូវរាប់ជាអំណរសព្វគ្រប់វិញ" (គកស១៦)។ កម្រងវេវចនសព្ទជួយយើងបន្ថែមក្នុងការបង្ហាញថាពាក្យ ចាត់ទុក និង រាប់ជា ជាវេវចនសព្ទ ដែលមានន័យដូចគ្នា។ ខគម្ពីរយោងរបស់យើងនិយាយអំពីគោលគំនិតនៃការបៀតបៀន ដែលនឹងបង្កើតជាលទ្ធផលនៃរង្វាន់នាពេលអនាគត។ ការបូកបញ្ចូលគ្នានៃចំណុចយោងទាំងនេះ អ្នកប្រហែលជាពន្យល់អំពីកណ្ឌគម្ពីរ យ៉ាកុប ១:២-៣ ដូចនេះ៖ *ឱបងប្អូនអើយ នៅពេលដែលបងប្អូនជួបការបៀតបៀន សូមរាប់ទុកថាវាជាប្រភពនៃអំណរនាពេលអនាគតចុះ ដោយដឹងថានៅពេលដែលសេចក្តីជំនឿរបស់អ្នករាល់គ្នាជួបការល្បងល នោះអ្នកនឹងរីកចម្រើននៅក្នុងសមត្ថភាពចេះខិតខំព្យាយាមជាមិនខាន។*

តើការពន្យល់របស់អ្នកត្រឹមត្រូវដែរឬទេ? អ្នកនឹងដឹងបានកាន់តែច្បាស់នៅពេលដែលអ្នកចាប់ផ្តើមអានសេចក្តីអធិប្បាយព្រះគម្ពីរ ដោយស្វែងរកមើលអ្វីដែលអ្នកប្រាជ្ញបានលើកឡើង ស្រដៀងទៅនឹងសេចក្តីសន្និដ្ឋានរបស់ពួកគាត់។ ទោះជាយ៉ាងណា អ្នកបានធ្វើនៅផ្នែកដែលព្យាយាមធ្វើការកាត់ស្រាយដោយខ្លួនឯង។ នៅពេលដែលគំនិតរបស់អ្នកអភិវឌ្ឍន៍ ប្រសិនបើអ្នកយល់ឃើញថាសេចក្តីពន្យល់របស់អ្នកដូចជាមិនទាន់ត្រឹមត្រូវ សូមគ្រាន់តែត្រឡប់ទៅធ្វើការកែលំអទៅលើការយល់ដឹងនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ឬនៅក្នុងក្រដាសអត្ថបទថតចម្លងរបស់អ្នកបានហើយ។

*ការពិគ្រោះជាមួយនឹងសេចក្តីអធិប្បាយព្រះគម្ពីរ*

នៅពេលដែលយើងបានចំណាយពេលខិតខំប្រឹងប្រែងស្វែងយល់ អំពីអ្វីដែលអត្ថបទបាននិយាយ និងស្វែងរកអត្ថន័យដោយខ្លួនឯងរួចហើយ



Khmer Women of the word_Layout.indd 165 12/3/26 3:56 in the afternoon

ឥឡូវនេះអ្នកអាចនឹងត្រៀមរួចរាល់នៅក្នុងការគិតពិចារណាអំពីអ្វីដែលអ្នកដទៃនិយាយបាន។ តាមរយៈសេចក្តីពន្យល់ក្នុងសៀវភៅអត្ថាធិប្បាយ នោះអ្នកនឹងរកឃើញនូវចំណុចដែលមានប្រយោជន៍ពីចំណុចសិក្សាធម្មតា ទៅកាន់ចំណុចដែលជាក់លាក់។ សូមចាប់ផ្តើមជាមួយនឹងកំណត់សម្គាល់ការសិក្សាព្រះគម្ពីររបស់អ្នក បន្ទាប់មកអានសេចក្តីអត្ថាធិប្បាយ ឬសេចក្តីបង្រៀនឲ្យបានជ្រៅជាងមុនដើម្បីជួយអ្នកគិតឲ្យបានប្រសើរជាងមុន។ សូមចាំថា អ្នកបានប្រើនូវធនធានសេចក្តីអធិប្បាយព្រះគម្ពីរដែលអាចទុកចិត្តបាន។ សូមស្វែងរកចំណុចដែលអ្នកយល់ស្រប និងចំណុចដែលអ្នកមិនយល់ស្របនៅក្នុងសេចក្តីអធិប្បាយព្រះគម្ពីររបស់អ្នកចុះ។ ចំណុចដែលអ្នកមិនយល់ស្របសូមសួរមកកាន់ខ្លួនឯងថា តើមានការកាត់ស្រាយណាមួយដែលល្អប្រសើរ តាមរយៈការខិតខំប្រឹងប្រែងប្រមូលនៅក្នុងការសិក្សាដោយខ្លួនឯងរបស់អ្នក។

## ការអនុវត្ត៖ តើអត្ថបទនេះគួរផ្លាស់ប្តូរខ្ញុំដូចម្តេច?

នៅពេលដែលអ្នកបានធ្វើនូវចំណុចនៃការយល់ដឹង និងការកាត់ស្រាយហើយ អ្នកអាចចាប់ផ្តើមគិតពិចារណាអំពីរបៀបនៅក្នុងការអនុវត្តនូវអ្វីដែលអ្នកបានរៀន ដោយនឹកគិតអំពីសំណួរ «តើអត្ថបទនេះគួរផ្លាស់ប្តូរខ្ញុំដូចម្តេច?» យើងនឹងទទួលបានចម្លើយតាមរយៈសំណួរតូចៗបី៖

- តើអត្ថបទព្រះគម្ពីរនេះបង្រៀនខ្ញុំអ្វីខ្លះអំពីព្រះជាម្ចាស់?
- តើទិដ្ឋភាពអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ផ្លាស់ប្តូរការយល់ឃើញរបស់ខ្ញុំអំពីខ្លួនឯងយ៉ាងដូចម្តេចខ្លះ?
- តើខ្ញុំត្រូវធ្វើអ្វីខ្លះក្នុងការឆ្លើយ

សូមចូលទៅមើលក្នុងកំណត់សម្គាល់របស់អ្នកនៅគែមទំព័រនៃកណ្ឌគម្ពីរយ៉ាកុប ១:១-១៨។ មកដល់ពេលនេះ អ្នកអាចរួចរាល់នៅក្នុងការទទួលយកនូវលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ និងអនុវត្តចេញពីចំណុចទាំងនោះបាន



Khmer Women of the word_Layout.indd 166 12/3/26 3:56 in the afternoon

ហើយ។ នៅក្នុងគំរូឧទាហរណ៍របស់យើងបានបង្ហាញសេចក្តីពិតអំពីព្រះជាម្ចាស់ជាច្រើនដែលបានកត់ត្រានៅតែមទំព័រ។ សូមកត់ចំណុចសម្គាល់ទាំងនេះចូលទៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកសរសេរនូវចំណុចឆ្លើយតបទៅនឹងការមើលឃើញចំពោះខ្លួនឯង និងឆ្លើយតបចំពោះគ្នាទៅវិញទៅមក៖

1. *ការមើលឃើញអំពីព្រះជាម្ចាស់៖* ព្រះ (ព្រះយេស៊ូវ) មានអំណាច (១:១)
   *ការមើលឃើញអំពីខ្លួនឯង៖* ខ្ញុំគ្មានអំណាចមកលើជីវិត ឬក៏កាលៈទេសៈរបស់ខ្ញុំឡើយ។
   *ការឆ្លើយតប៖* តើខ្ញុំអាចចុះចូលចំពោះព្រះយេស៊ូវជាព្រះអម្ចាស់របស់ខ្ញុំ ឲ្យបានប្រសើរដោយរបៀបណា? តើមានផ្នែកណាខ្លះនៅក្នុងជីវិតរបស់ខ្ញុំដែលខ្ញុំមានបំណងដាក់នៅក្រោមការត្រួតពិនិត្យនោះ?
2. *ការមើលឃើញអំពីព្រះជាម្ចាស់៖* ព្រះជាម្ចាស់មានប្រាជ្ញា ព្រះអង្គប្រទានឲ្យយើងដោយព្រះទ័យសប្បុរសនៅពេលដែលយើងសូមព្រះអង្គ (១:៥)។
   *ការមើលឃើញអំពីខ្លួនឯង៖* ខ្ញុំខ្វះប្រាជ្ញា ខ្ញុំបានធ្វើគ្រប់យ៉ាងដោយប្រាជ្ញារបស់ខ្លួនខ្ញុំ ជាជាងទូលសូមព្រះអង្គចំពោះប្រាជ្ញាដែលមកពីព្រះនោះ។
   *ការឆ្លើយតប៖* តើមានផ្នែកណាខ្លះនៅក្នុងជីវិតរបស់ខ្ញុំ ក្នុងពេលបច្ចុប្បន្ននេះដែលខ្ញុំត្រូវការប្រាជ្ញាមកពីព្រះជាម្ចាស់ខ្លាំងបំផុត? តើខ្ញុំបានទូលសូមព្រះអង្គហើយឬនៅ?

យើងអាចទាញយកចំណុចអនុវត្តចេញពីអត្ថបទ ប៉ុន្តែយើងត្រូវចាំថាសំណួរដែលផ្តោតទៅកាន់ព្រះជាម្ចាស់គួរតែ ជារឿយៗ ត្រូវតែជាចំណុចចាប់ផ្តើមរបស់យើង។ សំណួរទាំងនោះមិនមែនជាចំណុចបន្ទាប់បន្សំឡើយ។ ឧទាហរណ៍៖ ចំណុចអនុវត្តផ្សេងៗដែលអាចលើកឡើងដំបូងចេញពីការគិតពិចារណាអំពីចារឹកលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់នៅក្នុង កណ្ឌគម្ពីរយ៉ាកុប ១:១-១៨ រួមមាន៖

- ក្នុងពេលដែលគាត់មានជីវិតរស់នៅ៖ លោក យ៉ាកុប ដែលត្រូវបានគេហៅថាជា «ប្អូន» របស់ព្រះយេស៊ូវ គឺគាត់បានចាប់ផ្តើមសរសេរសំបុត្ររបស់គាត់



Khmer Women of the word_Layout.indd 167 12/3/26 3:56 in the afternoon

ដោយហៅព្រះយេស៊ូវថា «ព្រះអម្ចាស់» និង «ព្រះគ្រីស្ទ» តើខ្ញុំបានគោរពព្រះយេស៊ូវជាព្រះអម្ចាស់ និងជាព្រះគ្រីស្ទដែរឬទេ ឬក៏ខ្ញុំបានគិតអំពីព្រះអង្គដោយមិនបានយកចិត្តទុកដាក់សោះ?

- ព្រះជាម្ចាស់ប្រទានប្រាជ្ញា (១:៥) និងគ្រប់របស់ដែលល្អ និងអំណោយដ៏គ្រប់លក្ខណ៍ផង (១:១៦)។តើខ្ញុំបានទូលសូមប្រាជ្ញាពីព្រះអង្គដែរឬទេ? តើខ្ញុំមានបានអរព្រះគុណព្រះជាម្ចាស់សម្រាប់អំណោយល្អៗ ដែលព្រះអង្គបានប្រទានមកខ្ញុំដែរឬទេ?

សំណួរសម្រាប់ចំណុចអនុវត្តរបស់អ្នកអាចបង្កើតនូវចំណុចបញ្ចប់នៃការអធិស្ឋាន ឬក៏ប្រសិនបើអ្នកអញ្ជើញស្ត្រីឲ្យមកជួបជុំគ្នា ដើម្បីធ្វើការពិភាក្សា សំណួរទាំងនេះអាចជាចំណុចមូលដ្ឋាននៅក្នុងការចាប់ផ្ដើមចំណុចពិភាក្សាបាន។

## គ្រប់ទាំងគំរូឧទាហរណ៍សុទ្ធតែមានដែនកំណត់

ការសារភាព៖ ខ្ញុំជ្រើសរើសកណ្ឌគម្ពីរយ៉ាកុបជាឧទាហរណ៍ ពីព្រោះវាមានភាពងាយស្រួលក្នុងការបង្ហាញអំពីវិធីសាស្ត្រនៅក្នុងការសិក្សាថាមានដំណើរការយ៉ាងដូចម្ដេច។ កណ្ឌគម្ពីរយ៉ាកុប ពោរពេញទៅដោយចំណុចជាច្រើនប្រភេទដែលអ្នកអាចកត់សម្គាល់បាន។ យើងងាយស្រួលបកស្រាយ និងអនុវត្តណាស់។ គឺនិយាយចំៗត្រង់ទៅរកការកាត់ស្រាយ និងងាយស្រួលនៅក្នុងការអនុវត្ត។ ហើយមិនសូវវែង មិនមែនគ្រប់ទាំងកណ្ឌគម្ពីរទាំងអស់សុទ្ធតែអាចងាយយល់ និងអនុវត្តបាននោះឡើយ។

សូមចាំនៅក្នុងគំនិតថា ប្រសិនបើអ្នកសិក្សាកណ្ឌគម្ពីរដែលវែង នោះកំណត់សម្គាល់នៅក្នុងអត្ថបទរបស់អ្នកប្រហែលខ្លីជាងចំណុចឧទាហរណ៍របស់យើងដែលដកស្រង់ចេញពីកណ្ឌគម្ពីរយ៉ាកុប៖ ពាក្យ ឬគំនិតដដែលៗប្រហែលត្រូវចំណាយពេលវេលាយូរក្នុងការស្វែងរកឃើញចំណុចដែលជាក់លាក់។ ការយល់ដឹងប្រហែលពេញទៅដោយការប្រាប់ម្ដងហើយម្ដងទៀត



Khmer Women of the word_Layout.indd 168 12/3/26 3:56 in the afternoon

អំពីចំណុចធំនៃដំណើររឿងប្រវត្តិសាស្ត្រទាំងមូល។ ការកាត់ស្រាយប្រហែលបង្ហាញឲ្យយើងឃើញមានចំណុចសំខាន់ពីរបីប៉ុណ្ណោះ នោះនៅចុងបញ្ចប់ យើងមិនទទួលបាននូវចំណុចកត់សម្គាល់ឡើយ ពីព្រោះតែយើងខ្វះចន្លោះនូវព័ត៌មានជីវប្រវត្តិ។ លក្ខណសម្បត្តិប្រហែលបង្ហាញនៅក្នុងរបៀបមួយដែលមិនអាចពន្យល់បាន អ្នកនិពន្ធប្រហែលពោរពេញដោយភាពស្មុគស្មាញ ឬក៏ប្រធានបទដូចជាមិនសូវច្បាស់លាស់ មានភាសា និងមានរូបភាពដូចជាមានការភ័ន្តច្រឡំ។ ហើយភ្លេចនៅក្នុងការព្យាយាមបញ្ចេញឈ្មោះមនុស្សផងដែរ។

ប្រសិនបើអ្នកជួបនូវភាពស្មុគស្មាញ ឬក៏មានអារម្មណ៍ថាជាប់គាំង៖ សូមរម្លឹកខ្លួនឯងថា នេះគឺជាកិច្ចការងាររបស់យើងក្នុងនាមជាសិស្ស គឺត្រូវបន្តការប្រើប្រាស់នូវជំនាញនៃការសិក្សានេះឲ្យដំណើរការ។ ជាមួយនឹងពេលវេលាខុសគ្នា និងការសិក្សាកណ្ឌគម្ពីរផ្សេងៗគ្នា នោះអ្នកនឹងប្រើនូវជំនាញសិក្សាខុសៗគ្នា ហើយទទួលបានកម្រិតប្រសិទ្ធភាពផ្សេងៗគ្នាផងដែរ។ ប៉ុន្តែ យើងនៅតែប្រើប្រាស់ជំនាញទាំងនោះ។ យើងនៅតែស្វែងរកនូវទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងជាមួយនឹងអត្ថបទ មុនពេលស្វែងរកជំនួយពីប្រភពផ្សេងៗ។ លោក យ៉ាកុប នៅតែទទូចឲ្យយើងសូមប្រាជ្ញា ហើយទុកចិត្តដល់ព្រះអង្គថាទ្រង់នឹងប្រទានឲ្យយើង ហើយសូមចាំថាកិច្ចខិតខំប្រឹងប្រែងរបស់យើងគឺសម្រាប់រយៈពេលយូរអង្វែង។ ភាពស្មោះត្រង់ពិតប្រាកដនៅក្នុងសិស្សនោះគឺជាការអស្ចារ្យយ៉ាងពិតប្រាកដណាស់។

## គំនិតមួយចំនួនចុងក្រោយសម្រាប់ការសិក្សាផ្ទាល់ខ្លួនជាមួយនឹងវិធីសាស្ត្រទាំងប្រាំនេះ

ឥឡូវនេះ អ្នកបានធ្វើរួចហើយ អ្នកបានធ្វើដំណើរសិក្សានៅក្នុងអត្ថបទ ដូចជាសិស្សដែលបានសិក្សាមានវិធីសាស្ត្រ។ ប្រហែលពេលវេលារបស់អ្នករៀងរាល់ថ្ងៃ មិនសូវមានពេលគ្រប់គ្រាន់នៅក្នុងការសិក្សា ឬថ្ងៃខ្លះអ្នកមានពេលតិចជាងថ្ងៃផ្សេងៗ ប៉ុន្តែអ្នកបានប្រើពេលវេលាដែលអាចធ្វើទៅបាន ដើម្បីឲ្យ



Khmer Women of the word_Layout.indd 169 12/3/26 3:56 in the afternoon

តម្លៃទៅលើវិធីសាស្ត្រនៃការសិក្សាទាំងប្រាំនេះ។ តើអ្នកអនុញ្ញាតឲ្យខ្ញុំផ្តល់នូវចំណុចបន្ថែមចុងក្រោយមួយទៀតសម្រាប់អ្នកគិតពិចារណាដែរឬទេ? ប្រសិនបើអាចធ្វើទៅបានសូមចែកចាយការខិតខំប្រឹងប្រែងរបស់អ្នកជាមួយនឹងអ្នកដទៃផ្សេងទៀត។

ដូចខ្ញុំបានលើកឡើងពីដំបូងនេះ ការប្រមូលអ្នកដទៃផ្សេងទៀតមកពិភាក្សាអំពីអ្វីដែលអ្នកបានរកឃើញចេញពីការសិក្សាផ្ទាល់ខ្លួនរបស់អ្នក នឹងផ្តល់ផលប្រយោជន៍ដល់អ្នកយ៉ាងល្អប្រសើរ តាមរយៈកិច្ចការដែលអ្នកបានធ្វើ។ ការសិក្សាព្រះគម្ពីរពិតជាបានកើតឡើងតាមរយៈការសិក្សាផ្ទាល់ខ្លួនមែន ប៉ុន្តែនៅក្នុងសហគមន៍ គឺបង្ហាញនូវទំហំ និងការទទួលខុសត្រូវ ដែលនឹងមិនមានកន្លែងណាផ្សេងទៀតធ្វើបាននោះឡើយ។ ការសិក្សាជាមួយដៃគូ ឬជាក្រុមជួយអ្នកឲ្យបន្តដំណើរទៅមុខ និងជួយការពារអ្នកកុំឲ្យធ្លាក់ចូលទៅក្នុងការបកស្រាយ និងការអនុវត្តដែលមិនបានឲ្យតម្លៃទៅលើអត្ថបទ។ ប្រសិនបើអ្នកស្ថិតនៅក្នុងកន្លែង ឬដំណាក់កាលនៃជីវិតដែលពិបាកនៅក្នុងការប្រមូលផ្តុំ ការសិក្សាផ្ទាល់ខ្លួនពិតប្រាកដនឹងជួយអ្នកឆ្ពោះទៅរកចំណេះដឹងខាងឯព្រះគម្ពីរ។ ប៉ុន្តែ ប្រសិនបើគ្រប់ការទាំងអស់អាចដំណើរការបាន សូមអញ្ជើញអ្នកដទៃឲ្យសិក្សាជាមួយអ្នក។ ក្រុមសិក្សារបស់អ្នកនឹងក្លាយទៅជាមធ្យោបាយមួយសម្រាប់ការពិភាក្សា ការសារភាព ការប្រែចិត្ត ការលើកទឹកចិត្ត និងការបង្រៀនដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។ អ្នកនឹងដឹងយ៉ាងប្រាកដថា មិនមែនមានតែអ្នកទេដែលមានអារម្មណ៍ថា ការសិក្សាគឺមិនងាយស្រួលឡើយ ហើយអ្នកនឹងចែកចាយនូវអំណរនៃការស្វែងរកឃើញ និងការយល់ដឹងជាមួយគ្នាផងដែរ។

ក្រុមសិក្សារបស់អ្នកអាចបម្រើគ្នានូវចំណុចយោង ដើម្បីជួយអ្នកឲ្យស្ថិតនៅក្នុងចំណុចដែលត្រឹមត្រូវជាមួយនឹងការសិក្សារបស់អ្នក។ ការធ្វើដូច្នោះមានលក្ខណៈដូចជាការបង្រៀន និងការអធិប្បាយផងដែរ។ អំណោយទានសម្រាប់រូបកាយនៃអ្នកជឿទាំងនេះ គឺអាចប្រើប្រាស់បានល្អកាន់តែប្រសើរ



Khmer Women of the word_Layout.indd 170 12/3/26 3:56 in the afternoon

ជាងមុន។ មិនថាការជួបជុំជាក្រុមអាចធ្វើទៅបានសម្រាប់អ្នក ឬក៏មិនបាន សូមទាញយកនូវប្រយោជន៍នៃការសិក្សាដែលត្រឹមត្រូវនេះចេញពីប្រភពនៃប្រព័ន្ធអេឡិចត្រូនិកដែលបង្ហោះឲ្យយើងអាចប្រើប្រាស់បាន។ ប្រសិនបើអ្នកមិនប្រាកដថានឹងស្តាប់គ្រូណាមួយ សូមសួរគ្រូគង្វាលរបស់អ្នកតើការបង្រៀនរបស់គ្រូណាមួយដែលបានជួយគាត់ដោយផ្ទាល់។ សូមពិនិត្យមើលអ្វីដែលអ្នកបានរៀនផ្ទាល់ខ្លួនថា តើវាមានភាពស៊ីគ្នាទៅនឹងការបង្រៀនរបស់គ្រូស្មោះត្រង់ណាមួយដែរឬទេ។ សូមចាំថា អ្នកនឹងប្រើធនធានទាំងនេះគឺ បន្ទាប់ពីអ្នកបានប្រើប្រាស់វិធិសាស្រ្តទាំង៥ នៃការសិក្សាផ្ទាល់ខ្លួនរួចហើយប៉ុណ្ណោះ។ ការអធិប្បាយ និងការបង្រៀនគឺមានទ្រង់ទ្រាយធំ និងសម្រេចបានច្រើន នៅពេលដែលយើងយល់ទទួលបាននៅក្នុងអត្ថបទដែលពួកគេអធិប្បាយ។

ជារឿយៗ គឺជាការពិតដែលថាសិស្សដែលមានការអន្ទះសា ក្លាយទៅជាគ្រូដែលអន្ទះសាដែរ។ ខ្ញុំដឹងពីព្រោះនេះ គឺជាករណីរបស់ខ្ញុំ។ ខ្ញុំរំភើបនៅក្នុងការចែកចាយកំណប់ទ្រព្យនៃការយល់ដឹងដែលខ្ញុំទទួលបាន ដែលពេលនោះខ្ញុំបានផ្លាស់ប្តូរពីភាពជាសិស្សទៅជាគ្រូ។ ពិតណាស់ ខ្ញុំមិនបញ្ឈប់នៅក្នុងការធ្វើជាសិស្សឡើយ មានវិធីសាស្រ្តជាច្រើន តែការចាប់ផ្តើមបង្រៀន គឺជាវិធីមួយជួយឲ្យខ្ញុំមានការទទួលខុសត្រូវនៅក្នុងការសិក្សា។ ដោយដឹងថាមានមនុស្សជាច្រើនពឹងផ្អែកមកលើខ្ញុំ ការបង្ហាញអំពីការរៀបចំ និងដឹងថាព្រះជាម្ចាស់ពិតជាយកចិត្តទុកដាក់ទៅលើតួនាទីគ្រូបង្រៀន (យ៉ាកុប ៣:១) ជួយឲ្យខ្ញុំក្លាយជាសិស្សដែលមានលក្ខណៈល្អប្រសើរ ជាជាងអ្វីដែលខ្ញុំអាចទទួលបានដោយខ្លួនឯង។

ចំណុចមួយក្នុងនាមជាសិស្សដែលត្រូវមានការប្រុងប្រយ័ត្ន ការប្រើប្រាស់វិធីសាស្រ្តនៃការសិក្សាទាំង៥ គឺដើម្បីដឹកនាំ ឬការសិក្សារបស់អ្នក ប៉ុន្តែចំណុចមួយទៀតក៏ត្រូវមានការប្រុងប្រយ័ត្នដែរ ក្នុងនាមជាគ្រូ គឺណែនាំសិស្សរបស់អ្នកឲ្យពួកគេរៀនសូត្រ និងអនុវត្តនូវវិធីសាស្រ្តនៃការសិក្សាទាំង៥នេះ។ ប្រសិនបើអ្នកជាគ្រូបង្រៀន ខ្ញុំផ្តល់ឲ្យនូវគំនិតជាជំនួយមួយចំនួនសម្រាប់



Khmer Women of the word_Layout.indd 171 12/3/26 3:56 in the afternoon

អនុវត្ត គឺនៅជំពូកបន្ទាប់នេះ។

## សំណួរឆ្លុះបញ្ចាំង

១. សូមត្រឡប់ទៅមើលចំណុចដែលបានស្នើនៅក្នុងទំព័រទី១២១ តើចំណុចទាំងនេះហាក់បីដូចថ្មីសម្រាប់អ្នក ឬក៏ដូចជាមិនមានការចាំបាច់សោះ? តើមានអ្វីដែលអ្នកចង់បន្ថែមនៅក្នុងបញ្ជីនោះដែរឬទេ?

២. ដំណាក់កាលនៃការយល់ដឹងនឹងត្រូវការពេលវេលាច្រើន តើអ្នកនឹងប្រឈមជាមួយនឹងការបាក់ទឹកចិត្ត ការមិនមានភាពអត់ធ្មត់ នៅក្នុងដំណាក់កាលនេះដោយរបៀបណា? តើវិធីសាស្ត្រណាមួយនៅក្នុងដំណើរការនៃការយល់ដឹង ដែលអ្នកគិតថានឹងផ្តល់អត្ថប្រយោជន៍ ឬមានភាពសប្បាយរីករាយជាងគេ? តើមានចំណុចមួយណាដែលនឹងសាកល្បងការអត់ធ្មត់របស់អ្នកច្រើនជាងគេ?

៣. ហេតុអ្វីបានជាអ្នកគិតថា ខគម្ពីរយោង ការបកស្រាយ និងសេចក្តីអធិប្បាយព្រះគម្ពីរបង្ហាញជាក់ច្បាស់នៅក្នុងលំដាប់លំដោយច្បាស់លាស់ នៅក្នុងដំណាក់កាលនៃការកាត់ស្រាយ (ទំព័រ១២៦-១៣០)? តើលំដាប់លំដោយនេះបង្ហាញពីភាពខុសគ្នាអ្វីខ្លះ?



Khmer Women of the word_Layout.indd 172 12/3/26 3:56 in the afternoon

៤. តើអ្វីទៅជាប្រភេទនៃការអនុវត្តផ្សេងទៀត ក្រៅពីការអនុវត្តដែលដាក់ព្រះជាម្ចាស់នៅចំណុចកណ្ដាល ដែលយើងមានទំនោរឆាប់ចូលទៅកាន់ការអនុវត្តប្រភេទផ្សេងទៀតអ្វីខ្លះ? ហេតុអ្វីបានជាយើងត្រូវចាប់ផ្ដើមជាមួយនឹងការអនុវត្តដែលមានព្រះជាម្ចាស់នៅចំណុចកណ្ដាល?

៥. តើការចែកចាយអំពីការសិក្សារបស់អ្នកជាមួយនឹងក្រុម ទទួលបានផលប្រយោជន៍អ្វីខ្លះ? តើមានចំណុចណាមួយដែលអ្នកចាប់អារម្មណ៍ជាងគេ? តើមានចំណុចណាមួយដែលអ្នកត្រូវការជាងគេ?



Khmer Women of the word_Layout.indd 173 12/3/26 3:56 in the afternoon

ជំពូកទី៩

# ជំនួយសម្រាប់គ្រូបង្រៀន

ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះទុកជាមនុស្សដែលបានល្បងលជាប់ ហើយជាអ្នកធ្វើការ ដែលមិនត្រូវខ្មាសឡើយដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្តីពិតយ៉ាងត្រឹមត្រូវ។

២ធីម៉ូថេ ២:១៥

ខ្ញុំជាសមាជិកក្រុមតូចម្នាក់គួរឲ្យភ័យខ្លាច ប្រសិនបើអ្នកត្រូវបានបណ្តុះបណ្តាលសម្រាប់ដឹកនាំក្រុមតូច ខ្ញុំសង្ឃឹមថាអ្នកទទួលបានការណែនាំដ៏មានតម្លៃមួយនេះ៖ សូមកុំទំនាក់ទំនងខ្សែភ្នែកជាមួយសមាជិកក្រុមដែលចង់គ្រប់គ្រងការពិភាក្សា។ ក្រុមរបស់អ្នកគឺពឹងផ្អែកមកលើអ្នក ប្រសិនបើអ្នកមើលមកចំនាង នៅពេលដែលអ្នកកំពុងសួរសំណួរពិភាក្សាបន្ទាប់ គឺថាអ្នកចប់ហើយ។

ខ្ញុំគឺជាមនុស្សម្នាក់ដែលអ្នកមិនត្រូវមើលឡើយ ឬយ៉ាងហោចណាស់ខ្ញុំធ្លាប់ជាមនុស្សបែបនោះ។ ពេលវេលាក្រុមតូចគឺដូចជាសុបិន្តអាក្រក់សម្រាប់ខ្ញុំ និងសមាជិកផ្សេងៗទៀតនៅក្នុងក្រុមខ្ញុំដែរ។ ខ្ញុំនឹងមកក្រុមតូចរៀងរាល់សប្តាហ៍ជាមួយនឹងសៀវភៅកំណត់ហេតុរបស់ខ្ញុំ កំណត់សម្គាល់ជាមួយនឹងសំណួរបន្ថែមជាច្រើន និងគំនិតយោបល់ផ្ទាល់ខ្លួនដែលខ្ញុំបានរកឃើញក្នុងពេលសិក្សាផ្ទាល់ខ្លួន ពេលវេលា ពិភាក្សាដូចជាមិនគ្រប់គ្រាន់សោះសម្រាប់ខ្ញុំ។ ខ្ញុំមិនអាចរង់ចាំឲ្យពេល «រំភើប និងការព្រួយបារម្ភ» រំលងផុតទៅ ដែល



Khmer Women of the word_Layout.indd 175 12/3/26 3:56 in the afternoon

នោះមានន័យថា យើងដល់ពេលមើលទៅក្នុងមេរៀនឲ្យស៊ីជម្រៅជាមួយគ្នាហើយ។ (ខ្ញុំមិនឲ្យតម្លៃទៅលើការស្គាល់អ្នករត់សំបុត្រ ដែលជាជីដូនមួយរបស់អ្នកប៉ុន្មានទេ តែខ្ញុំចង់សិក្សាកណ្ឌគម្ពីររ៉ូមភ្លាមៗ។) ខ្ញុំតែងតែគិត ថាតើខ្ញុំនឹងសួរសំណួរយ៉ាងដូចម្ដេចឲ្យមានភាពខុសប្លែកពីគ្នា អ្វីដែលជាខគម្ពីរយោងដែលខ្ញុំចង់លើកឡើង និងគំនិតដែលសំខាន់ៗណាមួយដែលខ្ញុំនឹងបង្រៀន។ ខ្ញុំស្ទើរតែអង្គុយមិនជាប់កៅអីខ្លួន ដោយហៀបនឹងងើប ខណៈពេលដែលរង់ចាំពេលវេលាដែលខ្ញុំអាចស៊កបញ្ចូលនូវអ្វីដែលជាការសង្កេតមើល ឬអ្វីដែលខ្ញុំបានរកឃើញ ដាក់ចូលទៅក្នុងការសន្ទនានោះ។

ខ្ញុំចាំបានអំពីថ្ងៃដែលខ្ញុំបានផ្ដល់នូវគំនិតនៃការបកស្រាយមួយចំនួន អំពីអត្ថបទដែលអ្នកនិពន្ធសៀវភៅដែលក្រុមតូចយើងបានប្រើប្រាស់។ ខ្ញុំមិនដឹងថាភាពស្ងៀមស្ងាត់របស់ខ្ញុំបាននិយាយយ៉ាងឮៗ ឬក៏ថានិយាយយ៉ាងយូរ។ តាមពិតទៅនិយាយឲ្យចំ ការជួបជុំស្ត្រីលក្ខណៈក្រុមតូចគឺជាការដែលឲ្យតម្លៃទៅលើមតិយោបល់រួមគ្នា។ ការនេះដូចជាអ្វីដែលកើតឡើងនៅក្នុងថ្នាក់សាលាមត្តេយ្យដែរ។ តើមានរឿងអ្វីកើតឡើងចំពោះខ្ញុំ?

ខ្ញុំចង់សូមទោសដល់អ្នកដឹកនាំក្រុមតូចរបស់ខ្ញុំទាំងអស់គ្នាពីមុនៗ បើសិនខ្ញុំជាអ្នកវិញ ខ្ញុំនឹងខោកមួយចំកណ្ដាលថ្ងាសហើយ។ ហើយខ្ញុំចង់អរគុណដល់អ្នកដឹកនាំដែលបាននាំខ្ញុំទៅជ្រុងម្ខាង ហើយនិយាយថា “អ្នកដឹងទេ ខ្ញុំគិតថា អ្នកប្រហែលជាមានអំណោយទានខាងបង្រៀន”។ ខ្ញុំពិតជាអរគុណដល់អ្នកយ៉ាងអស់ពីដួងចិត្តរបស់ខ្ញុំ អរគុណដែលបានមើលឃើញអ្វីមួយនៅក្នុងខ្ញុំ ដែលខ្ញុំខ្លួនឯងផ្ទាល់មិនបានមើលឃើញ។

ប្រហែលជាអ្នកធ្លាប់ជួបបទពិសោធន៍ដូចខ្ញុំ។ ប្រហែលជាអ្នកដឹកនាំក្រុមតូចរបស់អ្នកបានគេចភ្នែក ចេញពីអ្នក។ ប្រហែលជាអ្នកដឹងអំពីអារម្មណ៍ដែលចង់ផ្ទុះចេញមក ទៅលើក្រុមតូចរបស់អ្នក ហើយឆ្ងល់ថា ប្រសិនបើអ្នកគ្រាន់តែមានភាពឆ្លាតវៃទៅលើចំណុចណាមួយ ដែលបានធ្វើឲ្យអ្នកក្លាយជាសិស្សសំណព្វចិត្តរបស់គ្រូ នោះគ្រូនឹងឲ្យអ្នកចែកចាយដែរហើយ។ ឬ



Khmer Women of the word_Layout.indd 176 12/3/26 3:56 in the afternoon

ប្រហែលជាអ្នកមានប្តី ឬប្រពន្ធ ឬដៃគូទទួលខុសត្រូវដែលអត់ធ្មត់ចុះចូលជាមួយអ្នករៀងរាល់សប្តាហ៍ (រៀងរាល់យប់?) ដែលអ្នកអាចបញ្ចេញនូវគ្រប់ចំណុចដែលអ្នកបានរៀនអំឡុងពេលសិក្សាផ្ទាល់ខ្លួនរបស់អ្នក។ វាគឺជាការសំខាន់នៅក្នុងការសួរសំណួរទាក់ទងទៅនឹងអំនួតរបស់ខ្លួន ប៉ុន្តែការគិតទៅលើសំណួរដែលមានការបង្ហាត់បង្រៀនក៏មានសារៈសំខាន់ផងដែរ ជាពិសេសប្រសិនបើមានអ្នកណាម្នាក់បាន កត់សម្គាល់អំពីភស្តុតាងនៃអំណោយទាននៃការបង្រៀនរបស់អ្នក។ ប្រហែលហេតុផលដែលអ្នកជាសមាជិកម្នាក់ក្នុងក្រុមតូចមិនសូវល្អ គឺដោយសារព្រះអង្គបានបង្កើតអ្នកមក ដើម្បីឲ្យធ្វើជាអ្នកបង្រៀនហើយ។

ខ្ញុំសង្ឃឹមថា អ្នកមានទំនោរចង់ធ្វើជាគ្រូបង្រៀន។ ខ្ញុំជឿថាក្រុមជំនុំពិតជាត្រូវការជាចាំបាច់នូវគ្រូបង្រៀនជាស្ត្រី ដែលទទួលបានការបណ្តុះបណ្តាលល្អ។ ស្ត្រីដែលនឹងបង្រៀនព្រះបន្ទូលដោយការខិតខំព្យាយាម និងយកចិត្តទុកដាក់ហើយជាស្ត្រីដែលមានដួងចិត្តចង់បានចំណេះដឹងខាងឯព្រះគម្ពីរ។ វាគឺជារឿងសំខាន់ដែលស្ត្រីបង្រៀនស្ត្រី ហើយពួកគេធ្វើដូច្នោះបានយ៉ាងល្អប្រសើរ។ ខ្ញុំជឿថា រឿងនេះសំខាន់ដោយមានហេតុផលបីយ៉ាង៖

## ហេតុអ្វីស្ត្រីត្រូវការគ្រូបង្រៀនជាស្ត្រី

ទីមួយ យើងត្រូវការ *គំរូ* ពីគ្រូបង្រៀនដែលជាស្ត្រី នៅពេលស្ត្រីឃើញអ្នកណាម្នាក់ដែលមានលក្ខណៈដូចនាង និងការបង្រៀនព្រះគម្ពីររបស់ស្ត្រីនោះពោរពេញដោយភាពឆេះឆួល និងភាពវៃឆ្លាត នាងចាប់ផ្តើមទទួលស្គាល់ថានោះគឺជាខ្លួនគាត់។ នាងអាចស្រឡាញ់ព្រះជាម្ចាស់ជាមួយនឹងគំនិតរបស់នាង—ប្រហែលលើសអំពីអ្វីដែលនាងបានគិតថាចាំបាច់ ឬក៏អាចទៅរួចទៀតផង។ តើខ្ញុំពិតជាធ្លាប់បានឮថា មានតែបុរសទេឬដែលអាចបង្រៀនព្រះគម្ពីរបានល្អ ខ្ញុំមិនបានគិតអំពីខ្លួនឯងមានសមត្ថភាពអាចធ្វើដូចគ្នាបាននោះទេ។ អរគុណព្រះអង្គដែលទ្រង់បានប្រទានឲ្យខ្ញុំនូវប្រាជ្ញា ស្ត្រីដែលវៃឆ្លាតធ្វើជាគំរូអំពីការ



Khmer Women of the word_Layout.indd 177 12/3/26 3:56 in the afternoon

បើកព្រះបន្ទូលរបស់ព្រះអង្គជាមួយនឹងការកោតខ្លាច និងការចុះចូលដោយមានជំនាញ។

ទីពីរ យើងត្រូវការ *ទស្សនៈ* អំពីគ្រូបង្រៀនដែលជាស្ត្រី គ្រូបង្រៀនដែលជាស្ត្រីនឹងស្រូបទាញអារម្មណ៍របស់ស្ត្រីឲ្យអនុវត្ត និងយល់ថាគាត់ក៏អាចធ្វើដូចនោះបាន ដូចដែលគាត់ឃើញស្ត្រីដែលកំពុងបង្រៀនធ្វើដោយមានភាពឆេះឆួលដែរ។ សូមគិត៖ បើប្រៀបធៀបតិចជាងនៃការលេងបាល់ទាត់ និងមើលខ្សែភាពយន្តវាយប្រហារ ច្រើនជាងទៅលើការមើលទូរទស្សន៍ និងខ្សែភាពយន្តមនោសញ្ចេតនាមានលក្ខណៈតិចតួចទៅលើការជក់មើលរឿងអាសអាភាស ឬការបោះបង់ការទទួលខុសត្រូវ។ លក្ខណៈច្រើនទៅលើបញ្ហាការមើលមកខ្លួនឯង និងអណ្តាតនៃអំពើបាប។ គ្រូបង្រៀនជាស្ត្រីនឹងលើកនូវសេចក្តីពិតខុសៗគ្នាចេញពីអត្ថបទដែលខុសពីបុរស។ នេះមិនមែនមានន័យថា នាងនឹងធ្វើឲ្យអត្ថបទមានលក្ខណៈជាស្ត្រីនិយមនោះទេ (នោះជាគ្រោះថ្នាក់ ដែលយើងនឹងពិភាក្សាអត្ថបទនោះឲ្យបានជ្រៅពេលក្រោយ) ប៉ុន្តែនាងនឹងធ្វើការបញ្ជាក់នូវចំណុចដែលជាសេចក្តីពិតនៃអត្ថបទទាំងនោះ ដែលបង្ហាញអំពីតួនាទីសំខាន់របស់ស្ត្រីនៅក្នុងប្រវត្តិសាស្ត្រនៃការប្រោសលោះ ឬក៏និយាយអំពីបញ្ហានៃអំពើបាបទូទៅដែលស្ត្រីបានជួប។

ទីបី យើងត្រូវការ *អំណាច* អំពីគ្រូបង្រៀនដែលជាស្ត្រី ស្ត្រីអាចប្រាប់ស្ត្រីផ្សេងទៀតឲ្យបញ្ឈប់នៅក្នុងការថ្វាយបង្គំរូបព្រះទៅដល់កូនៗ ឬទៅកាន់ប្តីរបស់ពួកគេក្នុងរបៀបមួយដែលបុរសមិនអាចធ្វើបាន។ ស្ត្រីអាចដោះស្រាយជាមួយស្ត្រីផ្សេងទៀតទាក់ទងទៅនឹងភាពឥតប្រយោជន៍ មោទនភាព ការចុះចូល និងអំណរ នៅក្នុងរបៀបមួយដែលបុរសមិនអាចធ្វើបាន។ គ្រូបង្រៀនជាស្ត្រីមានអំណាចនៅក្នុងការចេះយល់ចិត្តទៅលើសិស្សដែលជាស្ត្រីរបស់ពួកគេយើងមានសមត្ថភាពនៅក្នុងការនិយាយ «ខ្ញុំយល់ពីអំពើបាបដែលបានរំខានឥតឈប់ឈរ និងការភ័យខ្លាចរបស់ស្ត្រី ហើយខ្ញុំសូមផ្តល់ឲ្យអ្នកនូវខព្រះគម្ពីរដែលគ្រប់គ្រាន់ល្មមសម្រាប់ជាការណែនាំលើកទឹកចិត្ត»។



Khmer Women of the word_Layout.indd 178 12/3/26 3:56 in the afternoon

ដូច្នេះ នៅក្នុងគ្រប់ការទាំងអស់ សូមសួរមកកាន់ខ្លួនឯង តើព្រះជាម្ចាស់បានត្រាស់ហៅអ្នកឲ្យធ្វើជាគ្រូបង្រៀនឬទេ ក្រុមជំនុំត្រូវការស្ត្រីដែលជាគ្រូបង្រៀនទៅកាន់ស្ត្រី។ ប្រសិនបើព្រះជាម្ចាស់ឆ្លើយ «យល់ព្រម» សូមចាប់ផ្តើមប្រមូលស្ត្រីហើយចាប់ផ្តើមដំណើរការចុះ។ ប៉ុន្តែ សូមបង្រៀនដោយយកចិត្តទុកដាក់ កណ្ឌគម្ពីរ យ៉ាកុប បានព្រមានដល់យើងមិនត្រូវធ្វើការបង្រៀនដោយធ្វេសប្រហែសឡើយ ប៉ុន្តែសូមគិតដោយពិចារណាផងដែរថា អស់អ្នកដែលបង្រៀននឹងត្រូវកាត់ទោសធ្ងន់ជាងគេ (យ៉ាកុប ៣:១) ។

តើការបង្រៀនដោយធ្វេសប្រហែសមានលក្ខណៈយ៉ាងដូចម្ដេច? ខ្ញុំជឿថាការនេះកើតឡើងនៅពេលដែលអ្នកមានការភ័ន្តច្រឡំអំពីការបង្រៀន ជាមួយនឹងការនិយាយជាសាធារណៈ។ ទាំងពីរនេះគឺមិនដូចគ្នាទេ ពេលខ្លះក្រុមជំនុំមានការយឺតយ៉ាវនៅក្នុងការយល់ដឹងអំពីភាពខុសគ្នា រវាងអំណោយទាននៃការនិយាយជាសាធារណៈ និងអំណោយទានជាគ្រូបង្រៀន។ អ្នកនិយាយជាសាធារណៈ និងគ្រូបង្រៀនពឹងផ្អែកទៅលើសម្ភារៈដែលបានរៀបចំផ្សេងៗគ្នា និងមានគោលបំណងនៅក្នុងទស្សនវិស័យផ្សេងគ្នាដែរ។ អ្នក និយាយជាសាធារណៈ ពឹងផ្អែកទៅលើការមានវោហារសាស្ត្រ ចេះនិទានរឿង និងចេះនិយាយកំប្លុកកំប្លែង ដើម្បីផ្តល់ដំបូន្មាន និងជំរុញទឹកចិត្ត។ គ្រូពឹងផ្អែកលើចំណេះដឹង ការយល់ឃើញជ្រាលជ្រៅ និងសមត្ថភាពក្នុងការធ្វើឲ្យរឿងស្មុគស្មាញក្លាយជារឿងសាមញ្ញ ដើម្បីបង្រៀន និងណែនាំ។ អ្នកនិយាយជាសាធារណៈបង្កើតអ្នកគាំទ្រ គ្រូបង្រៀនបង្កើតសិស្ស។

យើងមិនបានធ្វើជាគ្រូបង្រៀនយ៉ាងល្អម៉ត់ចត់ទេ បើយើងឲ្យតម្លៃទៅលើសម្ភារៈនៃការនិយាយជាសាធារណៈលើសពីសម្ភារៈរបស់គ្រូបង្រៀន។ ខ្ញុំក៏ចូលចិត្តការលេងសើច និងការនិទានរឿងដូចអ្នកនៅជិតខាងខ្ញុំផងដែរ។ ខ្ញុំប្រើការទាំងនោះនៅក្នុងសៀវភៅរបស់ខ្ញុំ។ ប៉ុន្តែ គ្រូបង្រៀនជានិច្ចកាលត្រូវសួរខ្លួនឯង តើខ្ញុំបានពឹងផ្អែកទៅលើសម្ភារៈនៃការនិយាយជាសាធារណៈនៅក្នុងកម្រិតមួយ ដែលធ្វើឲ្យមាតិកានៃការបង្រៀនបានសាបរលាបបាត់អស់ចេញពី

ការបង្រៀនអប់រំដែរឬទេ។ ប្រសិនបើមនុស្សចងចាំសាច់រឿងរបស់ខ្ញុំ និងរឿងកំប្លែងតែមិនបានចាំមេរៀនរបស់ខ្ញុំ នោះមានន័យថាខ្ញុំមិនបានបំពេញតួនាទីរបស់ខ្ញុំទេ។ ជាការល្អប្រសើរ នៅពេលយើងមានអំណោយទានគ្រូបង្រៀន យើងក៏មានអំណោយទាននៃការនិយាយជាសាធារណៈដែរ ប៉ុន្តែបើឲ្យខ្ញុំជ្រើសរើសមួយដើម្បីធ្វើជាគោលការណ៍សូមឲ្យខ្ញុំជាគ្រូបង្រៀន។ គ្រូបង្រៀននឹងប្រឈមដោះស្រាយជាមួយនឹងចំណេះដឹងខាងឯព្រះគម្ពីររៀងរាល់ថ្ងៃ។

ដូច្នេះ តើយើងអាចធ្វើជាគ្រូបង្រៀនដោយមានការយកចិត្តទុកដាក់យ៉ាងដូចម្តេច សូមអនុវត្តតាមវិធីសាស្ត្ររបស់ខ្ញុំគឺចំណុចទាំងប្រាំនៃការសិក្សាដែលត្រឹមត្រូវ ហើយនឹងធ្វើការបណ្តុះបណ្តាលដល់អ្នកដទៃឲ្យស្រឡាញ់ និងប្រើប្រាស់ចំណុចទាំងប្រាំនោះនៅក្នុងការសិក្សារបស់ពួកគេមែនឬ? តើយើងរៀបចំមេរៀនរបស់យើងយ៉ាងដូចម្តេចដែលឲ្យតម្លៃដល់គម្រោង ដែលជាការតម្រង់លើការណែនាំដល់យើងនោះ? ដើម្បីធ្វើការនេះតម្រូវឲ្យយើងមានការរៀបចំដោយយកចិត្តទុកដាក់ រៀបចំរចនាសម្ព័ន្ធដោយឆ្លាតវៃ និងបង្រៀនដោយមានការទទួលខុសត្រូវ។

## ការរៀបចំដោយយកចិត្តទុកដាក់

ជាក់ស្តែង ដើម្បីបង្រៀនអំពីវិធីសិក្សាដែលខ្ញុំបានរៀបរាប់ អ្នកត្រូវអនុវត្តវាដោយខ្លួនឯងជាមុនសិន ដំបូងអ្នកត្រូវរៀននូវចំណុចទាំងនោះដោយខ្លួនឯងសិន។ ជឿ ឬមិនជឿ គ្រូបង្រៀនគឺជាមនុស្សស្មោះត្រង់បំផុតទៅកាន់សិស្សរបស់គាត់ នៅពេលដែលគ្រូបង្រៀនសិស្សទៅតាមអ្វីដែលជាចំណុចខ្វះខាតនៃការយល់ដឹងរបស់គ្រូផ្ទាល់ដែរ។ ខ្ញុំតែងតែជឿថាគ្រូបង្រៀនគាត់បង្រៀនពីព្រោះគាត់ដឹងច្រើនជាងសិស្សរបស់គាត់។ សម្រាប់ករណីនេះខ្ញុំលែងជឿហើយ ខ្ញុំបង្រៀនដោយព្រោះតែអ្វីមួយដែលខ្ញុំអត់បានដឹង។ ខ្ញុំចាប់ផ្តើមយល់ឃើញថា សំណួរដែលកើតមានឡើងចំពោះខ្ញុំនៅពេលដែលខ្ញុំអានអត្ថបទណាមួយ ក៏ប្រហែលជាសំណួរនេះអ្នកដទៃបានចោទសួរដែរ។ ភាពខុសគ្នា



Khmer Women of the word_Layout.indd 180 12/3/26 3:56 in the afternoon

រវាងអ្នកដទៃ ហើយនឹងខ្ញុំ រវាងគ្រូ និងសិស្សគឺថាៈ ខ្ញុំមិនអាចឲ្យសំណួរនោះនៅបន្តមានដោយមិនបានស្វែងរកចម្លើយនៅលើតែមទំព័រនៃព្រះគម្ពីររបស់ខ្ញុំបានឡើយ។ គ្រូបង្រៀនមិនមែនជាម្នាក់ដែលមានចំណេះដឹងខ្ពង់ខ្ពស់ឡើយ ប៉ុន្តែជាមួយនឹងការចង់ដឹងចង់ស្គាល់ដ៏ជ្រាលជ្រៅដោយធម្មជាតិក្នុងការស្វែងរកសំណួរដែលយើងទាំងអស់គ្នាបានជួបវិញ។ ដោយសារលក្ខណសម្បត្តិរបស់នាង នោះនាងគឺជាអ្នកដែលបានត្រៀមខ្លួនសម្រាប់ការដឹកនាំការយល់ដឹងច្រើនជាងក្រុមសិស្សរបស់នាង។ សេចក្តីរំភើបរីករាយនៅក្នុងការស្វែងរកឃើញរបស់នាង បានចាប់ផ្តើមរាលដាលក្នុងចំណោមសិស្សរបស់នាងដែរ។

ខ្ញុំបង្រៀនដើម្បីរៀន។ ដោយដឹងថាសិស្សរបស់ខ្ញុំត្រូវការខ្ញុំធ្វើការរៀនសូត្រឲ្យបានល្អ ការនេះជួយខ្ញុំក្នុងការរៀបចំមេរៀនដោយយកចិត្តទុកដាក់។ ការរៀបចំដោយយកចិត្តទុកដាក់ចាប់ផ្តើមដោយអនុវត្តតាមវិធីសាស្ត្ររបស់ខ្ញុំគឺចំណុចទាំងប្រាំនៃការសិក្សាដែលត្រឹមត្រូវទៅក្នុងការអនុវត្ត ហើយនៅក្នុងពេលវេលាដែលត្រឹមត្រូវខ្ញុំនឹងទាញយកនូវចំណុចដែលសំខាន់បំផុត ចេញពីការសិក្សាផ្ទាល់ខ្លួនរបស់ខ្ញុំផ្តល់ឲ្យសិស្ស។ សូមសាកល្បងរៀន យល់ដឹង ការបកស្រាយ និងអនុវត្តដោយខ្លួនឯងសិន ហើយចាំទៅពិគ្រោះជាមួយសេចក្តីអត្ថាធិប្បាយ។ បន្ទាប់មកគ្រូត្រូវជ្រើសរើសសេចក្តីអធិប្បាយមួយដែលល្អ វាពិតជាត្រូវការពេលវេលាក្នុងការដឹងថា អ្នកនិពន្ធមួយណាដែលអាចជឿទុកចិត្តបាន។ នៅពេលដែលអ្នកបានស្វែងរកឃើញពួកគេហើយ ពួកគេអាចនឹងក្លាយទៅជាវិធីមួយក្នុងការដឹកនាំអ្នក។ ខ្ញុំធ្លាប់បានដឹងអំពីការជ្រើសរើសសៀវភៅសម្រាប់ធ្វើការសិក្សាព្រះគម្ពីរ ដោយផ្អែកទៅលើថាតើអ្នកនិពន្ធដែលខ្ញុំចូលចិត្តបានសរសេរសេចក្តីអធិប្បាយក្នុងសៀវភៅនោះដែរឬទេ។

ខណៈពេលដែលអ្នកបានចាប់ផ្តើមរៀបចំបញ្ជីឈ្មោះនៃអ្នកធ្វើសេចក្តីអត្ថាធិប្បាយ ឬអំពីអ្នកនិពន្ធហើយ សូមសួរអ្នកដទៃឲ្យជួយដែរៈ គ្រូគង្វាលរបស់អ្នក អ្នកណាម្នាក់ដែលមានគំនិតដូចអ្នក ឬអាចជាគ្រូបង្រៀននៅសាលាព្រះ



Khmer Women of the word_Layout.indd 181 12/3/26 3:56 in the afternoon

គម្ពីរ។ នៅពេលអ្នកស្វែងរកឃើញអ្នកនិពន្ធដែលល្អប្រសើរហើយ សូមអាននូវធនធានរបស់គាត់។ តាមរយៈឯកសារយោង សូមមើលថា តើអ្នកណាបានជះឥទ្ធិពលទៅលើគំនិតអ្នកនិពន្ធរបស់អ្នក។ បន្ទាប់មក សូមអាននូវអ្វីដែលពួកគាត់បានសរសេរផងដែរ។ ឯកសារយោងប្រៀបដូចជាកន្លែងរ៉ែមាសក្នុងការស្វែងរកនូវធនធានបន្ថែម ដើម្បីធ្វើការពិគ្រោះយោបល់។

ដូចយើងបានធ្វើការកត់សម្គាល់ហើយ គ្រប់សេចក្តីអធិប្បាយទាំងអស់មិននិយាយដូចគ្នាទេ។ នៅពេលដែលអ្នកស្វែងរកឃើញការខ្វែងគំនិតគ្នានៅក្នុងធនធានដែលអ្នកបានទុកចិត្ត សូមសង្កេតមើលធនធានណាមួយដែលសង្ខេបជារួមមានការប្រឆាំងគ្នា និងមានការកាត់ស្រាយទេរទៅរកការយល់ដឹងផ្ទាល់ខ្លួនអំពីអត្ថបទដែលអ្នកកំពុងសិក្សា។ អ្នកប្រហែលត្រូវធ្វើការសម្រេចចិត្តថា តើការបង្រៀនចំណុចនោះមានការកាត់ស្រាយធម្មតា ឬក៏មានការស្របដូចគំនិតរបស់អ្នក។ ប្រសិនបើមិនបង្កឲ្យមានការភ័ន្តច្រឡំទេ សូមពិចារណាធ្វើទាំងពីរ។ សូមទទួលស្គាល់បង្ហាញនូវគោលជំហរផ្ទាល់ខ្លួនរបស់អ្នកទៅកាន់សិស្ស។ បន្ទាប់មកប្រាប់ពួកគេថា នេះជាចំណែកភាគតូចរបស់អ្នក ហើយសូមធ្វើការបង្ហាញដែលស្មោះត្រង់អំពីទស្សនៈទូទៅ។ សូមប្រាកដថាអ្នកបានរៀបចំដោយយកចិត្តទុកដាក់ និងត្រឹមត្រូវយ៉ាងផ្ចិតផ្ចង់បំផុត តាមដែលអាចធ្វើបាន។

នៅពេលដែលអ្នករៀបចំ សូមកត់សម្គាល់នូវប្រភពឯកសារធនធាននៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកផង។ ការនេះនឹងជួយអ្នកដឹងថាតើគំនិតនេះមានប្រភពមកពីណា ប្រសិនបើមានអ្នកណាម្នាក់សួរអំពីចំណុចនេះ ឬប្រសិនបើអ្នកត្រូវការរម្លឹករៀបចំដោយខ្លួនឯងម្តងទៀតបានផងដែរ។ ខ្ញុំបានសរសេរឈ្មោះដើមរបស់អ្នកនិពន្ធ និងទំព័រអត្ថបទក្នុងរង់ក្រចកក្បែរគំនិតដែលខ្ញុំរកឃើញដែលខ្ញុំអាចនឹងទៅរកមើលម្តងទៀតបាន នៅពេលក្រោយ។

ការរៀបចំដោយយកចិត្តទុកដាក់ទាមទារការប្តេជ្ញាចិត្តដែលចំណាយពេលច្រើនម៉ោង។ ពេលវេលាដែលអ្នកបានចំណាយបង្រៀនជាប្រភាគដ៏តូច



Khmer Women of the word_Layout.indd 182 12/3/26 3:56 in the afternoon

មួយ បើធៀបទៅនឹងពេលវេលាដែលអ្នកបានចំណាយពេលរៀបចំ។ ការងាររបស់អ្នកគឺជាការស្រូបយកឲ្យបានច្រើនអំពីព័ត៌មាន បន្ទាប់មកចម្រាញ់ចេញជាសមភាគដែលមានសារៈសំខាន់ផ្តល់ឲ្យសិស្សរបស់អ្នក។ សូមស្រមៃថាអ្នកជាអ្នករៀបចំវិជ្ជាជីវៈ ដែលកំពុងរៀបចំទូផ្ទុកឥវ៉ាន់មួយដែលណែនដោយវត្ថុ។ អ្នកបានប្រមូលព័ត៌មានច្រើនដើម្បីសម្រេចចិត្តអ្វីខ្លះដែលត្រូវរក្សាទុក និងទុកដាក់នៅកន្លែងណាការរៀបចំដាក់ផ្លាកដើម្បីឲ្យសិស្សមានភាពងាយស្រួលប្រើប្រាស់ និងស្វែងរកផងដែរ។

## រៀបចំរចនាសម្ព័ន្ធដោយឆ្លាតវៃ

គ្រូបង្រៀនមិនមែនគ្រាន់តែរៀបចំព័ត៌មានឲ្យងាយស្រួលនៅក្នុងការប្រើប្រាស់បាននោះទេ នាងត្រូវរៀបចំពីវិធីនៅក្នុងការចែកចាយផងដែរ។ របៀបអ្នករៀបចំការសិក្សានឹងប៉ះពាល់ដល់ចំនួនសម្ភារៈដែលអាចសិក្សា និងកម្រិតជ្រៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន។ តើអ្នកនឹងមានកិច្ចការផ្ទះដែរឬទេ? តើអ្នកនឹងប្រើពេលវេលានៃការសិក្សារបស់អ្នកសម្រាប់ការអធិស្ឋាន និងការពិភាក្សាគ្នាដែរឬទេ ឬក៏សម្រាប់តែការបង្រៀនមួយមុខ? រចនាសម្ព័ន្ធអំពីក្រុមសិក្សារបស់អ្នកនឹងកំណត់ទៅលើចំណុចដែលអ្នកបានផ្តោតការយកចិត្តទុកដាក់។

ក្រុមសិក្សាដែលខ្ញុំបានដឹកនាំមានរយៈពេលពីរម៉ោង គឺមានពេលសម្រាប់ពិភាក្សា ថ្វាយបង្គំ និងរៀន។ ក្រុមរបស់យើងធំ ដូច្នេះតម្រូវឲ្យមានរចនាសម្ព័ន្ធច្រើនជាងការជួបជុំតាមផ្ទះ។ ការរៀបចំសម្រាប់ការជួបជុំតាមផ្ទះ ការបង្រៀនប្រហែលជាមានការពិភាក្សាពាក់ព័ន្ធគ្នាទៅវិញទៅមក ហើយតម្រូវការសម្រាប់កម្មវិធីអាចផ្លាស់ប្តូរ ដោយបត់បែនបាន។

ក្រុមសិក្សារបស់ស្ត្រីជាច្រើនឲ្យតម្លៃលើចំណែកដ៏មានសារៈសំខាន់នៃពេលវេលារបស់ពួកគេទៅលើផ្នែកនៃការកសាងទំនាក់ទំនង ដូចជាការចែកចាយសំណូមពរអធិស្ឋាន ការប្រើសំណួរសម្រាប់ឲ្យកាន់តែស្គាល់គ្នាជាងមុនជាដើម។ ទាំងនេះសុទ្ធតែជាចំណុចដែលត្រូវការ ប៉ុន្តែចំណុចទាំងនោះអាច



Khmer Women of the word_Layout.indd 183 12/3/26 3:56 in the afternoon

ទំនងជាលុបបំបាត់នូវការពិភាក្សា និងពេលវេលានៃការបង្រៀន។ ប្រសិនបើក្រុមស្ត្រីនៅក្នុងក្រុមរបស់អ្នកមានឱកាសផ្សេងៗនៅក្នុងការទំនាក់ទំនងសង្គមច្រើនហើយ (ដូចជាក្រុមខាងសហគមន៍ ឬក៏ថ្នាក់សាលាថ្ងៃអាទិត្យ) សូមគិតអំពីការកំណត់ពេលវេលានៃការកាន់តែស្គាល់គ្នាជាងមុនទុកមួយឡែកសិន អំឡុងពេលជួបជុំក្រុមសិក្សារបស់អ្នក។ ខ្ញុំបានប្រាប់ក្រុមសិក្សារបស់ខ្ញុំតាំងពីជួបដំបូង ថាយើងចង់ឲ្យពួកគេមានទំនាក់ទំនងសង្គមជាមួយគ្នាទៅវិញទៅមក ប៉ុន្តែអ្វីដែលជាគោលបំណងចម្បងរបស់យើង នោះគឺជាការដែលឲ្យពួកគេលូតលាស់មានចំណេះដឹងអំពីព្រះជាម្ចាស់ និងមានសេចក្តីស្រឡាញ់ទៅចំពោះព្រះអង្គជាជាង។ យើងរក្សាពេលវេលាជួបជុំក្រុមតូចសម្រាប់ពិភាក្សាអំពីកិច្ចការផ្ទះ។ យើងមិនមែនមានការតឹងរ៉ឹងអំពីការនេះទេ យើងគ្រាន់តែចង់រក្សានូវចំណុចដែលយើងបានផ្តោត ទុកជាគោល។ សំណូមពរអធិស្ឋានគឺបានសរសេរនៅលើក្រដាសកំណត់សម្គាល់ និងបានចែកចាយតាមរយៈបណ្តាញសង្គមទៅកាន់សមាជិកក្រុមទាំងអស់រួចហើយ។ ប្រសិនបើមានតម្រូវការចាំបាច់ណាមួយ យើងនឹង អធិស្ឋានអំពីការនោះជាមួយគ្នានៅក្នុងក្រុមតូច។ នៅក្នុងការកសាងទំនាក់ទំនង ជារឿយៗអ្នកដឹកនាំអាចប្រមូលសមាជិកក្រុមសម្រាប់ការប្រកបអាហារ ក្រៅពីពេលវេលាដែលត្រូវសិក្សា។ យើងលើកទឹកចិត្តស្ត្រីឲ្យនៅបន្តដើម្បីជជែកជាមួយគ្នា រយៈពេលយូរប៉ុណ្ណាក៏បាន បន្ទាប់ពីពេលរៀនចប់។

## គំនិតផ្សេងៗអំពីកិច្ចការផ្ទះ

ប្រសិនបើអ្នកជាគ្រូបង្រៀនថ្មីដែលទើបនឹងចាប់ផ្តើមបង្រៀន នោះអ្នកកុំទាន់ឆាប់នឹងសរសេរបញ្ជីមេរៀន អ្នកប្រហែលចាប់ផ្តើមជាមួយនឹងការសួរសំណួរទៅកាន់ស្ត្រីនៅក្នុងក្រុមរបស់អ្នក ឲ្យពួកគេអានដដែលៗម្តងហើយម្តងទៀតហើយសរសេរចុះនូវការយល់ដឹង។ បន្ទាប់មក អ្នកអាចផ្ញើការកាត់ស្រាយបីទៅបួនបែបដល់ក្រុមរបស់អ្នក និងសំណួរនៃការអនុវត្តសម្រាប់ឲ្យពួកគេ

គិតពិចារណា មុននឹងមកថ្នាក់ជួបជុំផងដែរ។ ខ្ញុំបានសង្កេតឃើញថាមានការងារផ្ទះសប្តាហ៍ខ្លះគឺចាំបាច់នៅក្នុងការចំណាយពេលវេលាច្រើនជាមួយគ្នា។ មិនថាអ្នកបានឲ្យស្ត្រីអានម្តងហើយម្តងទៀត ឬបានដាក់សំណួរឲ្យដល់ពួកគេ សូមធ្វើឲ្យបានល្អប្រសើរស្វែងរកចំណុចនៅក្នុងសេចក្តីពន្យល់អត្ថាធិប្បាយរហូតដល់ពេលវេលាបង្រៀន ឬពិភាក្សា។ សូមរៀបចំការងារផ្ទះ និងការបង្រៀនរបស់អ្នកនៅក្នុងរបៀបមួយដែលឲ្យតម្លៃដល់ដំណើរការនៃការរៀនសូត្រ។

ខ្ញុំសរសេរបញ្ជីមេរៀនសម្រាប់ថ្នាក់បង្រៀននីមួយៗដែលខ្ញុំធ្វើការបង្រៀនរៀងរាល់សប្តាហ៍ស្ត្រីអាននូវផ្នែកដែលជាអត្ថបទ ហើយឆ្លើយនូវសំណួរអំពីផ្នែកនោះ។ សំណួរផ្តោតខ្លាំងទៅលើការយល់ដឹង ដោយផ្អែកទៅលើពីរបីសំណួរនៃការកាត់ស្រាយ និងការអនុវត្ត ជាទូទៅគឺនៅចន្លោះរវាងចំណុចទាំងនេះ។ កិច្ចការផ្ទះឲ្យពួកគេធ្វើការពន្យល់ បែបសម្រាយ ដោយស្វែងរកពាក្យនៅក្នុងវចនានុក្រម ពិនិត្យមើលខគម្ពីរយោង និងអាននូវការបកប្រែមួយចំនួន។ គោលដៅនៅក្នុងកិច្ចការផ្ទះរបស់ខ្ញុំ គឺថាសិស្សនឹងបានសិក្សាព្រះគម្ពីរ ហើយចំណាយពេលយ៉ាងយកចិត្តទុកដាក់ទទួលយកនូវអ្វីដែលអត្ថបទបានមានបន្ទូល (ការយល់ដឹង)។ ក្នុងអំឡុងពេលសិក្សាយើងប្រើពេលវេលាបង្រៀន និងពិភាក្សាដើម្បីធ្វើការស្វែងយល់ជាមួយគ្នា នូវអ្វីដែលជាអត្ថន័យរបស់អត្ថបទ (ការកាត់ស្រាយ) និងពីរបៀបដែលអត្ថបទបានជំរុញទឹកចិត្តយើងឲ្យមាន (ការអនុវត្ត) ផ្សេងៗគ្នាផងដែរ។ ខ្ញុំពិតជាចង់ឲ្យមានការលើកជាសំណួរឲ្យបានច្រើននៅក្នុងកិច្ចការផ្ទះ ដូចចម្លើយជាច្រើនដែលបានឆ្លើយដែរដើម្បីឲ្យស្ត្រីបានទទួលស្គាល់នូវអ្វីដែលពួកគេមិនបានដឹង។ បន្ទាប់មកខ្ញុំបានអនុញ្ញាតឲ្យពេលវេលានៃការពិភាក្សា និងការបង្រៀនដោះស្រាយនូវបញ្ហាមិនយល់ដែលមាននៅក្នុងកិច្ចការផ្ទះរបស់ពួកគេ។

សម្រាប់ខ្ញុំសំណួរនៅក្នុងកិច្ចការផ្ទះ គឺមានសេចក្តីពន្យល់អត្ថាធិប្បាយតិចតួច ខ្ញុំមិនបានផ្តល់នូវការពន្យល់ច្រើនទេ ឬអត្ថន័យនៃពាក្យ ដរាបណាមិន

មានការចាំបាច់ទេនោះ។ ការនេះជួយដល់សិស្សឲ្យចេះអភិវឌ្ឍន៍ជំនាញនៃការសួរសំណួរដោយខ្លួនឯង និងរៀនសូត្រដោយមិនភ័យខ្លាចការ “ដែលអត់ដឹង” នៅក្នុងដំណើរការនៃការរៀនសូត្រ។ យើងពិភាក្សាសំណួរនៅក្នុងកិច្ចការផ្ទះអំពីការកាត់ស្រាយ និងការអនុវត្តក្នុងអំឡុងពេលបង្រៀន ឬអំឡុងពេលយើងជួបជុំក្រុមតូច។ រៀងរាល់សប្តាហ៍កិច្ចការផ្ទះគឺបូកបញ្ចូលនូវការឆ្លុះបញ្ចាំងអំពីទិដ្ឋភាពនៃលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ បានបើកសម្ដែងនៅក្នុងអត្ថបទ និងតើការដែលយល់អំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់នោះ បានផ្លាស់ប្តូររបៀបដែលយើងគិត និងអនុវត្តយ៉ាងដូចម្តេចខ្លះ។

ការសរសេរកិច្ចការផ្ទះដែលមានប្រសិទ្ធិភាពតម្រូវឲ្យគ្រូបង្រៀន ត្រូវគិតដូចជាសិស្សដែរ។ នៅពេលដែលអ្នកចាប់ផ្តើមរៀបចំ សូមអានអត្ថបទទាំងមូលសរសេរសំណួរនៅគែមទំព័រដែលអ្នកអាចនឹងសួរបន្ទាប់ពីពេលអ្នកអានចប់។ សិស្សរបស់អ្នកអាចនឹងមានសំណួរដូចជាអ្នកផងដែរ។ សូមចាំថាសំណួរដែលមើលទៅដូចជាច្បាស់លាស់សម្រាប់អ្នកអាចជាសំណួរដែលចាំបាច់សម្រាប់សិស្សរបស់អ្នក។ សូមឲ្យពួកគេពន្យល់ពាក្យ កំណត់ចំនួនពាក្យ ឬឃ្លាដដែលៗ ឬនឹកចាំអំពីគំនិតសំខាន់ៗ ព្រោះការធ្វើបែបនោះនឹងជួយបណ្តុះបណ្តាលឲ្យពួកគេប្រើវិធីទាំងនេះ ដោយមិនចាំបាច់មានកម្មវិធីសិក្សាដើម្បីរំលឹក។ គឺជួយពួកគេឲ្យធ្វើការរៀនសូត្របានល្អប្រសើរដោយខ្លួនឯង។

សូមចងចាំផងដែរអំពីសារៈសំខាន់នៃការសួរសំណួរដែលពិបាក សំណួរដែលអ្នកអាចនឹងមានការភ័យខ្លាចនៅក្នុងការសួរខ្លួនឯង។ នេះគឺជាសំណួរដែលប៉ុនប៉ងឲ្យអ្នកនិយាយ “ខ្ញុំនឹងទុកចិត្តដល់ព្រះជាម្ចាស់សម្រាប់ការនេះ ហើយបន្តទៅមុខទៀត” ប្រសិនបើអត្ថបទនិយាយអំពីឪពុកដែលបានលក់កូនស្រីឲ្យធ្វើជាទាសករ សូមសួរសិស្សរបស់អ្នកនៅក្នុងកិច្ចការផ្ទះរបស់ពួកគេ តើព្រះរាជបញ្ញត្តិអ្វី បែបផែនយ៉ាងណាដែលយើងអាចនឹងទទួលបានពីព្រះវរបិតាដែលល្អ និងពេញដោយសេចក្តីស្រឡាញ់នោះ។ ប្រសិនបើអត្ថបទពណ៌នាអំពីព្រះយេស៊ូវដែលបានណែនាំអ្នកឲ្យកាត់ដៃរបស់អ្នក ដើម្បីកុំឲ្យអ្នក

ប្រព្រឹត្តអំពើបាប សូមសួរសិស្សរបស់អ្នកតើព្រះយេស៊ូវពិតជាបញ្ជាឲ្យកាត់ដៃរបស់យើងមែនឬ? អ្នកត្រូវដឹងថា ជារឿយៗប្រសិនបើការដកអត្ថបទចេញពីបរិបទនឹងបង្កឲ្យមានការប្រើខុសទៅលើអត្ថបទ។ «តើកណ្ឌគម្ពីរ ភីលីព ៤:១៣ មានន័យថាយើងអាចធ្វើគ្រប់ការទាំងអស់បានឲ្យតែយើងដាក់ចិត្តថានឹងធ្វើមែនទេ? ឬហេតុអ្វីក៏មិនមែន? តើអ្នកអាចគិតអំពីអត្ថបទណាមួយផ្សេងទៀត ដើម្បីគាំទ្រចម្លើយរបស់អ្នកដែរឬទេ?»

សូមធ្វើការធានាអះអាងទៅកាន់សិស្សរបស់អ្នក បើទោះជាពួកគេមិនអាចរកចម្លើយដែលសមស្របណាមួយឡើយក៏ដោយ ក៏ការទទួលស្គាល់នូវសំណួរដែលពិបាក ហើយការស្វែងរកចម្លើយគឺជាផ្នែកមួយឈានទៅរកការយល់ដឹងផងដែរ។ ការជៀសវាងសំណួរដែលពិបាកគឺមានតែបន្ថែមនូវចម្ងល់និងភាពភ័យខ្លាចរយៈពេលយូរប៉ុណ្ណោះ។ សូមធ្វើការធានាអះអាងទៅកាន់សិស្សរបស់អ្នកម្តងទៀតឲ្យពួកគេដឹងថាមិនមានបញ្ហាអ្វីទេនៅក្នុងការសួរសំណួរដែលពិបាក ហើយមនុស្សដែលមានប្រាជ្ញាបានគិតយ៉ាងច្រើនអំពីការនោះប្រហែលជិតពីរពាន់ឆ្នាំមកហើយដែរ។

ការសរសេរបញ្ជីមេរៀនជាការងារដែលពិបាក។ បើសិនជាអាចសូមស្វែងរកជំនួយពីមិត្តភក្តិមួយចំនួនឲ្យពួកគេជួយជាគំនិត និងធ្វើការវាយតម្លៃផងដែរ។ សូមឲ្យពួកគេជួយមើលផងដែរនៅក្នុងផ្នែកនៃការធ្វើកិច្ចការផ្ទះ ហើយផ្តល់មតិយោបល់ទៅលើសំណួរណាដែលនឹងជួយដល់សិស្ស សំណួរណាដែលធ្វើឲ្យសិស្សមានការភាន់ច្រឡំ ឬក៏មិនមានសារៈសំខាន់។ ជារឿយៗសំណួរដែលមានអត្ថន័យល្អសម្រាប់អ្នកប្រហែលត្រូវរៀបចំពាក្យនិយាយម្តងទៀត ដើម្បីឲ្យអ្នកដទៃអាចយល់បាន។

ដើម្បីរៀបចំនូវការសិក្សាមួយដែលល្អតម្រូវឲ្យគ្រូបង្រៀន អនុវត្តនូវវិធីសាស្ត្ររបស់ខ្ញុំទាក់ទងនឹងចំណុចទាំងប្រាំនៃការសិក្សាដែលត្រឹមត្រូវ ដោយធ្វើការសួរអំពីផ្នែកណាមួយនៃចំណុចនោះ ដែលមានការពិបាកសម្រាប់អ្នកដែលទើបចាប់ផ្តើមរៀននៅក្នុងការប្រើចំណុចទាំងនេះ។ តើសិស្សរបស់ខ្ញុំ



Khmer Women of the word_Layout.indd 187 12/3/26 3:56 in the afternoon

ធ្វើការយកចិត្តទុកដាក់ទៅលើពាក្យគន្លឹះដែរឬទេ? តើពួកគេបានធ្វើការកត់សម្គាល់ទៅលើគំនិត ដែលលើកឡើងម្តងហើយម្តងទៀតដែរឬទេ? តើពួកគេនឹងធ្វើការសង្កេតយ៉ាងយកចិត្តទុកដាក់ដែរឬទេ ដើម្បីទទួលបាននូវខ្លឹមសារមួយដែលមានគុណតម្លៃ? តើអ្វីដែលធ្វើឲ្យពួកគេមានការល្បួងនៅក្នុងការប្រញាប់ឆាប់ចប់? កន្លែងណាដែលពួកគេហាក់បីដូចជាជាប់គាំង?

ដើម្បីអាចចាប់ផ្តើមនៅក្នុងការស្វែងរកចម្លើយសម្រាប់សំណួរទាំងនេះ និងសំណួររបស់អ្នកដទៃផ្សេងទៀត ដូចជាសំណួរទាំងនេះតម្រូវឲ្យយើងរម្លឹកខ្លួនយើងជាប្រចាំអំពីរបៀបដែលអត្ថបទ បានបង្ហាញមកកាន់យើងនៅពេលដែលយើងបានអានលើកដំបូង។ នៅពេលដែលយើងបានយល់ដឹងស្គាល់អត្ថបទហើយ នោះយើងអាចបំភ្លេចនូវសំណួរ និងចំណុចពិបាកដែលបានចោទសួរយើងដើមដំបូង។ គ្រូបង្រៀនដែលល្អគឺអាចមើលអត្ថបទតាមរយៈភ្នែកកូនសិស្សរបស់ពួកគេ សម្រាប់ហេតុផលនេះខ្ញុំចាប់ផ្តើមសរសេរបញ្ជីមេរៀនមុនពេលខ្ញុំធ្វើការសិក្សាទៅលើអត្ថបទឲ្យបានលម្អិតសិន។ ការធ្វើបែបនេះអនុញ្ញាតឲ្យខ្ញុំអាចសួរនូវសំណួរដែលអាចមានការសួរច្រើនជាងគេ មុនពេលចំណុចទាំងនោះក្លាយទៅជាចំណុចដែលពិបាកយល់ដ៏មានសក្តានុពល តាមរយៈអ្នកធ្វើអត្ថាធិប្បាយជាច្រើន យើងត្រូវធ្វើការសង្កេតយ៉ាងយកចិត្តទុកដាក់បំផុត។ ខ្ញុំធ្វើការកែលម្អ និងបន្ថែមទៅលើសំណួរដែលខ្ញុំបានសរសេរបន្ទាប់ពីខ្ញុំបានធ្វើការសិក្សាបន្តិចក្រោយនោះមក។

នេះគឺជាភាពខុសប្លែកគ្នារវាងខ្ញុំ និងអ្នកនិយាយណែនាំផ្សេងៗ ខ្ញុំមិនចង់ឲ្យមានការបង្រៀនចេញពីកិច្ចការផ្ទះទេ ខ្ញុំចង់ឲ្យកិច្ចការផ្ទះជាអាទិភាពគឺជាចំណុចបន្ថែមទៅលើការយល់ដឹង និងចាប់ផ្តើមដំណើរការនៃការកាត់ស្រាយផ្ទាល់ខ្លួន និងអនុវត្តផងដែរ។ បើនិយាយឲ្យចំទៅ ការបង្រៀនគឺនៅក្នុងសេចក្តីពន្យល់អត្ថាធិប្បាយ។ គោលដៅរបស់ខ្ញុំសម្រាប់កិច្ចការផ្ទះគឺថា វានឹងបានជួយរៀបចំចិត្ត និងគំនិតដល់កូនសិស្សរបស់ខ្ញុំសម្រាប់ពេលវេលានៃការបង្រៀន។ ប្រសិនបើពួកគេបានរៀនយល់ដឹងដោយផ្ទាល់ខ្លួន ការកាត់

ស្រាយ និងអនុវត្តជាមុនមែន នោះពួកគេនឹងឮការបង្រៀនរបស់ខ្ញុំបានច្រើនជាមួយនឹងត្រចៀកនៃទស្សនៈដែលមានទាំងកម្លាំង និងចំណុចដែលខ្វះខាតផងដែរ។ ពួកគេនឹងដឹងនៅពេលដែលខ្ញុំបានរៀបចំអត្ថបទដោយទទួលខុសត្រូវ ពីព្រោះពួកគេបានវិនិយោគពេលវេលាដោះស្រាយជាមួយវាមុនពេលពួកគេមកជួបជុំក្រុមសិក្សា។ យើងត្រូវមានការទទួលខុសត្រូវកម្រិតខ្ពស់សម្រាប់កិច្ចការនេះ ហើយខ្ញុំពិតជាពេញចិត្តជាមួយនឹងការនេះណាស់។

សូមចាំថាអ្នកមិនចាំបាច់បង្កើតបញ្ជីមេរៀនផ្ទាល់ខ្លួនរបស់អ្នកឡើយ អ្នកអាចប្រើបញ្ជីមេរៀនដែលមានស្រាប់ ដោយធ្វើការឲ្យតម្លៃដល់ដំណើរការនៃការរៀនសូត្រ ដោយផ្តល់ឲ្យនូវសេចក្តីពន្យល់អត្ថាធិប្បាយតិចតួច និងសង្កត់ធ្ងន់ទៅលើការយល់ដឹង ឬអ្នកអាចឲ្យកូនសិស្សរបស់អ្នកគ្រាន់តែអានម្តងហើយម្តងទៀតនៅពេលដែលពួកគេរៀបចំ។ កុំឲ្យមានសម្ពាធទៅលើការអភិវឌ្ឍសម្ភារៈផ្ទាល់ខ្លួនទាញអ្នកចេញពីការបង្រៀនឡើយ។ មិនមែនគ្រប់គ្រូបង្រៀនទាំងអស់សុទ្ធតែជាអ្នកសរសេរបញ្ជីមេរៀននោះទេ ប៉ុន្តែគ្រប់គ្រូបង្រៀនអាចនាំសិស្សរបស់ពួកគេឲ្យមុជចូលជ្រៅទៅក្នុងព្រះបន្ទូល ដោយប្រើប្រាស់ទម្រង់កិច្ចការផ្ទះមួយចំនួនដើម្បីចាប់ផ្តើមនូវដំណើរការនៃការរៀនសូត្រ។

## បង្រៀនដោយមានការទទួលខុសត្រូវ

ការបង្រៀនអត្ថបទទៅកាន់អ្នកដែលបានសិក្សា គឺវាមានតម្រូវការច្រើនជាងការបង្រៀនទៅកាន់អ្នកដែលមិនបានធ្វើការសិក្សា។ សេចក្តីសង្ឃឹមរបស់ខ្ញុំគឺថា កិច្ចការផ្ទះនឹងជំរុញបានគ្រប់គ្រាន់ដល់ការគិតរបស់ពួកគេនៅពេលដែលពួកគេឮការបង្រៀនរបស់ខ្ញុំ ពួកគេនឹងមិនចេះតែទទួលយកអ្វីដែលខ្ញុំបង្រៀនឡើយ។ ដោយដឹងថាពួកគេនឹងគិតដោយយកចិត្តទុកដាក់អំពីការបង្រៀនរបស់ខ្ញុំ ដោយមានការទទួលខុសត្រូវជាមួយនឹងខ្ញុំ ដើម្បីជៀសវាងគ្រោះថ្នាក់ទាំង៧ នៃការបង្រៀនដែលអាចកើតមានឡើង។



Khmer Women of the word_Layout.indd 189 12/3/26 3:56 in the afternoon

## ១. លោតជុំវិញ

តើអ្នកធ្លាប់បានឮអំពីការបង្រៀនអត្ថបទដែលសំខាន់ តែងតែមានសភាពបែប នេះទេ គឺមានតែគ្រូបង្រៀនដែលអាននូវអត្ថបទទាំងមូលដោយសង្ខេប មុន ការចំណាយពេល៤០នាទីជាមួយគ្នា ដើម្បីធ្វើការឆ្លុះបញ្ចាំងមើលក្នុងព្រះគម្ពីរ ទាំងមូល? សិស្សដែលបានរៀនអស់រយៈពេលមួយសប្ដាហ៍ ពួកគេនឹងមិន មានការស្ដាប់ចិត្តទៅលើការនិយាយអំពីកណ្ឌគម្ពីរអេភេសូរឡើយ ប្រសិនបើ គ្រូបង្រៀនប្រើអត្ថបទដែលសំខាន់ទុកគ្រាន់តែជាចំណុចផ្ដើមគំនិតនោះ។ គ្រូ នឹងចង់នៅបន្តក្នុងចំណុចនោះតាមដែលគាត់អាចធ្វើបានគ្រូនឹងស្វែងយល់ ថា អត្ថបទផ្ទាល់គឺមានតម្លៃសម្រាប់៤០នាទីពេញក្នុងពេលជួបជុំក្រុម ហើយ ពេលវេលា៤០នាទីនោះប្រហែលជាមិនគ្រប់គ្រាន់ទេ ដើម្បីគ្រាន់តែសម្រាប់ ឆ្លើយសំណួរដែលមានក្នុងអត្ថបទនោះ។

ការបង្រៀនដែលល្អគឺត្រូវចាំបាច់ប្រើនូវខគម្ពីរយោង ប៉ុន្តែមិនត្រូវបោះបង់ អត្ថបទគោលឡើយ។ យើងដែលជាគ្រូងាយនឹងចាកប្រធានបទ ជាពិសេស នៅពេលដែលបទគម្ពីរគោលរបស់យើងគឺជាបទគម្ពីរដែលពិបាកពន្យល់។ គ្រូបង្រៀនដែលខិតខំនៅក្នុងការកសាងចំណេះដឹងខាងឯព្រះគម្ពីរត្រូវមាន ស្មោះភាព។ គោលបំណងចម្បងរបស់គ្រូមិនមែនជាការបង្ហាញអំពីរបៀប ដែលអត្ថបទសំខាន់ មានទំនាក់ទំនងជាមួយនឹងអត្ថបទរាប់ពាន់ផ្សេងទៀត ឡើយ។ ប៉ុន្តែ ជាការបង្រៀនអត្ថបទសំខាន់ដោយយកចិត្តទុកដាក់ ដែល អត្ថបទផ្សេងទៀតនោះនឹងចូលមកកាន់គំនិតដោយឯងៗ នៅពេលដែល សិស្សបានជួបនូវបាវចនាដែលមានលក្ខណៈស្រដៀងគ្នានៅកន្លែងផ្សេងទៀត ក្នុងពេលសិក្សារបស់ពួកគេ។

## ២. ការកាត់ស្រាយបែបមនុស្សស្រី

ស្ត្រីដែលបង្រៀនព្រះគម្ពីរដល់ស្ត្រី ជានិច្ចកាលជួបនូវការល្បួងឲ្យប្រើអត្ថបទ នោះ និងប្រើលើសដោយដាក់អត្ថន័យលំអៀងទៅរកភាពជាស្ត្រីតែមួយគត់។



Khmer Women of the word_Layout.indd 190 12/3/26 3:56 in the afternoon

គ្រប់ពេលដែលយើងប្រើអត្ថបទដែលសំដៅទៅរកមនុស្សទូទៅ ហើយយើងបែរជាបង្រៀនសេចក្តីនោះក្នុងគំនិតសំដៅទៅរកស្ត្រីវិញ នោះយើងកំពុងមានគ្រោះថ្នាក់នៅក្នុងការកាត់ស្រាយបែបតែសម្រាប់មនុស្សស្រីហើយ។

នេះមិនមែនមានន័យថា យើងមិនអាចស្វែងរកចំណុចអនុវត្តជាក់លាក់ទាក់ទងនឹងភេទចេញពីអត្ថបទដែលនិយាយសម្រាប់ភេទទាំងពីរនោះឡើយ។ ជាងនេះទៅទៀត យើងត្រូវការពារប្រឆាំងការផ្តល់ឲ្យនូវការកាត់ស្រាយ និងការអនុវត្តដែលលួចបន្លំអត្ថបទដែលនៅក្នុងអត្ថន័យដើមមានបំណងផ្តោតទៅលើគម្រោងជាក់លាក់នៃភេទទាំងស្រុងពេក។ កណ្ឌគម្ពីរនាងរស់ មិនមែនជាកណ្ឌគម្ពីរដែលនិយាយតែអំពីស្ត្រី ហើយសម្រាប់បែបតែអំពីមនុស្សស្រីនោះឡើយច្រើនជាងកណ្ឌគម្ពីរ យូដាស លើសពីសៀវភៅតែអំពីបុរសសម្រាប់បែបជាបុរសដែរ។ ព្រះគម្ពីរគឺជាសៀវភៅអំពីព្រះជាម្ចាស់សរសេរសម្រាប់មនុស្សក្នុងគ្រប់មធ្យោបាយទាំងអស់សេចក្តីបង្រៀននៅក្នុងទំនុកតម្កើង ១៣៩ ដូចជាមានទំនាក់ទំនងទៅកាន់ស្ត្រី និងរូបភាពនៃដងខ្លួន ប៉ុន្តែសូមបដិសេធនូវសេចក្តីប្រាថ្នា នៅក្នុងការបង្រៀនសេចក្តីនោះទាំងស្រុងដែរ។ វាមិនមែនជាតួនាទីរបស់គ្រូបង្រៀនដែលជាស្ត្រី នៅក្នុងការធ្វើឲ្យព្រះគម្ពីរសមស្រប ឬក៏មានន័យល្អមក្នុងការទទួលនោះទេ។ តែតួនាទីរបស់នាងបង្រៀនអត្ថបទដោយមានការទទួលខុសត្រូវ។ គ្រូបង្រៀនជាស្ត្រីពេលខ្លះនាំយកទស្សនៈដែលខុសពីអត្ថបទជាងគ្រូបង្រៀនដែលជាបុរស ពីព្រោះតែលក្ខណៈបែបភេទ ប៉ុន្តែមិនមែនតែងតែបែបនេះរហូតទេ។ សិស្សដែលបានចំណាយពេលមើលអត្ថបទមុនពេលឮការបង្រៀនសម្រាប់អត្ថបទនោះនឹងដឹងថា អត្ថបទគឺត្រូវបានកាត់ស្រាយសម្រាប់មនុស្សស្រី។

## ៣. ការសន្មតប្លែកៗ

ប្រយោជន៍នៅក្នុង «ការនាំអត្ថបទទៅកាន់ជីវិត» គ្រូបង្រៀនពេលខ្លះចុះចូលទៅក្នុងសេចក្តីល្បួង ក្នុងការបន្ថែមពណ៌តិចតួចជុំវិញទៅលើជាយតែមរូបភាព



Khmer Women of the word_Layout.indd 191 12/3/26 3:56 in the afternoon

នៃព្រះគម្ពីរ។ ខ្ញុំទទួលស្គាល់ថាវាគួរឲ្យចាប់អារម្មណ៍នៅក្នុងការប៉ាន់ស្មានអំពីគំនិតផ្សេងៗដែលមិនបានកត់ត្រាទុក និងអ្វីដែលជាកត្តាជំរុញដល់នាង ម៉ារា ដែលជាម្តាយរបស់ព្រះយេស៊ូវ។ នេះប្រហែលជាចំណុចដែលមានប្រយោជន៍ ប៉ុន្តែចំណុចមួយចំនួនបានធ្វើឲ្យពីអ្វីដែលមានប្រយោជន៍ក្លាយទៅជាការដាច់ចេញ និងបានក្លាយជាចំណុចសក្តានុពលដែលមិនមាននៅក្នុងព្រះគម្ពីរទៅវិញ។

ប្រសិនបើអ្នកបានមើលខ្សែភាពយន្តដែលផលិតមានលក្ខណៈស្រដៀងទៅនឹងសាច់រឿងនៅក្នុងព្រះគម្ពីរ នោះអ្នកនឹងយល់ពីចំណុចនេះ ការមានចំណេះដឹងកាន់តែច្រើនអំពីអ្វីដែលព្រះគម្ពីរមានបន្ទូល អំពីការចាកចេញពីប្រទេសអេស៊ីព្ទ នោះអ្នកនឹងមិនមានភាពរីករាយដែលលោក ស៊ីសៀល ប៊ី. ដាមិល (Cecil B. Demille) បាននិយាយសរុបរឿងអំពីការនោះឡើយ។ ការស្រមើស្រមៃលើសពីអត្ថបទធ្វើឲ្យមានភាពទាក់ទាញខ្លាំងដល់អ្នកទស្សនា ប៉ុន្តែការបង្ហាញនោះមានដែនកំណត់សម្រាប់អ្នកដែលជាសិស្ស។ នៅក្នុងការស្តាប់ការបង្រៀនអំពីអត្ថបទ បើសិស្សមានការយល់ដឹងអំពីអត្ថបទជាមុន នឹងធ្វើឲ្យមានការផ្លាស់ប្តូរចេញពីអ្នកទស្សនាមកក្លាយជាសិស្ស។ សិស្សដែលបានចំណាយពេលមួយសប្តាហ៍ពេញ ដើម្បីសិក្សាទៅលើអត្ថបទដែលអ្នកបង្រៀន ពួកគេនឹងដឹងនៅពេលណាដែលអ្នកបាន «ចេញឆ្ងាយពីអត្ថបទ»។

## ៤. ការពឹងផ្អែកខ្លាំងពេកទៅលើការនិយាយរឿង ឬភាពកំប្លែង

ដើម្បីធ្វើឲ្យជាប់ទាក់ទង ឬដំណើរការទៅបានគ្រូបង្រៀនបានប្រើការនិយាយរឿង និងរឿងសំណើចជាការប្រៀបធៀប។ នេះមិនខុសទេ ការនិយាយឲ្យមានការសើចនិងការនិយាយអំពីរឿងទាក់ទងទៅនឹងមនុស្សអ្វីដែលជួយដល់គ្រូបង្រៀន គឺធ្វើឲ្យអ្នកស្តាប់មានការចូលរួម និងធ្វើឲ្យចំណុចដែលត្រូវបង្រៀនមានការចងចាំ។ អ្វីដែលមិនល្អសម្រាប់គ្រូបង្រៀន គឺការមិនជាប់ទាក់ទងធុញទ្រាន់ ឬមិនមានការចងចាំ។ ប៉ុន្តែក៏ជាការមិនល្អសម្រាប់គ្រូបង្រៀនផង



Khmer Women of the word_Layout.indd 192 12/3/26 3:56 in the afternoon

ដែរ នៅពេលដែលគ្រូមានការពឹងផ្អែកពេកទៅលើការដែលធ្វើឲ្យគេសើច និង និយាយរឿង ឬប្រើចំណុចទាំងនេះនៅក្នុងរបៀបដើម្បីឲ្យមានដំណើរការ ឬ បន្លប់ចេញឆ្ងាយពីមេរៀន។ ប្រសិនបើពួកគេមិនមានការពង្រឹងទៅលើការ បង្រៀនទេ ពួកគេនឹងសម្រេបសម្រួលការបង្រៀន។

ប្រសិនបើមានអ្នកណាម្នាក់បំបែកការបង្រៀនរបស់អ្នកចេញជាចំណែក ពិន្ទុ តើនឹងបង្ហាញនូវចំណុចទាំងពីរនោះចំនួនប៉ុន្មាន? ប្រសិនបើអ្នកសួរទៅ កាន់សិស្សរបស់អ្នកឲ្យប្រាប់អ្នកអំពីអ្វីមួយដែលពួកគេបានចាំពីមេរៀនរបស់ អ្នក។ តើពួកគេចាំចំណុចសំខាន់មេរៀន ឬរឿងដែលអស់សំណើច? អ្នក ទស្សនាចូលចិត្តរឿងកំប្លែង និងការនិយាយអំពីរឿងមិនថាពួកគេគាំទ្រទៅ លើខ្លឹមសារ ឬក៏អត់នោះទេ។ សិស្សពេញចិត្តនូវអ្វីដែលត្រឹមត្រូវ និងមានការ ចងចាំច្រើនដោយសារការនិយាយរឿងធ្វើឲ្យសើច ឬការបង្ហាញត្រូវចំកន្លែង។ សិស្សដែលមានការរៀបចំល្អនឹងដឹងថាតើគ្រូបង្រៀនរបស់នាងប្រើការប្រៀប ធៀបគ្រាន់តែបំពេញ ឬជាការពង្រឹងមេរៀន។

## ៥. ការល្បួងលោមខាងអារម្មណ៍

នៅពេលដែលខ្ញុំអានព្រះគម្ពីរឮៗចេញពីវេទិកាជារឿយៗខ្ញុំយំ ខ្ញុំមិនដឹងថា មូលហេតុជាអ្វីទេ ក្រៅពីថា ខ្ញុំឃើញសេចក្តីពិត នៅក្នុងអត្ថបទដែលពិតជា បានប៉ះពាល់យ៉ាងខ្លាំង។ ការនេះធ្លាប់បានធ្វើឲ្យខ្ញុំអន់ចិត្ត ប៉ុន្តែព្រះជាម្ចាស់ បានបង្ហាញខ្ញុំថា ការបង្រៀនព្រះគម្ពីរក៏គួរតែទាក់ទងជាមួយនឹងអារម្មណ៍ ដែរ។ ដូច្នេះ ការបង្រៀនព្រះគម្ពីរគួរតែជាការធ្វើឲ្យភ្ញាក់ទាំងគ្រូ ហើយនិង សិស្សក្នុងការស្រឡាញ់ព្រះជាម្ចាស់ឲ្យបានជ្រាលជ្រៅជាងមុន ចំណុចដែល ជ្រៅមួយគឺបានប៉ះពាល់ដល់អារម្មណ៍របស់យើង។ ការស្រឡាញ់ព្រះជាម្ចាស់ ឲ្យអស់ពីគំនិតរបស់យើងគួរតែជាលទ្ធផល បង្ហាញចេញជាសេចក្តីស្រឡាញ់ ដល់ព្រះជាម្ចាស់អស់ពីចិត្តយ៉ាងជ្រៅ និងបរិសុទ្ធ។

យើងនឹងមានបញ្ហានៅពេលយើងមានបំណងសំដៅទៅរកអារម្មណ៍របស់



Khmer Women of the word_Layout.indd 193 12/3/26 3:56 in the afternoon

មនុស្ស ជាចេតនាក្នុងគោលដៅបង្កើតការចែករំលែកបទពិសោធន៍។ វាពិតជាងាយណាស់ក្នុងការរៀបចំមេរៀនដែលចាប់ផ្តើមដោយរឿងកំប្លែង និងបញ្ចប់ដោយរឿងរ៉ាវដែលធ្វើឲ្យគេហូរទឹកភ្នែក។ ហេតុអ្វី? ពីព្រោះវាជារូបមន្តនៃការប្រៀបធៀបវាដំណើរការ។ ពេលខ្លះ អ្នកស្តាប់អាចមានការភាន់ច្រឡំថា តើនោះជាការជំរុញទឹកចិត្តពីព្រះវិញ្ញាណបរិសុទ្ធ ឬក៏ពីភាពប៉ិនប្រសព្វតាមរយៈការរៀបចំមេរៀនយ៉ាងល្អរបស់មនុស្ស?

តើយើងអាចប្រាប់ពីភាពខុសប្លែកគ្នាបានយ៉ាងដូចម្តេច? ជាទូទៅមិនមែនជារឿងងាយស្រួលឡើយ ប៉ុន្តែនេះជាគំនិតមួយៈ អ្នកប៉ិនប្រសព្វខាងផ្នែកអារម្មណ៍នឹងបង្កើនសេចក្តី ស្រឡាញ់ដល់នាង នៅក្នុងអ្នកឲ្យបានច្រើនតាមដែលអាចធ្វើបាន ច្រើនជាងសេចក្តី ស្រឡាញ់ ដែលអ្នកមាន ចំពោះព្រះជាម្ចាស់។ តួនាទីរបស់គ្រូបង្រៀន គឺជាការទាញចំណាប់អារម្មណ៍ទៅកាន់ភាពស្រស់ស្អាតរបស់អត្ថបទ មិនត្រូវបង្កើតការចែករំលែកបទពិសោធន៍ដែលធ្វើឲ្យមានការប៉ះពាល់ឡើយ។ តួនាទីរបស់នាងគឺជាការលើកសរសើរដល់ព្រះជាម្ចាស់នៃព្រះគម្ពីរ មិនមែនសាងសង់ការលើកសរសើរចំពោះបុគ្គលិកលក្ខណៈខ្លួនឯងឡើយ។ សិស្សដែលមានការរៀបចំល្អ គឺមិនងាយទទួលឥទ្ធិពលនៃភាពប៉ិនប្រសព្វខាងការប្រើអារម្មណ៍ទេ។

## ៦. រៀបចំការបង្រៀនលើសជ្រុល

ការរៀបចំមេរៀនគឺជាកត្តាចម្បងដ៏ធំបំផុតដែលយើងត្រូវដឹង អ្វីដែលជាមាតិកាដែលត្រូវទុក និងអ្វីដែលត្រូវកាត់ចេញ។ គឺត្រូវការពេលនៅក្នុងការអភិវឌ្ឍយល់ដឹងអំពីចំណុចណាខ្លះដែលអ្នកនឹងលើកយកមកចែកចាយនៅក្នុងការបង្រៀនរបស់អ្នក។ ជាដំបូង គ្រូបង្រៀនភាគច្រើនមានកំហុសនៅក្នុងការរៀបចំមេរៀនច្រើនពេក។ ចំណុចនេះអាចនាំឲ្យមានការជាប់គាំងជាមួយព័ត៌មានទាំងនោះ ហើយធ្វើឲ្យសិស្សរបស់ពួកគេចំណាយពេលយូរជាងអ្វីដែលបានគ្រោងទុក។ មនុស្សមួយចំនួនមិនចូលចិត្តផឹកទឹកដែលបង្ហូរតាមទុយយោ



Khmer Women of the word_Layout.indd 194 12/3/26 3:56 in the afternoon

ពន្លត់ភ្លើងឡើយ ដើម្បីឲ្យអ្នកធ្វើការបង្រៀនបានមិនមែនជាបញ្ហាក្នុងការដែលមានកំណត់សម្គាល់ច្រើននោះទេ។ ជាការល្អដែលមានផែនការបម្រុងទុកនូវអ្វីដែលអ្នកនឹងកាត់ចេញប្រសិនបើអស់ពេល។

ម្តងទៀត គ្រូដែលមានសិស្សបានចំណាយពេលជាមួយនឹងអត្ថបទសំខាន់រួចហើយ ពួកគេនឹងទទួលបានប្រយោជន៍។ អ្វីដែលសិស្សបានចំណាយពេលនៅក្នុងការយល់ដឹង គឺបានវិនិយោគឲ្យអ្នកជាស្រេចដើម្បីឲ្យអ្នកមានពេលស្វែងរកការកាត់ស្រាយ និងការអនុវត្តដោយមិនចាំបាច់ចំណាយពេលទៅលើការពង្រីកចំណុចមូលដ្ឋានឡើយ។ អ្នកអាចពន្យល់បន្ថែម និងពង្រឹងទៅលើការយល់ដឹងរបស់ពួកគេជាជាងត្រូវចាប់ផ្តើមសារជាថ្មីគ្រប់ពេល។ សិស្សដែលមានការរៀបចំល្អ នឹងមិនត្រូវការការបង្រៀន ដែលមានការរៀបចំច្រើនពេកឡើយ។

## ៧. ការស្ទាក់ស្ទើរថាខ្លួនជាអ្នកជំនាញ

គ្មានអ្នកណាម្នាក់ចង់គិតថាខ្លួនឯងល្ងង់ ឬតូចទាបអន់ជាងគេឡើយ ដោយហេតុដូច្នេះគ្រូបង្រៀនពេលខ្លះស្ទាក់ស្ទើរក្នុងការទទួលស្គាល់នូវដែនកំណត់នៃចំណេះដឹងរបស់ខ្លួន។ សូមមានការស្មោះត្រង់អំពីដែនកំណត់របស់អ្នកៈ វាមិនមានបញ្ហាអ្វីទេដែលគ្រូបង្រៀននិយាយថា «ខ្ញុំអត់ដឹងទេ»។ តាមពិត វាអាចជាការដែលធ្វើឲ្យមានការទុកចិត្តដល់សិស្សរបស់អ្នក។ សូមអនុវត្តឲ្យបានពេញលេញនូវការបង្ហាញបែបនេះ ពេលដែលមានការកាត់ស្រាយលើសពីខ្លឹមសារដែលគេបានទទួលស្គាល់ជាទូទៅ។ ផ្តល់នូវចម្លើយស្មោះត្រង់ដែលទទួលស្គាល់នូវទស្សនៈផ្សេងៗគ្នា។ ការនេះផ្តល់ឲ្យសិស្សរបស់អ្នកនូវឱកាសដើម្បីគិតទៅលើទស្សនៈណាមួយដែលត្រូវជាមួយនឹងការអានអត្ថបទរបស់ពួកគេច្រើនជាង។ សិស្សដែលមានការរៀបចំល្អ ដឹងអំពីអត្ថបទដែលពិបាកតម្រូវឲ្យមានការយកចិត្តទុកដាក់ នាងនឹងដឹងថាអ្នកបានផ្តល់ឲ្យនូវចម្លើយដែលធម្មតាទៅលើសំណួរដែលស្មុគស្មាញ។ អ្វីដែលល្អប្រសើរជាងនេះភាព



Khmer Women of the word_Layout.indd 195 12/3/26 3:56 in the afternoon

ស្មោះត្រង់អំពីទំនុកចិត្តរបស់អ្នក (ឬក៏ការខ្វះខាត) នៅក្នុងការកាត់ស្រាយចំណុចជាក់លាក់ណាមួយ។

ចំណុចល្អនៅក្នុងការបង្រៀនព្រះគម្ពីរដល់ស្ត្រី អត្ថបទដែលពួកគេធ្លាប់បានរៀនរួចមកហើយ គឺជាការដែលធ្វើឲ្យគ្រូមានការទទួលខុសត្រូវ មិនមែន "ធ្វេសប្រហែសឡើយ"។ សិស្សដែលមានការរៀបចំអាចដឹងចំណុចរាក់កំផែលទៅលើផ្នែកដែលគ្រូបានរៀបចំ។ ការសួរច្រើនអំពីសិស្សរបស់ខ្ញុំនៅខាងមុខមាន ន័យថាសិស្សអាចសួរ និងគួរតែសួរច្រើនទៀតអំពីខ្ញុំអំឡុងពេលបង្រៀនដែរ។

## ហេតុអ្វីបង្រៀនដោយប្រើប្រាស់វិធីសាស្ត្រទាំងប្រាំនៃការបង្រៀនដ៏ត្រឹមត្រូវរបស់ខ្ញុំធ្វើឲ្យយើងមានសេរីភាព

ទោះបើជាការបង្រៀនជាការងារដែលលំបាកក៏ដោយ ក៏ការប្រើវិធីសាស្ត្រទាំងប្រាំនៃការបង្រៀនដ៏ត្រឹមត្រូវរបស់ខ្ញុំមានសារៈសំខាន់ក្នុងការសម្រាលបន្ទុកនេះ។ ភាពស្រស់ស្អាតនៅក្នុងការប្រើ ការទាំងប្រាំនៃការបង្រៀនដ៏ត្រឹមត្រូវ គឺថាបានជួយបង្រៀនឲ្យមានសេរីភាព ពីការសម្រេចចិត្តទៅលើប្រធានបទដែលពួកគេចង់បង្ហាញ។ មេរៀនរបស់គ្រូគឺសម្រេចដោយមាតិកានៅក្នុងអត្ថបទដោយផ្ទាល់។ ខ្ញុំពិតជាមានភាពងាយស្រួលដោយដឹងថា អត្ថបទនឹងណែនាំនូវអ្វីដែលត្រូវការចាំបាច់ នៅក្នុងពេលដែលចាំបាច់។ នៅក្នុងបរិបទដែលបង្ហាញនូវចំណុចដែលមានប្រយោជន៍ជាងគេ អ្វីដែលខ្ញុំត្រូវធ្វើគឺបង្រៀនខគម្ពីរបន្ទាប់ទៀត។ ការបង្រៀនអំពីប្រធានបទតម្រូវឲ្យខ្ញុំអភិវឌ្ឍន៍នូវទម្រង់ដោយយកចិត្តទុកដាក់ ដែលភ្ជាប់ទៅចំណុចខ្លឹមសារផ្សេងៗទៀត។ ការបង្រៀនជាមួយការទាំងប្រាំនៃការបង្រៀនដ៏ត្រឹមត្រូវនេះអនុញ្ញាតឲ្យអត្ថបទគឺជាទម្រង់របស់ខ្ញុំ។

ខ្ញុំយល់ស្របជាមួយលោកយ៉ាកុប៖ មិនមែនគ្រប់គ្នាសន្មតថាអាចបង្រៀនបានទេ ការសូន្យចេញនូវការយល់ដឹងរបស់អ្នកណាម្នាក់ឲ្យយល់ដឹងអំពី



Khmer Women of the word_Layout.indd 196 12/3/26 3:56 in the afternoon

ព្រះជាម្ចាស់ គឺជាការទទួលខុសត្រូវយ៉ាងធំ ហើយមិនត្រូវទទួលដោយធ្វេសប្រហែសដែរ។ ឥរិយាបថរបស់អ្នកដែលមានបំណងប្រាថ្នានៅក្នុងការបង្រៀនមិនមានកន្លែងសម្រាប់ការ «បន្លំធ្វើរហូតដល់ចេះ» នោះទេ។ អស់អ្នកដែលយកចិត្តទុកដាក់ជាមួយនឹងតួនាទីរបស់គេ នឹងចំណាយពេលច្រើនម៉ោងនៅក្នុងការរៀបចំសម្រាប់ការបង្រៀន៤០នាទីហើយរិះគិតម្តងទៀតអ្វីខ្លះដែលពួកគេត្រូវនិយាយ អ្វីដែលពួកគេត្រូវពន្យល់ និងការបង្ហាញបែបណាដែលពួកគេត្រូវប្រើដើម្បីពន្យល់។ នៅពេលស្ត្រីវ័យក្មេងម្នាក់ប្រាប់ខ្ញុំ «ខ្ញុំចង់បង្រៀនដូចជាអ្នកគ្រូដែរ» ខ្ញុំតែងគិត «ប្រហែលជាអ្វីដែលខ្ញុំបានធ្វើ ដូចជាងាយស្រួលពេកមែនទេ»។ ការបង្រៀនដូចជាការត្រាស់ហៅផ្សេងៗទៀតដែរ គឺប្រាកដណាស់មិនមានភាពងាយស្រួលឡើយ ប៉ុន្តែប្រសិនបើព្រះជាម្ចាស់ត្រាស់ហៅអ្នកឲ្យបង្រៀន អ្នកអាចទុកចិត្តទៅលើព្រះអង្គថាទ្រង់នឹងផ្គត់ផ្គង់នូវអ្វីដែលអ្នកត្រូវការជាមិនខាន។

## សំណួរឆ្លុះបញ្ចាំង

១. ហេតុអ្វីអ្នកគិតថាវាមានសារៈសំខាន់សម្រាប់គ្រូបង្រៀន ក្នុងការទទួលយកសំណួរដែលជំរុញទឹកចិត្តដែលអាចលេចឡើងក្នុងអំឡុងពេលសិក្សា និងការបង្រៀន? ហេតុអ្វីបានជាគ្រូបង្រៀនគេចចេញពីសំណួរដែលពិបាក? តើយើងនឹងទទួលបានអ្វីចេញពីការបង្ហាញសំណួរទាំងនោះដោយការជឿជាក់?

២. សូមឆ្លុះបញ្ចាំងមើលខ្លឹមសារនៅក្នុងទំព័រ១៨៩ «ការបង្រៀនអត្ថបទទៅកាន់អ្នកដែលបានសិក្សា គឺវាមានតម្រូវការច្រើនជាងការបង្រៀនទៅកាន់អ្នកដែលមិនបានធ្វើការសិក្សា»។ ហេតុអ្វីជាករណីសំខាន់? សម្រាប់អ្នក តើការសិក្សាព្រះបន្ទូលមុនឮការបង្រៀនរបស់គ្រូ ផ្លាស់ប្តូរការស្តាប់ និងរៀនបានបទពិសោធន៍យ៉ាងដូចម្តេច?



Khmer Women of the word_Layout.indd 197 12/3/26 3:56 in the afternoon

៣. ប្រសិនបើមានការពិបាកច្រើននៅក្នុងការបង្រៀន អ្នកស្ដាប់ត្រូវធ្វើការសិក្សាអត្ថបទជាមុន តើអ្វីជាការលើកទឹកចិត្តដល់គ្រូបង្រៀន ឲ្យចេះជំរុញទឹកចិត្តកូនសិស្សរបស់គាត់ឲ្យសិក្សាជាមុន? សូមផ្ដល់ចំណុចលើកទឹកចិត្តមួយចំនួនដែលអាចធ្វើទៅបាន។

៤. តើអ្វីជាភាពខុសគ្នារវាងអ្នកនិយាយជាសាធារណៈ និងគ្រូបង្រៀន? ហេតុអ្វីបានជាមានសារៈសំខាន់នៅក្នុងការស្គាល់អំពីភាពខុសគ្នានេះ?

៥. សូមត្រឡប់ទៅមើលឡើងវិញនៅចំណុចគ្រោះថ្នាក់ទាំង៧ នៃការបង្រៀនដែលយើងត្រូវជៀសវាង (ទំព័រ ១៩៩-១៥៤)។ នៅក្នុងនាមជាសិស្ស ចំណុចណាមួយក្នុងចំណុចទាំងនេះ ដែលធ្វើឲ្យយើងដឹងថាគ្រូបង្រៀនបានធ្លាក់ក្នុងចំណុចនោះ? ក្នុងនាមជាគ្រូបង្រៀន ចំណុចមួយណាដែលអ្នកបានប្រើប្រាស់ ឬបានល្បងឲ្យអ្នកប្រើប្រាស់នៅក្នុងការបង្រៀនរបស់អ្នក?



Khmer Women of the word_Layout.indd 198 12/3/26 3:56 in the afternoon

# សេចក្តីសន្និដ្ឋាន

## ស្វែងរកព្រះភក្ត្រព្រះអង្គ

«កាលទ្រង់មានបន្ទូលថា "ចូរស្វែងរកមុខអញ" នោះឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំបានទូលតបថា "ទូលបង្គំ នឹងស្វែងរកព្រះភក្ត្រទ្រង់ពិត"»។

ទំនុកតម្កើង ២៧:៨

បន្ទាប់ពីខ្ញុំដឹងថាខ្ញុំជាគ្រូបង្រៀនព្រះគម្ពីរម្នាក់ ថ្មីៗនេះមានគេសួរខ្ញុំ តើខ្ញុំជាអ្នកថ្វាយបង្គំព្រះជាម្ចាស់ ឬជាអ្នកថ្វាយបង្គំព្រះគម្ពីរ។ សំណួរនេះមិនបានធ្វើខ្ញុំឲ្យភ្ញាក់ផ្អើលនោះទេ។ ប្រសិនបើអ្នកបានចំណាយពេលជាច្រើនដូចដែលខ្ញុំសួរអ្នកដទៃឲ្យពួកគាត់យកចិត្តទុកដាក់ក្នុងការស្គាល់ព្រះគម្ពីររបស់ខ្លួន នោះនឹងមានអ្នកណាម្នាក់មុខជាសួរថា តើអ្នកធ្លាប់បាត់បង់ការមើលឃើញទេសភាពនៃព្រៃទាំងមូល ដោយសារដើមឈើទាំងនោះដែរឬទេ។ ចម្លើយរបស់ខ្ញុំសាមញ្ញ៖ ខ្ញុំចង់ធ្វើអ្វីស្របទៅតាមរូបអង្គរបស់ព្រះជាម្ចាស់។ តើខ្ញុំអាចធ្វើអ្វីតាមរូបអង្គនៃព្រះជាម្ចាស់បានយ៉ាងដូចម្តេចកើត បើខ្ញុំមិនដែលបានសង្កេតមើលរូបអង្គទ្រង់សោះ? ខ្ញុំមិនមែនជាអ្នកថ្វាយបង្គំព្រះគម្ពីរ ប៉ុន្តែខ្ញុំមិនអាចថ្វាយបង្គំព្រះជាម្ចាស់ពិតប្រាកដ ដោយមិនបានគោរពនិងស្រឡាញ់ ព្រះគម្ពីរឲ្យបានជ្រាលជ្រៅនោះឡើយ។ បើមិនដូច្នោះ នោះខ្ញុំនឹងថ្វាយបង្គំព្រះដែលខ្ញុំមិនស្គាល់ជាមិនខាន។



Khmer Women of the word_Layout.indd 199 12/3/26 3:56 in the afternoon

អ្នកថ្វាយបង្គំព្រះគម្ពីរស្រឡាញ់វត្ថុ អ្នកថ្វាយបង្គំព្រះជាម្ចាស់ស្រឡាញ់មនុស្ស។ យើងអាចស្រឡាញ់ព្រះគម្ពីរជាមួយនឹងគំនិតរបស់យើង ប៉ុន្តែយើងមិនអាចស្រឡាញ់ព្រះគម្ពីរជាមួយចិត្តរបស់យើងបានច្រើនលើសពីការស្រឡាញ់ឡាន ឬកាហ្វេរបស់យើងនោះទេ។ វត្ថុមិនអាចទទួលឬឆ្លើយតបចំពោះសេចក្តីស្រឡាញ់ឡើយ។ មានតែមនុស្សទេដែលអាចធ្វើការនេះបាន ដូច្នេះប្រសិនបើអ្នកបានអានសៀវភៅនេះជាមួយកិច្ចខិតខំប្រឹងប្រែងក្នុងការស្រឡាញ់ព្រះគម្ពីរឲ្យបានច្រើនជាងមុន ខ្ញុំចង់ទះដៃអបអរដល់អ្នកនិងរម្លឹកដាស់តឿនអ្នកទន្ទឹមគ្នាផងដែរ។ សូមធ្វើការសិក្សាស្រឡាញ់ព្រះជាម្ចាស់ជាមួយនឹងគំនិតរបស់អ្នកតាមរយៈការសិក្សាដោយស្មោះត្រង់ទៅលើព្រះបន្ទូលរបស់ព្រះអង្គ។ ហើយកុំភ្ជាប់ការស្រឡាញ់របស់អ្នកទៅលើអ្វីផ្សេងទៀត ក្រៅពីរូបអង្គផ្ទាល់របស់ព្រះជាម្ចាស់ឡើយ។ ការសិក្សាព្រះគម្ពីររបស់យើងគឺគ្រាន់តែផ្តល់ប្រយោជន៍នៅក្នុងការបង្កើនសេចក្តីស្រឡាញ់របស់យើង ចំពោះព្រះជាម្ចាស់ដែលយើងបានប្រកាសប៉ុណ្ណោះ។ ការសិក្សាព្រះគម្ពីរគឺជាវិធីទៅរកគោលដៅ មិនមែនជាការដែលចូលទៅក្នុងគោលដៅ និងបញ្ចប់ដោយខ្លួនឯងនោះទេ។ វាគឺជាវិធីនៅក្នុងការស្រឡាញ់ព្រះជាម្ចាស់ឲ្យបានច្រើនថែមទៀត និងរស់នៅដោយមានការខុសប្លែកពីមុន ពីព្រោះយើងបានរៀនសង្កេតមើលព្រះជាម្ចាស់ឲ្យបានល្អប្រសើរផងដែរ។ ហើយក៏ជាវិធីនៅក្នុងការប្រែក្លាយយើងទៅតាមអ្វីដែលយើងបានសង្កេតមើលផងដែរ។ ការដែលព្រះស្រឡាញ់យើង ហើយយើងស្រឡាញ់ទ្រង់វិញ នោះគឺជាសេចក្តីស្រឡាញ់ដែលនឹងបំផ្លាស់បំប្រែយើង។

នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ជំពូក១៣ ព្រះយេស៊ូវបានប្រាប់សាវ័ករបស់ព្រះអង្គថា ការជះឥទ្ធិពលរបស់ពួកគេនឹងមានការទទួលស្គាល់។ ព្រះអង្គបានប្រាប់ពួកគេថា លោកីយ៍នឹងស្គាល់ពួកគេដោយហេតុផលយ៉ាងច្បាស់៖ នោះគឺសេចក្តីស្រឡាញ់របស់ពួកគេចំពោះគ្នាទៅវិញទៅមក។ សេចក្តីស្រឡាញ់ដែលអ្នកមានចំពោះអ្នកដទៃគឺជាការហូរចេញពីសេចក្តីស្រឡាញ់ដែលអ្នក



Khmer Women of the word_Layout.indd 200 12/3/26 3:56 in the afternoon

មានចំពោះព្រះ។ សេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់នឹងកើនឡើង នៅពេលដែលអ្នករៀនស្គាល់ព្រះអង្គឲ្យបានកាន់តែប្រសើរជាងមុន។ ប៉ុន្តែសូមកុំឲ្យបាត់បង់ការមើលឃើញថា ឥទ្ធិពលរបស់អ្នកនឹងត្រូវបានកត់សម្គាល់គឺក្នុងរបៀបដែលអ្នកប្រើជាមួយដួងចិត្តរបស់អ្នកមិនមែនខួរក្បាលរបស់អ្នកឡើយ។ ចំណេះដឹងខាងឯព្រះគម្ពីរដែលមិនមានការផ្លាស់ប្រែនោះគឺ ជាការដេញតាមចាប់ខ្យល់។ គ្រីស្ទបរិស័ទនឹងត្រូវបានគេស្គាល់តាមរយៈសេចក្តីស្រឡាញ់របស់យើង មិនមែនចំណេះដឹងរបស់យើងទេ។

យើងមិនត្រូវបានស្គាល់ដោយសេចក្តីស្រឡាញ់ធម្មតាៗឡើយ យើងត្រូវបានស្គាល់គឺតាមរយៈសេចក្តីស្រឡាញ់ ដែលព្រះវរបិតាបានបង្ហាញមកកាន់យើង ហើយយើងនឹងបង្ហាញសេចក្តីស្រឡាញ់នោះដូចគ្នាទៅកាន់អ្នកដទៃផ្សេងទៀតផងដែរ។

## យើងនឹងក្លាយទៅជាអ្វីមួយដូចដែលយើងសង្កេតមើល

នៅពេលដែលខ្ញុំកំពុងរៀនថ្នាក់ទី៧ ខ្ញុំចង់ក្លាយដូចជាមិត្តខ្ញុំ ឈ្មោះ មីមី។ មីមីមានសក់ពណ៌ទង់ដែងទន់រលោង ដែលសមជាមួយនឹងសក់ការ៉េត្រឹមករយ៉ាងឥតខ្ចោះ។ នាងមានសម្លៀកបំពាក់ស្អាតដែលមនុស្សគ្រប់គ្នាច្រណែន។ នាងចេះនិយាយកំប្លែង ឆ្លាត និងមានប្រជាប្រិយភាព នាងស្តាប់បទចម្រៀងដែលពីរោះ និងឃ្លូរកាបូបដែលត្រូវនឹងនាង។ នាងមានដងខ្លួនស្អាតមានសម្បុរទឹកឃ្មុំ នាងដឹងអំពីរបៀបនៅក្នុងការផាត់មុខ នាងស្អាតគឺពេញដោយភាពឥតខ្ចោះ។

ដូច្នេះខ្ញុំធ្វើអ្វីៗជាច្រើនដូចជាក្មេងស្រីថ្នាក់វិទ្យាល័យចូលចិត្តធ្វើ៖ ខ្ញុំកាត់សក់ការ៉េត្រឹមក ខ្ញុំរកសម្លៀកបំពាក់ដែលមីមីចូលចិត្តនៅកន្លែងលក់ឡៃឡុង ហើយខ្ញុំអាចទិញបានជាមួយនឹងប្រាក់ដែលបានមកពីការមើលថៃក្មេងៗ។ ខ្ញុំផ្លាស់ប្តូររបៀបនិយាយស្តីរបស់ខ្ញុំ និងប្រភេទបទចម្រៀងដែលខ្ញុំស្តាប់ឲ្យបានដូចនាងខ្ញុំក៏បានព្យាយាមរៀនដើរឲ្យមានជំហានដំណើរដូចនាង។ ខ្ញុំ



Khmer Women of the word_Layout.indd 201 12/3/26 3:56 in the afternoon

សិក្សាគ្រប់យ៉ាងពីអ្វីៗដែលបានធ្វើឲ្យមីមីអស្ចារ្យ បន្ទាប់មកខ្ញុំព្យាយាមធ្វើតាមចំណុចទាំងនោះ សូម្បីតែចំណុចតូចៗផងដែរ។ បើទោះជាខ្ញុំខ្ពស់ជាងមីមីប្រហែល១៥សម នោះមិនជាបញ្ហាអ្វីទេ ជាមួយនឹងស្បែករាងស្លេកដែលមានអាចម៍រុយ និងរាង ធាត់ដូចក្មេងប្រុសដែលមានអាយុ១០ឆ្នាំបន្តិច។ ខ្ញុំបានធ្វើការសិក្សាយ៉ាងស៊ីជម្រៅអំពីនាង ហើយខ្ញុំបានធ្វើគ្រប់យ៉ាងជាមួយនឹងសមត្ថភាពរបស់ខ្ញុំដើម្បីឲ្យបានដូចជារូបរាងរបស់នាងដែរ។

ជារឿយៗ ខ្ញុំបានគិតអំពីការនេះនៅក្នុងជីវិតរបស់ខ្ញុំ គឺទាំងពីរនូវអ្វីដែលខ្ញុំបានធ្វើខុស និងអ្វីដែលខ្ញុំបានធ្វើត្រូវផងដែរ។ តាមពិតទៅ ខ្ញុំមានចំណុចល្អនៅក្នុងការស្គាល់នូវអ្វីដែលជាចំណុចដែលមានប្រសិទ្ធភាព ដើម្បីធ្វើតាមអ្នកណាម្នាក់ក្នុងការចំណាយពេលយ៉ាងយកចិត្តទុកដាក់ទៅលើចរិតលក្ខណៈរបស់នាង។ ហើយអ្វីដែលកាន់តែត្រឹមត្រូវនោះ គឺខ្ញុំចង់ធ្វើឲ្យបានដូចយ៉ាងឥតខ្ចោះតែម្តង។ ប៉ុន្តែ ខ្ញុំខុសក្នុងការគិតថាខ្ញុំអាចស្វែងរកចំណុចល្អនោះនៅក្នុងមនុស្សណាម្នាក់បាន។

យើងជាមនុស្សគឺចូលចិត្តធ្វើតាម តាំងពីពេលដែលយើងនៅជាទារកម្ល៉េះ យើងបានធ្វើតាមមនុស្សនៅជុំវិញយើង។ ពេលខ្លះយើងបានធ្វើតាមយ៉ាងសកម្ម ដូចជាពេលដែលខ្ញុំបានព្យាយាម ធ្វើជាមីមីដែរ។ ពេលខ្លះទៀតយើងធ្វើតាមដោយមិនបានដឹងជាមុន ដូចនៅពេលដែលយើងបានដឹងបន្តិចម្តងៗថា យើងកំពុងតែត្រឡប់ទៅមានលក្ខណៈដូចជាម្តាយរបស់យើង។ តើអាចទេថា យើងរៀបចំតាក់តែងឡើងតាមបែបយ៉ាងនេះសម្រាប់ហេតុផលអ្វីមួយ? ទំនោរនៅក្នុងការត្រាប់តាមរបស់យើងតាមពិត គឺមានគោលបំណងសម្រាប់ការល្អដល់យើងប៉ុណ្ណោះ?

កណ្ឌគម្ពីរ អេភេសូរ ៥:១ បានប្រាប់យើងថា «ដូច្នេះចូរត្រាប់តាមព្រះដូចជាកូនស្ងួនភ្ងា»។ កូនៗដែលដឹងថាឪពុក ម្តាយស្រឡាញ់ ពួកគេត្រាប់តាមឪពុកម្តាយរបស់ខ្លួនដោយមានចិត្តស្រឡាញ់និងរីករាយ។ ពួកគេចង់ធ្វើដូចជាឪពុកម្តាយរបស់ពួកគេ។ ហើយនេះគឺជាវិធីដែលយើងហៅថា ការត្រាប់



Khmer Women of the word_Layout.indd 202 12/3/26 3:56 in the afternoon

តាមព្រះជាម្ចាស់ដ៏ឥតខ្ចោះ៖ មិនមែនតាមសេចក្ដីប៉ងប្រាថ្នាឥតចន្លោះដូចកាលដែលយើងនៅថ្នាក់វិទ្យាល័យឡើយ ដែលយើងចង់បានភាពប្រសើរ និងភាពខុសប្លែកលើសពីអ្វីដែលយើងមានពេលបច្ចុប្បន្ន ប៉ុន្តែចេញពីការទទួលស្គាល់ដោយភាពអំណររីករាយ ដែលព្រះអង្គគួរឲ្យស្រឡាញ់ និងសាកសមឲ្យយើងគ្រាប់តាមទ្រង់ទាំងស្រុង។

ប៉ុន្តែសូមដឹងពីការនេះ៖ យើងមិនមែនគ្រាប់តាមព្រះអង្គដោយចៃដន្យឡើយ។ យើងបានក្លាយដូចជាម្ដាយរបស់យើងយ៉ាងពិតប្រាកដ ដោយមិនសូវមានការខំប្រឹងព្យាយាមប៉ុន្មានទេ ប៉ុន្តែយើងមិនមែនក្រោកឡើងនៅ១០ឆ្នាំក្រោយដោយគិតចាប់ពីពេលនេះ ហើយដឹងថាយើងគ្រាប់តាមនូវចរិតលក្ខណៈរបស់ព្រះជាម្ចាស់ ដោយព្រងើយកន្តើយនោះឡើយ។

## ការគ្រាប់តាមយ៉ាងសកម្ម

ការគ្រាប់តាមព្រះជាម្ចាស់គឺកើតឡើងដូចគ្នាច្រើន ទៅនឹងអ្វីដែលយើងបានធ្វើកាលពីនៅថ្នាក់វិទ្យាល័យគ្រាន់តែពេលនេះ យើងមានចំណុចដែលគួរធ្វើជាង។ ដូចគ្នាទៅនឹងអ្វីដែលខ្ញុំបានសិក្សាអំពីមិត្តរបស់ខ្ញុំយើងក៏ត្រូវធ្វើការសិក្សាអំពីព្រះជាម្ចាស់៖ អ្វីដែលព្រះអង្គស្រឡាញ់ អ្វីដែលព្រះអង្គស្អប់ តើព្រះអង្គមានព្រះបន្ទូល និងលូកព្រះហស្តយ៉ាងដូចម្ដេច។ យើងមិនអាចគ្រាប់តាមលក្ខណៈពិសេសរបស់ព្រះជាម្ចាស់ និងទម្លាប់របស់ទ្រង់ដោយយើងមិនបានសិក្សានោះទេ។ យើងត្រូវធ្វើការសិក្សាអំពីព្រះអង្គប្រសិនបើយើងចង់មានលក្ខណៈដូចជាទ្រង់ យើងត្រូវស្វែងរកព្រះភក្ត្ររបស់ព្រះអង្គ។

មានហេតុផលជាច្រើននៅក្នុងការចំណាយពេលសិក្សាអំពីព្រះបន្ទូលរបស់ព្រះ ប៉ុន្តែមិនមានចំណុចណាល្អជាងចំណុចនេះឡើយ៖ គឺជាមួយនឹងការខិតខំប្រឹងប្រែង ដែលពេញដោយគោលបំណង ឆ្ពោះទៅមុខជាមួយនឹងការដែលមាន ទស្សនៈ ភ្ជាប់ទៅក្នុងការអាន ជាមួយនឹងជំហាននៃការអត់ធ្មត់បន្តជាមួយនឹង ដំណើរការ នីមួយៗ ដែលរៀបចំនូវការខិតខំប្រឹងប្រែង ជាមួយ

នឹងការអធិដ្ឋាន ដោយមានការលាយឡំជាមួយនឹងអត្ថបទព្រះបន្ទូល។ តាមរយៈការធ្វើបែបនោះ យើងនឹងខិតចូលទៅជិតពន្លឺរបស់ព្រះអង្គ ហើយយើងនឹងចេញមកវិញ អមជាមួយនឹងពន្លឺនៃព្រះភក្ត្ររបស់ព្រះអង្គយ៉ាងពិតប្រាកដដែរ។ យើងមើលទៅព្រះអង្គក្នុងនាមជាព្រះអង្គទ្រង់ផ្ទាល់ ដែលជារង្វាន់យ៉ាងពិតប្រាកដ ប៉ុន្តែនេះគឺជារង្វាន់ជាមួយនឹងប្រយោជន៍បន្ទាប់បន្សំក្នុងការផ្លាស់ប្តូរ ការមើលឃើញរបស់យើងជារៀងរហូត។

យើងនឹងក្លាយទៅជាអ្វីមួយតាមរយៈអ្វីដែលយើងបានសង្កេតមើល តើយើងជឿការនេះដែរឬទេ? មិនថាដោយសកម្ម ឬបែបព្រងើយកន្តើយនោះទេ្បីយ។ យើងនឹងប្រែក្លាយទៅជាទម្រង់អ្វីមួយតាមរយៈការការចំណាយពេលសិក្សារៀនសូត្រអំពីការនោះ។

តើយើងកំពុងសម្លឹងមើលលើអ្វី? គណនីធនាគាររបស់អ្នក? ទម្ងន់គីឡូរបស់ខ្លួន? សាលាសិក្សាបន្ទាប់ទៀតសម្រាប់កូនរបស់អ្នក? ផ្ទះបាយក្នុងក្តីស្រមៃរបស់អ្នក? រឿងភាគដែលទទួលការគាំទ្រច្រើនជាងគេ? ទូរស័ព្ទរបស់អ្នក? នេះគឺជាបែបផែននៃជីវិតនេះដែលយើងត្រូវធ្វើការប្រយុទ្ធប្រឆាំងរាល់ថ្ងៃដើម្បីឲ្យមានទីកន្លែងសមស្របជាមួយនឹងការសម្លឹងមើលរបស់យើង ដែលយើងត្រូវធ្វើការខិតខំពុះពារ។ គ្រប់ការទាំងអស់សុទ្ធតែបានបង្ហាញថាត្រឹមត្រូវទៅលើចំណាប់អារម្មណ៍របស់យើង តើនៅពេលដែលភ្នែករបស់យើងទំនេរបន្តិចពីកូនតូចអាយុ២ឆ្នាំ ឬពីបញ្ជី សៀវភៅសិក្សាផ្សេងៗ ការលាងចាន តើយើងដាក់ការសម្លឹងមើលរបស់យើងទៅកន្លែងណា? ប្រសិនបើយើងដាក់ការសម្លឹងមើលរបស់យើងទៅលើការដែលតូចទាបអន់ៗ យើងនឹងក្លាយទៅជាអញ្ចឹងដែរ។ ការវាស់វែងឆ្នាំរបស់យើងផ្អែកទៅលើការសរសើររបស់មនុស្ស។

ប៉ុន្តែ នេះគឺជាដំណឹងល្អ៖ បុគ្គលមួយអង្គដែលយើងត្រូវការចំណាយពេលសម្លឹងមើល បានបង្ហាញអង្គទ្រង់ឲ្យយើងស្គាល់។ ព្រះអង្គបានបង្ហាញដានជាមួយនឹងព្រះហស្តដ៏ប៉ិនប្រសព្វរបស់ទ្រង់ បន្ទាត់ និងរូបរាងនៃព្រះភក្ត្ររបស់ព្រះអង្គ។ ព្រះអង្គបានធ្វើដូច្នេះនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ យើង



Khmer Women of the word_Layout.indd 204 12/3/26 3:56 in the afternoon

ត្រូវស្វែងរកនូវព្រះភក្ត្រនោះ ទោះបីជាទារកបន្ទុយំ វិក្កយបត្របង់ប្រាក់នៅតែកើនឡើង ដំណឹងអាក្រក់បន្តកើតឡើងដោយមិនឲ្យយើងដឹងជាមុនឡើយ។ ទោះបីជាមិត្តភាពរីកធំធាត់ ឬក៏អន់ថយទោះបើចំណុចទាំងពីរនៃការគោរពកោតខ្លាចព្រះមានលក្ខណៈងាយស្រួល ឬក៏ពិបាកធ្វើឲ្យដៃរបស់យើងចុះអន់ខ្សោយថ្វីបើមានមនុស្សរាប់ពាន់នាក់ មានមុខផ្សេងៗមកជួបជុំគ្នាធ្វើឲ្យយើងចាប់អារម្មណ៍ និងសម្លេងមនុស្សរាប់ពាន់អ្នកផ្សេងទៀតទាក់ទាញចំណាប់អារម្មណ៍យើងយ៉ាងណាក៏ដោយ។ តាមរយៈការសម្លឹងទៅលើមុខនោះ យើងបានឮការសរសើររបស់មនុស្សសម្រាប់ភាពបរិសុទ្ធប៉ុណ្ណោះ៖ «ហើយ [យើងរាល់គ្នា] ទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងផ្លាស់ប្រែទៅឲ្យដូចជារូបឆ្លុះនោះឯងពីសិរីល្អទៅដល់សិរីល្អ»។

មានតែការពីរយ៉ាងដែលអាចធ្វើទៅបាននៅក្នុងជីវិតនេះ៖ ឲ្យយើងបានប្រែក្លាយទៅដូចជារូបអង្គទ្រង់ ឬក៏ប្រែក្លាយទៅជាលក្ខណៈដូចលោកីយ៍នេះ។ ដោយមិនមានការសង្ស័យ គឺយើងចង់បានអ្វីៗដែលមានពីមុនតែសូមមានការប្រុងប្រយ័ត្ន៖ ពិភពលោកនេះគឺមានជីវិត និងសកម្ម ពិភពលោកនេះនឹងប្រែក្លាយអ្នក ហើយបែងចែកអ្នក។ ហើយនៅក្នុងការបែងចែក ការអស្ចារ្យនៅក្នុងភាពអស្ចារ្យទាំងនោះនឹងធ្វើឲ្យអ្នកបានពេញលេញ។ យើងនឹងក្លាយទៅជាអ្វីមួយតាមរយៈអ្វីដែលយើងបានសង្កេតមើល។ ខ្ញុំមិនបានដឹងអំពីអ្នកប៉ុន្តែខ្ញុំបាន «ប្រែក្លាយ» យ៉ាងច្រើននៅក្នុងការប្រព្រឹត្តរបស់ខ្ញុំ។ មានភាពធំទូលាយរវាងអ្វីដែលខ្ញុំជា និងអ្វីដែលខ្ញុំត្រូវតែក្លាយទៅជា ប៉ុន្តែវាគឺជាភាពធំទូលាយដែលអាចធ្វើទៅបាន ពីសេចក្ដីមេត្តាករុណា និងព្រះគុណរបស់ព្រះដែលយើងបានមើល។ នេះគឺជាសេចក្ដីត្រូវការដែលចាំបាច់បំផុតសម្រាប់ខ្ញុំ នៅក្នុងការសង្កេតមើល។ ពេលដែលយើងសង្កេតមើលទៅព្រះជាម្ចាស់ នោះយើងនឹងមានលក្ខណៈដូចជាព្រះអង្គ។

ដូច្នេះ ក្នុងនាមជាកូនស្ងួនភ្ងា សូមធ្វើការសិក្សាដោយស្មោះត្រង់អំពីព្រះ



Khmer Women of the word_Layout.indd 205 12/3/26 3:56 in the afternoon

អង្គដែលអ្នកចង់ត្រាប់តាម។ សិក្សាគ្រប់យ៉ាងអំពីអ្វីដែលបង្ហាញថាព្រះជាម្ចាស់ទ្រង់អស្ចារ្យ ដែលនាំឲ្យចិត្តរបស់អ្នកពេញដោយសេចក្តីរីករាយ នៅពេលដែលអ្នកមានសេចក្តីស្រឡាញ់ចំពោះព្រះអង្គ អ្នកនឹងបង្ហាញអំពីអំណរនៃសេចក្តីរីករាយនោះផងដែរ។ សូមបានឆ្លើយតបដូចជា ស្តេច ដាវីឌ “ចិត្តទូលបង្គំបានទូលតបថា “ទូលបង្គំនឹងស្វែងរកព្រះភក្ត្រទ្រង់ពិត”» (ទំនុកតម្កើង ២៧:៨)។ សម្រាប់អ្នកដែលស្វែងរកព្រះអង្គ ព្រះជាម្ចាស់សព្វព្រះទ័យនៅក្នុងការលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គគឺទាំងពេលនេះ និងអស់កល្បជានិច្ច។ សូមសិក្សាឲ្យបានម៉ត់ចត់អំពីរូបរាងនៃព្រះភក្ត្ររបស់ព្រះអង្គ។ សូមសម្លឹងមើលសេចក្តីស្រឡាញ់របស់ទ្រង់ដែលប៉ះពាល់ដល់ចិត្ត និងគំនិតរបស់យើង ហើយសូមធ្វើការផ្លាស់ប្រែចុះ។

## សំណួរឆ្លុះបញ្ចាំង

១. ក្នុងទំព័រទី១៥៧ ភាពខុសប្លែកគ្នារវាងអ្នកថ្វាយបង្គំព្រះគម្ពីរ និងអ្នកថ្វាយបង្គំព្រះជាម្ចាស់៖ តើថ្វាយបង្គំព្រះគម្ពីរមានន័យដូចម្តេច? ឬក៏ថ្វាយបង្គំតាមរបៀបនៃព្រះគម្ពីរ?

២. សូមពណ៌នាអំពីពេលដែលអ្នកព្យាយាមនៅក្នុងការត្រាប់តាមអ្នកណាម្នាក់។ តើមានអ្វីនៅក្នុងជីវិតរបស់គាត់ដែលធ្វើឲ្យអ្នកចង់ត្រាប់តាម? តើអ្នកបានត្រាប់តាមគាត់បានយ៉ាងល្អប្រសើរដល់កម្រិតណា?



Khmer Women of the word_Layout.indd 206 12/3/26 3:56 in the afternoon

៣. តើអ្នកគិតអំពីគោលការណ៍នេះយ៉ាងដូចម្ដេច «យើងនឹងក្លាយទៅជាអ្វីមួយតាមរយៈការដែលយើងសង្កេតមើល» សូមឆ្លើយការពិតអំពីជីវិតរបស់អ្នកទាំងចំណុចវិជ្ជមាន និងអវិជ្ជមាន?

៤. តើការស្រឡាញ់ព្រះគម្ពីររបស់យើង ជួយយើងឲ្យក្លាយជាអ្នក «ត្រាប់តាមព្រះជាម្ចាស់» ដោយរបៀបណា? តើការនោះជួយយើងយ៉ាងដូចម្ដេចក្នុងនាមជា «កូនស្ងួនភ្ងា» (អេភេសូរ ៥:១) ?

៥. តើអ្វីជាការបីយ៉ាងដែលអ្នកចងចាំជាងគេ ក្នុងការយកទៅអនុវត្តបន្ទាប់ពីអានសៀវភៅនេះហើយ?



Khmer Women of the word_Layout.indd 207 12/3/26 3:56 in the afternoon

Khmer Women of the word_Layout.indd 208 12/3/26 3:56 in the afternoon

# ការណែនាំឲ្យប្រើប្រាស់ធនធាន


### ជំនួយក្នុងការបង្កើតរបៀបសិក្សាដែលអាចទុកចិត្តបា

លោកស្រី Kay Arthur, លោក David Arthur, និងលោក Pete De Lacey. *The New How to Study Your Bible.* Eugene, OR: Harvest House, ឆ្នាំ២០១០។

លោកស្រី Kathleen Buswell Nielson. *Bible Study: Following the Ways of the Word.* Phillipsburg, NJ: P&R, ឆ្នាំ២០១១។

លោក John MacArthur. *How to Study the Bible.* Chicago: Moody, ឆ្នាំ២០០៩។

លោក Robert H. Stein. A Basic Guide to Interpreting the Bible: Playing by the Rules. 2nd ed. Grand Rapids, MI: Baker Academic, ឆ្នាំ២០១១។

### ធនធានទូទៅសម្រាប់សិក្សាព្រះគម្ពីរ

*ESV Scripture Journal.* Wheaton, IL: Crossway, ឆ្នាំ២០១៨ និងឆ្នាំ២០១៩។

ESV Study Bible. Wheaton, IL: Crossway, ឆ្នាំ២០១១។

*The New Bible Dictionary,* កែសម្រួលដោយ៖ លោក I. Howard Marshall, លោក A. R. Miller, លោកJ. I. Packer, និងលោក D. J. Wiseman. លើកទី៣។ Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៩៦។

### ការជ្រើសរើសសេចក្ដីអធិប្បាយដែលអាចទុកចិត្តបាន

លោក Keith Mathison. “Top Commentaries on Every Book of the Bible.” Available on Ligonier’s website: http://www.ligonier.org/blog/top-commentaries-on-every-book-of-the-bible/.

### ការបង្រៀនជាក់ស្ដែងសម្រាប់ស្ទើរតែគ្រប់កណ្ឌព្រះគម្ពីរ

LifeChange Bible study series. Colorado Springs, CO: NavPress.




Khmer Women of the word_Layout.indd 209 12/3/26 3:56 in the afternoon

## ការអានបន្ថែមសម្រាប់ដំណើររឿងធំៗ

លោក Justin Buzzard. *The Big Story: How the Bible Makes Sense Out of Life.* Chicago: Moody, ឆ្នាំ២០១៣។

## ប្រធានបទលក្ខណសម្បត្តិព្រះជាម្ចាស់

លោក A. W. Pink. លក្ខណសម្បត្តិព្រះជាម្ចាស់ អាចជាវបាននៅគេហទំព័រ៖ https://plovpit-shop.com/product/attributes-of-god-khmer/

លោក A. W. Tozer. The Knowledge of the Holy. New York: Harper, ឆ្នាំ១៩៦១។

## Free Online Study Aids

*Blue Letter Bible.* Available at www.blueletterbible.org.

BibleGateway. Available at www.biblegateway.com.

*Dictionary of Bible Themes.* Compiled by Martin Manser, Alister McGrath, J. I. Packer, and D. J. Wiseman. Available on Bible Gateway at http://www.biblegateway.com/resources/dictionary-of-bible-themes/toc.

## For the Auditory Learner, or for Those Who Find Repetitive Reading a Challenge

Download the free YouVersion app to your smartphone and listen to a book of the Bible while you exercise or drive, or anytime you might listen to music.

## For an Extensive Examination of the Role of the Mind in Christian Devotion

J. P. Moreland. *Love Your God with All Your Mind: The Role of Reason in the Life of the Soul.* Revised and expanded edition. Colorado Springs, CO: NavPress, 2012.




Khmer Women of the word_Layout.indd 210 12/3/26 3:56 in the afternoon

# កំណត់យោង

*អារម្ភកថា*

១. Edmund P. Clowney, *The Unfolding Mystery: Discovering Christ in the Old Testament* (Phillipsburg, NJ: P&R, 1988), 11.

*ជំពូកទី១ ការបង្វែរត្រឡប់មកវិញ*

២. "What Do We Value Most?" NPR Radio TED Radio Hour, May 25, 2012, 14:00, http://www.npr.org/player/v2/mediaPlayer.html?action=1&t=3&islist=true&id=57&d=04-27-2012.

៣. "Paul Bloom: The Origins of Pleasure," TED Talks, July 2011, http://www.ted.com/talks/paul_bloom_the_origins_of_pleasure.html.

*ជំពូកទី២ មូលហេតុដែលត្រូវចេះដឹងព្រះគម្ពីរ*

១. Vorjack, "Women Leaving the Church," *Patheos*, August 5, 2011, http://www.patheos.com/blogs/unreasonablefaith/2011/08/women-leaving-the-church/.

*ជំពូកទី៤* ការសិក្សាដោយមានទស្សនវិស័យ

១. Tom Mueller, "Underground Rome," *The Atlantic Monthly*, April 1997, http://www.theatlantic.com/past/docs/issues/97apr/rome.htm.

២. Stephan Faris, "Rome's Developing Subway," *Travel and Leisure*, April 2008, http://www.travelandleisure.com/articles/romes-developing-subway.

៣. *Merriam-Webster OnLine*, s.v. "literature," http://www.merriam-webster.com/dictionary/literature?show=0&t=1385582790.

៤. Gordon Fee and Douglas Stuart, *How to Read the Bible for All Its Worth* (Grand Rapids, MI: Zondervan, 1993), 74.

*ជំពូកទី៥* ការសិក្សាដោយមានការអត់ធ្មត់

១. *A League of Their Own*, 1992. "There's no crying in baseball!"



Khmer Women of the word_Layout.indd 211 12/3/26 3:56 in the afternoon

# លិបិក្រមតាមព្រះគម្ពីរ


**លោកុប្បត្តិ**
៣:១៥ ៧៤

**និក្ខមនំ**
៣:១១ ៣៣
៣:១២ ៣៣
៣:១៤ ៣៤

**១ពង្សាវតារក្សត្រ**
៨:៤៨ ៤០

**១របាក្សត្រ**
២២:១៩ ៤០

**ទំនុកតម្កើង**
១៦:១១ ៤២
២៧:៨ ១៩៩, ២០៦
៣៤:៣ ៧
១១៩:១០ ១៥៥

**សុភាសិត**
២៤:២៧ ១២១

**អេសាយ**
២៦:៣ ៤០
៤០:២១ ៦៧

**យេរេមា**
១៧:៩ ៥៥

**ម៉ាថាយ**
៥:១១ ១៦៣, ១៦៤
៥:១២ ១៦៣
១១:២៨ ៥៤
១៣:៥២ ៨៣

**ម៉ាកុស**
១២:៣០ ៣៨

**លូកា**
៨:១៥ ១០៣, ១១៦
២៤:៤៤ ៤០

**យ៉ូហាន**
៥:៣៩ ៣៧

**រ៉ូម**
១២:២ ៤០, ៤១, ៤១, ៤៤
១៥:៤ ៤៩

**១កូរិនថូស**
៦:១៩ ១៤២
១៤:១៤ ៤០

**កាឡាទី**
៥:២២ ១០៤

**អេភេសូរ**
២:១០ ៣២
៥:១ ២០២, ២០៧

**ភីលីព**
៤:៦ ៥៤
៤:១៣ ១៨៧

**២ធីម៉ូថេ**
២:១៥ ១៧៥




Khmer Women of the word_Layout.indd 213 12/3/26 3:56 in the afternoon

៣:១៦ ២៩

***យ៉ាកុប***

១:១ ១៦២, ១៦២, ១៦៦, ១៦៧

១:២ ១៦៣, ១៦៣, ១៦៤, ១៦៥

១:៥ ១៤៥

៣:១ ១៧១, ១៧៩

***១ពេត្រុស***

១:៦ ១៦៣, ១៦៣, ១៦៤




Khmer Women of the word_Layout.indd 214 12/3/26 3:56 in the afternoon